# ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៨

## ពលការិនីខ្មែរម្នាក់ត្រូវបានជួយសង្គ្រោះបន្ទាប់ពីថៅកែបង្ខំឲ្យធ្វើការដោយគ្មានកិច្ចសន្យា

https://wmc.org.kh/ ថ្ងៃពុធ ទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ ជូ វីរៈ

ភ្នំពេញ៖ពលការិនីខ្មែរម្នាក់បម្រើការងារជាស្ត្រីមេផ្ទះនៅប្រទេសម៉ាឡេស៊ីត្រូវបានអាជ្ញាធរនិងអង្គការសង្គមស៊ីវិលជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញទាំងមានស្ថានភាពជំងឺ។ នេះបើតាមអ្នកឃ្លាំមើល និងការពារសិទ្ធិមនុស្ស។ ពលករខ្មែរឈ្មោះ យ៉ន សុគា អាយុ២៨ ឆ្នាំ បានទៅបម្រើការងារជាជំនួយការមេផ្ទះនៅទីក្រុងកូឡាឡាំពួរប្រទេសម៉ាឡេស៊ីកាលពីឆ្នាំ២០១៤។កញ្ញា យ៉ន សុគា បានប្រាប់អ្នកឃ្លាំមើលសិទ្ធិមនុស្សថាថៅកែបានបង្ខំឲ្យបន្តធ្វើការពីរឆ្នាំទៀតបើទោះបីជានាងផុតអាណត្តិការងារហើយថៅកែព្រមានមិនបើកប្រាក់ខែចុងក្រោយ។ កញ្ញា យ៉ន សុគា៖«ខ្លួនត្រូវបានថៅកែជាម្ចាស់ផ្ទះបង្ខំឲ្យធ្វើការចំនួន២ឆ្នាំ ខណៈដែលខ្លួនចង់វិលត្រឡប់មកស្រុកខ្មែរហើយ ថៅកែបានព្រមានមិនបើកប្រាក់ខែចុងក្រោយឲ្យលុះត្រាតែមានអ្នកថ្មីមកជំនួស ប៉ុន្តែនាងគ្មានជំនឿថា មិនដឹងពេលណា។នាងផ្ដាច់ទូរស័ព្ទវិញខណៈថៅកែបានត្រឡប់មកដល់ផ្ទះវិញ។ នាងដង្ហោយហៅឲ្យជួយសង្គ្រោះចេញពីថៅកែនេះព្រោះថៅកែបានធ្វើបាបនិងជេរស្ដីឲ្យរាល់ថ្ងៃ»។

ពលករខ្មែរឈ្មោះ យ៉ន សុគា អាយុ២៨ ឆ្នាំ សម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យបង្អែកខេត្តកោះកុង។រូបភាព៖ អង្គការលីកាដូ កញ្ញា យ៉ន សុគា រៀបរាប់ប្រាប់មន្ត្រីសិទ្ធិមនុស្សទៀតថាកញ្ញានិងស្ត្រីបីនាក់ទៀតត្រូវបានក្រុមហ៊ុនឯកជនមួយមិនស្គាល់ឈ្មោះគឺប្ដីជាជនជាតិចិន និងប្រពន្ធជាជនជាតិខ្មែរបាននាំនាងទៅធ្វើការនៅប្រទេសម៉ាឡេស៊ីឆ្លងកាត់ច្រកព្រំដែនប៉ោយប៉ែតទៅប្រទេសថៃដោយប្រើប្រាស់ប្រភេទលិខិតឆ្លងដែនទេចរណ៍កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០១៤ដោយម្ចាស់ក្រុមហ៊ុននេះសន្យាផ្តល់ការងារនៅក្នុងហាង។តែផ្ទុយទៅវិញនាងនិងស្ត្រី៣នាក់ទៀតធ្វើការងារនៅក្នុងសណ្ឋាគារបន្ទាប់មកក៏ដូរការងារថ្មីទៅជាជំនួយការមេផ្ទះ។ ក្រោយពីចប់កិច្ចសន្យាការងារពីរឆ្នាំក្រុមហ៊ុនបាននាំពួកគេទៅធ្វើជំនួយការមេផ្ទះនៅន្លែងថ្មីទៀតដោយពួកគេមិនទាន់សងលុយថៅកែអស់។ ប៉ុន្តែពួកគេបដិសេធក៏ត្រូវបានថៅកែយកបំពងទីបវាយពួកគេ។ ទោះបីយ៉ាងណាកញ្ញា យ៉ន សុគា បានលួចរត់ចេញពីផ្ទះដោយមិនបើកប្រាក់ខែ។ «នាងសុខចិត្តទ្រាំនៅធ្វើបាន៦ខែ យ៉ន សុគា បានលួចរត់ចេញពីផ្ទះ ដោយមិនបានបើកប្រាក់ឈ្នួលទាំងអស់ដោយទៅសុំម្ចាស់ផ្ទះមុនធ្វើការសិន តែម្ចាស់ផ្ទះនេះទាមទារឲ្យនាងធ្វើការឲ្យខ្លួនរយៈពេល២ ឆ្នាំ តែនាងយ៉ន សុគា មិនព្រម។ម្ចាស់ផ្ទះចាស់នេះកំពុងបង្ខំនាងឲ្យធ្វើការចង់ឈប់លុះត្រាតែមានអ្នកថ្មីមកជំនួស។ក្រុមហ៊ុនដែលនាំនាង បានដកហូតយកPassportទុក ដោយមិនប្រគល់ឲ្យសាម៉ីខ្លួនកាន់ឡើយ»។

បើតាម លោក អ៊ិន គង់ជិត មន្ត្រីជាន់ខ្ពស់ផ្នែកអង្កេតរបស់អង្គការការពារសិទ្ធិលីកាដូប្រាប់វិទ្យុស្ត្រីថាពលករខ្មែរឈ្មោះ យ៉ន សុគា ក្រោយពីលួចរត់ចេញពីផ្ទះក៏មកសុំម្ចាស់ផ្ទះចាស់ដែលធ្លាប់បម្រើការងារអស់រយៈពេល២ឆ្នាំគឺពេលនោះហើយម្ចាស់ផ្ទះបង្ខំឲ្យធ្វើការពីរឆ្នាំទៀតតែនាងបដិសេធ។លោកថាក្រុមហ៊ុនបានដកហូតលិខិតឆ្លងដែនរបស់ពួកគេ។ លោក អ៊ិន គង់ជិត រំលឹងថាកញ្ញាសុគាបានទូរស័ព្ទមកលោកដើម្បីសុំឲ្យអន្តរាគមន៍នាងឲ្យបានត្រឡប់មកស្រុកកំណើតវិញ។ប៉ុន្តែនាងបានបិទទូរស័ព្ទនៅពេលថៅកែត្រឡប់មិនផ្ទះវិញ។ លោក អ៊ិង គង់ជិត បញ្ជាក់មិនយូប៉ុន្មានកញ្ញា យ៉ន សុគា ត្រូវបានជួយសង្គ្រោះនិងបញ្ជូនមកស្រុកកំណើតវិញហើយ។ប៉ុន្តែលោកកញ្ញា សុគា កំពុងមានបញ្ហាសុខាភាពគឺគ្រុនពោះវៀនតាំងពីនៅប្រទេសម៉ាឡេស៊ីមក ។ លោក អ៊ិង គង់ជិតថាកញ្ញាសម្រេចមិនដាក់ពាក្យប្ដឹងក្រុមហ៊ុននិងម្ចាស់ផ្ទះនោះទេព្រោះនាងបានត្រឡប់មកផ្ទះហើយ។ លោក អ៊ិង គង់ជិត៖«គាត់គិតថាគាត់ចង់បានត្រឡប់មកផ្ទះវិញគាត់រស់នៅក្នុងនោះដូចរស់នៅក្នុងឋាននរកអញ្ចឹក។ម្សិលមិញខ្ញុំជួបគាត់នៅមន្ទីរពេទ្យគាត់ប្រាប់ថាគាត់មកដល់ផ្ទះវិញដូចកើតម្ដងទៀត។អញ្ចឹងរឿងផ្លូវច្បាប់អីនិងគាត់អត់...ថៅកែចុងក្រោយបើកប្រាក់ខែអស់ហើយតែថៅកែមួយទៀតទីពីរគឺ៦ខែមិនបានបើកប្រាក់ខែអោយគាត់ទេ។គាត់សម្រេចមិនប្តឹងផ្តល់ទេកាលណាគាត់ប្ដឹងផ្ដល់គាត់អាចនឹងគាត់ចេញមកមិនរួច។»

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះកិច្ចព្រមព្រៀងបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ីឡើងវិញបន្ទាប់ពីផ្អាកអស់រយៈពេល៦ឆ្នាំ ចាប់តាំងពីឆ្នាំ២០១១ ក្រោយពីជនរងគ្រោះនិងអង្គការសង្គមស៊ីវិលប្តឹងអំពីការរំលោភបំពាន់សិទ្ធិការងារ។ លោក អ៊ិត សំហេងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងនៅ

ចុងខែមករា ឆ្នាំ ២០១៨ថាក្រសួងនឹងចាប់ផ្តើមបញ្ជូនពលករខ្មែរទៅប្រទេសម៉ាឡេស៊ីនៅដើមខែមិថុនា ឆ្នាំ ២០១៨ នេះ។ លោករដ្ឋមន្ត្រីថាដើម្បីធានាសុវត្ថិភាពជូនពលករខ្មែរភាគីទាំងពីរបានចុះកិច្ចព្រមព្រៀង៨ចំនុច។ ក្នុងចំណោមនោះត្រូវផ្តល់ទូរស័ព្ទដៃសម្រាប់ទំនាក់ទំនងរវាងស្ត្រី ជំនួយការមេផ្ទះនិងក្រុមគ្រួសារ។កំណត់យន្តការទស្សនកិច្ចដល់ទីកន្លែងធ្វើការរបស់ពលករ-ពលការិនីរៀងរាល់ត្រី មាសនិងផ្តល់ធានារ៉ាប់រងគ្រោះថ្នាក់ការងារនិងសុខភាព។ការត្រួតពិនិត្យទីភ្នាក់ងារជ្រើស រើសឯកជនជាដើម។បច្ចុប្បន្ននេះប្រទេសម៉ាឡេស៊ី មានពលករបរទេសកំពុងធ្វើការងារប្រមាណ១លាន៧សែននាក់ដែលធ្វើការងារទៅលើវិស័យ ឧស្សាហកម្ម ផលិតកម្ម និងការងារតាមផ្ទះ។ចំពោះពលករខ្មែរដែលធ្វើការងារស្របច្បាប់នៅប្រទេសម៉ាឡេស៊ីគិតមកដល់ចុងឆ្នាំ២០១៧ មាន ជា៨០០០នាក់៕

## អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានការងារ ផ្សព្វផ្សាយប្រកាសអន្តរក្រសួង ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសនៅកម្ពុជា និងកាតព្វកិច្ចធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេស

http://www.freshnewsasia.com/ 2018-03-01

(ភ្នំពេញ)៖ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ និងអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សព្វផ្សាយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងការងារ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសនៅកម្ពុជា និងសេចក្តីជូនដំណឹងពីកាតព្វកិច្ចធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេស។

កិច្ចប្រជុំផ្សព្វផ្សាយដែលធ្វើនៅព្រឹកថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨នេះ ត្រូវបានធ្វើឡើងក្រោមអធិបតីភាពនាយឧត្តមសេនីយ៍ សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងលោក សេង សក្កា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ កិច្ចប្រជុំនេះ ក៏មានការចូលរួមពី ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានាជាច្រើនរូបទៀតផងដែរ។ គោលបំណងនៃកិច្ចប្រជុំនេះ ដើម្បីរំលឹកផ្ទាល់ដល់ម្ចាស់រោងចក្រ សហគ្រាស ក្រុមហ៊ុន កាស៊ីណូ និងក្លឹបកំសាន្តនានា ដើម្បីជំរុញពលករបរទេសមកធ្វើប័ណ្ណ និងសៀវភៅការងារតាមច្បាប់ជាធរមាន។

ប្រកាសអន្តរក្រសួងបានបញ្ជាក់ថា ការទទួលយកជនបរទេសធ្វើការងារ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តនានា ជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងប្រទេសកម្ពុជា ត្រូវគោរពឲ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជា។ គ្មានជនបរទេសណាម្នាក់អាចប្រកបមុខរបរណាមួយ ក្នុងប្រទេសកម្ពុជាដោយគ្មានប័ណ្ណ និងសៀវភៅការងារដែលចេញឲ្យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងករណីម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកំសាន្តណាមួយ ដែលទទួលយកពលករបរទេសឲ្យធ្វើការងារ ឬពលករដែលធ្វើការ ឬប្រកបមុខរបរណាមួយដោយគ្មានប័ណ្ណ និងសៀវភៅការងារ ត្រូវធ្វើការផាកពិន័យប្រាក់ និងផ្តន្ទាទោសតាមទោសជំពូកទី១៦ នៃច្បាប់ស្តីពីការងារ និងផ្តន្ទាទោសតាមទោសប្បញ្ញត្តិជំពូកទី៥ និងការបណ្តេញចេញ តាមជំពូកទី៦ នៃច្បាប់ស្តីពីអន្តោប្រវេសន៍៕

## ពលករបរទេសជាង១០ម៉ឺននាក់ ធ្វើការនៅកម្ពុជាដោយគ្មានប័ណ្ណការងារ, ក្រសួងមហាផ្ទៃ និងក្រសួងការងារ ប្រកាសទុករយៈពេល១ខែ មុនចាត់វិធានការណ៍ច្បាប់

http://www.freshnewsasia.com/ 2018-03-01

(ភ្នំពេញ)៖ ក្រសួងមហាផ្ទៃ និងក្រសួងការងារ នឹងចាត់វិធានការណ៍តាមផ្លូវច្បាប់យ៉ាងដាច់ណាត់ ឬឈានដល់ការបណ្តេញពីកម្ពុជា ចំពោះពលករបរទេស ជាង១០ម៉ឺននាក់ ដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា ដោយគ្មានប័ណ្ណការងារ ដែលនាំឲ្យខាតបង់ប្រាក់ចំណូលចូលរដ្ឋ ប្រមាណ២០លានដុល្លារក្នុងមួយឆ្នាំ។

នាយឧត្តមសេនីយ៍សន្តិបណ្ឌិត សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងលោក សេង សក្កា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជី

វៈ បានបញ្ជាក់ដូចគ្នាថា ក្រសួងទុករយៈពេល១ខែជូនពលករបរទេស ដើម្បីមកចុះបញ្ជីការងារស្របតាមច្បាប់ ពោលគឺក្រោយចូលឆ្នាំប្រពៃណីជាតិខ្មែរ ក្រុមអធិការកិច្ចចម្រុះនៃអន្តរក្រសួង នឹងចុះពិនិត្យស្រាវជ្រាវលើករណីនេះ។ ការឲ្យដឹងបែបនេះ របស់នាយឧត្តមសេនីយ៍ សុខ ផល និងលោក សេង សក្ដា បានធ្វើឡើងក្នុងកិច្ចសម្ភាសន៍ជាមួយក្រុមអ្នកសារព័ត៌មាន នៅព្រឹកថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨នេះ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ដីពីការពង្រឹងការងារអធិការកិច្ច ហត្ថពលកម្មបរទេសនៅកម្ពុជា និងសេចក្ដីជូនដំណឹងពីកាតព្វកិច្ចធ្វើប័ណ្ណការងារ និងសៀវភៅការងារជនបរទេស។ នាយឧត្តមសេនីយ៍ សុខ ផល បានថ្លែងយ៉ាងដូច្នេះថា «យើងទុកពេលមួយខែតាមស្មារតីប្រកាសអន្តរក្រសួង រហូតទៅដល់ថ្ងៃក្រោយចូលឆ្នាំខ្មែរ យើងនឹងធ្វើការត្រួតពិនិត្យឡើងវិញ តើអវត្តមានដែលគាត់មិនបានបង់ទៅតាមសៀវភៅ និងប័ណ្ណការងារនេះ ហើយយើងនឹងធ្វើការត្រួតពិនិត្យជំហ៊ានមួយទៀត [...] ហើយផុតសុពលភាពមួយខែដែលកំណត់ យើងនឹងធ្វើការផាកពិន័យ»។

ជាមួយគ្នានេះ លោក សេង សក្ដា ក៏បានថ្លែងដោយជំរុញឲ្យពលករបរទេសទាំងអស់ សូមមកធ្វើប័ណ្ណ និងសៀវភៅការងារនៅក្នុងឆ្នាំ២០១៧ ឲ្យបានរួចរាល់ ហើយបើតាមច្បាប់អន្តោប្រវេសន៍ និងច្បាប់ស្ដីពីការងារ ក្នុងឆ្នាំ២០១៨នេះ គឺតម្រូវឲ្យធ្វើការផាកពិន័យ ប៉ុន្តែក្រសួងទាំង២មិនទាន់ធ្វើការផាកពិន័យនោះទេ គឺទុករយៈពេល១ខែ ដើម្បីឲ្យពលករទាំងអស់នោះមកបំពេញកាតព្វកិច្ច។ ប្រតិភូរាជរដ្ឋាភិបាលរូបនេះ បន្ថែមថា ប្រសិនបើពលករបរទេសទាំងនោះ មិនបានមកធ្វើសៀវភៅការងារ ឬបំពេញកាតព្វកិច្ចក្នុងការបង់ពន្ធជូនរដ្ឋ ដែលក្នុងមួយឆ្នាំមានតម្លៃ៤០ម៉ឺនរៀលនោះ ក្រសួងនឹងធ្វើការផាកពិន័យទៅតាមច្បាប់ ដោយកំណត់ផាកពិន័យពី៦០ថ្ងៃ ទៅ៩០ថ្ងៃ នៃប្រាក់ឈ្នួលប្រចាំថ្ងៃ ពោលគឺកំណត់ក្នុងមួយថ្ងៃ៤ម៉ឺនរៀល។

ក្រៅពីការផាកពិន័យជាប្រាក់ហើយនោះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត សុខ ផល បានគូសបញ្ជាក់ថា ប្រសិនបើពលករបរទេសទាំងអស់នេះ នៅតែបន្តរឹងរុះមិនព្រមបង់ពិន័យ នឹងប្រឈមជាមួយទោសទណ្ឌខាងផ្លូវតុលាការផងដែរ ដោយដាក់ពន្ធនាគាររយៈពេល៣ខែ រួចបណ្ដេញចេញពីកម្ពុជាតែម្ដង ឬម្យ៉ាងទៀត មិនដាក់ពន្ធនាគារទេតែបណ្ដេញចេញតែម្ដង ផ្អែកតាមច្បាប់អន្តោប្រវេសន៍។

សូមរំលឹកថា ពាក់ព័ន្ធករណីពលករបរទេសនេះ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨នេះ បានអំពាវនាវនិយោជក (ថៅកែរោងចក្រ) ទាំងអស់ កុំទទួលយកបុគ្គលិកជាជនជាតិបរទេស ដែលគ្មានប័ណ្ណការងារឲ្យចូលបម្រើការ ហើយប្រសិនក្រសួងរកឃើញថា មានបុគ្គលជាជនជាតិបរទេសនោះ និយោជកនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ ក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងទិសដៅបន្ត របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ សម្ដេចក្រឡាហោម ស ខេង បានបញ្ជាក់ថា ការទទួលបុគ្គលិកជនបរទេស ដែលគ្មានប័ណ្ណការងារឲ្យចូលធ្វើការនេះ នឹងធ្វើឲ្យរដ្ឋបាត់បង់ប្រាក់ចំណូល ប្រមាណ២០លានដុល្លារក្នុងមួយឆ្នាំ, លំបាកក្នុងការគ្រប់គ្រងសន្តិសុខ និងប៉ះពាល់ដល់ការងាររបស់ជនជាតិខ្មែរ។

របាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបង្ហាញថា ក្រុមការងារចម្រុះអធិការកិច្ចហត្ថពលកម្មបរទេស ដែលមានក្រសួងការងារ និងក្រសួងមហាផ្ទៃ បានចុះត្រួតពិនិត្យសហគ្រាស គ្រឹះស្ថាននានាចំនួន ៣,៩៦៩ គោលដៅ មានពលករបរទេស សរុបចំនួន៣២,៥១២នាក់ មាន៩៣សញ្ជាតិ ក្នុងនោះបានផាកពិន័យជនបរទេសប្រកបមុខរបរ និងបម្រើការងារគ្មានប័ណ្ណការងារ ចំនួន១,៣៨៩នាក់៕

**ថៃបញ្ជូនកម្មករ 35នាក់ ទៅសង្គ្រោះនៅមន្ទីរពេទ្យបន្ទាប់ពីធ្លាយឧស្ម័ន នៅក្នុងរោងចក្រធ្វើទឹកកក**

http://www.prakpheaktra.com March 1, 2018

មានករណីលេចធ្លាយហ្គាស៍ឧស្ម័ននៅក្នុងរោងចក្រផលិតទឹកកកបណ្ដាលឱ្យកម្មករចំនួន 35នាក់ ត្រូវបានបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យភ្លាម។ កាលពីវេលាម៉ោង12យប់ឈានចូលថ្ងៃព្រហស្បតិ៍ ទី01 ខែមិនា ឆ្នាំ2018 មានករណីលេចធ្លាយហ្គាស៍ឧស្ម័ន(អាំម៉ូលា) នៅក្នុងរោងចក្រផលិតទឹកកកមួយកន្លែងស្ថិតនៅក្នុងស្រុកអយុធ្យា ខេត្តអយុធ្យា ប្រទេសថៃ ។ យោងតាមប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថាកម្មករប្រុសនិងស្រីធ្វើនៅក្នុងរោង

ចក្រផលិតទឹកកកខាងលើចំនួន 35នាក់ ត្រូវបានភ្នាក់ងារសង្គ្រោះស្រុកអយុធ្យាបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យអយុធ្យា បន្ទាប់ពីកម្មករធ្វើការនៅក្នុងរោងចក្រទាំងអស់នោះបានស្រូបឧស្ម័នអាំម៉ូលាដែលលេចធ្លាយបណ្តាលឱ្យមានអាការៈថប់ដង្ហើមនិងវិលមុខតឹងដើមទ្រូង។ ក្រោយពេលកើតហេតុកម្លាំងសមត្ថកិច្ចថៃបានចុះធ្វើការត្រួតរោងចក្រខាងភ្លាមៗព្រមទាំងយករថយន្តពន្លត់អគ្គិភ័យមកបាញ់សម្អាតជាតិឧស្ម័នដែលលេចធ្លាយនៅក្នុងរោចក្រ។

## អាជ្ញាធរស្រុកជាំក្សាន្ត មកទទួលសពពលករខ្មែរ ពីភាគីថៃ

http://ann.com.kh/ ថ្ងៃព្រហស្បតិ៍, 1 ខែមីនា 2018 9:04 ព្រឹក

**ខេត្តព្រះវិហារៈ** អាជ្ញាធរស្រុកជាំក្សាន្ត កាលពីវេលាម៉ោងជាង៩យប់ ថ្ងៃទី២៨ កុម្ភៈ ម្សិលមិញ បានមកទទួលសពពលករ ខ្មែរម្នាក់ ពីភាគីថៃ នៅចំណុចច្រកតំបន់អានសេះ នៃខេត្តព្រះវិហារ។ លោក ជា គឹមសេង អភិបាលស្រុកជាំក្សាន្ត បានឲ្យដឹងថា សពពលករខ្មែរខាងលើ ឈ្មោះ យូរ សាវុធ ភេទប្រុស អាយុ៣៦ឆ្នាំ ជាកម្មករសំណង់ នៅភូមិជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ កាលពីថ្ងៃទី២៥ កុម្ភៈ នៅក្នុងខេត្តនុនបូរី ប្រទេសថៃ។ លោកបន្តថា បន្ទាប់ពីទទួលសពពីខាងភាគីថៃ បានដឹកប្រគល់ជូនក្រុមគ្រួសារយក មកធ្វើបុណ្យតាមប្រពៃណី នៅស្រុកកំណើត។ ជាមួយគ្នានោះ ឯកឧត្តម សួស យ៉ារ៉ា អ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រះវិហារ បានចូលរួមរំលែកទុក្ខដល់គ្រួសារសព និងចូលបច្ច័យចំនួន ៤០ម៉ឺនរៀល និងអង្ករ២បាវផងដែរ៕

## ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៨

## កម្ពុជាប្រើវិធានក្តៅគ្រោងបណ្តេញពលករបរទេសជាង១០ម៉ឺននាក់

http://www.ppd-news.net/ 02-March-2018 / ព័ត៌មានជាតិ

**រាជធានីភ្នំពេញ** ៖ កម្ពុជាគ្រោងនឹងប្រើវិធានការក្តៅទៅលើពលករបរទេសដែលបាននិងកំពុងធ្វើការនៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ហើយមិនគោរពច្បាប់ជាធរមានរបស់ កម្ពុជា ។ បន្ទាប់ពីរកឃើញថា មានពលករបរទេសប្រមាណជាង១០ម៉ឺននាក់ ដែលចូលមកធ្វើការ ដោយមិនស្របច្បាប់ កម្ពុជាក៏គ្រោងនឹងបណ្តេញជនបរទេសទាំងនោះចេញផងដែរ បើនៅតែមិន បំពេញបែបបទតាមការកំណត់នៃច្បាប់ ។

លោក សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានថ្លែងកាលពីព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨ ម្សិលមិញនេះ ថា កម្ពុជានឹងចាត់វិធានការតាមផ្លូវច្បាប់ ឬឈានទៅដល់ការបណ្តេញ ចេញពីកម្ពុជាតែម្តង នូវពលករបរទេសជាង១០ម៉ឺននាក់ដែលកំពុងធ្វើការមិនស្របច្បាប់នៅកម្ពុជា ដូចជាគ្មានប័ណ្ណការងារដែលនាំឲ្យខាតបង់ចំណូលរដ្ឋប្រមាណជា២០លានដុល្លារក្នុងមួយឆ្នាំៗ ឯណោះ ។ ការថ្លែងបែបនេះ ធ្វើឡើងក្នុងឱកាសដែលលោក សុខ ផល ចូលរួមក្នុងពិធីប្រជុំ ផ្សព្វផ្សាយប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងការងារ ស្តីពីការពង្រឹងការងារអធិការកិច្ច ហត្ថពលកម្ម បរទេសនៅកម្ពុជា រួមទាំងសេចក្តីជូនដំណឹងពីកាតព្វកិច្ចធ្វើប័ណ្ណ និង សៀវភៅជនបរទេសរបស់សហគ្រាស គ្រឹះស្ថាន កាស៊ីណូ និងជនបរទេស ដែលមកវិនិយោគឬ ប្រកបមុខរបរណាមួយនៅកម្ពុជា ។ យ៉ាងណាក៏ដោយ លោក សុខ ផល បានបញ្ជាក់ថា អាជ្ញាធរទុករយៈពេលមួយខែ សម្រាប់ជនបរទេស ដើម្បីមកចុះបញ្ជីការងារស្របច្បាប់ ហើយក្រោយពីរយៈពេលមួយខែនោះ អាជ្ញាធរនឹងចុះពិនិត្យស្រាវជ្រាវលើករណីនេះ ហើយបើរកឃើញជនបរទេសណាមិនទាន់អនុវត្ត តាមច្បាប់ត្រូវប្រឈមនឹងការពិន័យឬបណ្តេញចេញតែម្តង ។

ពាក់ព័ន្ធករណីនេះមន្ត្រីជំនាញក្រសួងការងារបានឲ្យដឹងថា បើតាមច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារក្នុងឆ្នាំ២០១៨ គឺពលករបរទេសទាំងនោះនឹងតម្រូវឲ្យផាកពិន័យ ប្រសិនបើមិន បានធ្វើប័ណ្ណ និងសៀវភៅការងារឆ្នាំ២០១៧ ។ ចំពោះកាតព្វកិច្ចបង់ជូនរដ្ឋសម្រាប់ជនបរទេស ក្នុងម្នាក់៤០ម៉ឺនរៀលក្នុងមួយឆ្នាំៗ ។ ប៉ុន្តែបើមិនបាន

បំពេញកាតព្វកិច្ចនេះ ក្រសួងនឹងផាកពិន័យ តាមច្បាប់ ដោយកំណត់ផាកពី៦០ថ្ងៃទៅ៩០ថ្ងៃ នៃប្រាក់ឈ្នួលប្រចាំថ្ងៃ ពោលគឺកំណត់យកមួយ ថ្ងៃ៤ម៉ឺនរៀល ។

ចំណែកលោកអគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានបញ្ជាក់បន្ថែមដែរថា ប្រសិនបើពលករបរទេស នៅតែមិនព្រមបង់ពិន័យនោះ នឹងត្រូវប្រឈមផ្លូវច្បាប់ ដោយអាចជាប់ ពន្ធនាគាររយៈពេលខែ ហើយត្រូវបណ្តេញចេញពីកម្ពុជា ៕

## ក្រសួង២ដាក់ចេញ៥ចំណុច ដើម្បីបន្ត តាមដានពលករបរទេស ធ្វើការនៅកម្ពុជា

https://www.dap-news.com/kh ព្រហស្បតិ៍, 01 មិនា ២០១៨ 17:55 ដោយ: ខា ជា ID:049

ភ្នំពេញ៖ ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨នេះ បានសម្រេចដាក់ចេញ នូវគោលការណ៍អនុវត្តន៍ចំនួន ៥ចំណុច ដើម្បីពង្រឹងនិងបន្ត តាមដានការធ្វើការងាររបស់ ពលករបរទេសនៅកម្ពុជា ។ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨នេះ លោក សេង សក្កា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងលោកនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត សុខ ផល អគ្គនាយកនៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបើកកិច្ចប្រជុំ ផ្សព្វផ្សាយ ប្រកាសអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការពង្រឹងការងារ អធិការកិច្ចហត្ថពលកម្ម បរទេសក្នុងប្រទេសកម្ពុជា និងសេចក្តីជូនដំណឹងស្តីពី កាតព្វកិច្ចធ្វើប័ណ្ណ និងសៀវភៅការងារជនបរទេស របស់ម្ចាស់ សហគ្រាស គ្រឹះស្ថាន កាស៊ីណូ និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយ ក្នុងប្រទេសកម្ពុជា ។

ក្នុងឱកាសនោះមានការចូលរួមពី គណៈអភិបាលខេត្តរងទទួលបន្ទុក ២៥រាជធានី-ខេត្ត ស្នងការនគរបាលរងទទួលបន្ទុក ២៤ខេត្ត ក្រុមចំរុះអធិការការងារ ជនបរទេស ម្ចាស់សហគ្រាសគ្រឹះស្ថានចំនួនជាង ៤០០ សមាគមនិយោជក និងសមាគមរោងចក្រកាត់ដេរ នៅកម្ពុជាផងដែរ ។ គោលការណ៍ អនុវត្តផែនការសកម្មភាព បន្តចំនួន៥ចំណុចសំខាន់ៗរួមមាន៖

ទី១.គណៈអភិបាលខេត្តទទួល បន្ទុកទាំង ២៤ខេត្ត ត្រូវធ្វើការផ្សព្វផ្សាយ បន្ត ដល់ម្ចាស់សហគ្រាសគ្រឹះស្ថាន ក្នុងរយៈពេលមួយសប្តាហ៍ ។

ទី២.ក្រុមចំរុះអធិការកិច្ចហត្ថពល កម្មបរទេស នឹងចុះត្រួតពិនិត្យប័ណ្ណ និងសៀវភៅការងារ ក្រោយបុណ្យចូលឆ្នាំ ប្រពៃណីខ្មែររួច ។

ទី៣.បង្កើតក្រុមការងារ ដើម្បីជួយ តាមដាន ការងារនេះប្រចាំថ្ងៃ។

ទី៤.ក្រុមការងារប្រចាំការ ដើម្បីដោះស្រាយ បញ្ហាចំពោះមុខភ្លាមៗ ចំពោះសំណូមពរ របស់ម្ចាស់ សហគ្រាសគ្រឹះស្ថាន ឬជនបរទេស ដូចជាពាក់ព័ន្ធ ឯកសារផ្សេងៗ។

និងទី៥.ម្ចាស់សហគ្រាសគ្រឹះស្ថាន និងជនបរទេស អាចស្នើសុំធ្វើប័ណ្ណ និងសៀវភៅការងារដោយ គ្រាន់តែចូលទៅក្នុងប្រព័ន្ធ ស្វ័យប្រវត្តិកម្ម តាមរយៈគេហទំព័រ ៕

## តុលាការលើកពេលប្រកាសសាលក្រម សំណុំរឿងបុរសចិន និងប្រពន្ធខ្មែរ នាំស្ត្រីខ្មែរទៅលក់នៅប្រទេសចិន

http://ann.com.kh/site/news/ ថ្ងៃសុក្រ, 2 ខែមីនា 2018 8:16 ព្រឹក

រាជធានីភ្នំពេញ៖ មិនដូចជាការគ្រោងទុកនោះទេ កាលពីព្រឹក ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨ លោក អ៊ី ថាវរៈ ប្រធានក្រុមប្រឹក្សា ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ មិនទាន់អាចបើសវនាការប្រកាសសាលក្រមផ្តន្ទាទោស បុរសជនជាតិចិន និងប្រពន្ធខ្មែរ ក្នុងសំណុំរឿង ជួញដូរស្ត្រីខ្មែរទៅរៀបការប្តីនៅប្រទេសចិន នោះទេ។ ប្រភពពីមន្ត្រីពន្ធនាគារព្រៃស ម១ និងម២ បានថ្លែងថា ប្រធានក្រុមប្រឹក្សាចៅជំនុំជម្រះ លោក អ៊ី ថាវរៈ មិនបានបញ្ជាក់ ពី

មូលហេតុនៃការលើកពេលប្រកាសសាលក្រមនៃសំណុំរឿននោះទេ ហើយក៏មិនទាន់បានកំណត់ពេលដាក់លាក់ថា នឹងបើកសវនាការប្រកាសសាលក្រមនៅពេលណានោះដែរ បានត្រឹមតែប្រើក្រឡាបញ្ជីមកប្រាប់ពួកលោកថា រឿងនេះ លើកពេលប្រកាសសាលក្រម។

សូមបញ្ជាក់ថា លោក សេង ហៀង ជាតំណាងអយ្យការសវនាការ បានចោទប្រកាន់លើជនជាប់ចោទ ឈ្មោះ ម៉ា ចាវហ្វូ ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិចិន និងឈ្មោះ ស៊ុ គន្ធា ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ពីបទនាំចេញដោយមិន ស្របច្បាប់សម្រាប់នាំឆ្លងដែន ប្រព្រឹត្តកាលពីអំឡុងឆ្នាំ២០១៦ នៅខេត្តកណ្ដាល និងរាជធានីភ្នំពេញ យោងតាមមាត្រា១១ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ក្នុងសវនាការកាលពីរសៀល ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ កន្លងទៅ ជនជាប់ចោទ ទាំង២នាក់ បានបដិសេធការចោទប្រកាន់ របស់តុលាការ ដោយអះអាងថា ពួកគេមានបំណងជួយឱ្យជនរងគ្រោះ បានប្តីនៅស្រុកចិន ក្រែងបានជីវភាពធូរជារជាងមុនតែប៉ុណ្ណោះ។

ចំណែកជនរងគ្រោះ ២នាក់ ទី១.ឈ្មោះ ព.ស.ត និងទី២.ឈ្មោះ ហ.ច.ប បានបញ្ជាក់ថា ជនជាប់ចោទ ទាំង ២នាក់ និងបក្ខ ពួក២នាក់ទៀត ដែលកំពុងរត់គេចខ្លួន បានលួងលោមពួកនាង ឱ្យទៅរៀបការប្តីនៅស្រុកចិនទៅ បានលុយចាយច្រើន រស់ស្រួល និងអាចបានលុយផ្ញើឱ្យម្តាយឪពុកនៅស្រុក ថែមទៀតផង។ ក្រៅពីនេះក្រុមជនជាប់ចោទ បានប្រាប់ថា ប្តីចិន ឱ្យថ្លៃទឹកដោះដំបូង ចំនួន ២,០០០ដុល្លារ ទៅឪពុកម្តាយរបស់ពួកនាង។ ក្រោយពីពួកនាង ព្រមទៅរៀបការប្តី នៅប្រទេសចិន ក្រុមជនជាប់ចោទ បានរត់ការធ្វើឯកសារឆ្លងដែន និងនាំពួកនាង ឆ្លងទៅប្រទេសចិន តាមប្រទេសវៀតណាម។ នៅពេលទៅដល់ប្រទេសចិន ក្រុមជនជាប់ចោទ បានឱ្យពួកនាង ទៅរៀបការប្តី ចិន។ ក្រោយពីការរួចរស់នៅបានមួយរយៈ ប្តីចិន បានវាយធ្វើបាបពួកនាង និងបង្ខាំងពួកនាងទុកតែក្នុងផ្ទះ និងបម្រុងលក់បន្តឱ្យទៅផ្ទះបនស្រី ទើបពួកនាង លួចរត់ឱ្យសមត្ថកិច្ចជូនទៅរកស្ថានទូតខ្មែរប្រចាំប្រទេសចិន ដើម្បីជួយសង្គ្រោះ បានត្រលប់មកប្រទេសកម្ពុជាវិញ។ ជនរងគ្រោះទាំង២នាក់ បានប្តឹងទាមទារ សំណង ពីជនជាប់ចោទ ក្នុងម្នាក់ៗ ចំនួន ២ ម៉ឺនដុល្លារ៕ ដោយ៖ ឡុក សំរិត

## ថៃ ចាប់ខ្មែរ និង បរទេសផ្សេងជាង ៧០ នាក់រឿងស្នាក់នៅ និងធ្វើការផុតទិដ្ឋាការ

http://www.postkhmer.com/ ភ្នំពេញប៉ុស្តិ៍ យុត សុភចរិយា | Publication date 01 March 2018 | 18:44 ICT

ភ្នំពេញៈ ជនបរទេសចម្រុះជាតិសាសន៍ជាង ៧០ នាក់ដែលរួមទាំងជនជាតិកម្ពុជាផងត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនដោយចោទពីបទស្នាក់នៅហួសទិដ្ឋាការនិងធ្វើការងារខុសច្បាប់។ នេះបើតាមកាសែត ឈ្មោះ «Khaosod English» ចេញផ្សាយកាលពីព្រឹកថ្ងៃទី១ ខែមីនា នេះ។ កាសែតនេះបានរាយការណ៍ថានៅម៉ោង ១:៣០ នាទីព្រឹកថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំនេះ នគរបាលទេសចរណ៍ ថៃ ដឹកនាំដោយលោកឧត្តមសេនីយ៍ទោស៊ូរ៉ាចិតហាក់ប៉ាល់ បានធ្មក់ចូលក្នុងតំបន់ទេសចរផ្លូវភេទល្បីឈ្មោះមួយនៅក្រុងបាងកកតាមដងវិថី Sukhumvit 23 ត្រង់ចំណុចផ្លូវកែង Soi Cow boy និង Asoke Montri។ ក្នុងប្រតិបត្តិការនោះសមត្ថកិច្ចបានឃាត់ខ្លួនជនបរទេស ៧៥ នាក់ រួមមានជនជាតិអ៊ុយហ្គង់ដា ស៊ូដង់ បង់ក្លាដេសឥណ្ឌានិងកម្ពុជាដោយចោទប្រកាន់ពីបទ «ស្នាក់នៅហួសកំណត់ទិដ្ឋាការនិងចូលមករស់នៅនិងធ្វើការខុសច្បាប់នៅទីនោះ»។ កាសែតនេះក៏បានដកស្រង់សម្តីរបស់លោកឧត្តមសេនីយ៍ ទោ ស៊ូរ៉ាចិត ហាក់ប៉ាល់ មកបញ្ជាក់ផងដែរថា៖ «ជនបរទេសភាគច្រើនបានចូលក្នុងប្រទេស ថៃ ដោយប្រើទិដ្ឋាការទេសចរណ៍និងធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស សាសនា ទូតឬជាកីឡាករបាល់ទាត់»។

កាលពីម្សិលមិញមន្ត្រីការទូតកម្ពុជាម្នាក់ប្រចាំក្រុង បាងកក បានបដិសេធការធ្វើអត្ថាធិប្បាយ ជុំវិញករណីនេះទេដោយអះអាងថា គាត់ពុំមានតួនាទីក្នុងការឆ្លើយជាមួយអ្នកសារព័ត៌មាន ខណៈលោក ឈីវ ធន្ទះ លេខាទី២នៃស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ក៏មិនអាចទាក់ទងសុំការអធិប្បាយបាន ។ ប៉ុន្តែបើតាមមន្ត្រីខ្មែរដែលកំពុងបំពេញបេសកកម្មផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅថៃបានឲ្យថាអាជ្ញាធរថៃជារឿយៗតែងចុះបង្ក្រាបនិងចាប់ជនបរទេសដែលស្នាក់នៅនិងធ្វើការងារលើវិស័យផ្សេងៗដោយខុសច្បាប់ក្នុងប្រទេសគេ។

ថ្លែងក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះមន្ត្រីរូបនោះបានបន្តថា៖ «វាពុំមានអ្វីប្លែកឬត្រូវព្រួយបារម្ភនោះទេ ព្រោះករណីចុះបង្ក្រាបជនបរទេសរស់នៅនិងធ្វើការងារខុសច្បាប់នៅថៃ គឺកើតមានស្ទើរជារៀងរាល់ថ្ងៃទៅហើយ។

ចំណែកជនសង្ស័យ ដូចករណីខាងលើនេះ ពួកគេត្រូវបានអាជ្ញាធរថៃចាប់ឃុំខ្លួនក្នុងរយៈពេលខ្លី ឬ ត្រូវផាកពិន័យបន្ទាប់មកនឹងត្រូវចាប់បញ្ជូនឲ្យត្រឡប់ទៅប្រទេសពួកគេវិញ»។ កាលពីដើមខែកុម្ភៈក្នុងប្រតិបត្តិការមួយដែលមានឈ្មោះថា «ប្រតិបត្តិការរាត្រីខ្មៅ» នគរបាលទេសចរណ៍ក្រុងបាងកកធ្លាក់ចូលក្នុងសណ្ឋាគារឈ្មោះ NANA ក្នុងតំបន់ Soi Sukhumvit 4 ដែលជាតំបន់ទេសចរផ្លូវភេទហើយបានចាប់ខ្លួនជនសង្ស័យ ១០ នាក់ដោយចោទពីបទល្មើសផ្សេងៗពីគ្នាប៉ុន្តែពុំមានជនជាតិកម្ពុជានោះទេគឺមានតែជនជាតិឥណ្ឌានិងអាហ្វ្រិកប៉ុណ្ណោះ៕

## ដំណឹងល្អ, ប្រកាសបើកធ្វើប៉ាស្ព័រជូនពលករខ្មែរ នៅក្នុងខេត្តសាមុតប្រាកាន នៅថ្ងៃទី05 ខាងមុខនេះ

http://www.prakpheaktra.com March 1, 2018

សេចក្តីជូនដំណឹងដល់បងប្អូនពលករខ្មែរដែលកំពុងធ្វើការរស់នៅក្នុងខេត្តសាមុតប្រាកាន នៅថ្ងៃច័ន្ទទី05 ខែមិនា ឆ្នាំ2018 ខាងមុខនេះគណៈកម្មការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជាក្នុងប្រទេសថៃ និងបើកធ្វើការផ្ទៀតសញ្ជាតិធ្វើប៉ាស្ព័រជូនបងប្អូនពលករខ្មែរ នៅក្នុងខេត្តសាមុតប្រាកាន ដូច្នេះសូមបងប្អូនពលករខ្មែរដែលធ្វើការរស់នៅក្នុងខេត្តសាមុតប្រាកានទៅទំនាក់ទំនងយកលេខរៀងនៅមន្ទីរការងារខេត្តសាមុតប្រាកាន (ក្រុមការចាត់ហាងាន) រួចធ្វើដំណើរទៅធ្វើប៉ាស្ព័រហាងអ៊ីមផូលៀបសំរោង ខេត្តសាមុតប្រាកាន ចាប់តាំងពីថ្ងៃច័ន្ទទី05ខែមិនាឆ្នាំ2018 ខាងមុខនេះតទៅ ។

## មិនដឹងប្រញាប់ទៅណា.? ពលករខ្មែររងរបួសម្នាក់

http://www.prakpheaktra.com March 2, 2018

នារីថៃម្នាក់បើកម៉ូតូលឿនដូចហោះរួចជាន់ហ្វ្រាំងមិនទាន់បុកគូទម៉ូតូពលករខ្មែរបណ្តាលឲ្យរងរបួសទាំងពីរនាក់ កាលពីវេលាម៉ោង10:00យប់នាថ្ងៃព្រហស្បតិ៍ទី01 ខែមិនា ឆ្នាំ2018 មានករណីគ្រោះថ្នាក់ចរាចរណ៍រវាងម៉ូតូនិងម៉ូតូបណ្តាលឱ្យបុរសពលករខ្មែរម្នាក់របួស។ ករណីគ្រោះថ្នាក់ចរាចរបានកើតឡើងនៅសណ្ឋាគារមួយនៅត្រង់ចំណុចមុខផ្សារសាំងការសុីស្ថិតនៅស្រុកបានផែវ ខេត្តរ៉ាក់យ៉ង។ ប្រភពពីកន្លែងកើតហេតុបានរៀបរាប់ឲ្យដឹងថា គេឃើញម៉ូតូមួយគ្រឿងបើកបរនារីជនជាតិថៃម្នាក់ដោយល្បឿនលឿនហើយបានជ្រុលបុកកន្ទុយម៉ូតូ មួយគ្រឿងទៀតដែលបើកបរដោយបុរសខ្មែរពីរនាក់ ខណៈពេលកំពុងបត់ចូលក្នុងសណ្ឋាគារក្បែរកន្លែងកើតហេតុ បានឲ្យអ្នកបើកបរម៉ូតូទាំងពីររងរបួសធ្ងន់។ នៅក្រោយពេលកើតហេតុជនរងគ្រោះទាំងពីរត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង ចំណែកឯម៉ូតូទាំងពីរគ្រឿងត្រូវបានសមត្ថកិច្ចថៃធ្វើការវាស់វែងរួចយកទៅរក្សាទុកនៅអធិការដ្ឋានតម្រួតខេត្តរ៉ាក់យ៉ងដើម្បីរង់ចាំរកខុសត្រូវនៅពេលក្រោយ។

## រឿងស្មានមិនដល់! ថៃនឹងចេញបម្រាម ប្រឆាំងទេសចរណ៍ផ្លូវភេទ

https://www.dap-news.com/kh ព្រហស្បតិ៍, 01 មិនា ២០១៨ 21:06 ដោយ: ណៃ តុលា ID:030

បរទេស៖ ប្រទេសថៃដែលត្រូវបាន គេស្គាល់ថា ជាប្រទេសដែលមួយដ៏ល្បីល្បាញ មានប្រាសាទបែបពុទ្ធសាសនា ប្រជាជនរួសរាយរាក់ទាក់ និងឆ្នេរសមុទ្រស្រស់ស្អាតនោះ ឥឡូវនេះកំពុងប្រឆាំងនឹងទម្រង់ទេសចរណ៍ផ្លូវភេទហើយ ក្នុងពេលដែលថៃ កាលពីឆ្នាំមុន រកប្រាក់បានជាង ៥៣,៧៦លានដុល្លារ ពីវិស័យទេសចរណ៍។ យោងតាមសារព័ត៌មាន Sputnik ចេញផ្សាយនៅថ្ងៃទី០១ ខែមីនា បានឲ្យដឹងថា អង្គភាពទេសចរណ៍ថៃ បានចេញសេចក្តីថ្លែងការណ៍មួយថា ដើម្បីធ្វើឱ្យប្រទេសថៃក្លាយជាគោលដៅដែលមានគុណភាពនោះ ទេសចរណ៍ផ្លូវភេទនឹងមិនត្រូវបានអត់ឱនឱ្យបានឡើយ។ អាជ្ញាធរទេសចរណ៍ថៃ (TAT) បញ្ជាក់ថា យុទ្ធសាស្រ្ត និងគោលនយោបាយទីផ្សាររបស់ថៃនឹងជំរុញឱ្យប្រទេសថៃឆ្ពោះទៅមុខជាគោលដៅគុណភាព ហើយក៏បានជំទាស់យ៉ាងខ្លាំងក្លាចំពោះទំរង់ទេសចរណ៍ផ្លូវភេទ។

សូមជម្រាបផងដែរថា ប្រទេសថៃរំពឹងថានឹងស្វាគមន៍អ្នកទេសចរចំនួន ៣៧,៥៥លាននាក់នៅឆ្នាំ២០១៨នេះ ហើយទោះបីជាពេស្យាចារជាអំពើខុសច្បាប់ក៏ដោយ ក៏ប្រទេសនេះបានអត់ធ្មត់ ក្នុងពេលដែលមានផ្ទះបនរាប់ពាន់កន្លែងបើកនៅទូទាំងប្រទេស។ វង្គសាល Go-Go ដ៏គួរឱ្យកត់សម្គាល់នៅក្នុងទីក្រុងបាងកក និងផ្ទះបន ផ្តល់សេវាកម្ម

ម៉ាស្សាដោយប្រើសាប៊ូ ដែលសេវាកម្មនេះបានជួយគាំទ្រដល់កេរ្តិ៍ឈ្មោះរបស់ថៃជាគោលដៅផ្លូវភេទដ៏ពេញនិយមទៀតផង៕

## ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៨

## សម្តេចតេជោ បានដាក់ចេញនូវសារសំខាន់ៗ៩ចំនុចជុំវិញសុខុមាលភាពកម្មករពលករ

http://www.rasmeinews.com/ March 4, 2018, 10:43 AM

(ភ្នំពេញ)៖នៅព្រឹកថ្ងៃអាទិត្យទី០៤ ខែមីនា ឆ្នាំ២០១៨ នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបសំណេះសំណាល ជាមួយកូនក្មួយកម្មករ កម្មការនីចំនួន ១៤.០២៥នាក់មកពីរោងចក្រចំនួន១៤បន្ថែមទៀតបន្ទាប់ពីបានជួបសំណេះសំណាលកាលពីម្សិលមិញប្រមាណជាង ២ម៉ឺននាក់ ស្ថិតក្នុង ភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ក្នុងទឹកដីនៃខេត្តព្រះសីហនុ។ ក្នុងឱកាសនេះសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានដាក់ចេញនូវសារសំខាន់ៗ៩ចំនុចដើម្បីអោយក្រសួងពាក់ព័ន្ធយកទៅអនុវត្តអោយមានប្រសិទ្ធភាព មានដូចជា៖

១) ត្រូវអនុវត្តប្រាក់ខែអប្បបរិមា១៧០ដុល្លារ ចាប់ពីថ្ងៃ១ ខែមករា ឆ្នាំ២០១៨ តទៅ។

២)ត្រូវអនុវត្តការចុះពិនិត្យនៅតាមមន្ទីរពេទ្យរដ្ឋ ចំពោះការពិនិត្យសុខភាព និងការព្យាបាល កម្មករកម្មការិនីរោងចក្រ រួមទាំងកីឡាករ កីឡាការិនី ក្រុមប្រឹក្សាភូមិ ឃុំ ក៏ត្រូវបានអនុវត្តដូចគ្នាជាពិសេសរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងការងារត្រូវធ្វើអោយបានហ្មត់ចត់។

៣)ត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃពោះសំរាលកូនគឺនឹងទទួលបានពេលវេលាឈប់សម្រាក ពីការងាររយៈពេល ៣ខែហើយហើយនៅទទួលបានប្រាក់ខែ១២០% (៥០% ដោយក្រុមហ៊ុន និង៧០%ដោយបេឡាជាតិ)ក្រសួងពាក់ព័ន្ធត្រូវតាមដានការងារអោយបានជិតដល់ចំពោះការអនុវត្តន៍សកម្មភាពនេះ។

៤.ត្រូវអនុវត្ត ចំពោះកម្មការនីសម្រាលបានកូន(១)គឺទទួលថវិកា៤០ម៉ឺនរៀល និងពិនិត្យផ្ទៃពោះដោយឥតគិតថ្លៃ។បើសម្រាលបានកូនភ្លោះ(២)គឺទទួលបានថវិកា៨០ម៉ឺនរៀល។បើសម្រាលបានកូន(៣)គឺទទួលបានថវិកា១លាន២សែនរៀលហើយបូកប្រាក់ឧបត្ថម្ភចំនួន៥លានរៀលទៀតពីសម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត។

៥)ត្រូវអនុវត្តចំពោះរបបសន្តិសុខសង្គម ដោយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ តទៅ កម្មករកម្មករនីមិនចាំបាច់បង់ទៀតទេគឺម្ចាស់ក្រុមហ៊ុនជាអ្នកបង់ជំនួស ១០០%។

៦)អនុវត្តតាមដានមើលបញ្ហា ទឹក ភ្លើង គឺត្រូវខិតខំបន្ត តទឹកតភ្លើងដល់ផ្ទះរបស់កម្មករយើងដែលនៅឆ្ងាយដែលមិនទាន់ទៅដល់អោយបានគ្រប់គ្រាន់ និងតំលៃផ្ទះជួលដល់កម្មករកម្មការនីកុំ អោយមានការឡើងថ្លៃក្នុងឆ្នាំ ២០១៨ពីព្រោះកន្លងមកយើងមានកំណត់រួចរាល់ហើយ។

៧)អនុវត្តប្រាក់សោធននិវត្តន៍ ចាប់ពីឆ្នាំ ២០១៩ ទៅក្មួយកម្មករ និងទទួលបានប្រាក់ចូលនិវត្តន៍(ប្រាក់រ៉ឺត្រែត)ដូចច្នេះក្នុងរយៈពេល១ឆ្នាំ(២០១៨)ត្រូវត្រៀមរៀបចំអោយហើយដើម្បីអោយដំណើរការបានល្អនៅក្នុងឆ្នាំ ២០១៩នូវរបបសោធននិវត្តន៍នេះ។

៨)អនុវត្តចូលរួមបន្តយកចិត្តទុកដាក់និងដោះស្រាយបញ្ហាផ្សេងៗដែលបងប្អូនពលករទៅក្រៅប្រទេសជួយសម្រួលនូវបែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានា និងដើម្បីទទួលបាននូវល័ក្ខខ័ណ្ឌការងារ ល្អប្រសើរ។

៩) ក្រសួងការងារត្រូវចុះអនុវត្តតាមដានភ្លាមៗអោយបានជិតដល់ និងចូលរួមដោះស្រាយបញ្ហា ប្រឈមនានាចំពោះកម្មករនៅពេលដែលម្ចាស់រោងចក្ររត់ចោល។ ក្នុងនោះគឺត្រូវដោះស្រាយផ្តល់ ប្រាក់ឈ្នួលជាបន្ទាន់ដល់កម្មករកម្មការិនីដែលបានធ្វើការក្នុងពេលដែលថៅកែរោងចក្របានរត់ចោល ហើយត្រូវបន្តដោះស្រាយបញ្ហានានាជាមួយម្ចាស់រោងចក្រដោយផ្ទាល់។ ទន្ទឹមនឹងនោះដែរ គឺត្រូវជួយរកការងារធ្វើដល់កម្មករកម្មការនីអោយបានឆាប់បំផុត៕ ដោយ៖*វាសនា*,ប្រភព៖*fbសម្តេច*

# កម្ពុជាមានសហគ្រាស ក្នុងប្រព័ន្ធជាង១ម៉ឺន និងសហគ្រាសក្រៅប្រព័ន្ធជាង៥៦ម៉ឺន ផ្តល់ការងារជិត៤លាននាក់

http://www.rasmeinews.com/ March 4, 2018, 9:45 AM

(ភ្នំពេញ)៖រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានឱ្យដឹងថា ក្នុងឆ្នាំ២០១៨នេះ គ្រឹះស្ថានសេដ្ឋកិច្ច ក្នុងប្រព័ន្ធ ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានជាង១២ពាន់គ្រឹះ ស្ថានក្នុងនោះមានកម្មករនិយោជិតជាង ១,៤លាននាក់ និងសហគ្រាសគ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបមានជាង៥៦ម៉ឺនគ្រឹះស្ថាន ក្នុងនោះមានកម្មករជាង ២,៤ លាននាក់។

ការបញ្ជាញឱ្យដឹងរបស់លោករដ្ឋមន្ត្រីក្រសួងការងារបែបនេះ ធ្វើឡើងនាឱកាសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រី នៃកម្ពុជា បានអញ្ជើញជួបសំណេះសំណាល ជាមួយកម្មករ និយោជិត នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ នាព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨ កន្លងមក ។ ក្នុងពិធីនេះ លោករដ្ឋមន្ត្រី បានឱ្យដឹងថា វិស័យការងារនៅកម្ពុជា បានបន្តរីកចម្រើន សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ច ក្នុងប្រព័ន្ធ ដែលបានចុះបញ្ជី នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួនសរុប ១២.២៨៧ គ្រឹះស្ថាន កើនចំនួន ១០,០២ ភាគរយ និងមានកម្មករ និយោជិត សរុបចំនួន ១.៤៣៧.៧៩៤ នាក់ កើនចំនួន ២១,១១ ភាគរយ (ស្រី ៨២០.៧៨៧នាក់) ធៀបនឹងឆ្នាំ២០១៦ ព្រមទាំងផ្តល់ការងារធ្វើដោយ ប្រយោលដល់ប្រជាពលរដ្ឋ។ លោករដ្ឋមន្ត្រីក្រសួងការងារ បានមានប្រសាសន៍ថា ក្រៅពីសហគ្រាសក្នុងប្រព័ន្ធ កម្ពុជាក៏មានសហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ច ក្រៅប្រព័ន្ធ សរុបចំនួន ៥៦៩.៦៨៨ គ្រឹះស្ថាន ក្នុងនោះមានកម្មករ និយោជិត ជាង ២,៤ លាននាក់។

លោកបានបន្តឱ្យដឹងថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងយកចិត្តទុកដាក់ ដល់ពលករកម្ពុជាចំនួន ១,២ លាននាក់ ដែលកំពុងធ្វើការនៅក្រៅប្រទេស ដោយបន្តពង្រឹងកិច្ចសហការជាមួយប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង ជប៉ុន ហុងកុង សិង្ហបុរី និងប្រទេសមួយចំនួនទៀត ដើម្បីពង្រឹងឱកាសការងារជូនពលករ និងការពារសិទ្ធិផលប្រយោជន៍ពលករដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ និងបង្កលក្ខណៈសម្បត្តិ ឱ្យពលករទទួលបានរបបគាំពារសង្គម ទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ។

គួរបញ្ជាក់ថា កាលពីអំឡុងឆ្នាំ២០១៧ កន្លងមក ប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិត គឺ១៥៣ដុល្លារ និងឈានចូលដល់ឆ្នាំ២០១៨នេះ ប្រាក់ឈ្នួលគោលរបស់កម្មករ និយោជិត បានឡើងចំនួន១៧០ ដុល្លារអាមេរិក។ ចំនួនប្រាក់ឈ្នួលនេះបើគេគិតបូករួមទាំងប្រាក់បន្ថែមម៉ោង ប្រាក់បំណាច់ផ្សេងៗ គឺកម្មករម្នាក់ អាចទទួលបានប្រាក់ឈ្នួលរហូតដល់ ២០០ ដុល្លារ និងអ្នកខ្លះអាចកើនឡើង រហូតដល់ ២៥០ ផងដែរ ក្នុងមួយខែ៕ដោយ៖ *ដេប៉ូ/sn*

## ពលករខ្មែរ 1នាក់ ត្រូវពលករខ្មែរដូចគ្នាចាក់សម្លាប់នៅមុខបន្ទប់ស្នាក់នៅយ៉ាងអាណោចអាធ័ម

http://www.prakpheaktra.com March 4, 2018

កាលពីរាត្រីថ្ងៃសៅរ៍ទី03 ខែមិនា ឆ្នាំ2018 មានករណីបុរសពលករខ្មែរម្នាក់ធ្វើការសំណង់នៅក្នុងខេត្តនុនថាកបុរី ប្រទេសថៃ ត្រូវកម្មករខ្មែរមួយក្រុមចាក់សម្លាប់នៅមុខបន្ទប់ស្នាក់នៅយ៉ាងអាណោចអាធ័ម។ ករណីអំពើឃាតកម្មនេះបានកើតឡើងនៅមុខបន្ទប់ស្នាក់នៅក្នុងការដ្ឋានសំណង់មួយកន្លែង ស្ថិតនៅសង្កាត់បាងយ៉ៃស្រុកមឿងខេត្តនុនថាកបុរី ប្រទេសថៃ។ ជនរងគ្រោះត្រូវគេសម្លាប់មាន ឈ្មោះ ប៉ុនថាន បូ (តុលា) ភេទប្រុស អាយុ 25ឆ្នាំ ស្រុកកំណើតរស់នៅក្នុងខេត្តព្រៃវែង។ ក្រោយពេលកើតហេតុសាកសពជនរងគ្រោះត្រូវបានសមត្ថកិច្ចថៃយកទៅរក្សាទុកនៅមន្ទីរពេទ្យ ដើម្បីធ្វើការកោសលវិច័យរួចប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី ចំណែកឯជនដៃដល់សមត្ថកិច្ចថៃកំពុងធ្វើការតាមស្រាវជ្រាវចាប់ខ្លួនយកមកផ្តន្ទាទោសតាមច្បាប់។ ក្នុងករណីខាងលើនេះដែរមន្ត្រី

ស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក ប្រទេសថៃ កំពុងធ្វើការទំនាក់ទំនងទៅក្រុមគ្រួសារសពដើម្បីជួយអន្តរាគមន៍ក្នុងការបញ្ជូនសាកសពយកទៅធ្វើបុណ្យតាមប្រពៃណីឯស្រុកកំណើតរបស់របស់សព។

## ពលរដ្ឋខ្មែរ នៅម៉ាឡេស៊ី អំពាវនាវឲ្យខាងស្ថានទូត អន្តរាគមន៍ជួយ ដើម្បីអាចយកសាកសព មិត្តភក្តិ ចេញពីមន្ទីរពេទ្យ

https://www.dap-news.com/kh/ អាទិត្យ, 04 មិនា ២០១៨ 16:37 ដោយ: ស៊ាន កុសល ID:019

**ភ្នំពេញ៖** ពលរដ្ឋខ្មែរ ដែលទៅបម្រើការងារ ជាអ្នកចៀរជ័រកៅស៊ូ នៅប្រទេសម៉ាឡេស៊ី អំពាវនាវដល់ខាងស្ថានទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី សូមជួយអន្តរាគមន៍ ដើម្បីជួយយកសាកសពមិត្តភក្តិ ពីរនាក់ប្តីប្រពន្ធ ដែលស្លាប់ក្នុងមន្ទីរពេទ្យចេញ ខណៈខាងមន្ទីរពេទ្យ មិនអនុញ្ញាតិ គឺទាមទាររកលិខិតស្នាម ពីខាងស្ថានទូត ។

បើតាមពលរដ្ឋខ្មែរម្នាក់ ដែលបម្រើការងារ នៅប្រទេសម៉ាឡេស៊ី បានផ្ញើរសារចូលក្នុងហ្វេសប៊ុក មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល នៅរសៀលថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៨នេះ បានរៀបរាប់ថា កាលពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨ កន្លងទៅនេះ មិត្តភក្តិរបស់គាត់ពីរនាក់ប្តីប្រពន្ធ ដែលបម្រើការងារ ជាអ្នកចៀរជ័រកៅស៊ូ ឲ្យក្រុមហ៊ុនឯកជនមួយ នៅភូមិបាទូកាទុយ ខេត្តកាជាស ប្រទេសម៉ាឡេស៊ី បានជួបគ្រោះថ្នាក់ ដោយត្រូវដើមកៅស៊ូ បាក់ធ្លាក់សង្កត់របួសធ្ងន់ ហើយត្រូវបានបញ្ជូន ទៅកាន់មន្ទីរពេទ្យ ។

ប្រភពដដែលបន្តទៀតថា មិត្តភក្តិរបស់គាត់ ពីរនាក់ប្តីប្រពន្ធបានស្លាប់ ហើយខាងក្រុមគ្រូពេទ្យ នៅប្រទេសម៉ាឡេស៊ី មិនអនុញ្ញាតិ ឲ្យយកសាកសពចេញនោះទេ ពោលគឺទាមទារឲ្យមាន ការចេញលិខិតបញ្ជាក់ ពីខាងស្ថានទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី អីញ្ចឹងហើយរូបគាត់ ក្នុងនាមជាពលរដ្ឋធម្មតាម្នាក់ ហើយរស់នៅ លើទឹកដីគេទៀត មិនដឹងធ្វើយ៉ាងមិច មានតែតាមរយៈមជ្ឈមណ្ឌល ព័ត៌មានដើមអម្ពិល ដើម្បីបង្ហាញសារ ជូនស្ថានទូតខ្មែរប្រចាំម៉ាឡេស៊ី មេត្តាជួយអន្តរាគមន៍ផង៕

## ប៉ូលីសថៃជួយសង្គ្រោះពលករខ្មែរត្រូវបានគេញប្រវ័ញ្ចកម្លាំងពលកម្ម

https://wmc.org.kh/ ថ្ងៃសុក្រ ទី២ ខែមីនា ឆ្នាំ២០១៨ធូ វីរៈ

ភ្នំពេញ៖ យោងតាមការចុះផ្សាយរបស់គេហទំព័រវិទ្យុអាស៊ីសេរីភាសាអង់គ្លេសដែលមានការិយាល័យនៅប្រទេសឡាវឲ្យដឹងថាមន្ត្រីនគរបាលថៃនិងអង្គការសង្គមស៊ីវិលបានជួយសង្គ្រោះពលករខ្មែរជាច្រើននាក់ត្រូវបានថៅកែរោងចក្រកេញប្រវ័ញ្ចកម្លាំងពលកម្មក្នុងប្រទេសថៃ។ ការចុះផ្សាយរបស់គេហទំព័រវិទ្យុអាស៊ីសេរី ឲ្យដឹងថា នគរបាលថៃសហការណ៍ជាមួយអ្នកតស៊ូមតិខាងសិទ្ធិការងារបានជួយសង្គ្រោះពលករចំណាក់ស្រុកចំនួន១៩នាក់ ពីរោងចក្រទឹកកកមួយកន្លែងនៅប្រទេសថៃ។ ការជួយសង្គ្រោះពលករនេះធ្វើឡើងបន្ទាប់ពីពលករម្នាក់បានរត់គេចដោយរាយការណ៍ប្រាប់ប៉ូលិសថៃអំពីស្ថានភាពគារងារអាក្រកនៅក្នុងរោងចក្រ។ ក្នុងចំណោមនោះពលករខ្មែរ១៣នាក់និងពលករឡាវ៦នាក់ ហើយខ្លះក្នុងនោះជាពលករស្ថិតក្នុងវ័យជំទងមិនទាន់គ្រប់អាយុធ្វើការត្រូវបានថៅកែបង្ខំឲ្យរស់នៅក្នុងរោងចក្រនិងបង្ខំឲ្យធ្វើការជាច្រើនម៉ោងដោយផ្តល់ប្រាក់ខែតិចតួចបំផុត។ ពលករទាំងនោះក៏រងការគំរាមកំហែងដោយយកកាំបិតចង្អុលមុខពីសន្តិសុខយាមរោងចក្រដែលថៅកែរោងចក្រទឹកកកជួល។

គេហទំព័រនេះបន្តថាពលករទាំងនេះធ្វើក្នុងរោងចក្រអស់រយៈពេល២ឆ្នាំដោយទទួលបានប្រាក់ខែពី១៥០ ទៅ១៧០បាត ស្មើនឹងប្រហែល៥ដុល្លារអាមេរិកក្នុងមួយថ្ងៃ។ ចំណែកពលករជាបុរសទទួលបានប្រាក់ខែពី២២០ទៅ២៧០ បាតស្មើប្រហែល៧ដុល្លារទៅ៩ដុល្លារ។ ក្រុមជួយសង្គ្រោះថាពួកគេត្រូវបានដាក់នៅក្នុងបន្ទប់ហ៊ុំព័ទ្ធដោយបន្លាលួស ដើម្បីការពារការរត់គេចខ្លួនហើយបង្ខំឲ្យធ្វើការងារចាប់ពីម៉ោង៥ព្រឹករហូតដល់ម៉ោង៥រសៀលដោយថ្ងៃឈប់សម្រាកមានតែមួយថ្ងៃគតក្នុងខែ។

អ្នកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រីនិងកុមារនៃអង្គការសមាគមអាដហុកមើលឃើញថាស្ថានភាពជួញដូរកម្លាំងពលកម្មនិងការជួញដូរមនុស្សដើម្បីនាំទៅធ្វើការនៅប្រទេសក្រៅមិនទាន់មានការថយចុះនោះទេ។ អ្នកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រីនិងកុមារនៃអង្គការសមាគមការពារសិទ្ធិមនុស្សអាដហុកសង្កេតឃើញថាប្រជាពលរដ្ឋមានជីវភាពក្រីក្រនិងចំណេះដឹកទាបនៅតែចាញ់ការបោកបញ្ឆោត និងការអូសទាញពីក្រុមមេខ្យល់នាំលក់ទៅក្រៅប្រទេសដោយឃោសនាថាធ្វើការទទួលបានប្រាក់កម្រៃខ្ពស់។ អ្នកស្រីថាម្យ៉ាងអាចមកពីកត្តាតម្រូវការការងារក្នុងស្រុកគ្មានតុល្យភាពនិងចំនួនប្រជាពលរដ្ឋកម្ពុជាគ្រប់អាយុធ្វើការ។ បើតាមរបាយការណ៍របស់អង្គការសមាគមការពារសិទ្ធិមនុស្សអាដហុកករណីការជួញដូរកម្លាំងពលកម្ម និងជួញដូរមនុស្សទៅក្រៅប្រទេសក្រោមរូបភាពរៀបការដោយបង្ខំក្នុងឆ្នាំ២០១៧នេះមានចំនួនប្រហាក់ប្រហែលឆ្នាំមុនដែរគឺ១៥២ករណី។ ករណីខ្លះធ្ងន់ធ្ងរហួតដល់ជនរងគ្រោះធ្លាក់ខ្លួនឈឺធ្ងន់និងរបួសស្នាមជាដើម។

គេហទំព័រវិទ្យុអាស៊ីសេរីឲ្យដឹងទៀតថាប៉ូលិសសម្រេចចោទប្រកាន់ថៅកែរោងចក្រទឹកកកដោយរំលោភលើសិទ្ធិការងារកម្មករចំនួន៦ករណីដូចជា ការបង្ខាំងទុក ធ្វើការងារហួសម៉ោងតាមច្បាប់កំណត់ ការផ្ដល់ប្រាក់ខែទាបនិងការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ជាដើម។

បើយោងតាមក្រសួងការងារថៃពលករខ្មែរធ្វើការងារនៅប្រទេសថៃ១លាន២សែននាក់។ គេប៉ាន់ប្រមាណថាពលករបរទេសខុសច្បាប់នៅប្រទេសថៃប្រមាណ២លាននាក់៕

**សេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏**

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 04/03/2018 at 12:46am •

ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏ សូមជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណព័ណ៌ស៊ីជំពូ) លិខិតបញ្ជាក់ទំនាក់ទំនងរវាងពលករនិងនិយោជកនិងសៀវភៅធ្វើការផ្នែកនេសាទ (seabook) ដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ មេត្តាជ្រាបថា អាជ្ញាធរថៃ នឹងបើកដំណើរការការិយាល័យចក្រចេញចូលតែមួយទូទាំងប្រទេស ដើម្បីបន្តសុពលភាពការស្នាក់នៅ និងធ្វើការ ជូនដល់បងប្អូនពលករកម្ពុជារហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨។ សូមបងប្អូនពលករកម្ពុជាប្រញាប់រួសរាន់ ទៅចុះឈ្មោះពន្យាសុពលភាពការស្នាក់នៅ និងធ្វើការ នៅតាមការិយាល័យច្រកចេញចូលតែមួយ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តដែលបងប្អូនធ្វើការ ចាប់ពីថ្ងៃទី ៥ ខែកុម្ភៈ ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៨។ សូមបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ មេត្តាជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយបន្ត។

## ថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៨

## តុលាការថៃកាត់ទោសកម្មករនេសាទខ្មែរ ៥ នាក់ឱ្យជាប់គុកម្នាក់ៗ ៥០ ឆ្នាំ ពីបទវាយប្រហារពួកអ្នកទេសចរបារាំងមួយក្រុម រួចចាប់រំលោភនារី ២ នាក់

https://khmeread.com/ សង្គម March 06, 2018 06:42AM

មន្ត្រីម្នាក់បាននិយាយកាលពីថ្ងៃចន្ទទី៥មីនាថា តុលាការថៃបានផ្តន្ទាទោសកម្មករនេសាទកម្ពុជា ៥ នាក់ឱ្យជាប់គុកម្នាក់ៗ ៥០ ឆ្នាំពីបទវាយប្រហារដោយហិង្សាកាលពីឆ្នាំ ២០១៦ ទៅលើអ្នកទេសចរជនជាតិបារាំងមួយក្រុមដែលក្នុងនោះនារីបារាំង ២ នាក់ ត្រូវបានចាប់រំលោភ។ នេះបើយោងតាមវេបសាយសារព័ត៌មាន Straitstimes។ បុរសទាំងនោះត្រូវបានកាត់ទោសអតិបរមាពីបទចោទប្រកាន់ជាច្រើនរួមទាំងការចាប់រំលោភផងដែរ បន្ទាប់ពីពួកគេត្រូវបានចាប់ខ្លួនកាលពីជាង២ឆ្នាំមុនពីបទវាយប្រហារក្រុមអ្នកទេសចរបារាំងនៅលើកោះ Kut របស់ថៃ ដែលគេស្គាល់ផងដែរថាកោះ Kood។ មន្ត្រីតុលាការម្នាក់នៅខេត្តត្រាតប្រទេសថៃបានប្រាប់ទីភ្នាក់ងារសារព័ត៌មាន AFP ថា "ជនជាប់ចោទ

ទាំង ៥ នាក់ត្រូវបានរកឃើញថាមានពិរុទ្ធពីបទរំលោភសេពសន្ថវៈ បង្កការវាយតប់កម្រិតស្រាល និង បង្កការវាយតប់កម្រិតធ្ងន់"។

មន្ត្រីម្នាក់នោះដែលសុំមិនបញ្ចេញឈ្មោះនិយាយថា ជនជាប់ចោទម្នាក់ក្នុងចំណោមនោះត្រូវបានកាត់ទោសពីបទប៉ុនប៉ងមនុស្សឃាត។ កោះ Kut មានទីតាំងនៅជិតព្រំដែនភាគខាងកើតថៃជាប់ជាមួយកម្ពុជា ហើយប៉ូលិសនិយាយថា បុរសទាំងនោះបានហែលទឹកសមុទ្រទៅកាន់ឆ្នេរ ដើម្បីវាយប្រហារក្រុមអ្នកទេសចរបារាំងចំនួន៤នាក់ ដោយប្រើកាំបិតកាលពីខែកុម្ភៈឆ្នាំ ២០១៦។ បុរសរងរបួស២នាក់បានរត់គេចខ្លួនទៅប្រាប់អាជ្ញាធរហើយអ្នកនេសាទទាំងអស់នោះត្រូវបានចាប់ខ្លួនបានភ្លាមៗបន្ទាប់ពីនោះ៕

## សេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 15 hrs • Bangkok, Thailand •

ដើម្បីជួយដោះស្រាយនូវចម្ងល់ និងបញ្ហាផ្សេងៗជូនបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការ នៅក្នុងប្រទេសថៃ សូមបងប្អូនពលករទាំងអស់ មេត្តាចូល comment ជាសំនួរនៅខាងក្រោមនេះ ។ ក្រុមការងារស្ថានទូតនឹងយកសំនួរ និងបញ្ហារបស់បងប្អូនទាំងអស់រៀបចំជាចម្លើយជូនបងប្អូនវិញ នាថ្ងៃបន្ទាប់។ ដូច្នេះបងប្អូនដែលមានចង្ងល់អ្វី សូមបងប្អូនសរសេរជូនមកស្ថានទូត។ សូមបងប្អូនរងចាំចម្លើយនាពេលឆាប់ ក្រុមការងារនឹងឆ្លើយតបបងប្អូនទាំងអស់ តែមិនអាចឆ្លើយតបភ្លាមៗនោះទេ។

## លោក ប្រាយុទ្ធ គំរាមចាប់ពលករដែលកំពុងធ្វើការនៅលើទឹកដីថៃ

https://thmeythmey.com/ 06, Mar 2018 , 2:14 pm

ដោយ: តន ចាន់វិទ្ធារ៉ា មកទល់ពេលនេះ ពលករបរទេសខុសច្បាប់រាប់សែននាក់ដែលកំពុងធ្វើការនៅប្រទេសថៃ នៅមិនទាន់បានបំពេញឯកសារស្របច្បាប់នៅឡើយ។ នាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចន្ទអូចា បានបន្ទោសក្រសួងការងារថៃ ចំពោះភាពស្ពឹកស្រពន់របស់ខ្លួនក្នុងការបំពេញការងារនេះ។ លោក ប្រាយុទ្ធ ក៏បានគំរាមចាប់ខ្លួនពលករខុសច្បាប់ទាំងអស់ បើពួកគេមិនអាចបំពេញឯកសារឲ្យទាន់ការកំណត់នៅក្នុងខែមិថុនាទេនោះ។ នាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចន្ទអូចា នៅថ្ងៃទី៥ ខែមីនា បានបង្ហាញការខឹងសម្បារយ៉ាងខ្លាំងចំពោះការយឺតយ៉ាវក្នុងការផ្តល់ឯកសារស្របច្បាប់ដល់ពលករបរទេសខុសច្បាប់រាប់សែននាក់ ដែលកំពុងធ្វើការនៅលើទឹកដីថៃ។ លោក ប្រាយុទ្ធ ខឹងបែបនេះ បន្ទាប់ពីមន្ត្រីក្រសួងការងារលោក Anurak Thossarat បានប្រាប់លោកថា ការងារផ្តល់ឯកសារនេះមានដំណើការយឺត ព្រោះតែម៉ាស៊ីនស្កេនដើម្បីបញ្ជាក់អត្តសញ្ញាណពលករ មានមិនគ្រប់គ្រាន់។

«ហេតុអ្វីមិនទិញម៉ាស៊ីនស្កេនហ្នឹងទៅ? បញ្ហានេះគួរបញ្ចប់នៅត្រឹមយើងនេះ។ អ្នកត្រូវតែធ្វើគ្រប់យ៉ាង ហើយប្រសិនបើមិនអាចបញ្ចប់នៅត្រឹមមិថុនា គ្មានការលើកលែងទៀតទេ។» នេះជាសម្តីពោរពេញដោយកំហឹងរបស់លោក ប្រាយុទ្ធ អំឡុងការចុះត្រួតពិនិត្យការចុះឈ្មោះពលករនៅខេត្ត Samut Sakorn និងផ្សាយដោយសារព័ត៌មាន The Nation ។ មេដឹកនាំរបបយោធាថៃរូបនេះ ក៏គំរាមចាប់ខ្លួនពលករបរទេសទាំងឡាយណា ដែលមិនអាចបំពេញឯកសារស្របច្បាប់ទាន់ពេលវេលានោះ។

ការបញ្ជាក់អត្តសញ្ញាណ គឺជារឿងសំខាន់ក្នុងដំណើការចុះឈ្មោះពលករបរទេសរាប់លាននាក់ ដើម្បីឲ្យពួកគេមានសិទ្ធិធ្វើការស្របច្បាប់នៅលើទឹកដីថៃ។ កាលពីឆ្នាំមុន ថៃបានចាប់ផ្តើមពង្រឹងការអនុវត្តច្បាប់លើពលករខុសច្បាប់ ដែលបង្ខំឲ្យមនុស្សរាប់លាននាក់ធ្វើដំណើរទៅកាន់ទឹកដីកំណើតដូចជាមីយ៉ាន់ម៉ា កម្ពុជា និងឡាវ ដើម្បីស្វែងរកឯកសារត្រឹមត្រូវ មុននឹងត្រឡប់ទៅធ្វើការវិញ។ ចរន្តហូរចេញនេះ ធ្វើឲ្យបណ្តាសហគ្រាសថៃបារម្ភខ្លាំងជុំវិញការបាត់បង់កម្លាំងពលកម្ម។ ដោយសារបញ្ហានេះ រដ្ឋាភិបាលថៃ បានពន្យារពេលអនុវត្តច្បាប់អន្តោប្រវេសន៍ថ្មី និងទុកពេលឲ្យពល

ករខុសច្បាប់ទាំងអស់ស្វែងរកឯកសារសិន។ អាជ្ញាធរថៃបានសហការជាមួយអាជ្ញាធរប្រទេសជិតខាងរបស់ខ្លួនក្នុងការបង្កើតទីតាំងចុះឈ្មោះនៅលើទឹកដី ដើម្បីសម្រួលការធ្វើដំណើររបស់ពលករបរទេស ដោយមិនចាំបាច់ត្រឡប់ទៅស្រុកកំណើតឡើយ។

បើតាមលោក Anurak ពលករមីយ៉ាន់ម៉ាចំនួន៩៨៨៧៩៨នាក់ បានចុះឈ្មោះបញ្ជាក់សញ្ជាតិរបស់ពួកគេរួចរាល់ហើយ ក្នុងនោះពលករមីយ៉ាន់ម៉ាមានចំនួន៧៨៤ ០៩១នាក់ កម្ពុជាចំនួន១៥៧២៣២នាក់ និងឡាវចំនួន៤៧ ៤៧៥នាក់។ នៅសល់ពលករចំនួនប្រមាណជិត៧សែននាក់ទៀតដែលមិនទាន់ទៅបញ្ជាក់អត្តសញ្ញាណនៅឡើយ ហើយពួកគេមានពេលត្រឹមខែមិថុនាដើម្បីបំពេញឯកសារចាំបាច់ និងអាចបន្តធ្វើការនៅថៃបានពីរឆ្នាំដោយស្របច្បាប់៕

## សេចក្តីព្រាងច្បាប់ពរពោះជំនួស នឹងដាក់ទៅក្រសួងពាក់ព័ន្ធ នៅសប្តាហ៍ក្រោយ

https://www.dap-news.com/kh/ អង្គារ, 06 មិនា ២០១៨ 14:23 ដោយ: ស សំណាង ID:014

ភ្នំពេញ៖ លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌ បានថ្លែងថា សេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស បានពិភាក្សានិងចងក្រងរួចរាល់ហើយ ហើយនឹងបញ្ជូនទៅអន្តរក្រសួង នៅសប្តាហ៍ក្រោយ ហើយក៏បានដាក់ទៅឲ្យលោកស្រី ណារ៉ូ ស្មីត អ្នករាយការណ៍ពិសេសរបស់ អង្គការសហប្រជាជាតិឲ្យពិនិត្យផងដែរ។

ច្បាប់ស្តីពីការ ទប់ស្កាត់ការពរពោះជំនួស ព្រោះដើម្បីការពារកុមារដែលកើតនៅក្នុងផ្ទៃស្ត្រី ដែលគេចង់បាន តែផ្ទុយទៅវិញ ប្រសិនបើមានករណីណាមួយ ដែលមិនក្រតីម្តាយ-ឪពុក ដែលចង់បាននោះ មិនទទួលស្គាល់នឹងពិបាកព្រោះកូនដែលកើតមក នឹងគ្មានអត្តសញ្ញាណច្បាស់លាស់ ហើយផ្លូវច្បាប់ ពិបាករកឪពុក-ម្តាយពិតប្រាកដ។ សូមបញ្ជាក់ថា ពាក់ព័ន្ធការពរពោះជំនួសនេះ ដោយគ្មានការអនុញ្ញាតនេះ កាលពីរសៀលថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចធ្វើការ ចោទប្រកាន់ ស្ត្រីជនជាតិអូស្ត្រាលី និងជនជាតិខ្មែរពីរនាក់ទៀត ពាក់ព័ន្ធករណីពរពោះជំនួសនោះ ចំនួនពីរបទល្មើស តាមមាត្រា៣៣២ និងមាត្រា៦៣២។

ក្នុងពេលដែល បណ្តាប្រទេស ដទៃចេញច្បាប់ បិទមិនឲ្យមានការជួលស្ត្រីពរពោះ ដើម្បីកើតកូនជំនួស បណ្តាញជំនួញនេះ បានហូរចូលកម្ពុជា ហើយបង្កើតមេខ្យល់ ឲ្យដើរលួង លោម អូសទាញ ស្ត្រីឲ្យរកស៊ីឈ្នួល ពរពោះជំនួស អ្នកដែល ចង់បានកូន ហើយហូតដល់ ក្រុមមនុស្សប្រុស ស្រឡាញ់ប្រុសដូចគ្នា ចង់បានកូន ក៏មកកម្ពុជារកកូនដែរ ។ ជំនួញមួយនេះ ធ្វើឲ្យពួកឈ្មួញចំណេញ កប់ពពក អ្នកចង់បានកូន ត្រូវចំណាយ៥ម៉ឺនដុល្លារ ។

អាជ្ញាធរកម្ពុជាធ្លាប់បាន អះអាងថា មិនទាន់មានទិន្នន័យ ពាក់ព័ន្ធចំនួនស្ត្រីកម្ពុជា ដែលកំពុងស៊ីឈ្នួលពពោះជំនួស នេះទេ។ ប៉ុន្តែមានគ្លីនិកមួយត្រូវបាន គេបង្ហើបថា មានស្ត្រី ២៣នាក់ ដែលបានស៊ីឈ្នួល ពរពោះ ហើយ មានក្រុមហ៊ុន លាក់កំបាំង មួយចំនួនទៀត កំពុងជួលស្ត្រីខ្មែរ ផ្តល់សេវាពពោះ ជំនួស ជាថ្នូរនឹងប្រាក់រាប់ពាន់ដុល្លារ៕

## ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៨

## ក្រសួងយុត្តិធម៌ប្រកាសថា កម្ពុជានឹងមានច្បាប់ពរពោះជំនួស ដើម្បីទប់ស្កាត់ការធ្វើពាណិជ្ជកម្ម និងការជួញដូរមនុស្ស

http://www.akp.gov.kh/ AKP ភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨

មន្ត្រីជាន់ខ្ពស់ក្រសួងយុត្តិធម៌បានប្រកាសថា កម្ពុជានឹងមាន ច្បាប់ពរពោះជំនួស ដើម្បីទប់ស្កាត់ការធ្វើពាណិជ្ជកម្មមនុស្ស ស្របពេលដែលសេចក្តីពង្រាងច្បាប់នេះ កំពុងស្ថិតក្នុងដៃក្រសួងយុត្តិធម៌ ដែលត្រៀមបើកកិច្ចពិភាក្សាជាមួយអន្តរក្រសួងក្នុងពេលឆាប់ៗនេះ។ អ្នកនាំពាក្យយុត្តិធម៌បានប្រកាសថា ក្រសួងនឹងបញ្ជូនសេចក្តីពង្រាងច្បាប់ពរពោះជំនួសនេះ ទៅក្រសួង កិច្ចការនារី ដើម្បីឱ្យពិនិត្យលើលក្ខណៈបច្ចេកទេសឡើងវិញ មុននឹងដាក់ ចូលក្នុងកិច្ចប្រជុំអន្តរក្រសួង។ ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មានក្រោយពីជំនួបពិភាក្សារវាងឯកឧត្តម អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួង យុត្តិធម៌

និងលោកស្រី រ៉ូណា ស្មីត (Rhona Smith) អ្នករាយការណ៍ពិសេស របស់អង្គការ សហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា កាលពីព្រឹកថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងយុត្តិធម៌ ឯកឧត្តម ជិន ម៉ាលីន អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងយុត្តិធម៌ បានបញ្ជាក់ថា រហូតមកដល់ពេលនេះ ច្បាប់ស្តីពីការ ពរពោះជំនួសនេះ ត្រូវបានបញ្ចប់សេចក្តី ព្រាងបឋមរួចរាល់ហើយ ប៉ុន្តែនៅសល់ការពិនិត្យឡើងវិញនូវខ្លឹមសារ ពាក្យពេជន៍ច្បាប់មួយចំនួន ដើម្បីឱ្យមានអត្ថន័យ និងខ្លឹមសារ គ្រប់ គ្រាន់។

ឯកឧត្តមបានលើកឡើងថា ការធ្វើច្បាប់ពរពោះជំនួសនេះ គឺស្របទៅតាមបរិបទ សង្គមនាពេលបច្ចុប្បន្ន ហើយប្រសិនបើកម្ពុជាមិនមានច្បាប់ក្នុងការគ្រប់គ្រងនោះទេ បញ្ហាពរ ពោះជំនួសនេះ វានឹងក្លាយទៅជា ផលអវិជ្ជមាន និងប៉ះពាល់ដល់ស្ត្រី និងកុមារក្នុងករណីនៃការបម្រើចេតនាក្នុងវិស័យពាណិជ្ជកម្ម និងការជួញដូរមនុស្ស។ ឯកឧត្តមបានបន្ថែមថា ករណីពរពោះជំនួបនេះកន្លងមកបានកើតឡើងនៅកម្ពុជា និងបណ្តាមួយចំនួនក្នុងតំបន់និងពិភពលោក ដែលកម្ពុជាត្រូវតែមានច្បាប់នេះ ដើម្បីការពារផលប្រយោជន៍ដល់ស្ត្រី និងកុមារកម្ពុជា ជាពិសេសជានាឱ្យមានសណ្តាប់ធ្នាប់សង្គម។

លោកស្រី រ៉ូណា ស្មីត (Rhona Smith) បានកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំ តាក់តែងសេចក្តីព្រាងច្បាប់នេះក្នុងគោលដៅជួយការពារដល់កុមារ និងស្ត្រីដែលស្របទៅតាមស្តង់ដារអន្តរជាតិ និងសិទ្ធិមនុស្ស។ លោកស្រីបានបន្តថា អង្គការសហប្រជាជាតិនឹងជួយដល់ការរៀបចំសេចក្តីព្រាងច្បាប់នេះ និងការផ្តល់យោបល់ទាក់ទងនឹងខ្លឹមសារច្បាប់ ដើម្បីធ្វើយ៉ាងណាឱ្យច្បាប់នេះមានលក្ខណៈល្អស្របតាមស្តង់ដារអន្តរជាតិ និងជាគំរូសម្រាប់ឱ្យប្រទេសផ្សេងៗទៀតដែលបាន និងកំពុងរៀបចំធ្វើច្បាប់នេះយកគំរូតាមកម្ពុជា។ លោកស្រីបានបន្តទៀតថា អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស នឹងជួយផ្តល់យោបល់ការសិក្សាស្រាវជ្រាវបន្ថែមទៀតដល់សេចក្តីព្រាងច្បាប់ ស្តីពីការពរពោះជំនួប ដើម្បីឱ្យការកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជាកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។ សូមបញ្ជាក់ថា ច្បាប់ស្តីពីការពរពោះជំនួសនេះត្រូវបានក្រសួងយុត្តិធម៌ពិនិត្យរួចរាល់ហើយដែលមាន ៩ជំពូក និង៦២មាត្រា ដែលមានក្រុមការងារបច្ចេកទេសអន្តរក្រសួងធ្វើការពិនិត្យឡើងវិញ និងសម្រេចជាចុងក្រោយ មុននឹងដាក់ជូនទៅគណៈរដ្ឋមន្ត្រី៕ ដោយ អ៊ុន រិទ្ធី

## សន្និសីទជាន់ខ្ពស់ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីទប់ស្កាត់បទឧក្រិដ្ឋ និងរក្សាសុវត្ថិភាពសង្គម

http://cambodiapolice.com/ 3:59 pm 6 មីនា 2018 25

បាងកក ៖ នាថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកឧត្តម នាយឧត្តមសេនីយ មាស វីរិទ្ធ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លោក ជំទាវ ឡាយ ច័ន្ទរស្មី ទីប្រឹក្សាស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ និងមន្ត្រីជំនាញកម្ពុជាជាច្រើនរូបទៀតបានចូលរួមនៅក្នុងសន្និសីទជាន់ខ្ពស់ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីទប់ស្កាត់បទឧក្រិដ្ឋ និងរក្សាសុវត្ថិភាពសង្គម (High Level Conference on Sustainable Development, Crime Prevention, and Safe Societies) ដែលសន្និសីទអន្តរជាតិនេះសហការរៀបចំដោយ ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មសហប្រជាជាតិ ជាមួយវិទ្យាស្ថានកិច្ចការយុត្តិធម៌ថៃ ។ សន្និសីទអន្តរជាតិមានការយាង និងអញ្ជើញចូលរួមពីព្រះអង្គម្ចាស់ក្សត្រី ផាត់ចារ៉ាក់ គិទិយ៉ាផា ម៉ាហីឌុន (Bajakitiyabha Mahidol) ឯកអគ្គរាជទូតសុច្ចន្ទៈ ស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មសហប្រជាជាតិ ឯកឧត្តម យូរី ហ្វេដូតូស (Yury Fedotov) អគ្គលេខាធិការរង និងជាអគ្គនាយកប្រតិបត្តិរបស់អង្គការ ស ហ ប្រ ជា ជាតិ ទទួល

បន្ទុកកិច្ចការគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និងតំណាងប្រទេសផ្តល់ជំនួយ ប្រទេសក្នុងតំបន់ ជាច្រើនផ្សេងទៀត ។

ថ្លែងក្នុងពិធីបើកសន្និសីទ ឯកឧត្តម យូរី ហ្វេដូតូស (Yury Fedotov) បានគូសបញ្ជាក់ថា បច្ចុប្បន្ន នេះប្រទេសជាច្រើនក្នុងតំបន់បានប្រឈមមុខទៅនឹងការគំរាមកំហែងនានាជាច្រើនដូចជា អំពើពុករលួយ ភេរវកម្ម ការជួញដូរមនុស្ស និងការជួញដូរផ្សេងៗទៀតតាមច្រើនរូបភាព ដែលប្រទេសទាំងអស់កំពុងជួបប្រទះ ។ បញ្ហាទាំងនេះភាគច្រើនបណ្តាល មក ពីប្រព័ន្ធច្បាប់ នៅទន់ខ្សោយ និងការយល់ដឹងនៅមានកម្រិត។ អង្គការ UNODC បានរួមចំណែកយ៉ាងសកម្ម និងកំពុងខិតខំផ្តល់ជំនួយបច្ចេកទេស ដើម្បីលើកកំពស់ ការយល់ដឹងឲ្យកាន់តែប្រសើរឡើងថែមទៀត ដល់បណ្តាប្រទេសទាំងអស់នៅ ក្នុងតំបន់ដែលថ្ងៃនេះអង្គសន្និសីទពិភាក្សាគ្នាអំពី ៖

១-បញ្ហាប្រឈមអំពីប្រព័ន្ធច្បាប់ របស់ បណ្តាប្រទេសក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ។ ២-ទិដ្ឋភាពរួមនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាក់ទងទៅនឹងការផ្លាស់ប្តូរ និង៣-ផែនទីបង្ហាញផ្លូវទាក់ទងទៅនឹងសម្រេចបាននូវគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព ៕

## គណៈរដ្ឋមន្ត្រីថៃ, សម្រេចអនុម័តបន្ថយទោសពលករខុសច្បាប់ ត្រឹមតែកំរិតមធ្យម

http://www.prakpheaktra.com March 6, 2018

គណៈរដ្ឋមន្ត្រីថៃសម្រេចអនុម័តបន្ថយទោសពលករខុសច្បាប់ ដែលលួចធ្វើការដោយគ្មានច្បាប់អនុញ្ញាត ពីទោសកំរិតធ្ងន់មកនៅត្រឹមកំរិតមធ្យម ត្រឹមតែផាកពិន័យជាប្រាក់។ បន្ទាប់ពីចប់កិច្ចប្រជុំសញ្ញាណចរបសគណៈរដ្ឋមន្ត្រីថៃ នៅថ្ងៃអង្គារទី06 ខែមិនា ឆ្នាំ2018 នៅក្នុងសណ្ឋាគារ Dusit Thani នៅក្នុងស្រុកឆាកអាំ ខេត្តផេតបុរី កាលពីវេលាម៉ោង01:00រសៀល រួចមក គណៈរដ្ឋមន្ត្រីថៃបានយល់ព្រមសម្រេចកែសម្រួលច្បាប់គ្រប់គ្រងពលករបរទេសថ្មីចំនួនពីរមាត្រា ក្នុងមានច្បាប់ ផ្តល់ដំណឹងពីរកន្លែងស្នាក់នៅរបស់ពលករហៅថា(Zoneing) និងច្បាប់ទោសទណ្ឌជួលពលករខុសច្បាប់អោយធ្វើការ ព្រមទាំងបន្ថយទោសមួយចំនួនចំនួនដូចជាក្នុងមាត្រា101- ក្នុងករណីជួលពលករគខុសច្បាប់ (គ្មានបៃអនុញ្ញាត) អោយធ្វើការត្រូវមានទោសផាកពិន័យជាប្រាក់ចាប់ពីពីរម៉ឺនបាតទៅមួយសែនបាត.(20,000฿ – 100,000฿) និងត្រូវជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំ តែបានកែសម្រួលជាថ្មីដោយបន្ថយទោសនៅសល់តែពិន័យជាប្រាក់ចាប់ពីប្រាំពាន់បាតទៅប្រាំម៉ឺនបាត(5000฿-50,000฿) និងលុបទោសពន្ធនាគារចោល។

មាត្រា102 ក្នុងករណីថៅកែថៃជួលពលករខុសច្បាប់(គ្មានបៃអនុញ្ញាត)អោយធ្វើការត្រូវមានទោសពិន័យជាប្រាក់ចាប់ពីបួនសែនបាតទៅប្រាំបីសែនបាត(400,000฿-800,000฿) ក្នុងចំនួនពលករខុសច្បាប់ 1នាក់ តែបានកែសម្រួលជាថ្មីដោយបន្ថយទោសនៅសល់តែពិន័យជាប្រាក់ចាប់ពីមួយម៉ឺនបាតទៅមួយសែនបាត(10,000฿-100,000฿) ក្នុងចំនួនពលករខុសច្បាប់ 1នាក់ ក្នុងករណីមិនរាងចាលត្រូវមានទោសជាប់ពន្ធនាគារមិនលើសពីមួយឆ្នាំ(1ឆ្នាំ) និងពិន័យជាប្រាក់ចាប់ពីប្រាំម៉ឺនបាតទៅពីរសែនបាត(50,00฿-200,000฿) និងហាមឃាត់មិនអោយជួលពលករបរទេសអោយធ្វើការរយៈបីឆ្នាំ(3ឆ្នាំ)។

អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រីថៃ លោកសាន់សឺន កែវកាំនើត បានបញ្ជាក់បន្ថែមផងដែរថា ដើម្បីឲ្យច្បាប់ដែលបានកែសម្រួលថ្មីនេះមានប្រសិទ្ធភាពនិងស្របទៅតាមលក្ខខ័ណ្ឌសិទ្ធិសេរីភាពអន្តរជាតិ ប្រព័ន្ធច្បាប់ថ្មីនេះនិងបញ្ជូនទៅកាន់មណ្ឌលការិយាល័យមន្ទីរការងារ និងមន្ត្រីក្រសួងការងារដូចជា÷ ករណីពលករស្របច្បាប់ត្រូវប្តូរកន្លែងធ្វើការ, ព្រមទាំងប្រកាសយកលើកកន្លែងស្នាក់នៅ,និងស្នាក់នៅកន្លែងមួយណាក៏បាន។ ក្នុងនោះដែរច្បាប់បានហាមថៅកែកាត់ប្រាក់ឈ្នួលធ្វើការរបស់ពលករដាច់ខាតលើកលែងតែថ្លៃប្រកាន់សុខភាព,ច្បាប់អនុញ្ញាតធ្វើការ, ថ្លៃធ្វើលិខិតធ្វើដំណើរ តែប៉ុណ្ណោះ ក្នុងច្បាប់ទាំងអស់នេះធ្វើឡើងដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សនិងការជិះជាន់ពលកម្មលើពលករ។ ក្នុងករណីរក្សាទុកឯកសារសម្គាល់ខ្លួនរបស់ពលករត្រូវមានការយល់ព្រមពីភាគីទាំងសងខាងទើបអាច

យកទៅរក្សាទុកបាន ក្នុងករណីពលករទាមទារឯកសារសម្គាល់ខ្លួនវិញ ថៅកែថៃផ្តល់ជូនទៅតាមតំរូវការរបស់ពលករ ដោយមិនមានលក្ខណខ័ណ្ឌអ្វីទាំងអស់។ ដកស្រង់ព័ត៌មានពី:Matichon

## ប្រទះឃើញសាកសពពលករខ្មែរម្នាក់ លង់ទឹកស្លាប់យ៉ាងអាណោចអាធ័ម

http://www.prakpheaktra.com March 7, 2018

បុរសពលករខ្មែរវ័យ36ឆ្នាំម្នាក់ ត្រូវបានគេប្រទះឃើញលង់ទឹកស្លាប់នៅក្រោមស្ពានបន្ទាប់ពីមានជំងឺគ្រៀមនិងទៅពេទ្យនៅព្រឹកឡើង។ មានករណីប្រទះឃើញសាកសពពលករខ្មែរស្លាប់អណ្តែតទឹកនេះបានកើតឡើងនៅវេលាម៉ោង07ព្រឹក ថ្ងៃច័ន្ទទី05 ខែមិនា ឆ្នាំ2018 នៅត្រង់ចំណុចនៅក្រោមស្ពាន(ហង្សយ៉េន) ស្ថិតនៅកំពុងផែរចតទូកបានភេរ ស្រុកបានផេរ ខេត្តរ៉ាក់យ៉ង ប្រទេសថៃ។ យោងតាមរបាយការណ៍របស់សមត្ថកិច្ចថៃ ចុះត្រួតពិនិត្យសាកសពនៅកន្លែងគេប្រទះឃើញសាកសព បានអោយដឹងថា អ្នកស្លាប់មានឈ្មោះ Nil Wan អាយុ 36ឆ្នាំសញ្ជាតិខ្មែរ ជាពលករធ្វើការនៅលើទូកនេសាទត្រីក្នុងខេត្តរ៉ាក់យ៉ង។ ប្រភពពីមិត្តរួមការងាររបស់អ្នកស្លាប់ដែលជិះកង់មកប្រទះឃើញសាកនោះ បានប្រាប់អោយដឹងថា នៅព្រឹកថ្ងៃនេះអ្នកស្លាប់គ្រៀមខ្លួននិងទៅរកពេទ្យដើម្បីព្យាបាលជំងឺ តែអកុសលត្រូវបានគេមកប្រទះឃើញស្លាប់អណ្តែតទឹកវិញ។ ក្រោយពេលកើតសាកសពអ្នកស្លាប់ត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅធ្វើកោសល្យវិច័យនៅមន្ទីពេទ្យរួចប្រគល់ជូនសាចញ្ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។ ក្នុងករណីពលករខ្មែរស្លាប់បាត់បង់ជីវិតនេះដែរ មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ កំពុងធ្វើការទំនាក់ទំនងទៅក្រុមគ្រួសារសពដើម្បីជួយអន្តរាគមន៍ក្នុងការបញ្ជូនសពយកដើម្បីទៅបុណ្យនៅឯស្រុកកំណើតរបស់សពភ្លាមៗផងដែរ។

## ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៨

## ជនសង្ស័យជនជាតិអង់គ្លេសពីរនាក់ត្រូវបានឃុំក្នុងពន្ធនាគារក្រោមបទចោទអំពើអាស

https://wmc.org.kh/ ថ្ងៃពុធ ទី៧ ខែមីនា ឆ្នាំ២០១៨ជូ វីរៈ

ភ្នំពេញ៖ប៉ូលិសប្រឆាំងការជួញដូរមនុស្សខេត្តសៀមរាបបានបញ្ជូនជនសង្ស័យសញ្ជាតិអង់គ្លេសពីរនាក់ទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារក្រោមបទចោទអំពើអាសលើក្មេងប្រុសច្រើននាក់។ ជនសង្ស័យមានសញ្ជាតិអង់គ្លេងឈ្មោះ Leslie Peter HENMAN មានអាយុ៦៤ឆ្នាំនិងម្នាក់ទៀតឈ្មោះ David Malcom BROCK អាយុ៦៩ឆ្នាំត្រូវបានចាប់ឃាត់ខ្លួនកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៨។

លោក ជា ហេង ប្រធានការិយាល័យនៃនាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងអនិតិជននៅខេត្តសៀមរាបបានឲ្យដឹងថាបុរសជនជាតិអង់គ្លេងទាំងពីរនេះបានព្រឹត្តអំពើអាសលើក្មេងប្រុសចំនួន១២នាក់ជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១៧រហូតមកដល់ឆ្នាំ២០១៨នេះ។ លោក ជាហេង៖ «គាត់ប្រព្រឹទ្ធយូរគាត់ធ្វើមករហូតក្នុងអំឡុងឆ្នាំ២០១៧។ជនរងគ្រោះ១២នាក់ប្រុសចោទពីបទអំពើអាសប្រឆាំងអនិតិជនអាយុក្រោម១៥ឆ្នាំប្រឈមមុខ)ជាប់ពន្ធនាគារ១ឆ្នាំទៅ៣ឆ្នាំ។» លោក ជា ហេង បន្ថែមថា ជនសង្ស័យទាំងពីរត្រូវបានបញ្ជូនទៅតុលាការក្រោមបទចោទ«អំពើអាសប្រឆាំងអនិតិជនអាយុក្រោម១៥ឆ្នាំ»ដែលអាចនឹងប្រឈមមុខជាប់ពន្ធនាគារពី១ឆ្នាំទៅ៣ឆ្នាំ។

អង្គការការពារកុមារ(Children Protection Unit) បានបង្ហោះនៅលើបណ្តាញសង្គមហ្វេសប៊ុកថាសមាជិកក្រុមការងាររបស់អង្គការនេះនឹងបន្តសម្ភាសជនរងគ្រោះចំនួន១២នាក់ត្រូវបានកំណត់អត្តសញ្ញាណ។ អង្គការ Children Protection Unit បានឱ្យដឹងថាប៉ូលិសខេត្តសៀមរាបបានស៊ើបអង្កេតលើជនសង្ស័យជាជនជាតិអង់គ្លេសពាក់ព័ន្ធនឹងអំពើអាស បន្ទាប់ពីជនសង្ស័យទាំងពីរនេះបានហៅក្មេងប្រុសជាច្រើននាក់ទៅហែលទឹកនៅអាងហែលទឹករបស់គាត់ដែលនៅពេលនោះជនងបរទេសនេះប្រព្រឹត្តិអំពើអាសលើក្មេងប្រុសទាំងនោះ៕

## ឯកសារសម្រាប់ទៅតវីសារពីរឆ្នាំនៅសូន្យOSS ក្នុងប្រទេសថៃ

http://www.prakpheaktra.com March 8, 2018

ដើម្បីភាពងាយស្រួលនៅពេលបងប្អូនទៅតវីសារពីរឆ្នាំនៅសូន្យOSS ថ្ងៃនេះខ្ញុំនិងបង្ហាញពីឯកសារសម្រាប់ទៅតវីសារពីរឆ្នាំនៅសូន្យOSS ទូទាំងខេត្តក្រុងនៅក្នុងប្រទេសថៃ និងតម្លៃសេវាតវីសារពីឆ្នាំដូចខាងក្រោមនេះ÷

១.ខិតឆ្លងដែនច្បាប់ថតចម្លងចំនួនមួយសន្លឹក

២.ត្រាវីសារដាច់ខែបីច្បាប់ថតចម្លងចំនួនមួយសន្លឹក

៣.សុំណុំបែបបទចេញចូលច្បាប់ថតម្លងចំនួនមួយសន្លឹក

៤.ប័ត្រស៊ីជម្ពូច្បាប់ថតចម្លងចំនួនមួយសន្លឹក

៥.លិខិតសុំណុំបែបបទស្នើវីសារ

៦.ប័ត្រប្រាក់ធាឈុនណាយចាងច្បាប់ថតចម្លងចំនួនមួយសន្លឹក

៧.សំណោត្បៀតបានថៅកែច្បាប់ថតចម្លងចំនួនសន្លឹក

៨.លិខិតសុំណុំបែបបទប្រវត្តិរូបរបស់ពលករចំនួនមួយសន្លឹក

៩.ករណីថៅកែមិនទៅត្រូវមានលិខិតម៉បអំណាចចំនួនមួយសន្លឹក

**-តម្លៃតវីសារពីរឆ្នាំ(ធ្វើប្រកាន់សង្គម)**

១.ត្រួតពិនិត្យសុខភាព 500បាត

២.ប្រកាន់សុខភាពបីខែ 500បាត

៣.វីសារ 500បាត

៤.បៃអនុញ្ញាតធ្វើការ 1900បាត

៥.ប័ត្រស៊ីជម្ពូ 80បាត

**សរុបទាំងអស់3480បាត**

**-តម្លៃតវីសារពីរឆ្នាំ(ធ្វើបប្រកាន់សុខភាពពីឆ្នាំ)**

១.ត្រួតសុខភាព 500បាត

២.ប្រកាន់សុខភាព 3200បាត

៣.វីសារ 500បាត

៤.បៃអនុញ្ញាតធ្វើការ1900បាត

៥.ប័ត្រស៊ីជម្ពូ 80បាត

**សរុបទាំងអស់ចំនួន6180បាត**

## លេខរៀងក្លែងក្លាយ

http://www.prakpheaktra.com March 9, 2018

ហ្វេសប៊ុក(ต่างด้าว)ស៊ែរករណីបៃឃ្វីរទៅត្រួតសញ្ជាតិធ្វើប៉ាស្ព័ររបស់ពលករខ្មែរ បៃបក្លែងក្លាយកំពុងតែចរាចរនៅលើទីផ្សារលក់លេខរៀងជូនពលករ។ ម្ចាស់ទំព័រហ្វេសប៊ុកឈ្មោះ(ต่างด้าว)បានផុសតឿនដល់បងប្អូនពលករខ្មែរសូមមេត្តាពិនិត្យអោយបានច្បាស់លាស់បន្ទាប់ពីមានអ្នកផ្តល់រូបភាពករណីលេខរៀងទៅត្រួតសញ្ជាតិធ្វើប៉ាស្ព័ររបស់ពលករខ្មែរក្លែងក្លាយកំពុងតែចរាចរនៅលើទីផ្សារលេខរៀងរបស់ក្រុមអ្នករត់ការធ្វើប៉ាស្ព័រ។

# ទូតកម្ពុជាប្រចាំ៤ប្រទេស អន្តរាគមន៍ជួយសង្គ្រោះស្ត្រីខ្មែរ ៧នាក់

https://www.dap-news.com/kh សុក្រ, 09 មិនា ២០១៨ 09:55 ដោយ: ដើមអម្ពិល ID:014

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

## ស្ថានទូតកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ៧នាក់

------------

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**២នាក់** មកពីខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង២នាក់នោះ បានមកដល់កម្ពុជាវិញ នៅថ្ងៃទី**០៤ ខែមីនា ឆ្នាំ២០១៨** ។

២. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**វៀតណាម** បានសហការជាមួយអាជ្ញាធរវៀតណាមជួយសង្គ្រោះស្ត្រីខ្មែរ**៣នាក់** ដែលត្រូវបានមេខ្យល់បោកបញ្ឆោតបម្រុងនាំទៅរៀបការជាមួយបុរសជនជាតិចិន។ ស្ត្រី២នាក់ មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ បានធ្វើដំណើរចេញពីកម្ពុជាតាមរថយន្ត ទៅដល់ទីក្រុងហាណូយ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨ រួចបន្តដំណើរឆ្ពោះទៅព្រំដែនវៀតណាម-ចិន ប៉ុន្តែត្រូវបាននគរបាលច្រកទ្វារព្រំដែនខេត្តឡាងសឺន (វៀតណាម) ឃាត់ខ្លួន នៅថ្ងៃទី២៦ ខែកុម្ភៈ។ ចំណែកស្ត្រីរងគ្រោះ១នាក់ទៀត មកពីភ្នំពេញ ត្រូវបានមេខ្យល់នាំឆ្លងកាត់តាមប្រទេសវៀតណាមទៅចិន កាលពីអំឡុងខែតុលា ឆ្នាំ២០១៧ ទៅរៀបការជាមួយបុរសជនជាតិចិន ហើយចុងក្រោយត្រូវបានមេខ្យល់បំបរបង់ចោលក្នុងខេត្តឡាងសឺន ប្រទេសវៀតណាម ដោយសារនាងមានជំងឺ។

ស្ថានទូតបានទទួលស្ត្រីទាំង៣នាក់មកស្នាក់នៅបណ្ដោះអាសន្នក្នុងស្ថានទូត និងបានបញ្ជូនពួកគេតាមយន្តហោះ ត្រឡប់មកដល់កម្ពុជាវិញជាបន្តបន្ទាប់ នៅថ្ងៃទី**០២** និងទី**០៧ ខែមីនា ឆ្នាំ២០១៨** ។

៣. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ចិន** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចខេត្តជាំងស៊ី ជួយសង្គ្រោះស្ត្រីខ្មែរ**១នាក់** ឈ្មោះ**ឡ.ស** អាយុ២២ឆ្នាំ មកពីខេត្តកណ្ដាល ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការជាមួយបុរសជនជាតិចិននៅអំឡុងខែធ្នូ ឆ្នាំ២០១៧។

ស្ថានទូត បានផ្ដល់កន្លែងស្នាក់នៅ អាហារបរិភោគ សម្ភារៈប្រើប្រាស់ និងរៀបចំឯកសារធ្វើដំណើរ ហើយនាងបានមកដល់កម្ពុជាវិញ នៅថ្ងៃទី**០១** ខែ **មីនា ឆ្នាំ២០១៨** ។

៤. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**សិង្ហបុរី** បានជួយរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ**១នាក់** អាយុ២៤ឆ្នាំ មកពីខេត្តព្រៃវែង ដែលមិនអាចទ្រាំទ្រការងារលំបាកនៅសិង្ហបុរីបាន ។

ស្ថានទូត បានផ្ដល់កន្លែងស្នាក់នៅ អាហារបរិភោគ និងជួយទាមទារលិខិតឆ្លងដែននិងសំបុត្រយន្តហោះពីភ្នាក់ងារនាំពលករ ហើយពលការិនីបានមកដល់កម្ពុជាវិញ នៅថ្ងៃទី**២០** ខែ **កុម្ភៈ ឆ្នាំ២០១៨** ។

ថ្ងៃ សុក្រ ៨រោច ខែ ផល្គុន ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៨

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## អ្នកទោសខ្មែរម្នាក់ត្រូវបានក្រុមអាជ្ញាធរថៃដោះលែងហើយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៨ម៉ោង ០៩:២៦ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានធ្វើការដោះលែងអ្នកទោសខ្មែរម្នាក់ឱ្យមានសេរីភាពវិញ នាំមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជា កាលពីវេលាម៉ោង៣និង៤០នាទីល្ងាចថ្ងៃទី៨ ខែមិនានេះ នៅមាត់ច្រកទ្វារអន្តរជាតិជាំ ស្ថិតក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃដោះលែងឈ្មោះ មី អៀង ភេទប្រុស អាយុ៤៥ឆ្នាំ រស់នៅភូមិអភិវឌ្ឍន៍ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្រុមទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី៨ ខែមិនា ឆ្នាំ២០១៦ កន្លងទៅចូលតាមច្រកអូរឬស្សី ស្ថិតនៅក្នុងភូមិទួលគ្រួស ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ទល់មុខភូមិស្ទឹងច័ន្ទ ឃុំស្ទឹងច័ន្ទ ស្រុកឃុនហាន ខេត្តស៊ីសាកេតប្រទេសថៃ ។

យោងតាមរបាយការណ៍ពីក្រុមអាជ្ញាធរកម្ពុជាដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា ក្រុមអាជ្ញាធរថៃបានធ្វើការដោះលែងអ្នកទោសខ្មែរ ដែលចោទពីបទឆ្លងដែនខុសច្បាប់ កាប់ឈើគ្រញូង ជាបន្តបន្ទាប់ នៅដើមខែមករាហូតមកទល់ខែមិនា ២០១៨នេះ មាន៣៧នាក់ ស្រីម្នាក់ តាមមាត់ច្រកទ្វារអន្តរជាតិជាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ខណៈនោះក្រោយពីបានទទួលពីក្រុមអាជ្ញាធរ រួចខាងក្រុមអាជ្ញាធរកម្ពុជាបានធ្វើការអប់រំ និងឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារ ៕

## ដឹងអត់ថា ជនបរទេសដែលជាប្រពន្ធ របស់ បុរសកូរ៉េខាងត្បូង ៧០ភាគរយ ជាជនជាតិអ្វី ហើយមានស្ត្រីខ្មែរទេ?

https://www.dap-news.com/kh ព្រហស្បតិ៍, 08 មិនា ២០១៨ 10:29 ប្រែសម្រួល: ណៃ តុលា ID:049

បរទេស៖ ទិន្នន័យដែលបានបង្ហាញនៅថ្ងៃពុធ បានឲ្យដឹងថា ជិត ៧៣ភាគរយនៃស្ត្រីបរទេសដែលរៀបការជាមួយបុរសកូរ៉េខាងត្បូង នៅចន្លោះឆ្នាំ ២០១៤ និង ២០១៦ គឺជាជនជាតិវៀតណាម។ យោងតាមសារព័ត៌មាន Korean Times ចេញផ្សាយនៅថ្ងៃទី០៧ ខែមីនា បានឲ្យដឹងថា ទិន្នន័យបានបង្ហាញថា អាយុជាមធ្យមកូនកម្លោះកូរ៉េដែលរៀបអាពាហ៍ពិពាហ៍ គឺច្រើនជាង ៤៣ឆ្នាំ ខណៈពេលដែលកូនក្រមុំ បរទេសរបស់ពួកគេគឺច្រើនជាង ២៥ឆ្នាំ។ អាយុរបស់កូនកម្លោះកូរ៉េខាងត្បូងដែលរៀបការ ជាមួយស្ត្រីបរទេសទាំងនោះ គឺមានអាយុជិត ១១ឆ្នាំ មានន័យថា ចាស់ជាងអាយុជា មធ្យមរបស់កូន កម្លោះកូរ៉េដែលរៀបការជាទូទៅនៅក្នុងឆ្នាំ ២០១៧ ខណៈពេលដែលកូនក្រមុំបរទេសមានអាយុទាបជាងកូនក្រមុំកូរ៉េ ៥ឆ្នាំ។ ជាមួយគ្នានេះដែរប្រជាជនកម្ពុជាក៏បានក្លាយជា ផ្នែកដែលធំជាងគេទីពីរនៃភរិយាបរទេស របស់ស្វាមីកូរ៉េខាងត្បូង គឺមាន ៨,៨ភាគរយ បន្ទាប់មកគឺជនជាតិចិន មាន ៧,៦ភាគរយ និងប្រជាជនហ្វីលីពីន មាន ៣,៧ភាគរយ៕

## កម្មករនេសាទខ្មែរ នៅថៃ ជាញឹកញាប់ត្រូវគេគេចប្រាក់ឈ្នួល

http://www.postkhmer.com/ Leonie Kijewski | Publication date 09 March 2018 | 10:43 ICT

**ភ្នំពេញ:** កម្មករនេសាទជនជាតិកម្ពុជា និងមីយ៉ាន់ម៉ាក្នុងប្រទេសថៃជាញឹកញាប់ត្រូវបានផ្តល់ឲ្យនូវប្រាក់ឈ្នួលក្រោមកម្រិតប្រាក់ឈ្នួលអប្បបរមា ហើយប្រាក់ឈ្នួលរបស់ពួកគេត្រូវបានរក្សាទុក និងប្រឈមមុខនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្សេងៗ។ នេះបើតាមការសិក្សាស្រាវជ្រាវថ្មីមួយរបស់អង្គការពលកម្មអន្តរជាតិ។ ចំពោះការសិក្សាស្រាវជ្រាវនេះអង្គការពលកម្មអន្តរជាតិបានសម្ភាសកម្មករនេសាទភាគច្រើនបំផុតជាជនជាតិកម្ពុជា និងជនជាតិមីយ៉ាន់ម៉ា និងកម្មករនៅក្នុងឧស្សាហកម្មអាហារសមុទ្រដើម្បីវាយតម្លៃស្ថានភាពការងាររបស់ពួកគេ។ ទោះយ៉ាងណាក្តីពួកគេបានផ្តោតតែទៅលើទូកនេសាទដែលធ្វើដំណើរនេសាទរយៈពេលខ្លី។

លោក មុំ សុខចា នាយកអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រីបានថ្លែងថា ស្ថានភាពគឺមានលក្ខណៈកាន់តែអាក្រក់ខ្លាំងជាងនេះចំពោះទូកនេសាទដែលចេញរយៈពេលយូរដែលកំពុងនេសាទនៅសមុទ្រជ្រៅ។ លោកថ្លែងថា៖ « អ្នកនេសាទដែលយើងបានធ្វើការជាមួយបានប្រាប់យើងថា ពួកគេមិនមានទឹកស្អាត ឬមានអាហារគ្រប់គ្រាន់ដើម្បី

ទទួលទាន ហើយជាញឹកញាប់ទទួលរងការដាក់ទោសទណ្ឌរាងកាយ ឬថែមទាំងរងការធ្វើទារុណកម្ម»។ ប៉ុន្តែសូម្បីតែទូកនេសាទរយៈពេលខ្លីមានតែ ២៩ ភាគរយនៃអ្នកឆ្លើយតបនៅក្នុងវិស័យនេសាទដែលមានអ្នកនេសាទជនជាតិកម្ពុជាភាគច្រើនបានរាយការណ៍មិនមានសូចនាករនៃការងារបង្ខំ ខណៈ ៤៨ ភាគរយបានបង្ហាញសូចនាករនៃការងារបង្ខំចំនួន ២ ឬច្រើនជាងនេះ។ ឧទាហរណ៍ សូចនាករទាំងនេះរួមមានលក្ខខណ្ឌការងាររំលោភបំពានការបំភិតបំភ័យ ការរក្សាទុកឯកសារអត្តសញ្ញាណ ឬការរក្សាទុកប្រាក់ឈ្នួល។ ជាលក្ខណៈកត់សម្គាល់ ការរក្សាទុកប្រាក់ឈ្នួលបានកើនពី ១២ ភាគរយក្នុងឆ្នាំ ២០១៣ ទៅ ២៤ ភាគរយក្នុងឆ្នាំ ២០១៧។ លោក មុំ សុខចា ថ្លែងថាការរក្សាទុកប្រាក់ឈ្នួលគឺជាបញ្ហាសំខាន់នៅក្នុងឧស្សាហកម្មនេសាទ ហើយបានកើតឡើងចំពោះអ្នកត្រឡប់មកវិញជាច្រើនដែលអង្គការរបស់លោកបានធ្វើការជាមួយពួកគេ។

«វិធីបើកប្រាក់ឈ្នួលគឺថា អ្នកត្រូវធ្វើការរយៈពេល ៦ ខែ ១ ឆ្នាំឬ ២ ឆ្នាំហើយបន្ទាប់មកអ្នកទទួលបានប្រាក់ឈ្នួលនោះ»។ លោកបានថ្លែងថា នៅពេលដែលទូកនេសាទត្រឡប់មកវិញអ្នកនេសាទជាញឹកញាប់ត្រូវបានចាប់ខ្លួននៅពេលនគរបាលរកឃើញថា ពួកគេមិនមានឯកសារ។ លោក សុខចា បានថ្លែងថា អ្នកនេសាទទាំងនេះមិនដែលទទួលបានប្រាក់ខែរបស់ខ្លួនទេ។ អ្នកដទៃទៀតឃើញថា ប្រាក់ឈ្នួលរបស់ពួកគេត្រូវបានកាត់យ៉ាងច្រើននៅពេលត្រឡប់មកដីគោកវិញ។ ជាងនេះទៀតមានតែ ៤១ ភាគរយនៃអ្នកនេសាទបានរាយការណ៍អំពីលទ្ធភាពទទួលបានបង្គន់សមស្រប។ ការសិក្សានេះក៏បានរកឃើញគម្លាតរវាងបុរស និងស្ត្រីដោយបុរសជាមធ្យមទទួលបានប្រាក់ ៩៨៥០ បាត (ប្រហែល ៣១៤ ដុល្លារ) ហើយស្ត្រីទទួលបាន ៩០១០ បាត (ប្រហែល ២៨៨ ដុល្លារ) ជាមធ្យមក្នុងមួយឆ្នាំ។ ប្រាក់ឈ្នួលអប្បបរមាគឺ ៩០០០ បាត (ប្រហែល ២៨៧ ដុល្លារ)។

រដ្ឋាភិបាលថៃក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ បានបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងការនេសាទខុសច្បាប់ គ្មានការរាយការណ៍ និងមិនមានការដាក់បញ្ញត្តិ ដើម្បីឆ្លើយតបនឹង «កាតលឿង» ដែលប្រទេសថៃបានទទួលពីការព្រមានរបស់សហភាពអឺរ៉ុប ដែលបានដាក់កម្រិតការនាំចេញរបស់ថៃទៅសហភាពអឺរ៉ុបឲ្យស្ថិតក្នុងការពិនិត្យតឹងរ៉ឹងខ្លាំងជាងមុន។ ប្រភពពីសហភាពអឺរ៉ុបបានថ្លែងកាលពីថ្ងៃពុធថា បេសកកម្មបច្ចេកទេសដោយអ្នកជំនាញសហភាពអឺរ៉ុបនឹងធ្វើទស្សនកិច្ចទៅប្រទេសថៃនាខែមេសាដើម្បីវាយតម្លៃពីវឌ្ឍនភាព៕ PS

## តំណាងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ជួបអាជ្ញាធរកណ្តាលនៃប្រទេសអ៊ីតាលី ពិភាក្សាពង្រឹងការងារ លើការអនុវត្តច្បាប់សុំកូនអន្តរប្រទេស

http://freshnewsasia.com/ 2018-03-09

**(ភ្នំពេញ)៖** លោក សួង ម៉េងឡុង អនុរដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ បានជួបជាមួយពិភាក្សាការងារជាមួយ លោកស្រី Laura Laera អនុប្រធានអាជ្ញាធរកណ្តាលនៃប្រទេសអ៊ីតាលី នាទីស្តីការក្រសួងសង្គមកិច្ច។

ការជួបពិភាក្សារវាងថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច និងជាមួយភាគីអាជ្ញាធរកណ្តាលនៃប្រទេសអ៊ីតាលី នាពេលនេះ ធ្វើឡើងក្នុង គោលបំណង ដើម្បីចែករំលែកបទពិសោធន៍ការងារល្អៗជាមួយគ្នា និងដើម្បីជាការចាប់ផ្តើមការងារជាថ្មី ក្រោយមានការផ្អាក ក្នុងការរៀបចំច្បាប់សុំកូនអន្តរប្រទេសផងដែរ។ នៅក្នុងជំនួបនោះ លោក សួង ម៉េងឡុង តំណាងរដ្ឋមន្ត្រី បានបង្ហាញពីការស្វាគមន៍ និងថ្លែងអំណរគុណ ដល់អាជ្ញាធរកណ្តាល នៃប្រទេសអ៊ីតាលី ដែលបានចូលរួមចំណែក និងសហការការងារដ៏ល្អ ជាមួយក្រសួងនាពេលកន្លងមក ទាក់ទងនឹងការងារសុំកូន យកទៅចិញ្ចឹម នៅប្រទេសអ៊ីតាលី។ ជារួមលោក សួង ម៉េងឡុង អនុរដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច ក៏មានស្នើសុំ ទៅដល់ភាគី អ៊ីតាលី ឲ្យជួយដល់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីរបស់ក្រសួងសង្គមកិច្ច ទាក់ទងនឹងការងារសុំកូនអន្តរប្រទេស និងការផ្លាស់ប្តូរទស្សនកិច្ចទៅកាន់ ប្រទេសអ៊ីតាលី ដើម្បីចែករំលែកបទពិសោធន៍ឲ្យគ្នាទៅវិញទៅមក។ តំណាងរដ្ឋមន្ត្រី លោក សួង ម៉េងឡុង បានសន្យាថា ទាំងថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងសង្គមកិច្ច នឹងចូលរួមបំពេញការងារជាមួយភាគីអ៊ីតាលី ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២ លើការងារសុំកូនអន្តរប្រទេស និងការងារសង្គមកិច្ចជាបន្ត

បន្ទាប់ទៀត។ លោក សួង ម៉េងឡុង បានបន្ថែមថា កន្លងមក ភាគីកម្ពុជា និងអ៊ីតាលី បានបំពេញការងារល្អជាមួយគ្នា ដោយគោរពទៅតាមច្បាប់ និងគោលការណ៍រៀងៗខ្លួន។

ជាមួយគ្នានោះ លោកស្រី Laura Laera អនុប្រធានអាជ្ញាធរកណ្តាលនៃប្រទេសអ៊ីតាលី ក៏បានអរគុណ ដល់ថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច ដែលបានអនុញ្ញាតឲ្យក្រុមការងាររបស់លោកស្រី ចូលជួបសម្តែងការគួរសមនាពេលនេះ។ លោកស្រី បានបញ្ជាក់ថា ចំពោះ ការស្នើសុំរបស់លោក សួង ម៉េងឡុង និងមន្ត្រីក្រសួងនាពេលនេះ ក្រុមការងារលោកស្រីស្វាគមន៍ ចំពោះភាគីកម្ពុជា ហើយក៏បានទទួលយកការស្នើសុំរបស់ក្រសួងសង្គមកិច្ច យកទៅពិចារណា និងជួយតាមលទ្ធភាពជាក់ស្តែង នៅពេលក្រោយ។ លោកស្រី Laura Laera បានបន្ថែមថា ចំពោះការងារសុំកូនអន្តរប្រទេសនេះ គឺប្រទេសអ៊ីតាលី បានធ្វើរួចហើយ រាល់ការទំនាក់ទំនងលើការងារនេះ ជាទូទៅគឺទទួលបានលទ្ធផលល្អ ដោយកុមារដែលទទួលយកមកចិញ្ចឹម គឺគ្មានការរងគ្រោះ ដោយការជួញដូរកុមារ តាមរយៈការសុំកូនយកទៅចិញ្ចឹម នៅក្រៅប្រទេស ជាពិសេសគឺថា កុមារកម្ពុជា ជាទូទៅគឺមាន ឪពុកម្តាយធម៌ និងចិញ្ចឹម របស់កុមារពិតប្រាកដ ទៅតាមច្បាប់ និងគោលការណ៍ដែលបានកំណត់ គឺគ្មានការរំលោភបំពាននោះឡើយ។ គួរបញ្ជាក់ថា គិតពីឆ្នាំ២០០២ រហូតមកដល់ឆ្នាំ២០១១ កម្ពុជា បានផ្តល់កុមារកម្ពុជា តាមការស្នើសុំរបស់អ៊ីតាលី បានចំនួន៧៩៥នាក់៕

## ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៨

## សហគមន៍ស្រុកតំបែរបារម្ភពីការចំណាកស្រុកទៅក្រៅប្រទេសកាន់តែមានច្រើន

https://www.rfa.org/khmer/ ដោយ វ៉ែន សុមេធ 2018-03-11

ប្រជាសហគមន៍នៅឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តត្បូងឃ្មុំ កត់សម្គាល់ថា ពលរដ្ឋក្នុងមូលដ្ឋាននាំគ្នាចាកចេញពីស្រុកកំណើត ដើម្បីទៅស្វែងរកការងារធ្វើនៅតំបន់ឆ្ងាយៗ ពិសេសទៅក្រៅប្រទេសកាន់តែមានច្រើនឡើង។ បញ្ហានេះ កើតឡើងដោយសារ នៅក្នុងមូលដ្ឋានរបស់ពួកគាត់គ្មានមុខរបរ និង ការងារសម្រាប់ធ្វើដូចពេលមុន ម្យ៉ាងពួកគាត់ត្រូវរកប្រាក់ដើម្បីដោះបំណុលគេថែមទៀតផង។

ប្រជាសហគមន៍នៅឃុំត្រពាំងព្រីង កាន់តែបារម្ភ ខណៈឃើញភូមិស្រុករបស់ខ្លួនកាន់តែមានសភាពស្ងប់ស្ងាត់ ដោយសារពលរដ្ឋពេញកម្លាំងចេះតែនាំគ្នាចំណាកស្រុកជាបន្តបន្ទាប់។ ពលរដ្ឋខ្លះនាំគ្នាទៅរកការងារធ្វើនៅខេត្តឆ្ងាយៗ ប៉ុន្តែពលរដ្ឋមួយចំនួនទៀតចេញទៅរកការងារធ្វើនៅក្រៅប្រទេស ពិសេសប្រទេសថៃតែម្តង។ ក្នុងចំណោមពលរដ្ឋចេញទៅប្រទេសថៃនោះ គឺ មានខ្លះចេញទៅដោយស្របច្បាប់ ប៉ុន្តែអ្នកភូមិខ្លះគឺចេញដោយប្រថុយប្រថានជាដើម។ ពលរដ្ឋនៅភូមិស្រែប្រាំង ឃុំត្រពាំងព្រីង លោក ម៉ុន ស៊ីថូ មានប្រសាសន៍ថា បញ្ហាចំណាកស្រុកគឺជារឿងមួយដែលអ្នកភូមិកំពុងព្រួយបារម្ភ។ ព្រួយបារម្ភពីព្រោះ ក្នុងភូមិស្រុកកាន់តែស្ងាត់ជ្រងំ ដោយសារមនុស្សពេញកម្លាំងចាកចេញច្រើន ប៉ុន្តែពួកគាត់ខ្លះចេញទៅក្រៅប្រទេសដោយប្រថុយប្រថានទៀតផង។ ប្រភពដដែល មើលឃើញថា ដោយសារពលរដ្ឋភាគច្រើនជំពាក់បំណុលធនាគារ ហើយតម្លៃលក់កសិផលកាលពីឆ្នាំមុនមានតម្លៃថោកពេក។ ជាក់ស្តែងដំឡូងមី ស្រស់កាលពីឆ្នាំ ២០១៧ លក់បានមួយគីឡូក្រាម ជាង ១០០រៀល ធ្វើឱ្យកសិករមួយចំនួនបង្ខំចិត្តទុកដីទំនេរចោល ឬ លក់ដីនោះ ដើម្បីសងបំណុលគេតែម្តង។ ដោយឡែកឆ្នាំនេះ ដំឡូងមីលក់មួយ(១)គីឡូក្រាម តម្លៃ ៣ ០០រៀល ប៉ុន្តែការផ្តល់ផលបែរជាធ្លាក់ចុះទៅវិញ ដោយសារដំឡូងមិនល្អ និងមានជំងឺផ្សេងៗផង៖ «តាមសង្កេតមើលទៅ សុទ្ធតែអ្នកខ្វះខាត មិនថាគេមិនថាខ្ញុំទេ។ នៅស្រុកខ្មែរយើងដូចថា រកចិញ្ចឹមគ្រួសារហ្នឹងដូចថា ផ្គត់ផ្គង់ទប់មិនបាន»។

ពលរដ្ឋនៅឃុំត្រពាំងព្រីង មានចំនួនជាង បីពាន់គ្រួសារ( ៣ ៥៨៣) ហើយភាគច្រើនពួកគាត់មានមុខរបរធ្វើស្រែ និងចម្ការ។ ក្នុងចំណោមពលរដ្ឋទាំងនេះ គឺមានប្រមាណ ៨០ភាគរយ ជំពាក់បំណុលធនាគារ។ ក្រៅពីបញ្ហាជំពាក់បំណុលគេ ពលរដ្ឋជាច្រើនក្នុងឃុំត្រពាំងព្រីង គឺមានបញ្ហាប្រឈមពាក់ព័ន្ធរឿងដីព្រៃសហគមន៍ជាង ៥ពាន់ហិកតារ ដែលត្រូវបានអ្នកមានប្រាក់ និងមានអំណាច រំលោភយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។ លើសពីនេះទៀត ប្រជាសហគមន៍នៅភូមិចំនួន៣ ទៀត គឺ ភូមិជីទ្រុន ភូមិបុស្សស្នោ និង ភូមិស្រែប្រាំង គឺមានវិបត្តិដីធ្លីជាង ១ ពាន់ហិកតារ ជាមួយក្រុម

ហ៊ុនចិនឈ្មោះ ហាមិនីវេន អ៊ិនវេសមេន (Hamenivent Investment) នៅតំបន់នោះទៀតផង។ ពលរដ្ឋម្នាក់ទៀត លោក សែម ចំណាន កត់សម្គាល់ថា ដោយសារកត្តាខ្វះខាតក្នុងជីវភាពរស់នៅ និងកង្វះការងារក្នុងស្រុក ទើបបង្ខំឱ្យអ្នកភូមិជាច្រើននាំគ្នាចំណាកស្រុក ទៅរកការងារធ្វើនៅតំបន់ផ្សេង ពិសេសទៅក្រៅប្រទេស។ លោកថា កាលពីមុន ពលរដ្ឋអាចធ្វើស្រែវស្សាផង និងស្រែប្រាំងផង ឬស៊ីឈ្នួលអ្នកភូមិគ្នាឯង និងរកចំណូលពីអនុផលពីព្រៃសហគមន៍របស់ខ្លួន។ ប៉ុន្តែ បច្ចុប្បន្នការធ្វើស្រែប្រាំង មិនបានផល ម្យ៉ាងមុខរបរក្នុងស្រុកក៏គ្មាន ពីព្រោះពលរដ្ឋមួយចំនួនដែលធ្លាប់មានដីធ្វើចម្ការពីមុនមក នាំគ្នាលក់ដីទាំងនោះដើម្បីយកប្រាក់សងបំណុលគេវិញ ។ លើសពីនេះ ដី សហគមន៍របស់ពួកគាត់កំពុងមានជម្លោះជាមួយក្រុមហ៊ុនចិន ហើយដីសហគមន៍ផ្សេងទៀតត្រូវបានអ្នកមានប្រាក់ និងមានអំណាចគ្រប់គ្រងជាដើម៖ «ឥឡូវហ្នឹងការងារនៅក្នុងស្រុកវាអត់មាន ម្យ៉ាងទៀត និយាយទៅពលរដ្ឋនៅក្នុងស្រុកខ្ញុំផ្ទាល់ហ្នឹងវាអត់ការងារធ្វើ។ អត់ការងារធ្វើ មានតែទៅធ្វើការងារនៅស្រុកគេ អាសេដ្ឋកិច្ចក្នុងស្រុកអត់ដំណើរការអីចឹងលោកគ្រូ»។

លោក សែម ចំណាន មើលឃើញថា នៅថ្ងៃមុខ ពិសេសក្រោយពេលបុណ្យចូលឆ្នាំប្រពៃណីខ្មែររួច ពលរដ្ឋក្នុងភូមិ នឹងចំណាកស្រុកបន្ថែមទៀត ប្រសិនបើសេដ្ឋកិច្ចនៅក្នុងស្រុកមិនរីកចម្រើន ឬខ្វះការងារធ្វើដូចបច្ចុប្បន្ន៖ «ទីមួយខ្ញុំសុំឱ្យរាជរដ្ឋាភិបាល ពិសេសសម្តេចតេជោ ហ៊ុន សែន ធ្វើយ៉ាងណាជួយឱ្យមានរោងចក្រ នៅក្នុងស្រុកមួយ។ អាហ្នឹងជាការការពារពលរដ្ឋចំណាកស្រុក ដើម្បីឱ្យពលរដ្ឋធ្វើការងារក្នុងស្រុក។ ទីពីរ រាជរដ្ឋាភិបាល និងសម្តេចហ្នឹង ពន្លឿន នៃការដោះស្រាយ បញ្ហាដីធ្លីហ្នឹងដើម្បីកាត់បន្ថយពលរដ្ឋចំណាកស្រុក»។ កាលពីពេលកន្លងមក អភិបាលស្រុកតំបែរ លោក នាថ រ៉ាវុធ ធ្លាប់មានប្រសាសន៍ថា ខាងលោកតែងណែនាំពលរដ្ឋឱ្យពួកគាត់នាំគ្នាស្វែងរកការងារធ្វើ នៅក្នុងស្រុក ហើយជៀសវាងការធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយប្រថុយប្រថាន ឬដោយខុសច្បាប់។

ទោះជាយ៉ាងណា កាលពីខែធ្នូ ឆ្នាំ ២០១៧ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថា ការចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស គឺពុំមែនមានតែប្រទេសកម្ពុជានោះឡើយ ហើយទីផ្សារកម្លាំងពលកម្មរបស់កម្ពុជាត្រូវប្រកួតប្រជែងជាមួយទីផ្សារក្នុងតំបន់ថែមទៀត៖ «យើងហ្នឹងបន្តពង្រីកជាមួយហ្នឹងទីផ្សារការងារ របស់យើងនៅក្រៅប្រទេស។ ជាមួយហ្នឹង ការប្រកួតប្រជែងជាមួយកម្មករនៃប្រទេសដទៃ»។ របាយការណ៍បូកសរុបការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកាលពីឆ្នាំ២០១៦ និងបានផ្សព្វផ្សាយនៅដើមឆ្នាំ២០១៧ បង្ហាញថា ចំនួនពលរដ្ឋដែលបានទៅធ្វើការងារនៅក្រៅប្រទេសមានចំនួនជាង១ លាននាក់ ដោយពួកគេទៅធ្វើការងារនៅប្រទេសថៃ ម៉ាឡេស៊ី សិង្ហបុរី ជប៉ុន និង កូរ៉េខាងត្បូង។ ក្នុងចំណោមប្រទេសទាំងនេះ ប្រទេសថៃ មានចំនួនពលករខ្មែរទៅធ្វើការងារច្រើនជាងគេ មានចំនួនជាង ១លាននាក់ ហើយពលករដែលមិនទាន់មានឯកសារត្រឹមត្រូវមានចំនួនជាង ៣០ម៉ឺននាក់។

យ៉ាងនេះក្តី ក្នុងឆ្នាំ ២០១៧នោះដែរ រាជរដ្ឋាភិបាលខ្មែរ និងថៃ បានចាប់ផ្តើមរៀបចំបំពេញឯកសារជូនពលករខុសច្បាប់ទាំងនោះ ដើម្បីឱ្យពួកគេមានឱកាសបំពេញការងារនៅក្នុងប្រទេសថៃដោយស្របច្បាប់ឡើងវិញ។ មន្ត្រីផ្នែកអង្កេតសមាគមការពារសិទ្ធិមនុស្សអាដហុក(ADHOC) ខេត្តត្បូងឃ្មុំ លោក ឡេង សេងហាន មានប្រសាសន៍ថា ប្រទេសក្នុងតំបន់អាស៊ាន ដូចជាប្រទេសថៃជាដើមនោះ ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ភាគច្រើនជាប្រភេទកម្មករជំនាញ មិនមែនភាគច្រើនជាប្រភេទកម្មករប្រើកម្លាំង ឬជាពលករបម្រើការងារតាមផ្ទះដូចកម្ពុជានោះទេ។ លោកថា ការចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេសក៏មានចំណុចវិជ្ជមានដែរ ដូចជាទទួលបានប្រាក់កម្រៃខ្ពស់ និង មានប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ សំខាន់ឱ្យតែការចំណាកស្រុកនោះ ធ្វើឡើងដោយស្របច្បាប់ និងមានការយកចិត្តទុកដាក់ខ្ពស់ពីក្រុមហ៊ុន ព្រមទាំងរាជរដ្ឋាភិបាល។ ប្រភពដដែល មើលឃើញថា មូលហេតុដែលធ្វើឱ្យពលរដ្ឋនៅស្រុកតំបែរ នាំគ្នាចំណាកស្រុកជាបន្តបន្ទាប់ គឺ ដោយសារបញ្ហាប្រឈមក្នុងគ្រួសារតែម្តង។ ជាក់ស្តែង ពលរដ្ឋភាគច្រើនជំពាក់បំណុលធនាគារ ខ្វះដីធ្លីសម្រាប់បង្កបង្កើនផល កង្វះចំណេះដឹង កង្វះការងារធ្វើ ឬ មានប្រាក់កម្រៃទាប ព្រមទាំងបញ្ហាតម្លៃកសិ

ផលថោកៈ «ស្រុកយើងមុខរបរវាមិនសូវមានទេ ហើយការធ្វើកសិកម្មរបស់គាត់ហ្នឹងក៏ប្រឈមទៅហ្នឹង ការខាតបង់ ឬក៏គ្មានទីផ្សារអីច្បាស់លាស់»។

មន្ត្រីផ្នែកអង្កេតរូបនេះ យល់ថា ប្រសិនបើ រាជរដ្ឋាភិបាល ចេះតែបញ្ជូនពលករទៅធ្វើការងារនៅក្រៅប្រទេស ម្យ៉ាងពលរដ្ឋខ្លួនឯងចេះតែចំណាកស្រុកបន្ថែមទៀត នៅថ្ងៃខាងមុខ ប្រទេសកម្ពុជានឹងប្រឈមកង្វះកម្លាំងពលកម្មជាក់ជាមិនខាន។ បញ្ហានេះ នឹងប៉ះពាល់ដល់ការរីកលូតលាស់នៃសេដ្ឋកិច្ចរបស់ជាតិទៀតផង។ លោកគិតថា ដើម្បីកាត់បន្ថយការចំណាកស្រុកទៅក្រៅប្រទេស រដ្ឋាភិបាលគប្បីដោះស្រាយវិបត្តិដីធ្លីជូនពលរដ្ឋមានជម្លោះ។ បង្កើតការងារក្នុងស្រុកឱ្យបានច្រើន និងមានប្រាក់ខែសមរម្យ ព្រមទាំងស្វែងរកទីផ្សារលក់ផលិតផលកសិកម្ម ឬកសិ-ឧស្សាហកម្ម ក្នុងតម្លៃខ្ពស់ជូនកសិករជាដើម៕

## រដ្ឋបាលខេត្តកោះកុង ប្រជុំផ្សព្វផ្សាយ ពីការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ១២ មិនា ២០១៨ 11:10 ដោយ: ដារ៉ា ID:012

កោះកុង ៖ លោកស្រី ឈុន វ៉ារុជ អភិបាលរង ខេត្តកោះកុង នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨នេះ បាន អញ្ជើញប្រជុំផ្សព្វផ្សាយ សេចក្តីសម្រេច ស្តីពីការកែសម្រួល សមាសភាព របស់លេខា ធិការដ្ឋាន នៃគណៈកម្មាធិការ ខេត្តប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ដោយមាន ការចូលរួមគ្រប់បណ្តាអង្គភាព ដែលពាក់ព័ន្ធជាច្រើនរូបទៀត ។

ក្នុងកិច្ចប្រជុំនេះ លោកស្រី ឈុន វ៉ារុជ អភិបាលរង ខេត្តបានលើកឡើងថា រដ្ឋបាលខេត្ត កោះកុង បានធ្វើការផ្លាស់ប្តូរ សមាសភាពមួយចំនួន ដើម្បីជាជំនួយការ ប្រតិបត្តិរបស់ គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្ត ក្នុងការអនុវត្តភារកិច្ច ដែលដាក់ជូន គណៈកម្មាធិការជាតិ លើការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ត្រូវរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយអោយបាន ទូលំទូលាយអំពីច្បាប់ គោលនយោបាយ បទដ្ឋានពាក់ព័ន្ធ ពង្រឹង ទំនាក់ទំនង សហការក្នុងក្រុមការងារជំនាញមន្ទីរ និងអង្គភាពពាក់ព័ន្ធ លើកផែនការ ពង្រឹង សមត្ថភាពមន្ត្រី តាមដានលំហូរ ពលករអន្តោរប្រវេសន៍ ទប់ស្កាត់ការចំណាកស្រុក ជាដើម។ លោកស្រីបានបញ្ជាក់ថា "យើងត្រូវចូលរួមសហការគ្នា ទាំងថ្នាក់មូលដ្ឋាន ស្រុក ក្រុង ខេត្ត ហើយត្រូវមានការទំនាក់ទំនង ជាមួយប្រទេសជិតខាងអោយជាប់ ជានិច្ច ហើយមន្ត្រីទាំង អស់ត្រូវយកចិត្តទុកលើកការងារជាចាំបាច់ ត្រូវបើកអោយទូលំទូលាយ ក្នុងការផ្សព្វផ្សាយ ព័ត៌មាន ជូនប្រជាពលរដ្ឋអោយបានញឹកញាប់ អោយគាត់បានយល់កាន់ តែច្បាស់លើ ព័ត៌មាន"៕

## នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បើកវគ្គបណ្តុះបណ្តាលស្តីពី យុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ

http://cambodiapolice.com/blog/ 11:45 am 12 មីនា 2018 6

ភ្នំពេញ ៖ នាព្រឹកម៉ោង៨និង៣០នាទី ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអានីតិជន មាន រៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពី យុទ្ធវិធីប្រតិបត្តិការ និងការប្រើ ប្រាស់អាវុធនៅអគ្គស្នងការដ្ឋាននគរបាលជាតិ វគ្គបណ្តុះបណ្តាលនេះ ចាប់ផ្តើមពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ ដោយមានសិក្ខាកាម ចូលរួមចំនួន២០រូប (មកពីនាយក ដ្ឋាន៥រូប , ភ្នំពេញ ៣រូប , កំពង់ចាម ១រូប , ត្បូងឃ្មុំ ២រូប , ព្រះសីហនុ ២រូប , កណ្តាល២រូប , កោះកុង១រូប , ព្រះវិហារ១រូប , តាកែវ ២រូប និង ខេត្តកំពត១រូប)។ ក្នុងពិធីនេះ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារ អនីតិជន និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ,លោក អេរិច មេលឌ្រឹម នាយកផ្នែកស៊ើបអង្កេតនៃអង្គការមេត្រីអន្តរជាតិ (AIMSWAT) និងលោកដុកទ័

រ ជេស ប្រុជស្តី ស្ថាបនិក និងជាប្រធានអង្គការសេចក្តី អំណរអន្តរជាតិ ។ លោក អេរិច មេលទ្រីម នាយកផ្នែកស៊ើបអង្កេត នៃអង្គការមេត្រី អន្តរជាតិ (AIMSWAT) បានមានប្រសាសន៍ថា នេះជាលើកទី១០ ដែល អង្គការមេត្រីអន្តរជាតិបានរៀបចំឲ្យមានវគ្គបណ្តុះបណ្តាលនេះឡើង លោកមានការត្រេកអរនៅពេលដែលមាននគរបាលជានារីចូលរួមរៀនវគ្គបណ្តុះបណ្តាលនេះ ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋានប្រឆាំង ការជួញដូរមនុស្ស និងការពារអនីតិជនបានមានប្រសាសន៍ថា ឯកឧត្តម សូមផ្តាំផ្ញើទៅសិក្ខាកាមទាំងអស់ ត្រូវគោរពវិន័យ និងខិតខំ យកចិត្តទុកដាក់ក្នុងការហ្វឹកហាត់ឲ្យបានល្អ សំដៅនាំយកចំណេះដឹង ទាំងនេះទៅអនុវត្តនិងចែករំលែកបទពិសោធន៍ដល់មិត្តរួមការងារក្នុង ការបំពេញភារកិច្ចរបស់ខ្លួនឲ្យសម្រេចបានជោគជ័យ ។ ឯកឧត្តម ប្រធាននាយកដ្ឋានប្រឆាំងបានបន្តទៀតថា ក្នុងនាមសិក្ខាកាម ជាមន្ត្រីនគរបាលយើងត្រូវគិតពីអ្វីដែលចាំបាច់បំផុតក្នុងការដោះស្រាយបញ្ហាជាទូទៅ ហើយមុននឹងធ្វើអ្វីឬដោះស្រាយអ្វី ត្រូវគិតត្រូវរិះរក វិធីដើម្បីដោះស្រាយដោយសន្តិវិធី ទើបយើងអនុវត្តទទួលបានជោគជ័យ ហើយក្នុងការអនុវត្តឲ្យទទួលបានជោគជ័យនេះទៀតសោធ ចាំបាច់សិក្ខាកាម ត្រូវមានចំណេះជំនាញ និងសមត្ថភាពគ្រប់គ្រាន់ បូករួមទាំងមានឆន្ទៈ និងបទពិសោធន៍ដែលរៀមច្បងយើងថែមទៀត។ គ្រប់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គឺមានការបង្រ្កាបបទល្មើស យើងប្រឈមប្រយុទ្ធជាមួយពួកជនល្មើស យើងប្រឈមប្រយុទ្ធ ប្រឆាំងជាមួយអំពើជួញដូរមនុស្សដែលនាំស្ត្រីខ្មែរទៅធ្វើការនៅក្រៅប្រទេស ហើយដើម្បីប្រយុទ្ធប្រឆាំងជាមួយអំពើរជួញដូរមនុស្ស និង បង្រ្កាបឲ្យទទួលបានជោគជ័យ ទី១ត្រូវប្រមូលព័ត៌មានឲ្យបានច្បាស់ លាស់ ក្តាប់សភាពការណ៍និងស្ថានភាពភូមិសាស្រ្តឲ្យបានច្បាស់លាស់ថាតើកន្លែងនោះមានជនរងគ្រោះប៉ុន្មាននាក់ ហើយមានជនល្មើស ប៉ុន្មាននាក់ ជនល្មើសមានអាវុធប៉ុន្មានដើម អាវុធស្អីខ្លះ ហើយទីតាំង ខាងក្រៅនិងខាងក្នុងវាមានការលំបាកយ៉ាងម៉េចខ្លះ ពេលដែលយើង ស៊ើបអង្កេតដឹងច្បាស់ហើយយើងត្រូវមានវិធានការណ៍ បង្រ្កាបជន ល្មើសយ៉ាងម៉េចដើម្បីកុំឲ្យប៉ះពាល់ដល់អាយុជីវិតជនរងគ្រោះ ពេល ដែលយើក្តាបស់សភាពការណ៍ដឹងច្បាស់ហើយ យើងអាចបង្ក្រាប ទទួលបានជោគជ័យ ។

ឯកឧត្តម ប្រធាននាយកដ្ឋានប្រឆាំងបានបន្តទៀតថា ការបើកវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធនេះ គឺក្នុងគោលបំណងពង្រឹងសមត្ថភាពបន្ថែម ហើយឯកឧត្តមដឹងថាហើយថា សិក្ខាកាមយើងធ្លាប់រៀនសូត្រច្រើនមកហើយតែវគ្គនេះជាលំហាត់ផ្ទាល់ជាការចុះប្រតិបត្តិការផ្ទាល់ចឹងយើងឮមួយរយដងមិនស្មើនឹងឃើញម្តង ហើយឃើញមួយរយដងមិនស្មើការអនុវត្តម្តង ដូច្នេះចាំបាច់ត្រូវការអនុវត្តផ្ទាល់ នេះជាសំណូមពររបស់ឯកឧត្តម ៕

## រដ្ឋបាលខេត្តកោះកុង បើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការកែសម្រួលរបស់លេខាធិការដ្ឋានគណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2018-03-12

**(កោះកុង)៖** លោកស្រី ឈុន រ៉ាវុធ អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨នេះ បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ដោយមានការចូលរួមគ្រប់បណ្តាអង្គភាព ដែលពាក់ព័ន្ធជាច្រើនរូបផងដែរ។

ក្នុងកិច្ចប្រជុំនេះលោកស្រី ឈុន រ៉ាវុធ បានលើកឡើងថា រដ្ឋបាលខេត្តកោះកុង បានធ្វើការផ្លាស់ប្តូរ សមាសភាពមួយចំនួន ដើម្បីជាជំនួយការប្រតិបត្តិរបស់គណៈកម្មារប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្សខេត្ត ក្នុងការអនុវត្តភារកិច្ច ដែលដាក់ជូនគណៈកម្មាធិការជាតិ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអោយបានទូលំទូលាយអំពីច្បាប់ គោលនយោបាយ បទដ្ឋានពាក់ព័ន្ធ ពង្រឹងទំនាក់ទំនង សហការក្នុងក្រុមការងារជំនាញ

មន្ទីរ និងអង្គភាពពាក់ព័ន្ធលើកផែនការ ពង្រឹងសមត្ថភាពមន្ត្រី តាមដានលំហូរពលករសន្តោរប្រវេសន៍ ទប់ស្កាត់ការចំណាកស្រុក ជាដើម។ លោកស្រី បានបញ្ជាក់ថា **«យើងត្រូវចូលសហការណ៍គ្នា ទាំងថ្នាក់មូលដ្ឋានស្រុកក្រុងខេត្ត ហើយត្រូវមានការ ទំនាក់ទំនងជាមួយប្រទេសជិតឲ្យជាប់ជានិច្ច ហើយមន្ត្រីទាំងអស់ត្រូវយកចិត្តទុកដាក់ លើកការងារជាចាំបាច់ត្រូវបើកឲ្យទូលំទូលាយក្នុងការផ្សព្វផ្សាយព័ត៌មាន ជូនប្រជាពលរដ្ឋឲ្យបានញឹកញាប់ឲ្យគាត់ បានយល់កាន់តែច្បាស់លើព័ត៌មាន»**។

## ពលករខ្មែរចេញទៅធ្វើការនៅបរទេសសរុបជិត៤ម៉ឺននាក់ កាលពីឆ្នាំមុន

http://bayontv.com.kh/ 12/03/2018

ភ្នំពេញ ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា ចំនួនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករ ទៅបរទេស ចំនួនសរុបជាង៣ម៉ឺន ៨ពាន់នាក់ នៅឆ្នាំ២០១៧ កើនឡើង១០ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០១៦ ដែលមានពលករចំនួន៣ម៉ឺន ៤ពាន់នាក់ បានចេញទៅធ្វើការងារនៅបរទេស។ យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានបង្ហាញ នៅព្រឹកថ្ងៃទី១២ មីនា ឆ្នាំ២០១៨នេះបានបញ្ជាក់ថា ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេស មានចំនួន៧ប្រទេស រួមមាននៅប្រទេសម៉ាឡេស៊ី២៧នាក់, អារ៉ាប់ប៊ីសាអូឌីត១២នាក់, ថៃជាង៧ពាន់នាក់, ជប៉ុនជាង១ពាន់នាក់, សឹង្ហបុរី៨៧នាក់, តំបន់រដ្ឋបាលពិសេសហុងកុង៥នាក់ និងប្រទេសកូរ៉េចំនួនជិត៦ពាន់នាក់។ ប្រភពដដែលនេះ បន្ថែមទៀតថា គិតចាប់ពីឆ្នាំ២០០៧ មកដល់ឆ្នាំ២០១៧ ប្រជាពលរដ្ឋទទួលបាន ការងារថ្មីចំនួនជិត១លាននាក់ ក្នុងនោះធ្វើការនៅក្នុងប្រទេសជិត៦០ម៉ឺននាក់ និងចេញទៅធ្វើការនៅក្រៅប្រទេសជាង២៧ម៉ឺននាក់។

## កម្ពុជាបញ្ជូនពលករ ទៅបំរើការងារ នៅក្រៅប្រទេស ជិត១០ម៉ឺននាក់ នៅឆ្នាំ២០១៧

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ១២ មិនា ២០១៨ 12:50 ដោយ: ស សំណាង ID:012

ភ្នំពេញ ៖ កម្ពុជាបានបញ្ជូន កំលាំងពលកម្ម ទៅបំរើការងារ នៅក្រៅប្រទេស ដើម្បីទទួល ប្រាក់កម្រៃមកផ្គត់ផ្គង់គ្រួសារមានជិត១០ម៉ឺននាក់ ក្នុងឆ្នាំ២០១៧ ដែលមានការ កើនឡើង ១២.៦% បើប្រៀបធៀប នឹងឆ្នាំ២០១៦ មានជាង៨ម៉ឺននាក់។ យោងតាមរបាយការណ៍ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញ ផ្សាយ ក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ថា ក្រសួងការងារបានបញ្ជូនពលករទៅធ្វើការ នៅក្រៅប្រទេស មាន ចំនួន៩៦.៣៣៨នាក់ (ស្រី៣៨.១៩៨នាក់) បើធៀបនឹងឆ្នាំ២០១៦ មានចំនួន៨៥.៥៧៦នាក់ (ស្រី ៣៤.៧៣០នាក់)។ របាយការណ៍ឲ្យដឹងទៀតថា ពលករបញ្ជូនទៅរួមមាន៖ ថៃចំនួន៨៧.៩០៩នាក់ (ស្រីចំនួន ៣៥.១៦៤នាក់) កូរ៉េចំនួន៥.៩៦៧នាក់ (ស្រីចំនួន១.៦៣១នាក់) ជប៉ុនចំនួន២.២៨០នាក់ (ស្រីចំនួន១.២៤១នាក) ម៉ាឡេស៊ីចំនួ ២៧នាក់ (ស្រីចំនួន៧នាក់) សិង្ហបុរីចំនួន១៣៨នាក់ (ស្រីចំនួន ១៣៨នាក់) អារ៉ាប់ប៊ីសាអូឌីតចំនួន១២នាក់ (ស្រីចំនួន១២នាក់) និងតំបន់រដ្ឋបាល ពិសេសហុងកុងចំនួន៥នាក់ (ស្រី៥នាក់)។

របាយការណ៍របស់ក្រសួងការងារក៏បានឲ្យដឹងទៀតថា គិតចាប់ឆ្នាំ២០០៧ ដល់ឆ្នាំ ២០១៧ ពលរដ្ឋទទួលបានការងារធ្វើចំនួន៩១៦.២៤៩នាក់ (ស្រីចំនួន៥១៩.៨៧០នាក់) ក្នុងនោះ ក្នុងប្រទេសចំនួន៥៩៣.០៨៧នាក់ (ស្រីចំនួន៣៨២.៦៨៨នាក់) នៅក្រៅប្រទេស ចំនួន ២៧០.៩២៧នាក់ (ស្រីចំនួន១១៧.០៩៨នាក់) ថៃ ចំនួន២២០.៨៩៧នាក់ (ស្រី៨៧.១៧៧នាក់) កូរ៉េចំនួន៥៦.៧១០នាក់ (ស្រីចំនួន១១.៧៦៣នាក់) ជប៉ុនចំនួន៦.១៣០នាក់ (ស្រី៣៥២៣នាក់) ម៉ាឡេស៊ីចំនួន ៣៨.៧៨៣នាក់ (ស្រី៣៤.០៧៧នាក់) សិង្ហបុរីចំនួន៦២៥នាក់ (ស្រីចំនួន

៦២៥នាក់) អារ៉ាប់ប៊ីសាអូឌីតចំនួន១២នាក់(ស្រី១២នាក់) និងតំបន់រដ្ឋបាលពិសេស ហុងកុងចំនួន៥នាក់(ស្រី៥នាក់)។

បើតាមលោករដ្ឋមន្ត្រី អ៊ិត សំហេង បច្ចុប្បន្នមានពលករកម្ពុជា ជាង១.២លាននាក់ កំពុងធ្វើការងារនៅបរទេស ហើយបាននាំយកប្រាក់ ចំណូលមកក្នុងប្រទេសវិញ ជិត២លានដុល្លារក្នុង១ឆ្នាំ ព្រមទាំងទទួលបានមុខជំនាញវិជ្ជាជីវៈដើម្បីរួមចំណែក ក្នុងការអភិវឌ្ឍប្រទេសជាតិផងដែរ៕

## ឆ្នាំ២០១៧ កម្ពុជា-ថៃ រួមគ្នាទប់ស្កាត់ ការកាប់ឈើ៤៧លើក បង្ក្រាបគ្រឿងញៀន១៤លើក និងជួញដូរ អាវុធ១ករណី

https://www.dap-news.com/kh/ សុក្រ, 09 មិនា ២០១៨ 15:31 ដោយ: ស៊ាន កុសល ID:012

ភ្នំពេញ ៖ សភាពការណ៍ សន្តិសុខព្រំដែនកម្ពុជា-ថៃ ក្នុងឆ្នាំ២០១៧ កន្លងមកនេះ ភាគីទាំងពីរ បានរួមគ្នាទប់ស្កាត់ ការកាប់ឈើ របស់ពលរដ្ឋខ្មែរ ក្នុងទឹកដីថៃ បានចំនួន៤៧លើក និងបង្ក្រាប ករណីគ្រឿងញៀនរួមគ្នា ចំនួន១៤លើក រួមនិងបទល្មើសមួយចំនួនផ្សេងទៀត។

នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការ ការងារព្រំដែន អគ្គបញ្ជាការ លោកឧត្តម សេនីយ៍ឯក សៀក សុជាតិ ក្នុងពិធីបិទកិច្ចប្រជុំបូក សរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិស ដៅឆ្នាំ២០១៨ របស់ការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ នៅព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨នេះ បានមានប្រសាសន៍ថា "ក្នុងឆ្នាំ២០១៧ ស្ថានភាពពលរដ្ឋយើងធ្វើចំណាកស្រុក ទៅរកការងារធ្វើដោយស្របច្បាប់ និងខុសច្បាប់នៅប្រទេសថៃ មានចំនួនច្រើន ដែលប្រឈម ឧបសគ្គជាយថាហេតុផ្សេងៗ ក្នុងនោះ ពលរដ្ឋយើងរងការទប់ស្កាត់ការកាប់ឈើ ៤៧លើក ក្នុងនោះដោយសមត្ថកិច្ចថៃ៤៥លើក បាញ់របួស១នាក់ (ប្រុស) រត់រួច៧នាក់ (ប្រុស) ចាប់ខ្លួន ៩នាក់ (ស្រី១នាក់) រឹបអូសឈើក្រញូង១៣៩ដុំ រថយន្ត Tundra ១គ្រឿង និងឧបករណ៍ ពាក់ព័ន្ធមួយចំនួន ដោយឡែកសមត្ថកិច្ចយើងទប់ស្កាត់២លើក ឃាត់មកអប់រំ រួចឲ្យត្រឡប់ ទៅវិញ"។

ចំពោះករណីគ្រឿងញៀនវិញ លោកឧត្តមសេនីយ៍ឯក សៀក សុជាតិ បានបញ្ជាក់ថា "ការបង្ក្រាប ករណីគ្រឿងញៀន១៤លើក ក្នុងនោះដោយសមត្ថកិច្ចថៃ ៤លើក ចាប់ខ្លួន៤នាក់ (ស្រី២នាក់) រឹបអូសកញ្ឆា៦គីឡូក្រាម ថ្នាំញៀន៦៤គ្រាប់, ដោយសមត្ថកិច្ចយើង១០លើក ចាប់ខ្លួន២៧នាក់ (ស្រី៣នាក់) ជនជាតិវៀតណាម១០នាក់ រឹបអូសថ្នាំញៀន៤.០៩៦គ្រាប់ ម៉ាកទឹកកក៣១២គ្រាប់ និងអាវុធខ្លីមួយដើម មាន១០គ្រាប់។ សមត្ថកិច្ចថៃចាប់ខ្លួនពលរដ្ឋថៃ និងពលរដ្ឋខ្មែរ ៧លើក ក្នុងករណីជួញដូរអាវុធឆ្លងដែន១លើក ចាប់ខ្លួនជនជាតិថៃ៥នាក់ រឹបអូសអាវុធធុនត្បាលចំនួន៣ដើម រួមមាន ៨១ម.ម ចំនួន១ដើម, ៨២ម.ម ចំនួន២ដើម និងគ្រាប់៣គ្រាប់ ខ្សែអុជបញ្ឆេះ៣ឈុត, ករណីកម្មសិទ្ធិបញ្ញា ៣លើក ឃាត់ខ្លួនពលរដ្ឋ ខ្មែរ១នាក់ប្រុស, ករណីឆ្លងដែនខុសច្បាប់៣លើក ឃាត់ខ្លួនពលរដ្ឋខ្មែរយកមក ផ្តន្ទាទោស ១៤នាក់ (ស្រី៨នាក់)"។

ដោយឡែលពលរដ្ឋខ្មែរ ត្រូវបានដោះលែងពីការឃុំខ្លួន នៅប្រទេសថៃ ១២លើក សរុប៣៨ នាក់ (ស្រី៨នាក់) ក្នុងនោះករណីឆ្លងដែនខុសច្បាប់៦លើក សរុប២៣នាក់ (ស្រី៧នាក់ កុមារ២នាក់) ករណីកាប់ឈើ៤លើក សរុប១២នាក់ ករណីគ្រឿងញៀន១លើក សរុប២នាក់ (ស្រី១នាក់) ករណីកម្មសិទ្ធិបញ្ញា១លើក សរុប១នាក់។ ចំពោះករណីអត្តឃាតខ្លួន ៨លើក ស្លាប់ពលរដ្ឋខ្មែរ៩នាក់ (ស្រី២នាក់) នៅប្រទេសថៃ៤លើក ស្លាប់៤នាក់ ក្នុងភូមិសាស្ត្រ៤លើក ស្លាប់៥នាក់ (ស្រី២នាក់) ករណីឃាតកម្ម៩លើក ស្លាប់១២នាក់ (ស្រី៦នាក់) ចាប់ខ្លួន៨នាក់ ជនល្មើសជនជាតិថៃ១នាក់ នៅប្រទេសថៃ៧លើក ស្លាប់៩នាក់ (ស្រី៤នាក់) ក្នុងភូមិសាស្ត្រ២ លើក ស្លាប់៤នាក់ (ស្រី២នាក់), ករណីចោរកម្ម៦លើក ចាប់ខ្លួន៣នាក់ នៅប្រទេសថៃ២លើក ក្នុងភូមិសាស្ត្រ៤លើក សរុបបាត់បង់ម៉ូតូ២គ្រឿង ប្រាក់ប្រមាណ ៣.៥០០ដុល្លារ ទូរស័ព្ទ២ គ្រឿង ពិល១, គ្រោះថ្នាក់ចរាចរ ៦៨លើក ក្នុងនោះនៅប្រទេសថៃ ៣៦លើក ពលរដ្ឋខ្មែររង

របួស២នាក់ (ស្រី១នាក់) របួសធ្ងន់១នាក់ ស្លាប់៤១នាក់ (ស្រី៩នាក់) ក្នុងភូមិសាស្ត្រ ៣២លើក របួស៥២នាក់ (ស្រី១នាក់ កុមារ១នាក់) របួសធ្ងន់១៨នាក់ ស្លាប់៧នាក់ (ស្រី១នាក់) ពលរដ្ឋខ្មែរ ស្លាប់ដោយសារជំងឺនៅប្រទេសថៃ១៣២នាក់ (ស្រី២៧នាក់ កុមារ១នាក់) ចូលព្យាបាល៣នាក់ (កុមារ១នាក់) រោគខ្យល់គ៦៦នាក់ រោគលើសឈាម១២នាក់ រោគមហារីក៨នាក់ រោគសួត១ នាក់ រោគធ្លាយក្រពះ២នាក់ រោគផ្សេងៗ៤៣នាក់ និងអគ្គិភ័យនៅផ្សាររោងគ្លឿថៃ ១លើក ឆេះតូបលក់របស់អាជីវករខ្មែរ ១៨តូបខូចខាតឥវ៉ាន់ ទំនិញជាច្រើន៕

## ពលករខ្មែរ, តូចចិត្តនឹងថៅកែថៃមិនបើកប្រាក់ខែអោយ សម្រេចចិត្តចងកសម្លាប់ខ្លួន ដើម្បីបញ្ចប់បញ្ហា

http://www.prakpheaktra.com March 9, 2018

ករណីនេះបានកើតឡើងកាលពីវេលាម៉ោង03:30នាទី ថ្ងៃសុក្រ ទី09 ខែមីនា ឆ្នាំ2018 ស្ថិតនៅក្នុងបន្ទប់ស្នាក់នៅរបស់កម្មករសំណង់មួយកន្លែងស្ថិត សង្កាត់សែនសុខ ស្រុកមឿង ខេត្តឈុនបុរី ប្រទេសថៃ ជនរងគ្រោះដែលចងកសម្លាប់ខ្លួនមានឈ្មោះ ហឿន វុទ្ធី អាយុ 33ឆ្នាំ ជាជាងសំណង់ធ្វើការនៅកន្លែងកើតហេតុ។ យោងតាមប្រភពពីប្រពន្ធអ្នកស្លាប់បានប្រាប់អោយដឹងថា ក្រោយពេលសម្រាកហូបបាយថ្ងៃត្រង់ហើយប្តីរបស់គាត់បានចុះទៅហើយ រួចបានដើរមកបន្ទប់ស្នាក់នៅវិញដើម្បីយកស្លាបព្រាកអិត តែមួយសន្ទុះក្រោយមកត្រូវគេប្រទះឃើញប្តីគាត់ចងកសម្លាប់ខ្លួនក្នុងបន្ទប់ស្នាក់នៅទៅវិញ។ ប្រភពដដែលបានបន្តទៀតថាប្តីរបស់គាត់ត្រូវថៅកែថៃបោកអោយទៅធ្វើការនៅស្រុកសាមខូគ ខេត្តណាខនប៉ាធុម អស់រយៈពេលជាងមួយខែដោយមិនបើកប្រាក់ខែអោយ ធ្វើអោយជនរងគ្រោះពិបាកចិត្តគិតច្រើន ណាមួយជំពាក់ប្រាក់គេនៅឯផ្ទះច្រើនផងធ្វើអោយគិតខ្លីចងកសម្លាប់ខ្លួនតែ។

ក្រោយពេលកើតហេតុសមត្ថកិច្ចតម្រួតសង្កាត់សែនសុខចុះត្រួតពិនិត្យសាកសពនៅកន្លែងកើតហេតុ រួចយកទៅរក្សាទុកនៅមន្ទីរពេទ្យម៉បូរីផា ដើម្បីធ្វើការកោសលវិច័យម្តងទៀត ក្នុងករណីនេះសមត្ថកិច្ចថៃកំពុងធ្វើការស្រាវជ្រាវរកមូលហេតុពិតប្រាកដនៃការចងសម្លាប់នេះ។ ក្នុងករណីពលករខ្មែរចងកសម្លាប់នេះដែរមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ កំពុងធ្វើការទំនាក់ទំនងទៅក្រុមគ្រួសាររបស់អ្នកស្លាប់ដើម្បីអន្តរាគមន៍និងស្វែងរកយុត្តិធម៌ជូនអ្នកស្លាប់។

## ឃាត់ខ្លួន(តាងជាង)ស្នាក់នៅខុសច្បាប់ចំនួន19នាក់

http://www.prakpheaktra.com March 10, 2018

កម្លាំងអាជ្ញាធរតម្រួតនៅតំបន់ទេសចរណ៍ក្រុងប៉ាតាយាប្រទេសថៃ បើកយុទ្ធនាការចុះត្រួតពិនិត្យនិងឃាត់ខ្លួនជនជាតិបរទេសនិងពលករខុសច្បាប់ខុសច្បាប់ដែលស្នាក់ផុតទិដ្ឋាការវីសារ និងគ្មានបែអនុញ្ញាតធ្វើការក្នុងប្រទេសថៃ។ កាលពីថ្មីៗកន្លងទៅនេះកម្លាំងសមត្ថកិច្ចតម្រួតក្រុងប៉ាតាយ៉ាស្រុកបាងឡាម៉ុងខេត្តឈុនបុរីបាន ធ្វើការឃាត់ខ្លួនជនជាតិបរទេសនិងពលករខុសច្បាប់ដែលកំពុងធ្វើការដោយគ្មានបែអនុញ្ញាតនិងស្នាក់នៅផុតកំណត់ទិដ្ឋាការវីសារនៅក្នុងតំបន់ទេសចរណ៍ក្រុងប៉ាតាយា។

## ម្តាយយំបោកខ្លួន,បន្ទាប់ពីប្រទះឃើញកូនប្រុសជួលម៉ូតូស្លាប់នៅខេត្តរះយ៉ង

http://www.prakpheaktra.com March 11, 2018

កាលពីវេលាម៉ោង06ល្ងាច នាថ្ងៃសុក្រ ទី09 ខែមីនា ឆ្នាំ2018 មានករណីប្រទះឃើញសាកសពបុរសពលករខ្មែរ 01នាក់ ឈ្មោះភួន អាយុ 24ឆ្នាំ កំពុងដេកស្លាប់នៅលើផ្លូវជាតិ(បាយផាត់-រ៉ាក់យ៉ង)ស្ថិតនៅសង្កាត់ថាក្វៀន ស្រុកក្រែងខេត្តរ៉ាក់យ៉ង ដោយមានសាច់ញាតិអង្គុយ ទ្រហោយំយ៉ាងវេទនា។ ប្រភពពីកន្លែងកើតហេតុបានប្រាប់អោយដឹងថាមុនពេលកើតហេតុអ្នកស្លាប់បានបើកបរម៉ូតូមកជាមួយមិត្តភក្តិចំនួនបួនគ្រឿង ដោយល្បឿនលឿនលុះដល់ចំណុចកើតហេតុជាផ្លូវកោងធ្វើអោយកាច់ចង្កូតមិនទាន់បុកផ្ទាំងថ្មកាន់ផ្លូវបណ្តាលឲ្យបោកក្បាលស្លាប់ភ្លាមៗនៅកន្លែងតែម្តង។

ក្រោយពេលកើតអាផ្ទាធរខេត្តរ៉ាក់យ៉ងបានចុះធ្វើការ កោសលវិច័យត្រួតពិនិត្យសាកសពរួចបញ្ជូនយកទៅរក្សាទុកនៅមន្ទីរពេទ្យក្រុងខេត្តរ៉ាក់យ៉ងដើម្បីអោយពេទ្យពិនិត្យម្តងទៀតរួចប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។

## រដ្ឋាភិបាលថៃបោសសម្អាតក្រុមជនល្មើសឆ្លងទ្វីប

http://nokorwatnews.com/ ថ្ងៃទី 11 ខែមីនា ឆ្នាំ២០១៨

កម្លាំងប៉ូលិស និងទាហានថៃ បាន និងកំពុងតែបោសសម្អាតជាទ្រង់ទ្រាយធំនូវ បទល្មើសអន្តរជាតិ ដែលកំពុងតែសម្ងំ លាក់ខ្លួននៅក្នុងប្រទេសថៃ។ ប៉ូលិសក៏ បានឃុំខ្លួនមនុស្សជាច្រើនផងដែរ នៅក្នុងសកម្មភាពបោសសម្អាតខាងលើនេះ។ លោក Surachet Hakpal ស្នងការរង ប៉ូលិសទេសចរណ៍ថៃ បានឲ្យដឹងថា ប៉ូលិស បានស្វែងរកចាប់ខ្លួនជនល្មើសជាង២០០លើកនៅទូទាំងប្រទេស ដោយឃុំខ្លួន មនុស្សជាង១៨០នាក់ ជាជនបរទេសរស់នៅក្នុងច្បាប់នៅក្នុងប្រទេសដោយខុស ច្បាប់ ភាគច្រើនជាជនជាតិស្បែកខ្មៅមកពីអាហ្វ្រិក។ លោក Surachet Hakpal បន្តទៀតថា «អ្នកទាំងនោះទៅកាន់ប្រទេសថៃ ក្នុងនាម ជាអ្នកទេសចរ ប៉ុន្តែបានប្រព្រឹត្តបទល្មើស ប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់របស់ពលរដ្ឋថៃ»។

តាមការលើកឡើងពីប៉ូលិសថៃបានឲ្យដឹងថា ក្រុមជនល្មើសខាងលើ ស្ថិតនៅក្នុង បណ្តាញ អ្នកប្រើប្រាស់លុយក្លែងក្លាយ ជំរិតទារប្រាក់ និងលក់ពេជ្រក្លែងក្លាយនៅលើទឹកដីថៃ និងប្រទេសផ្សេងទៀត។ ក្នុង ចំណោមអ្នកដែលបានចាប់ខ្លួន មានមួយ ចំនួន ត្រូវប៉ូលិសអន្តរជាតិតាមចាប់ខ្លួនដែរ។ ក្រៅពីនេះមានមនុស្សជាច្រើន ប្រើប្រាស់មុខរបរជាគ្រូបង្រៀនភាសាអង់គ្លេស ដើម្បីបិទបាំងធាតុពិតរបស់ខ្លួន។ ក្រៅពីបទល្មើសអន្តរជាតិ ថៃក៏បាន បោសសម្អាតពលករខុសច្បាប់ផងដែរ ដែលមកពីប្រទេសនៅក្នុងតំបន់អាស៊ាន។ នាយករដ្ឋមន្ត្រីថៃ លោក Prayut Chan Ocha បានប្រកាសថា លោកមិនចង់ឲ្យ ប្រទេសថៃក្លាយជាទីកន្លែង ដើម្បីលាក់ខ្លួនជនល្មើសច្បាប់អន្តរជាតិនោះឡើយ៕ ម៉ែវ សាធី

## ក្រុមជនចំណាកស្រុក ជាង ២៥០នាក់ ត្រូវបានជួយសង្គ្រោះនៅក្នុងដែនទឹកក្បែរឆ្នេរសមុទ្រ លីប៊ី

http://www.postkhmer.com/ AFP | Publication date 11 March 2018 | 15:09 ICT

**ក្រុងទ្រីប៉ូលី:** កាលពីថ្ងៃសៅរ៍ កងទាហានជើងទឹក បានជួយសង្គ្រោះក្រុមចំណាកស្រុក២៥២នាក់ដែលប៉ុនប៉ងធ្វើដំណើរឆ្លងកាត់ទៅកាន់ទ្វីបអឺរ៉ុបអំឡុងប្រតិបត្តិការដាច់ដោយឡែកពីគ្នាពីរនៅ ក្បែរឆ្នេរសមុទ្រភាគខាងលិចនៅក្នុងប្រទេសនេះ។ លោក អនុសេនីយ៍ឯកនៃកងទាហានជើងទឹក Rami al-Hadi Ghomed បានថ្លែងថា៖ «យើងត្រូវបាន គេផ្តល់ដំណឹង... ឲ្យដឹងអំពីទីតាំងស្ថិតនៅរបស់ទូកដឹកក្រុមជនចំណាកស្រុកមួយគ្រឿងដែលស្ថិត«ចម្ងាយប្រហែល៣០គីឡូម៉ែត្រក្បែរឆ្នេរសមុទ្រZawiya នៅខាងលិចទីក្រុងធំទ្រី ប៉ូលី ។ លោកបានថ្លែងថា ក្រុមជនចំណាកស្រុក១៤០នាក់ជិះនៅលើទូកនោះ រួមទាំង ស្ត្រី១៤នាក់និងក្មេង១៤នាក់ត្រូវបានបញ្ជូនទៅកាន់មូលដ្ឋានទាហានជើងទឹកក្នុងទីក្រុងទ្រីប៉ូលីមុនពេលត្រូវបញ្ជូនបន្តទៅកាន់មណ្ឌលឃុំខ្លួនមួយកន្លែង។

ចាប់តាំងពីការដួលរលំក្នុងឆ្នាំ២០១១និងការសម្លាប់មេដឹកនាំផ្តាច់ការលោកMoamer Kadhafi លីប៊ីដែលកំពុងមានភាពចលាចល បានក្លាយជាចំណុចចាប់ផ្តើមដ៏សំខាន់មួយសម្រាប់ក្រុមជនចំណាកស្រុកព្យាយាមធ្វើដំណើរទាំងក្តីអស់សង្ឃឹមដើម្បីឆ្លងកាត់ទៅកាន់ទ្វីបអឺរ៉ុប ជារឿយៗធ្វើដំណើរតាមទូកដែលមិនសូវអំណោយផលសម្រាប់ការធ្វើដំណើរតាមផ្លូវសមុទ្រ។ ដើម្បីសន្សំលុយកាក់សម្រាប់បង់ឲ្យក្រុមឈ្មួញជាថ្លៃធ្វើដំណើរឆ្លងកាត់ទៅមុខទៀតនោះ ក្រុមជនចំណាកស្រុកបានស្នាក់នៅនិងធ្វើការនៅក្នុងទឹកដីលីប៊ី...ដូចជា លោក Sunday Adeleghe ជាឪពុកជនជាតិនីហ្សេរីយ៉ា អាយុ៤២ឆ្នាំដែលមានកូននៅក្នុងបន្ទុកចិញ្ចឹមបីបាច់។ លោកគឺជាមនុស្សម្នាក់ក្នុងចំណោមក្រុមជនដែលបានព្យាយាមផ្សងសំណាងរបស់ពួកគេនៅលើទូកដែលត្រូវបានជួយសង្គ្រោះនៅក្នុងដែនទឹកក្បែរឆ្នេរសមុទ្រZawiya។

អ្នកនាំពាក្យកងទាហានជើងទឹក លោក Ayoub Kacem បានឲ្យដឹងថា កងទាហានជើងទឹក បានជួយសង្គ្រោះ«ក្រុមជនចំណាកស្រុក១១២នាក់រួមទាំងស្ត្រី៣០នាក់ព្រមទាំងកូនក្មេង៣នាក់កំពុងជិះនៅលើទូកដែលដាក់ខ្យល់ពេញ»

។ លោក Kacem បានថ្លែងថា៖«ក្រុមជនចំណាកស្រុកមកពីក្រុមប្រទេសនៅអាហ្វ្រិក...ត្រូវបានផ្ដល់ការយកចិត្តទុកដាក់ថែរក្សាខាងផ្នែកសុខាភិបាលមុនពេលត្រូវបានបញ្ជូនទៅកាន់មណ្ឌលឃុំខ្លួនTajoura»នៅក្នុងទីក្រុងទ្រីប៉ូលី។ កងទាហានជើងទឹកមិនបានផ្ដល់សេចក្ដីលម្អិតស្ដីអំពីប្រភពរបស់ទូកទាំងនោះ ប៉ុន្តែ ក្រុមឈ្មួញរត់ពន្ធ ជាធម្មតា បានចាប់ផ្ដើមធ្វើដំណើរចេញពីលីប៊ីភាគខាងលិច ចម្ងាយតែ៣០០គីឡូម៉ែត្រពីឆ្នេរសមុទ្រប្រទេសអ៊ីតាលី។ AFP/ SN

## ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៨

## ស្ត្រីខ្មែររងគ្រោះនៅម៉ាឡេស៊ី ធ្លាក់ខ្លួនឈឺពេលមកដល់កម្ពុជាវិញ

https://www.rfa.org/khmer/ ដោយ តាំង សារ៉ាដា 2018-03-12

ស្ត្រីខ្មែរម្នាក់ដែលរងគ្រោះនៅប្រទេសម៉ាឡេស៊ី ដោយសារចាញ់បោកក្រុមហ៊ុននាំទៅធ្វើការខុសច្បាប់នោះ បានធ្លាក់ខ្លួនឈឺ ដោយសារថៅកែជនជាតិម៉ាឡេស៊ី បង្ខាំង និងបង្ខំឲ្យធ្វើការហួស កម្លាំងជាច្រើនឆ្នាំ។ ស្ត្រីខ្មែររូបនេះ បានរត់គេចខ្លួន និងត្រូវបានស្ថានទូតខ្មែរ ជួយសង្គ្រោះ និងបានមកដល់ស្រុកខ្មែរវិញហើយកាលពីថ្ងៃទី១១ កុម្ភៈ។ ស្ត្រីរងគ្រោះ និងមន្ត្រីសិទ្ធិមនុស្សស្នើឲ្យអាជ្ញាធរ និងស្ថាប័ពាក់ព័ន្ធ ជួយស្វែងរកក្រុមហ៊ុនដែលមិនបានគោរពកិច្ចសន្យា ចាត់ការតាមច្បាប់ និង ជួយផ្ដល់ចំណេះជំនាញវិជ្ជាជីវៈមុខរបរដល់ស្ត្រីរងគ្រោះ។ ពលការិនីខ្មែររងគ្រោះម្នាក់ ដែលមានដើមកំណើតនៅភូមិតាមាយ ឃុំអណ្ដូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង បានរៀបរាប់ពីទុក្ខលំបាករបស់ខ្លួនក្នុងនាមជាអ្នកបម្រើការនៅតាមផ្ទះជាច្រើនឆ្នាំ នៅក្នុងប្រទេសម៉ាឡេស៊ី ក្រោយពីនាង បានមកដល់ស្រុកខ្មែរវិញ កាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៨ តាមរយៈកិច្ចអន្តរាគមន៍របស់ស្ថានទូតខ្មែរ និងអង្គការសង្គមស៊ីវិល។

កញ្ញា យ៉ន សុគា អាយុ ២៨ឆ្នាំ រៀបរាប់ថា ដោយសារតែជីវភាពគ្រួសារក្រីក្រលំបាកខ្លាំងនោះ នាង បានបង្ខំចិត្តចាកចោលគ្រួសារ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ចំនួនពីរលើក គឺនៅឆ្នាំ២០០៦ម្ដង និងនៅឆ្នាំ២០១៤ ម្ដង។ នាងបញ្ជាក់ថា កាលទៅធ្វើការលើកទី១ គឺក្រុមហ៊ុន មិនបានបោកប្រាស់ នោះទេ ហើយក៏បានធ្វើការរស់នៅជាមួយថៅកែល្អដែរ ប៉ុន្តែលើកទី២ គឺនៅខែមិថុនា ឆ្នាំ២០១៤ នោះ នាងបានទៅធ្វើការនៅប្រទេសម៉ាឡេស៊ីម្ដងទៀត តាមរយៈក្រុមហ៊ុនផ្សេង។ ក្រុមហ៊ុនថ្មីនេះ នាងមិនចាំឈ្មោះនោះទេ គ្រាន់តែដឹងថា មានប្ដីជាជនជាតិចិន និងប្រពន្ធជាជាតិខ្មែរ មានទីតាំងនៅ មុំខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ តែបច្ចុប្បន្ន បានប្ដូរទីតាំង។ មុនទៅប្រទេសម៉ាឡេស៊ី ខាងក្រុមហ៊ុន សន្យាថា នាំនាងទៅធ្វើការតាមហាង និងកាត់ប្រាក់ខែចំនួន ៧ខែមុន តែទីបំផុតនាំនាងទៅធ្វើការនៅក្នុងសណ្ឋាគារ និងវាយបង្ខំអោយធ្វើការតាមផ្ទះ។ «»កញ្ញា យ៉ន សុគា បន្តថា ពេលក្រុមហ៊ុន វាយបង្ខំឲ្យនាងទៅធ្វើការងារក្នុងក្រុមហ៊ុនផ្ដល់សេវាកម្ម បម្រើការតាមផ្ទះរបស់ជនជាតិម៉ាឡេស៊ី ដែលជាថៅកែទី៣ នោះ គឺស្ថានភាពការងារកាន់តែលំបាក ព្រោះជា រៀងរាល់ថ្ងៃ នាងត្រូវថៅកែបង្ខំឲ្យធ្វើការងារតាំងពីម៉ោង៥ព្រឹក រហូត ដល់ម៉ោង ៨យប់ ដោយត្រូវបោស ជូតសម្អាតពីផ្ទះមួយ ទៅផ្ទះមួយ ហើយគ្មានអាហារហូបគ្រប់គ្រាន់ឡើយ។ នាងទ្រាំធ្វើការ នៅទីនោះ ទាំងឈឺទាំងជារយៈពេលជាង៦ខែ ហើយសម្រេចចិត្តរត់ចេញទាំងមិនបានបើក ប្រាក់ខែមួយរៀលឡើយ។ «» កញ្ញា យ៉ន សុគា បានរត់គេចខ្លួន ហើយបានព្យាយាមទាក់ទងមកគ្រួសារ ដើម្បីដាក់ពាក្យបណ្ដឹងនៅអង្គការលីកាដូ និងអង្គការផ្សេង។ បន្ទាប់មកស្ថានទូតខ្មែរប្រចាំប្រទេសម៉ាឡេស៊ី បានទាក់ទងទៅនាង និងបានជួយសង្គ្រោះ ព្រមទាំងបានបញ្ជូននាងមកដក់ស្រុកខ្មែរនៅ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៨ ប៉ុន្តែខាងស្ថានទូត បានទារប្រាក់ពីនាង ចំនួន១រយដុល្លារ។

ស្ត្រីរងគ្រោះរូបនេះ ឲ្យដឹងដែរថា ប្រាក់ខែដែលនាងខំធ្វើការជាង ៣ឆ្នាំនោះ គឺត្រូវបានក្រុមហ៊ុន បើកយកទាំងអស់ ហើយនាងត្រឡប់មកដល់ខ្មែរ គ្មានសល់លុយក្នុងខ្លួនឡើយ មានតែជំងឺប្រចាំកាយស្គមរីងរៃ និងមានអាការៈភ្លេចភ្លាំងស្មារតីប៉ុណ្ណោះ។ «» នាងបានរៀបរាប់ត្រឡប់ថយក្រោយបន្ថិចថា ក្នុងពេលដែលក្រុមហ៊ុននាំនាងទៅប្រទេសម៉ាឡេស៊ី នោះ មិនមែនមានតែនាងម្នាក់ទេ គឺមានស្ត្រីខ្មែរ ៣នាក់ទៀតរស់នៅខេត្តក្រចេះ។ ក្រុមហ៊ុន បាន ដឹកពួកនាងទៅប្រទេសម៉ាឡេស៊ី ឆ្លងតាមច្រកប៉ោយប៉ែត និងតាមប្រទេសថៃដោយប្រើប្រាស់ទិដ្ឋាការ ឬវីសា (VISA) ទេសចរណ៍។

ពេលទៅប្រទេសម៉ាឡេស៊ី ក្រុមហ៊ុនបានដកឯកសារឆ្លងដែនទុកទាំងអស់។ នាងអះអាងថា បច្ចុប្បន្នស្ត្រីដែលទៅជាមួយនាងទាំង ៣នាក់នោះ និងស្ត្រីខ្មែរផ្សេង ជាច្រើនទៀត កំពុងតែរងគ្រោះយ៉ាងខ្លាំងនៅប្រទេសម៉ាឡេស៊ី និងស្នើសុំអោយអាជ្ញាធរជួយសង្គ្រោះពួកគេផង។ «» អង្គការសង្គមស៊ីវិល ក៏ស្នើឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិ រហូតដល់រដ្ឋាភិបាល ត្រូវមានទំនួលខុសត្រូវចំពោះជនរងគ្រោះតាមរយៈការផ្តល់ចំណេះជំនាញវិជ្ជាជីវៈ មុខរបរ ការព្យាបាល ព្រោះថា ប្រសិនបើគ្មានការជួយជ្រោមជ្រែងទេនោះ ពួកគេនឹងកាន់តែធ្លាក់ខ្លួនលំបាក និងងាយរងគ្រោះបន្តទៀត។ ទន្ទឹមគ្នាអាជ្ញាធរមានកាតព្វកិច្ចទាក់ទងជនរងគ្រោះ សួរនាំព័ត៌មានបន្ថែម ដើម្បីតាមស្វែងរកក្រុម ហ៊ុនដែលបោកប្រាស់ និងទាមទារសំណងរួមទាំងប្រាក់ឈ្នួលជូនពលការិនីរងគ្រោះនោះ។

ប្រធានមន្ទីរកិច្ចការនារីខេត្តកោះកុង អ្នកស្រី សុខ សុធារី លើកឡើង ថា ស្ថានភាពស្ត្រីរងគ្រោះគឺបានធូរស្រាលច្រើនហើយ បន្ទាប់ពីព្យាបាលនៅមន្ទីរពេទ្យខេត្ត។ អ្នកស្រីអះអាងថា នឹងចុះទៅជួបគាត់ផ្ទាល់ម្តងទៀត ដើម្បីសួរនាំលម្អិតថា តើស្ត្រីរងគ្រោះចង់ប្តឹងស្វែងរកក្រុមហ៊ុន និងចង់បានការជួយជ្រោមជ្រែងបែបណា ព្រោះកន្លងមក ស្ត្រីរងគ្រោះធ្លាប់បដិសេធមិនចង់ប្តឹងក្រុមហ៊ុនឡើយ ដោយសារ មិនស្គាល់ឈ្មោះនិងទីតាំងក្រុមហ៊ុន។ «» ថ្វីដ្បិតប្រជាពលករខ្មែរតែងតែរងគ្រោះនៅក្រៅប្រទេសជាបន្តបន្ទាប់ក្តី ប៉ុន្តែរដ្ឋាភិបាល នៅតែមានគម្រោងបញ្ជូនពលការិនីទៅធ្វើការជាមេផ្ទះនៅក្រៅប្រទេសឲ្យបាន ១៣ន់នាក់ក្នុងឆ្នាំ២០១៨ ជាពិសេសប្រទេសដែលធ្លាប់មានកេរ្តិ៍ឈ្មោះអាស្រូវរឿងធ្វើបាបពលករ ដូចជា ប្រទេសម៉ាឡេស៊ីជាដើម។ សម្រាប់ខែមីនានេះ រដ្ឋាភិបាល ត្រៀមបញ្ជូនស្ត្រីខ្មែរប្រមាណ ៣០០នាក់ ទៅបម្រើការងារនៅតាមផ្ទះក្នុងប្រទេសម៉ាឡេស៊ីលើកដំបូងម្តងទៀត បន្ទាប់ពីបានផ្អាកកាលពីឆ្នាំ២០១១ ក្រោយពេលមានពលករខ្មែរមួយចំនួន ត្រូវបានថៅកែជនជាតិម៉ាឡេស៊ី វាយ និងរំលោភបំពាន។

អ្នកសម្របសម្រួលផ្នែកឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៃអង្គការលីកាដូ (Licadho) លោក អ៊ិន គង់ជិត ដែលតាមដានករណីនេះ សម្តែងការព្រួយបារម្ភថា ចេះតែបញ្ជូនស្ត្រីខ្មែរទៅធ្វើការតាមផ្ទះ ប៉ុន្តែគ្មានវិធាន ការតាមដានក្រុមហ៊ុនជ្រើសរើសពលករ និងតាមដានសុវត្ថិភាពពលការិនី ព្រមទាំងវិធានការសង្គ្រោះបន្ទាន់ទេនោះ គឺនឹងមាន ពលការិនីខ្មែររងគ្រោះ បន្តបន្ទាប់ទៀត។ «» ពលករខ្មែរដែលចំណាកស្រុកមិនស្របច្បាប់ទៅប្រទេសម៉ាឡេស៊ី ថៃ ចិនជាដើម តែងតែទទួលរងនូវបញ្ហារំលោភបំពាន និងការប្រឈមមានដូចជាការបង្ខំឲ្យធ្វើការហួសកម្លាំង គ្មានពេលសម្រាក ធ្លាក់ខ្លួនឈឺ មិនព្យាបាល ការធ្វើទារុណកម្ម ការវាយដំរបួសធ្ងន់ ការបើកប្រាក់ខែមិនគ្រប់ចំនួន ការគំរាមកំហែង ការចាប់ដាក់គុក ការបង្ខំឲ្យបន្តអាណត្តិការងារដោយខុសច្បាប់ និងការផ្តាច់ទំនាក់ ទំនងរវាងគ្រួសារជាដើម។ អ្នកខ្លះពេលត្រឡប់មកដល់កម្ពុជាវិញ មានជំងឺ និងខ្លះពិការ ហើយកន្លងមក អ្នកទៅធ្វើការតាមផ្ទះនៅម៉ាឡេស៊ី ក៏ត្រូវបានគេធ្វើបាបរហូតបាត់បង់ជីវិតជាច្រើននាក់ផងដែរ។ អង្គការសង្គមស៊ីវិល និងអ្នកវិភាគយល់ថា ប្រទេសខ្មែរតូច និងមានប្រជាជនតិចណាស់ ដូច្នេះរដ្ឋាភិបាល មិនគួរបណ្តោយអោយប្រជាពលរដ្ឋខ្មែរ ត្រូវបន្តរងគ្រោះគ្រប់ទីកន្លែង និងគ្រប់ជំពូក ដោយសារតែ ការស្វែងរកការងារធ្វើចិញ្ចឹមក្រពះនោះទេ។ រដ្ឋាភិបាល គួរតែព្យាយាមលុបបំបាត់អំពើពុករលួយ និងបង្កើនប្រសិទ្ធភាពដឹកនាំរបស់រដ្ឋាភិបាល ព្រមទាំងយកចិត្តទុកដាក់បង្កើតការងារ អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ សុខុមាលភាពប្រជាជន និងធ្វើនយោបាយទាក់ទាញ វិនិយោគិនបរទេស ព្រោះវាមានសារៈសំខាន់សម្រាប់ប្រជាជាតិមួយនេះ៕

## មេឃុំអណ្តូងពោធិ ខេត្តស្វាយរៀង ៖ ស្ត្រីក្នុងឃុំនេះ ធ្វើចំណាកស្រុកទាំងប្រថុយប្រថានច្រើនជាងបុរស

https://wmc.org.kh/ ថ្ងៃចន្ទ ទី១២ ខែមីនា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ ទន្ទឹមនឹងការរកឃើញរបស់អង្គការសង្គមស៊ីវិលដែលប្រឆាំងការជួញដូរស្ត្រី ថា ខេត្តស្វាយរៀងមានពលរដ្ឋចំណាកស្រុកច្រើនជាងបណ្តាខេត្តផ្សេងៗ ហើយចំណាកស្រុករបស់ពួកគេ ភាគច្រើនធ្វើឡើងទាំងប្រថុយ

ប្រថាន។ លោកស្រី មេឃុំអណ្ដូងពោធិ៍ ទទួលស្គាល់ថា ពលរដ្ឋក្នុងឃុំលោកស្រី ពិតជាមានអ្នកចំណាកស្រុកទាំងប្រថុយប្រថានច្រើនមែន ហើយពិសេសគឺស្ត្រី។ តែយ៉ាងលោកស្រី មេឃុំ ប្ដេជ្ញាបន្តសកម្មភាពការងារ ចុះអប់រំផ្សព្វផ្សាយពីការចំណាកស្រុកដោយសុវត្ថិភាពឲ្យកាន់តែខ្លាំង។ ក្នុងអំឡុងឆ្នាំ២០១៧ អង្គការសម្ព័ន្ធចាប់ដៃ ដែលជាអង្គការសង្គមស៊ីវិលធ្វើការងារប្រឆាំងការជួញដូរស្ត្រី និងកុមារ ទៅក្រៅប្រទេស បានជួយសង្គ្រោះស្ត្រីពីការជួញដូរឲ្យបានវិលមកកម្ពុជាវិញចំនួន ១១០ នាក់។ ស្ត្រីទាំងអស់នោះ ត្រូវបានមេខ្យល់បោកបញ្ឆោត តាមរូបភាពរកការងារឲ្យធ្វើនៅក្រៅប្រទេស និងទទួលបានប្រាក់ខែច្រើន។ អង្គការសម្ព័ន្ធចាប់ដៃ រកឃើញថា ក្នុងចំណោមខេត្តទូទាំងប្រទេស គឺខេត្តស្វាយរៀងមានប្រជាពលរដ្ឋធ្វើចំណាកស្រុកច្រើនជាងគេ។

ជុំវិញករណីនេះ លោកស្រី គឹម ស៊ុនណារី មេឃុំអណ្ដូងពោធិ ស្រុក រមាសហែក ខេត្តស្វាយរៀង ទទួលស្គាល់ថា ពលរដ្ឋក្នុងឃុំរបស់លោកស្រី បានធ្វើចំណាកស្រុកច្រើន ទៅកានប្រទេសកូរ៉េ ជប៉ុន ម៉ាឡេស៊ី និងប្រទេសថៃ។ តែយ៉ាងណាលោកស្រីបន្តថា បច្ចុប្បន្ននេះ មានពលរដ្ឋតិចតួចបំផុត ដែលបានធ្វើចំណាកស្រុកដោយស្របច្បាប់។ លោកស្រី មេឃុំអណ្ដូងពោធិ បន្តទៀតថា ពលរដ្ឋមួយចំនួនធំបានធ្វើចំណាកស្រុកទាំងប្រថុយប្រថាន ទៅប្រទេសថៃ ព្រោះជឿតាមពាក្យមេខ្យល់ ដែលប្រាប់ពួកគេថា ការធ្វើចំណាកស្រុកតាមរយៈក្រុមហ៊ុន គឺបានប្រាក់ខែតិច ជាងការធ្វើចំណាកស្រុកដោយលួចលាក់។ លោកស្រី គឹម ស៊ុនណារី ៖«ដូចថា មានមេខ្យល់ តែខ្ញុំមិនបានស្គាល់ទេមេខ្យល់ហ្នឹង ដូចថាគេដើរបញ្ចុះបញ្ចូលថា បើទៅតាមក្រុមហ៊ុន បានលុយតិច ហើយបើទៅតាមគេបានប្រាក់ខែច្រើន។ អញ្ចឹងមនុស្សយើងមានការលោភលន់អញ្ចឹងទៅ ទៅតាមអញ្ចឹងទៅ អ្នកខ្លះក៏បានលាភសក្ការៈមកផ្ទះទៅ ហើយអ្នកខ្លះក៏អត់មាន ហើយអ្នកខ្លះគ្រោះថ្នាក់អញ្ចឹងទៅ»។ ព្រោះតែការខ្វះព័ត៌មានស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ពលរដ្ឋខ្មែរ ដែលពុំសូវមានចំណេះដឹង តែងតែងាយជឿលើពាក្យដែលមេខ្យល់បញ្ចុះបញ្ចូល។ លោកស្រី ស៊ុនណារី បន្តថា រហូតមកដល់ពេលនេះ លោកស្រីនៅតែរកមេខ្យល់ដែលបាននាំពលរដ្ឋក្នុងឃុំរបស់លោកស្រី ទៅកាន់ប្រទេសថៃ មិនឃើញនៅឡើយទេ ពីព្រោះបុគ្គលរូបនោះមិនមែនជាពលរដ្ឋរស់នៅក្នុងភូមិឃុំរបស់លោកស្រី។

តែយ៉ាងណាអាជ្ញាធរ ក្នុងឃុំរបស់លោកស្រី តែងតែព្យាយាមចុះទៅជួបពលរដ្ឋដល់ផ្ទះ ដើម្បីប្រាប់ និងពន្យល់ពីគ្រោះថ្នាក់ ដែលនឹងកើតមាន ខណៈពួកគេធ្វើចំណាកស្រុកដោយលួចលាក់។ ជាមួយគ្នានេះ ពលរដ្ឋនៅពេលដែលអាជ្ញាធរចុះទៅអប់រំ តែងតែឆ្លើយថា ពួកគេបានយល់ តែសកម្មភាពជាក់ស្ដែងពួកគេនៅតែបន្តការលួចឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃដោយខុសច្បាប់ដដែល។ ត្រង់ចំណុចនេះ បានក្លាយជាក្ដីបារម្ភយ៉ាងខ្លាំងមួយ សម្រាប់លោកស្រី ដែលជាអាជ្ញាធរដឹកនាំក្នុងឃុំនេះ។ លោកស្រី គឹម ស៊ុនណារី ៖«បារម្ភណាស់ បារម្ភមែនទែន បារម្ភពីសុវត្ថិភាពរបស់ប្រជាពលរដ្ឋយើង។ យើងមិនឃាត់ទេ ប៉ុន្តែយើងត្រូវចំណាកស្រុក ដោយមានសុវត្ថិភាព យើងត្រូវដឹងថា គោលដៅយើងទៅកន្លែងណា អញ្ចឹងក្រុមហ៊ុនណាមានអាជ្ញាបណ្ណស្របច្បាប់ សុំច្បាប់អីត្រឹមត្រូវអញ្ចឹងទៅ»។ សម្រាប់ពលរដ្ឋដែលរស់នៅក្នុងអណ្ដូងពោធិ ស្រុក រមាសហែក ខេត្តស្វាយរៀង យ៉ាងតិចណាស់ជាង ១០០០នាក់ បានធ្វើចំណាកស្រុក ហើយស្ត្រីមានចំនួន រហូតដល់៧០ភាគរយ។ ជាធម្មតាស្ត្រី តែងតែងាយរងគ្រោះជាងបុរស មិនថា ការទទួលអំពើហិង្សា ការជួញដូរ ឬក៏ការចាប់រំលោភ។ ករណីស្ត្រី ដែលធ្វើចំណាកស្រុកទាំងប្រថុយប្រថាន ទៅក្រៅប្រទេស ភាគច្រើនគឺជាការជំរុញរបស់ឪពុក ម្ដាយ ដែលមើលឃើញគ្រួសារញាតិជិតខាងរបស់ខ្លួនមានជីវភាពធូរធាព្រោះការចំណាកស្រុក។ ឪពុកម្ដាយ មួយចំនួនបានឲ្យកូនស្រីរបស់ខ្លួនទៅក្រៅប្រទេស ដោយមិនបានដឹងពីគ្រោះថ្នាក់ ដែលអាចកើតឡើងចំពោះកូនស្រីរបស់ខ្លួន ខណៈនាងទៅធ្វើការស្រុកឆ្ងាយតែម្នាក់ឯង។ ស្ត្រីដែលធ្វើចំណាកស្រុក តាមរយៈមេខ្យល់ដោយខុសច្បាប់ តែងតែប្រឈមការជួញដូរខ្ពស់ជាងស្ត្រីដែលធ្វើចំណាកស្រុកតាមរយៈក្រុមហ៊ុន ដែលមានទទួលស្គាល់ដោយក្រសួងការងារកម្ពុជា។ ក្នុងអំឡុងឆ្នាំ២០១៧ ករណីជួញដូរស្ត្រីទៅក្រៅប្រទេស ត្រូវបានអង្គការសម្ព័ន្ធចាប់ដៃសហការជាមួយអាជ្ញាធរកម្ពុជាប្រចាំនៅក្រៅប្រទេស ដូចជាប្រទេសចិន ថៃ និងប្រទេសម៉ាឡេស៊ី ជួយសង្គ្រោះស្ត្រីរង

គ្រោះពីការជួញដូរ បានហួតដល់ ១១០នាក់។ នេះបើយោងតាមបទសម្ភាសដែលលោក ស្រ៊ន់ ឡុង់ដា ប្រធានគម្រោងក្នុងគម្រោងគាំទ្រករណី នៃការជួញដូរ របស់អង្គការសម្ព័ន្ធចាប់ដៃ។

ប្រធានគម្រោង របស់អង្គការសម្ព័ន្ធចាប់ដៃ បញ្ជាក់ថា កាលបើមានកាលណាបើការចំណាកស្រុកដោយខុសច្បាប់ គឺករណីជួញដូរ នឹងអាចកើតឡើង។ ត្រង់ចំណុចនេះ លោក ស្រ៊ន់ ឡុង់ដា សំណូមពរដល់ប្រជាពលរដ្ឋគ្រប់រូបត្រូវបញ្ឈប់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមរយៈមេខ្យល់ ហើយនៅក្នុងករណីដែលសម្រេចថា នឹងធ្វើចំណាកស្រុក ត្រូវទៅកក្រុមហ៊ុនដែលមានការទទួលស្គាល់ពីក្រសួងការងារកម្ពុជា ប្រសិនជា មិនចង់ត្រូវបានគេជួញដូរធ្វើទាសករផ្លូវភេទ។ លោក ស្រ៊ន់ ឡុង់ដា ៖«ប្រសិនបើគាត់សម្រេចចិត្តថា ចំណាកស្រុកទៅក្រៅប្រទេសសូមសួរឲ្យច្បាស់ថា តើក្រុមហ៊ុនដែលនាំគាត់ទៅហ្នឹង ជាក្រុមហ៊ុនស្របច្បាប់ឬក្រុមហ៊ុនអត់ស្របច្បាប់។ សូមមេត្តាសុំលិខិតមើលឲ្យបានត្រឹមត្រូវពីក្រុមហ៊ុនហ្នឹង តើគាត់មានលិខិតចេញពីក្រសួងការងារឬក៏អត់»។ អង្គការសម្ព័ន្ធចាប់ដៃ បានជួយស្ត្រីខ្មែរ ពីការជួញដូរទៅក្រៅប្រទេសតាំងតែពីឆ្នាំ២០០៥។ ស្ត្រីដែលត្រូវបានជួយសង្គ្រោះភាគច្រើន មកពីប្រទេចិន ថៃ និងប្រទេសម៉ាឡេស៊ី ពួកគេស្ទើរតែក្លាយជាមនុស្សមានវិបត្តិផ្លូវចិត្ត ព្រោះតែការធ្វើទារុណកម្ម ការចាប់រំលោភ និងការវាយដំផ្សេងៗ។ លោក ស្រ៊ន់ ឡុង់ដា ៖«ប្រសិនបើរងគ្រោះ បើសិនជានិយាយពីវិបត្តិ ការប៉ះទង្គិចផ្លូវចិត្តគឺធ្ងន់ធ្ងរមែនទែនសឹងតែមិនអាចនិយាយទៅរួច អ្នកខ្លះអាចប៉ះពាល់ទៅដល់ផ្លូវអារម្មណ៍ អាចវង្វេងក៏មានដែរ។ នៅពេលដែលគាត់ត្រឡប់មកវិញពេលខ្លះគាត់បាត់បង់សតិក៏មាន»។

ជុំវិញបញ្ហាទាំងអស់នេះ លោកស្រី គឹម ស៊ុនណារី មេឃុំអណ្តូងពោធិ ស្រុក រមាសហែក ខេត្តស្វាយរៀង ប្តេជ្ញាថា ក្នុងឆ្នាំ២០១៨ លោកស្រី នឹងបន្តការចុះអប់រំផ្សព្វផ្សាយ ពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ឲ្យបានកាន់តែខ្លាំង។ តែយ៉ាងណាសម្រាប់ស្ត្រី ម្ចាស់តំណែងមេឃុំ អណ្តូងធិ ៤អាណត្តិនេះ សំណូមពរដល់ពលរដ្ឋ ដែលសម្រេចិត្តធ្វើចំណាកស្រុកទាំងអស់ ត្រូវតែគិត និងពិចារណាឲ្យបានច្បាស់លាស់ គឺមិនត្រូវចេះតែទៅ ដោយគ្រាន់តែឮតាមគ្នានោះទេ។ ជាមួយគ្នានេះ លោកស្រី ក៏សំណូមពរដល់អាជ្ញាធរឃុំ សង្កាត់ ទាំងអស់ត្រូវចុះផ្សព្វផ្សាយប្រាប់ និងពន្យល់ពលរដ្ឋឲ្យបានដឹង ពីហានិភ័យពីការធ្វើចំណាកស្រុកដោយខុសច្បាប់ ឲ្យបានញឹកញាប់ មិនមែនចុះតែម្តងហើយឈប់នោះទេ។ លោកស្រី គឹម ស៊ុនណារី ៖«*ខ្ញុំស្នើសុំដល់មេឃុំ ចៅសង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា សុំឲ្យផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋ ឲ្យគាត់យល់ដឹង។ ផ្សព្វផ្សាយមិនមែនផ្សព្វផ្សាយតែម្តងទេ យើងធ្វើដូចភ្លៀងរលើមអញ្ចឹងយ៉ាងហោចយូរៗទៅគាត់គង់តែស្តាប់យើងថា តើគាត់និយាយនេះ ក្នុងនាមជាអាជ្ញាធរគាត់មានបំណងយ៉ាងម៉េច*»។

សូមជម្រាបថា ក្នុងរយៈពេលចុងក្រោយនេះ បន្ទាប់ពីមានការរកឃើញថា ពលរដ្ឋខ្មែរជាច្រើនត្រូវបានជនខិលខូចបោកបញ្ឆោតជួញដូរទៅក្រៅប្រទេស មន្ត្រីរដ្ឋាភិបាលកម្ពុជា ដែលប្រចាំនៅក្រៅប្រទេស បានជួយពលរដ្ឋខ្មែរបានមួយចំនួនឲ្យបានវិលត្រឡប់មកកម្ពុជាវិញ ។ ពួកគេត្រូវបានជួយសង្គ្រោះមកពី ប្រទេសចិន ប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសសឹង្ហបុរី ជាដើម។ ក្នុងចំណោមពលរដ្ឋខ្មែរដែលត្រូវបានជួយសង្គ្រោះ គឺភាគច្រើនសុទ្ធសឹងតែជាស្ត្រី៕

**រដ្ឋមន្ត្រីក្រសួងការងារថៃ, ចុះត្រួតពិនិត្យសូន្យបញ្ជាក់អត្តសញ្ញាណស្តែនកែវភ្នែកពលករនេសាទ**

http://www.prakpheaktra.com March 12, 2018

លោករដ្ឋមន្ត្រីក្រសួងការងារថៃចុះត្រួតពិនិត្យសូន្យបញ្ជាក់អត្តសញ្ញាណនិងស្តែនកែវភ្នែកពលករធ្វើការការនេសាទនិងផ្នែកការងារសមុទ្រក្នុងខេត្តសាមុតសាខន។ កាលពីថ្ងៃអាទិត្យទី11 ខែមីនា ឆ្នាំ2018 លោកអាដុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃបានចុះទៅត្រួតពិនិត្យទីតាំងសូន្យបញ្ជាក់អត្តសញ្ញាណស្តែនកែវភ្នែករបស់ពលករខ្មែរ,ឡាវ, ភូមា,ធ្វើការនេសាទនិងផ្នែកការងារសមុទ្រនៅក្នុងខេត្តសាមុតសាខនប្រទេសថៃ ដើម្បីពន្លឿនការបញ្ជាក់អត្តសញ្ញាណរបស់ពលករធ្វើការនេសាទអោយបានចប់រួចរាល់មុនថ្ងៃទី31ខែមេសាឆ្នាំ2018ខាងមុខនេះ។

## អាជ្ញាធរថៃ, ស្កាត់ចាប់រថយន្តដឹក(គាងជាង)ខុសច្បាប់ចូលមកស្វែងរកការងារធ្វើនៅក្នុងប្រទេស

http://www.prakpheaktra.com March 13, 2018

រថយន្តមេខ្យល់ដឹកពលករចំណាកស្រុកខុសច្បាប់ ចំនួនពីរគ្រឿងបើកបុកកុងត្រូលត្រួតពិនិត្យរបស់សមត្ថកិច្ចព្រំដែនតំបន់ភូមិភាគខាងត្បូងនៃប្រទេសថៃឃាត់បានមួយគ្រឿងចំណែករថយន្តមួយគ្រឿងទៀតបើករត់គេចខ្លួនផុត។ កាលពីវេលាម៉ោង09ព្រឹកថ្ងៃច័ន្ទ12 ខែមីនា ឆ្នាំ2018 កម្លាំងអាជ្ញាធរការពារព្រំដែនតំបន់ភូមិភាគខាងត្បូងនៃប្រទេសថៃបានធ្វើការស្ទាក់ប្រដេញចាប់រថយន្តមេខ្យល់ដឹកពលករចំណាកស្រុកខុសច្បាប់ចំនួនពីរគ្រឿង បន្ទាប់ពីរថយន្តរថយន្តទាំងពីរគ្រឿងនេះបានបើកបំបុកកុងត្រូលត្រួតពិនិត្យរបស់សមត្ថកិច្ចថៃ នៅត្រង់ចំណុច(ខួនមិតខួនមីន)ស្ថិតនៅក្នុងភូមិបានខួនមិត សង្កាត់ប៉ាធឹង ស្រុកចាក់ណាក់ ខេត្តសង់ក្លា ប្រទេសថៃ ។

យោងតាមរបាយការណ៍របស់សមត្ថកិច្ចថៃបានឲ្យដឹងថារថយន្តម៉ាក(មីស៊ុយមីស៊ី)ពីរបាងមួយគ្រឿងពាក់ស្លាកលេខ22707ខេត្តប៉ាតតានី ត្រូវបានកម្លាំងអាជ្ញាធរថៃប្រដេញធ្វើការស្ទាក់ចាប់បានខណៈពេលកំពុងបើករត់ជារថយន្តមួយគ្រឿងទៀត បន្ទាប់ពីបុកកុងត្រូលត្រួតពិនិត្យរបស់សមត្ថកិច្ចថៃ ក្នុងស្ទាក់ចាប់រថយន្តខាងលើកម្លាំងសមត្ថកិច្ចថៃ បានរកឃើញពលករចំណាកខុសច្បាប់សញ្ជាតិភូមាចំនួន 07នាក់ ព្រមទាំងឃាត់ខ្លួនបានមេខ្យល់ជាបើកបររថយន្តខាងលើ 01នាក់ផងដែរ ចំណែករថយន្តម៉ាកtoyota vigosពណ៌អត់ពាក់ស្លាកលេខមួយគ្រឿងទៀតបានបើករត់គេចខ្លួនផុត។

តាមការសាកសួរសមត្ថកិច្ចពលករភូមាម្នាក់បានប្រាប់សមត្ថកិច្ចអោយដឹងថាពួកគេបានលួចឆ្លងដែនខុសច្បាប់ចូលមកប្រទេសថៃដោយមានមេខ្យល់នាំចូលមកដោយគិតថ្លៃធ្វើដំណើរក្នុងមនុស្សម្នាក់1500฿ ក្រោយពេលឃាត់ខ្លួនពលករចំណាកខុសច្បាប់និងមេខ្យល់ត្រូវសមត្ថកិច្ចបញ្ជូនយកទៅការសាកសួរបន្ថែមនៅអធិការដ្ឋានត្រួតខេត្តសង់ក្លាដើម្បីចាត់វិធានការតាមផ្លូវ។

## ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៨

## ពលករខ្មែរចាប់ផ្តើមវិលមកធ្វើការក្នុងស្រុកដោយសារលក្ខខណ្ឌការងារល្អ និងប្រាក់ឈ្នួលកើនឡើង

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 14 March, 2018

ភ្នំពេញ ៖ ដោយសារកម្លាំងពលកម្មមួយចំនួនធំ បានចេញទៅធ្វើការងារនៅក្រៅប្រទេស ធ្វើឱ្យខ្វះ កម្លាំងពលកម្មនៅក្នុងស្រុកយ៉ាងច្រើន ដែលជាហេតុធ្វើឱ្យប្រមុខរាជរដ្ឋាភិបាលមានការព្រួយបារម្ភណ៍ នឹងប្រឹងប្រែងរកយន្តការដើម្បីឱ្យពលករបានត្រឡប់មកធ្វើការងារនៅក្នុងស្រុកវិញ។

ទាក់ទិននិងបញ្ហាកង្វះកម្លាំងពលកម្មនេះ លោក បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានអះអាងថា ថ្មីៗនេះ មានពលករមួយចំនួនបានវិលត្រលប់មកធ្វើការងារនៅក្នុងស្រុកវិញហើយ ដោយសារពួកគេមើលឃើញថា បច្ចុប្បន្ននេះ ប្រាក់ឈ្នួលនៅក្នុងស្រុកល្អ លក្ខខ័ន្តការងារក៏ល្អ ប្រព័ន្ធសន្តិសុខសង្គមក៏កាន់តែល្អធ្វើឱ្យការជ្រើសរើស និងបញ្ជូនពលករទៅក្រៅប្រទេសមានបញ្ហាពិបាកក្នុងការជ្រើសរើសផងដែរ។ លោក បណ្ឌិត រដ្ឋមន្ត្រីបន្ថែមថា ចំពោះការសម្រេចចិត្ត របស់បងប្អូនប្រជាពលរដ្ឋយើងមិនមានការហាមឃាត់ទេ គឺទុកលទ្ធភាពឱ្យគាត់ ពិនិត្យ ពិចារណា និងសម្រេចដោយខ្លួនឯង ដោយស្ម័គ្រចិត្ត ។ រាជរដ្ឋាភិបាលមិនបង្ខំ ឬ ជម្រុញនោះទេ បើគាត់សម្រេចចិត្តបែបណានោះយើងនិងគោរពតាមការសម្រេចចិត្តនោះ បើគាត់សម្រេចយកការចេញទៅក្រៅប្រទេស រដ្ឋាភិបាលនឹងរៀបចំបែបបទនិតិវិធីបញ្ជូនគាត់ទៅ ហើយតាមការពារ ដូចដែលបានផ្តល់សេវាជូននាពេលបច្ចុប្បន្ននេះស្រាប់។ យ៉ាងណា លោក បណ្ឌិត អ៊ិត សំហេង បញ្ជាក់ថា បើទោះជានៅក្នុងស្រុកមានការខ្វះកម្លាំងពលកម្មយ៉ាងណាក៏ដោយ ប៉ុន្តែកូតាពីប្រទេសកូរ៉េ ហុងកុង ជប៉ុន ម៉ាឡេស៊ី និងប្រទេសថៃក៏នៅតែមានជាធម្មតា។

ជាមួយគ្នានោះដែរ ទាក់ទិននិងការនាំចេញ ផ្លែកវាយនគណ្ឌកាត់ដេរវិញ លោកបណ្ឌិត រដ្ឋមន្រ្តី ក៏បានអះអាងថា ការបញ្ជាទិញពីទីផ្សារធំៗ ឬ ពីក្រុមហ៊ុនធំៗ គឺពេញទាំងអស់ ព្រោះឯកឧត្តម បានជួបជាមួយរោងចក្រ ដែលផលិតសម្រាប់ផ្គត់ផ្គង់ការនាំចេញ បានឱ្យដឹងថា មកដល់ពេលនេះការបញ្ជារទិញពេញ ហើយបានពង្រីកសង្វាក់ផលិតកម្មរបស់ខ្លួនបន្ថែមទៀត ដើម្បីឆ្លើយតបនឹងតម្រូវការ។ ដូច្នេះ សម្រាប់ឆ្នាំ២០១៨ រំពឹងថា ការនាំចេញនូវផ្លែកវាយនគណ្ឌកាត់ដេរ នឹងមានកំណើនថែមទៀត៕

## វិចារណកថា: ច្រករបៀងច្រើន កន្លែង ក្នុងខេត្តបន្ទាយមានជ័យ នៅតែដំណើរ ការយ៉ាងរលូន

https://www.dap-news.com/kh/ ថ្ងៃពុធ, ១៤ មិនា ២០១៨ 10:50 ដោយ: វាសនាជាវរជ័យ ID:012

សេចក្តីរាយការណ៍ ពីប្រជាពលរដ្ឋ រស់នៅតាមតំបន់ព្រំដែន ក្នុងក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ ស្រុកថ្មពួក និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា នៅក្នុងមូលដ្ឋានពួកគាត់ នៅតែមានច្រករបៀង ដំណើរការយ៉ាងរលូនដដែល ព្រោះសមត្ថកិច្ចការពារព្រំដែន នៅតែបន្ត បើកច្រករបៀងដូចមុនដដែល ដើម្បីជាថ្នូរនឹងផលប្រយោជន៍ ។ ប្រភពបានឲ្យដឹងទៀតថានៅ តាមច្រករបៀងទាំងនោះសមត្ថកិច្ចបាន ឃុបឃិតឲ្យឈ្មួញ នាំចូលទំនិញគេចពន្ធ ទំនិញខុស ច្បាប់ ពីប្រទេសថៃតាមអំពើចិត្ត ហើយក៏មានឈ្មួញនាំចេញ ទំនិញពីប្រទេសកម្ពុជា ចូលទៅ ប្រទេសថៃ តាមច្រករបៀងទាំងនោះដែរ ។ ប្រការនេះហើយដែលធ្វើ មានការរិះគន់ថា មន្រ្តី អាជ្ញាធរ និងសមត្ថកិច្ច ខេត្តបន្ទាយមានជ័យ មិនអនុវត្តន៍តាមបទបញ្ជា របស់ថ្នាក់ដឹកនាំ ក្រសួងមហាផ្ទៃដែល តម្រូវឲ្យ បិទច្រករបៀងតាមព្រំដែន កម្ពុជា-ថៃ ទាំងស្រុងនោះទេ ព្រោះ ច្រករបៀងជាច្រើនកន្លែងកំពុងដំណើរការយ៉ាងរលូន។

ប្រភពពីមន្រ្តីអាជ្ញាធរ និងសមត្ថកិច្ចមូលដ្ឋានក្នុងសង្កាត់ ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា ច្រករបៀងដើមគ ក្នុងភូមិក្បាលកោះ ដែលស្ថិតនៅក្រោមការ គ្រប់គ្រងរបស់អង្គភាពនគរបាលរការពារព្រំដែនលេខ៨៩១ កំពុងដំណើរការយ៉ាងរលូន។ ប្រភពបានឲ្យដឹងទៀតថា នៅច្រក របៀងដើមគ សព្វថ្ងៃនេះមានឈ្មួញនាំចូលទំនិញគេចពន្ធ និងទំនិញខុសច្បាប់យ៉ាងពេញបន្ទុក ជាពិសេសនៅពេលយប់ ហើយអ្វីៗអាចប្រព្រឹត្តទៅបានយ៉ាងរលូនគឺមានការឃុបឃិតជាប្រព័ន្ធ។ នៅច្រកនេះដែរមានឈ្មួញខ្មែរដឹកជញ្ជូនទំនិញទៅលក់នៅស្រុកថៃតាមអំពើចិត្ត ហើយមានករណីពលករខ្មែរឆ្លងដែន ខុនច្បាប់ចូលទឹកដីថៃ រកការងារធ្វើ ដោយសារមានសមត្ថកិច្ច ប្រចាំច្រករបៀងឃុបឃិតជាមួយមេខ្យល់ ដើម្បី ប្រមូលលុយ តាមរបៀងពុករលួយយ៉ាងសុខស្រួល។ ការដែលឈ្មួញនាំចូល ទំនិញគេចពន្ធ និងទំនិញខុសច្បាប់តាមច្រករបៀងដើមគ ភូមិ ក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមាន ជ័យ កំពុងធ្វើឲ្យរដ្ឋត្រូវខាតបង់ចំណូលពន្ធយ៉ាងច្រើនក្នុងមួយខែ ៗហើយ ផលប្រយោជន៍បានទៅលើក្រុមមន្រ្តី និងសមត្ថកិច្ចពុករលួយ ដែលគិតតែផលប្រយោជន៍ ផ្ទាល់ខ្លួន។

ប្រភពពីមន្រ្តីអាជ្ញាធរ និងសមត្ថកិច្ចមូលដ្ឋាន ក៏ដូចជាប្រជាពលរដ្ឋរស់នៅ តាមតំបន់ព្រំដែន ក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ បានឲ្យដឹងថាច្រក របៀងអូរបីជាន់ នៅតែដំណើរការដូចមុន ដដែល ហើយឈ្មួញនៅតែអាចនាំចូលទំនិញគេចពន្ធនិងទំនិញខុសច្បាប់យ៉ាងពេញបន្ទុក។ ប្រភពបានឲ្យដឹងទៀតថាសមត្ថកិច្ច យោធានិងសមត្ថកិច្ច នគរបាលឈរជើង តាមព្រំដែន នៅច្រករបៀងអូរពីជាន់ នៅតែបន្តឃុបឃិតឲ្យឈ្មួញ នាំចូលមាន់រស់ ជ្រូករស់និងគោក្របី ពីទឹកដីថៃយ៉ាងគគ្រឹកគគ្រេងហើយក៏មាន ការឃុបឃិតពីមន្រ្តីពេទ្យសត្វ និងសមត្ថកិច្ច ពាក់ព័ន្ធដទៃទៀត ផងដែរ។ ក្នុងនោះមានឈ្មួញជាមន្រ្តីនគរបាលនិងមន្រ្តីយោធា មួយ ចំនួនបានធ្វើសកម្មភាពលួចនាំចូលម៉ូតូគេចពន្ធទំនើបៗក៏ ដូចជានាំចូលរថយន្តគេចពន្ធ និងរថយន្តចង្កូតស្តាំពីទឹកដីថៃ ដោយគ្មានញញើតអ្វីទាំងអស់។ មន្ត្រីអាជ្ញាធរនិង សមត្ថកិច្ច ក្នុងខេត្តបន្ទាយមានជ័យ បានមើលរំលងបញ្ហាទាំងនេះក្នុងខណៈដែល បទល្មើសឆ្លងដែនកើត ឡើងកាន់តែច្រើនជាងមុនទៅទៀត។

ប្រភពពីប្រជាពលរដ្ឋរស់នៅភូមិប្រាសាទត្បែង ឃុំបន្ទាយ ឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមាន ជ័យ បានឲ្យដឹងថានៅច្រក របៀងប្រាសាទត្បែង មួយរយៈកន្លងទៅនេះមានឈ្មួញដឹកធ្យូង ចូលទឹកដីថៃរាប់ម៉ឺនការុង ហើយធ្យូងទាំងនោះ

មានប្រភពចេញពីខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ។ ប្រភពបានឲ្យដឹងទៀតថាមន្ត្រីយោធានិងមន្ត្រីនគរបាល ប្រចាំ ច្រករបៀងប្រាសាទ តែ្បង គាបយកលុយពីឈ្មួញដឹកធ្យូងក្នុងមួយការុង១៥០០រៀល ហើយ បើកដៃឲ្យឈ្មួញដឹកជញ្ជូនធ្យូងចូលទឹកដីថៃតាមអំពើចិត្តតែម្តង។ ប្រការនេះកំពុងធ្វើឲ្យព្រៃ ដែលសេសសល់ក្នុងខេត្ត ឧត្តរមានជ័យនិងខេត្តបន្ទាយមានជ័យ ត្រូវប្រឈមនឹងសេចក្តី វិនាស ព្រោះសកម្មភាពកាប់ឈើដុតធ្វើធ្យូងលក់កំពុងកើត ឡើងយ៉ាងរាលដាល ព្រោះមាន ឈ្មួញចាំទិញធ្យូងដឹកជញ្ជូនទៅ ប្រទេសថៃ។ រហូតមកដល់ពេលនេះ សកម្មភាពឈ្មួញ ដឹកជញ្ជូ ន ធ្យូងទៅលក់នៅប្រទេសថៃ តាមច្រករបៀងប្រាសាទតែ្បងនៅ តែកើតឡើងយ៉ាង ពេញបន្ទុកព្រោះមានការឃុបឃិតបើកដៃពីសំណាក់សមត្ថកិច្ច នគរបាលនិងយោធាប្រចាំ ច្រកនេះដែលគិត គូតែរឿងតែរឿងផលប្រយោជន៍ផ្ទាល់ខ្លួន។

ប្រភពពីប្រជាពលរដ្ឋរស់នៅតាមតំបន់ព្រំដែនក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ក៏បានឲ្យដែរថា បច្ចុប្បន្នឈ្មួញមួយចំនួននៅតែនាំចូលទំនិញគេចពន្ធ ទំនិញខុសច្បាប់ ម៉ូតូគេចពន្ធនិងរថយន្តចង្កូតស្តាំតាមច្រករបៀងចំការគ ឃុំស្លក្រាម ស្រុកស្វាយ ចេក យ៉ាងរលូនព្រោះមានការឃុប ឃិតពីសមត្ថកិច្ច ប្រចាំច្រកនេះ។ ប្រភពបានឲ្យដឹងទៀតថាឈ្មួញដែលរក់ស៊ីនាំ ចូលម៉ូតូគេចពន្ធនិងរថយន្តចង្កូតស្តាំ តាមច្រករបៀង ចំការគ ស្រុកស្វាយចេក គឺជាសាច់ញាតិរបស់មន្ត្រីជាន់ខ្ពស់នៅក្នុង ខេត្តបន្ទាយមានជ័យផងដែរ។ ហេតុនេះហើយទើបសមត្ថកិច្ចពាក់ព័ន្ធមិនហ៊ាបបង្ក្រាបឈ្មួញ ទាំងនោះ ព្រោះខ្លាចឥទ្ធិពលមន្ត្រី ជាន់ខ្ពស់ដែលជាខ្នងបង្អែករបស់ក្រុមឈ្មួញ ហើយ សមត្ថកិច្ចខ្លះ ជាអ្នកឃុបឃិតទទួលផលប្រយោជន៍ពីឈ្មួញ។ សរុបសេចក្តី មកច្រក របៀងជាច្រើនកន្លែងតាមព្រំដែនក្នុងខេត្តបន្ទាយមានជ័យ នៅតែដំណើរការយ៉ាង រលូនបើទោះបីថ្នាក់ដឹកនាំក្រសួង មហាផ្ទៃចេញបទបញ្ជាឲ្យបិទច្រក របៀងទាំង នោះយ៉ាងណាក៏ ដោយព្រោះសមត្ថកិច្ចប្រចាំច្រករបៀងទាំងនោះ មិនខ្វល់ពីរឿង អនុវត្តន៍តាមបទបញ្ជា របស់ថ្នាក់លើឡើយ៕

## ក្រសួងមហាផ្ទៃបើកកិច្ចប្រជុំបញ្ហាជនទេសន្តប្រវេសន៍ ដើម្បីស្វែងរកភាពស្របច្បាប់ជូនពលករ

http://cambodiapolice.com/ 10:03 am 14 មីនា 2018 20

**ភ្នំពេញ ៖** ខណៈកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំក្រុមប្រទេសបញ្ចូនទាំង៣ កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ក្រសួងមហាផ្ទៃបានបើកកិច្ចប្រជុំក្នុងការគ្រប់គ្រង និងការស្វែងរកភាពស្របច្បាប់ដល់ទេសន្តប្រវេសន៍ សម្រាប់ពលករខ្មែរកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ។ នារសៀលថ្ងៃទី១៣ ខែមីនា ឆ្នាំ០១៨នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំកិច្ចប្រជុំអំពីការគ្រប់គ្រងទេសន្តប្រវេសន៍ ដែលកិច្ចពិភាក្សានេះមានការចូលរួមពីរដ្ឋមន្ត្រីចំនួន៣បន្ថែម គឺរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ , រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ។ ក្នុងចំណោមក្រសួងពាក់ព័ន្ធចំនួន៦ មាន ក្រសួងមហាផ្ទៃ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចកានារី ។

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មការអេចិន្ត្រៃយ៍ គ.ជ.ប បានថ្លែងប្រាប់អ្នកសារព័ត៌មានក្រោយកិច្ចប្រជុំ ថា កិច្ចប្រជុំនេះធ្វើឡើង ខណៈកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំក្រុមប្រទេសបញ្ចូនទាំង៣ ដែលនឹងប្រព្រឹត្តទៅរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី ២៩-៣០ ខែមីនា ដែលនឹងពិភាក្សាកំណត់រកបញ្ហាចំពោះជនទេសន្តប្រវេសន៍ និងភាពប្រឈមលើការងារគ្រប់គ្រងលំហូរទេសន្តប្រវេសន៍ ព្រមទាំងកំណត់ដំណោះស្រាយរួមគ្នា ដើម្បីអនុវត្តក្នុងក្របខណ្ឌប្រទេសទាំង៣ ដោយឈានទៅរកការលើកកម្ពស់សុវត្ថិភាព ផលប្រយោជន៍ស្របច្បាប់របស់ពលករដែលកំពុងធ្វើការនៅប្រទេសថៃ ។ លោកជំទាវ ជូ ប៊ុនអេង បន្តថា ការរៀបចំកិច្ចប្រជុំក្រុមប្រទេសបញ្ជូនទាំង៣នេះដល់ទេសន្តប្រវេសន៍ គឺដើម្បីរក្សាសុវត្ថិភាព រៀបរយ និងស្របច្បាប់នេះ ដើម្បីកាត់បន្ថយផលប៉ះពាលទៅលើមនុស្សក្នុងសង្គម ក៏ដូចជាទៅលើសេដ្ឋកិច្ច និងនយោបាយជាតិ ពិភពលោក ដែលកើតមកពីការរំលោភបំពាន កេងប្រវ័ញ្ច រត់ពន្ធ និងជួញដូរមនុស្សជាដើម ៕

## ឧទ្ធរណ៍ជម្រះក្តីឡើងវិញ លើជនជាប់ចោទដែលជាប់គុក ១៥ ឆ្នាំតាំងពី ៩ ឆ្នាំមុន

http://www.postkhmer.com/ គឹម សារុំ | Publication date 13 March 2018 | 17:39 ICT

**ភ្នំពេញៈ** សាលាឧទ្ធរណ៍នៅថ្ងៃនេះ បានលើកសំណុំរឿងបុរសជាប់ចោទម្នាក់មកជម្រះឡើងវិញ តាមបង្គាប់របស់តុលាការកំពូល ពាក់ព័ន្ធនាំក្មេង ប្រុស-ស្រី ជាអនីតិជនចំនួន ១០ នាក់ ទៅធ្វើជាពលករនៅប្រទេសថៃ តាមច្រកចាំយាម ខេត្តកោះកុង កាលពីឆ្នាំ ២០០៩។ តាមអង្គហេតុរបស់នគរបាលខេត្តកោះកុង បានបង្ហាញថា កាលពីថ្ងៃ ២៦ ខែមករា ឆ្នាំ ២០០៩ ឈ្មោះ នាង រុណ អាយុ ៥៤ ឆ្នាំនៅថ្ងៃទី ៩ ខែ មករាឆ្នាំ ២០០៩ បានបើករថយន្តតាក់ស៊ីដឹកក្រុមជនរងគ្រោះ ប្រុស-ស្រី ចំនួន ១០ នាក់ ដើម្បីចូលធ្វើការនៅក្នុងប្រទេស ថៃ។ ប៉ុន្តែពេលជនជាប់ចោទបើករថយន្តដល់ច្រកចាំយាម ឃុំប៉ាកខ្លង ស្រុកដងទុង ខេត្តកោះកុង ដោយមានការសង្ស័យសមត្ថកិច្ចក៏ឃាត់រថយន្តនិងឃាត់ខ្លួនជនជាប់ជាប់តែម្តង។

សំណុំរឿងនេះ ត្រូវសាលាដំបូងខេត្តកោះកុងបើកសវនាការ និង ប្រកាសសាលក្រមនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ផ្តន្ទាទោសដាក់ពន្ធនាគារ ១៥ ឆ្នាំ ចោទបទ «ការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែននិងសមគំនិត» តាមបញ្ញត្តមាត្រា ១១ ច្បាប់ស្តីពី ការបង្ក្រាបការជួញដូរមនុស្សនិង មាត្រា ៦៨ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែជនជាប់ចោទមិនសុខចិត្តប្តឹងទាស់មក សាលាឧទ្ធរណ៍ ហើយត្រូវឧទ្ធរណ៍តម្កល់សាលក្រមនៅថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១១ ហើយជនជាប់ចោទមិនសុខចិត្តប្តឹងសារទុក្ខទៅតុលាការកំពូលទៀតហើយត្រូវតុលាការកំពូលបើកសវនាការនិង ប្រកាសសាលដីកានៅថ្ងៃទី ៥ខែ មករា ឆ្នាំ ២០១២ ដោយសម្រេចបង្វិលសំណុំរឿងនេះមកសាលាទ្ធរណ៍ជម្រះឡើងវិញ។ ជនជាប់ចោទឆ្លើយប្រាប់ចៅក្រមនៅក្នុងបន្ទប់សវនាថាៈ «ខ្ញុំជាអ្នកបើកតាក់ស៊ីហើយក្រុមជនរងគ្រោះបានជួលរថយន្តខ្ញុំជិះដើម្បីឆ្លងដែនទៅប្រទេស ថៃ។ ខ្ញុំមិនបានជួយរត់ការធ្វើលិខិតឆ្លងដែនឲ្យពួកគេទេការបំពេញលិខិតទាល់តែសាម៉ីខ្លួនទៅផ្ទាល់ទើបធ្វើបាន។ ពួកគេចូលបំពេញបែបបទខ្លួនគេទេខ្ញុំសូមតុលាការដោះលែងខ្ញុំវិញផង»។

លោកស្រីព្រះរាជអាជ្ញា សា កញ្ញារិទ្ធ តំណាងមហាអយ្យការសន្និដ្ឋានថាៈ«រឿងនេះបើតាមចម្លើយរបស់ជនចាប់ចោទមានលក្ខណៈស៊ីសង្វាក់នឹងអង្គហេតុ។ដូច្នេះសូមក្រុមប្រឹក្សាជំនុំជម្រះពិចារណាតាមច្បាប់»។

ដោយឡែក លោក គិន វិបុល ជាមេធាវីចាត់តាំងការពារសិទ្ធិឲ្យជនចាប់ចោទសន្និដ្ឋានថា រឿងនេះតុលាការថ្នាក់ក្រោមបានចោទកូនក្តីលោកពីបទ «ការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែននិងសមគំនិត» តាមបញ្ញត្តមាត្រា ១១ ច្បាប់ស្តីពី ការបង្ក្រាបការជួញដូរមនុស្សនិងមាត្រា ៦៨ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែ ត្រូវតុលាការកំពូលបង្គាប់ឲ្យឧទ្ធរណ៍ជំនុំជម្រះឡើងវិញ ព្រោះតុលាការកំពូលពិនិត្យឃើញថាកូនក្តីលោកមិនពាក់ព័ន្ធការទទួលលុយពីជនរងគ្រោះទេតែសាច់ញាតិគាត់ជាអ្នកទទួល។ លោកថ្លែងថាៈ«គាត់អះអាងថាមិនបានទទួលលុយពីជនរងគ្រោះទេគាត់ថាគ្រាន់តែជូនពួកគេទៅតែប៉ុណ្ណោះ។តុលាការកំពូលចង្អុលមកឧទ្ធរណ៍វិញព្រោះមានវិមតិសង្ស័យច្រើនក្នុងរឿងនេះខ្ញុំសូមក្រុមប្រឹក្សាលើកលែងទោសឲ្យកូនក្តីខ្ញុំផង»។ បន្ទាប់ពីបើកសវនាជំនុំជម្រះ ប្រមាណជាងកន្លះម៉ោងមក លោកស្រីចៅក្រម គឹម ដានី ថ្លែងថា សាលដីកាសំណុំរឿងនេះប្រកាសនៅថ្ងៃទី២២ មីនា ខាងមុខ៕

## ពលករខុសច្បាប់យ៉ាងហោចណាស់ចំនួន24នាក់ ត្រូវបានអាជ្ញាធរថៃ ចាប់ខ្លួន

http://www.prakpheaktra.com March 13, 2018

ពលករខ្មែរនិងភូមាយ៉ាងហោចណាស់25នាក់ ត្រូវកម្លាំងអាជ្ញាធរតម្រួតទេសចរណ៍ និងតម្រួត191ថៃធ្វើការឃាត់ខ្លួននៅកណ្តាលទីក្រុងបាងកកកាលពីថ្ងៃមុន។ កាលពីថ្ងៃសសុក្រទី09 ខែមីនា ឆ្នាំ2018 កន្លងទៅថ្មីៗនេះកម្លាំងសមត្ថកិច្ចតម្រួតទេសចរណ៍និងអាជ្ញាធរពិសេសថៃ បានបើកយុទ្ធនាការបិត(សយ) ចុះត្រួតពិនិត្យនិងបង្ក្រាបជនអន្តោប្រវេសន៍និងពលករខុសច្បាប់ដែលកំពុងធ្វើការស្នាក់នៅក្នុងតំបន់ផ្សាររាត្រីហៅ(តាឡាតរតហ្វៃ)សយារាដានៅកណ្តាល

ទីក្រុងបាងកកប្រទេសថៃ។ យោងតាមរបាយការណ៍របស់សមត្ថកិច្ចថៃបានប្រាប់ឲ្យដឹងថាជនអន្តោប្រវេសន៍សញ្ជាតិស្បែកខ្មៅចំនួន144នាក់ និងពលករសញ្ជាតិផ្សេងដែលលបលួចធ្វើការខុសច្បាប់ចំនួន 24នាក់ ។ បច្ចុប្បន្នជនអន្តោប្រវេសន៍និងពលករខុសច្បាប់ខុសច្បាប់ទាំងអស់ត្រូវបានអាជ្ញាធរថៃបញ្ជូនយកទៅធ្វើការសាកសួរនៅអធិការដ្ឋានតម្រួតទីក្រុងបាងកករួចឃុំខ្លួនទុកដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## កម្ពុជា ធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំបច្ចេកទេសជាមួយឡាវ-ភូមា រឿងបញ្ជូនពលករទៅថៃ នៅថ្ងៃទី២៩-៣០មីនា

http://bayontv.com.kh/ 14/03/2018

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានដឹកនាំកិច្ចប្រជុំចង្អៀតជាមួយអនុប្រធានក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សាកំណត់ទិសដៅក្នុងការងារគ្រប់គ្រង់ និងត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រទេសបញ្ជូនទាំងបី (កម្ពុជា ឡាវ និងភូមា) កាលពីរសៀលថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ៕

## រហូតដល់ពេលនេះ ក្រសួងការងារ ជួយរកការងារក្រៅប្រទេស ជូនពលរដ្ឋបានជាង១.២លាននាក់, នៅថៃច្រើនជាងគេមានជាង១លាននាក់

http://www.freshnewsasia.com/ 2018-03-14

**(ភ្នំពេញ)៖** លទ្ធផលនៃសន្និបាតបូកសរុបការងារ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា រហូតមកដល់ឆ្នាំ២០១៨នេះ រាជរដ្ឋាភិបាល បានផ្តល់សេវាជួយស្វែងរកការងារធ្វើនៅក្រៅប្រទេស ជូនប្រជាពលរដ្ឋបានជាង ១.២លាននាក់។ ក្នុងសេចក្តីជូនដំណឹងអំពីលទ្ធផលសន្និបាត ដែលបានចេញផ្សាយនាថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១៨ បានឲ្យដឹងថា ក្នុងចំណោមពលករទាំង១.២លាននាក់នោះមាននៅ៖

* ប្រទេសថៃមានចំនួន ១,០៥៦,៣៥៨នាក់
* ប្រទេសកូរ៉េខាងត្បូងមានចំនួន ៥៤,២២៩នាក់
* ប្រទេសជប៉ុនមានចំនួន ៦,០០០នាក់
* ប្រទេសម៉ាឡេស៊ីមានចំនួន ៣០,០០០នាក់
* ប្រទេសសិង្ហបុរីមានចំនួន ៤៨៧នាក់
* តំបន់រដ្ឋបាលពិសេសហុងកុង បានចាប់ផ្តើមបញ្ជូនពលការិនីមានចំនួន ១៥នាក់។

ចំណែកពលករបរទេស ដែលកំពុងធ្វើការនៅប្រទេសកម្ពុជាវិញមានចំនួន ៣២,៥១២នាក់ ក្នុងនោះមាន ៩៣សញ្ជាតិ ដែលកំពុងបម្រើការងារនៅក្នុងគ្រឹះស្ថានចំនួន ៣,៩៦៩គោលដៅ។ នេះបើតាមនាយឧត្តមសេនីយ៍ សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ។ តាមរបាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបង្ហាញថា ក្រុមការងារចម្រុះអធិការកិច្ចហត្ថពលកម្មបរទេស ដែលមានក្រសួងការងារ និងក្រសួងមហាផ្ទៃ បានផាកពិន័យជនបរទេសប្រកបមុខរបរ និងបម្រើការងារគ្មានប័ណ្ណការងារចំនួន១,៣៨៩នាក់៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨

កាលពីថ្ងៃចន្ទ ១១រោច និងអង្គារ ១២រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១២-១៣ ខែមីនា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការអញ្ជើញចូលរួមរបស់ ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សាអមក្រសួង អគ្គលេខាធិការ អគ្គនាយក តំណាងក្រសួងស្ថាប័ន តំណាងថ្នាក់ក្រោមជាតិ តំណាងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ព្រមទាំងមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ក្រសួងសរុបចំនួន ៤៧០នាក់។ ក្នុងរយៈពេល ២ថ្ងៃនេះ អង្គសន្និបាតបានធ្វើបទបង្ហាញ និងពិភាក្សាលើប្រធានបទអាទិភាពកំណែទម្រង់ទាំង៥ ដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ២០១៤-២០១៨ ដូចខាងក្រោម៖

### ក- លទ្ធផលការងារឆ្នាំ២០១៧
### ១- ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

- បានរៀបចំនូវបញ្ជីត្រួតពិនិត្យអធិការកិច្ចការងារកាន់តែមានប្រសិទ្ធភាព តម្លាភាព និងភាពជឿជាក់ ព្រមទាំងដាក់ឱ្យប្រើប្រាស់ក្រមសីលធម៌សម្រាប់មន្ត្រីអធិការកិច្ចការងារ ជាពិសេសរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា។
- បានចុះធ្វើអធិការកិច្ចការងារនៅទូទាំងប្រទេសបានចំនួន ៩ ៧១៧លើក បានដាក់កំហិតសហគ្រាស គ្រឹះស្ថាន ចំនួន ៨៩៣សហគ្រាស គ្រឹះស្ថាន បានចេញលិខិតផាកពិន័យចំនួន ៨១ សហគ្រាស គ្រឹះស្ថាន និងប្តឹងទៅតុលាការចំនួន ៥ករណី។
- បានដោះស្រាយវិវាទការងាររួមចំនួន ១២៧ករណី (ថយចុះ ៨០% ធៀបនឹងឆ្នាំ២០១៦) ក្នុងនោះករណីសះជាចំនួន ៥៦ករណី មិនសះជា ៧០ករណី និងមោឃៈ ០១ករណី។
- បានពង្រឹងការអនុវត្តច្បាប់ស្តីពីសហជីព ដោយបានចុះបញ្ជីអង្គការវិជ្ជាជីវៈសរុបចំនួន៣ ៩៦២ ក្នុងនោះសហជីពមូលដ្ឋានមានចំនួន ៣ ៧៩៣ សហព័ន្ធសហជីពមានចំនួន១៣៨ សហភាពសហជីពមានចំនួន ២៣ និងសមាគមនិយោជកចំនួន៨។ ក្នុងឆ្នាំ២០១៧ នេះ បានចុះបញ្ជិកាសហជីពមូលដ្ឋានថ្មីចំនួន ៦៣៥ សហព័ន្ធសហជីពចំនួន ៤០ និងសហភាពសហព័ន្ធសហជីពចំនួន ៦។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- បានដោះស្រាយបញ្ហាកូដកម្មចំនួន ៩៧រោងចក្រ ស្មើ ៩៧ករណី (សះជា ៩០ករណី) (ថយចុះ ៤២% ធៀបនឹងឆ្នាំ២០១៦)។
- សហគ្រាស គ្រឹះស្ថាន ប្រមាណ៨៨% មានគិលានដ្ឋានប្រចាំក្នុងរោងចក្រ កន្លែងហូបបាយ ៣៣% បន្ទប់បំបៅកូន ២១% និងទារកដ្ឋាន ២៨%។
- បានផ្តល់បណ្ណ និងសៀវភៅការងារដល់កម្មករនិយោជិតខ្មែរចំនួន ២៤៧ ៧៩៦នាក់ និងជនបរទេសចំនួន ៥៦ ៩៧៥នាក់។
- បានពង្រឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មជនបរទេស តាមការស្នើសុំកូតា បណ្ណ និងសៀវភៅការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។
- បានដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងពី ១៥៣ដុល្លារអាមេរិក ដល់ចំនួន ១៧០ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់ឆ្នាំ២០១៨ បូករួមនឹងអត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗអាចទទួលប្រាក់ខែពី ១៨៧ ទៅដល់ ១៩៨ដុល្លារអាមេរិក។
- បានបន្តដំណើរការគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) ព្រមទាំងបានពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារ ។
- បានចេញសេចក្តីណែនាំដើម្បីឱ្យម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាននានា អនុវត្តការអនុញ្ញាតឱ្យបងប្អូនកម្មការិនីមានផ្ទៃពោះ ចេញមុនម៉ោងធ្វើការងារយ៉ាងតិច១៥នាទី និងអនុញ្ញាតឱ្យបងប្អូនកម្មករនិយោជិតជាស្ត្រីខ្មែរឥស្លាមអាចប្រើប្រាស់សម្លៀកបំពាក់តាមប្រពៃណីឥស្លាម។
- បានជំរុញគ្រប់រោងចក្រត្រូវរៀបចំបន្ទប់បំបៅកូន សម្រាប់កម្មការិនីដែលមានកូនក្រោមអាយុ ១២ខែ និងត្រូវមានទារកដ្ឋានសម្រាប់កម្មការិនីដែលមានកូនអាយុលើស ១៨ខែ។
- បានដាក់ចេញវិធានការដោះស្រាយទប់ស្កាត់ករណីដួលសន្លប់ ដោយតម្រូវឱ្យគ្រប់រោងចក្រសហគ្រាសទាំងអស់ ពិនិត្យលក្ខណៈបច្ចេកទេស និងស្ថានភាពជុំវិញរោងចក្រឱ្យមានសុវត្ថិភាពមុនពេលចូលធ្វើការ។
- បានរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស គ្រឹះស្ថាន។

**២- ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- រៀបចំឱ្យមានអនុក្រឹត្យស្តីពីទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET DAY) កំណត់យកថ្ងៃទី១៥ ខែមិថុនា ជារៀងរាល់ឆ្នាំ។
- បានធ្វើការបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្ររយៈពេលខ្លី (ក្រោមរយៈពេល១ឆ្នាំ) សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បរិញ្ញាបត្រ បច្ចេកវិទ្យា សញ្ញាបត្រវិស្វករ បរិញ្ញាបត្រជាន់ខ្ពស់ និងហ្វឹកហ្វឺនកូនជាងដល់សិក្ខាកាម សិស្ស និងនិស្សិត បានចំនួនប្រមាណជាង ៦០ ០០០នាក់ លើមុខជំនាញឧស្សាហកម្ម ពាណិជ្ជកម្ម បច្ចេកទេស សិប្បកម្មសេវាកម្មទេសចរណ៍ និងកសិកម្ម។
- បានអភិវឌ្ឍកញ្ចប់ស្តង់ដាផ្អែកលើសមត្ថភាព (គុណវុឌ្ឍិជាតិកម្រិត២, ៣ និង៤) ក្នុងវិស័យសំណង់វិស័យមេកានិច និងវិស័យសេវាកម្មធុរកិច្ច/ព័ត៌មានវិទ្យាចំនួន ២១មុខរបរ ដែលមាន ៥៦គុណវុឌ្ឍិ។
- បានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលជំនាញសម្រាប់ពាណិជ្ជកម្ម និងពិពិធកម្មសេដ្ឋកិច្ច គុណវុឌ្ឍិជាតិកម្រិត ១, ២, ៣ និង៤ ក្នុងមុខរបរជួសជុលអគ្គិសនី មុខរបរបន្សុីលោហៈ មុខរបរផលិតផល មុខរបរកែច្នៃបន្លែ និងផ្លែឈើ លាបថ្នាំអគារ បរិក្ខារត្រជាក់ក្នុងគេហដ្ឋាន បរិក្ខាត្រជាក់ពាណិជ្ជកម្ម ផ្សារទំនើប ចំនួន ៨ មុខរបរ ដែលមាន ១៨គុណវុឌ្ឍិ។

- បានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលគុណវុឌ្ឍិជាតិកម្រិត ១ វិញ្ញាបនបត្រវិជ្ជាជីវៈ (Vocational Skill Certificate, VSC) សម្រាប់ ៥វិស័យ ដូចជា៖ សំណង់ មេកានិចរថយន្ត ធុរកិច្ច/ICT អគ្គិសនី និង កម្មន្តសាល។
- បានធ្វើយុទ្ធនាការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការតម្រង់ទិសដល់សិស្សចំនួន ៣៨ ៧៩៤នាក់ ហ្វឹកហ្វឺន និងធ្វើតេស្តកូនជាងចំនួន ២៣ ៣០១នាក់។

## ៣- ការអភិវឌ្ឍមុខរបរ និងការងារ

- សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបមានចំនួន ១២ ២៨៧គ្រឹះស្ថាន កើនចំនួន១០,០២% និងមានកម្មករនិយោជិតសរុបចំនួន ១ ៤៣៧ ៧៩៤នាក់ កើនចំនួន ២១,១% ដោយបានទទួលប្រាក់ឈ្នួលជាមធ្យមប្រមាណជាង ២ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។
- សហគ្រាសផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធមានចំនួន ២២ ០៦៧ មានកម្មករនិយោជិតចំនួន ១៨៧ ៩០៩នាក់ បានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ បានដើរតួនាទីយ៉ាងសកម្មក្នុងការបំពេញឱ្យគ្នាទៅវិញទៅមករវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងបានរួមវិភាគទានយ៉ាងធំក្នុងសេដ្ឋកិច្ចជាតិប្រមាណ ៦ពាន់លានដុល្លារ ក្នុងមួយឆ្នាំ។
- កម្លាំងពលកម្មសរុប ៩៩,៣% មានការងារធ្វើ។
- បាននឹងកំពុងអនុវត្តកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិស្តីពីមុខរបរ និងការងារសម្រាប់យុវជននៅកម្ពុជា ដើម្បីអភិវឌ្ឍន៍យុវជន និងស្ត្រីវ័យក្មេងកាន់តែច្រើនឡើងទទួលបានឱកាសការងារសមរម្យ និងមានផលិតភាព។
- បានផ្តល់សេវាជួយស្វែងរកការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋ បានចំនួនប្រមាណជាង ១,២លាននាក់ ក្នុងនោះមាន៖
  - ប្រទេសថៃមានចំនួនប្រមាណ ១ ០៥៦ ៣៥៨នាក់
  - ប្រទេសកូរ៉េ មានចំនួនប្រមាណ ៤៤ ២២៩នាក់
  - ប្រទេសជប៉ុនមានចំនួនប្រមាណ ៦ ០០០នាក់
  - ប្រទេសម៉ាឡេស៊ី មានចំនួនប្រមាណ ៣០ ០០០នាក់
  - ប្រទេសសឹង្ហបុរី មានចំនួនប្រមាណ ៤៨៧នាក់
  - តំបន់រដ្ឋបាលពិសេសហុងកុង ទើបចាប់ផ្តើមបញ្ជូនពលការិនីចំនួន ១៥នាក់
- បានប្រមូលចុះឈ្មោះអ្នកស្វែងរកការងារចំនួន ១៥ ១៣៣នាក់ បានផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារចំនួន ៨៨ ៨៧៥ និងជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋតាមមូលដ្ឋានភូមិ ឃុំ និងតាមរយៈវេទិកាការងារនានាដែលរៀបចំដោយទីភ្នាក់ជាតិមុខរបរ និងការងារ និងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងតាមរយៈទីភ្នាក់ងារជ្រើសរើសពលករស្របច្បាប់។
- បានផ្តល់មគ្គុទេសន៍ក្នុងការរៀបចំផែនការអាជីពនិងជ្រើសរើសជំនាញសិក្សា ដល់សិស្សមធ្យមសិក្សាទុតិយភូមិតាមរយៈសិក្ខាសាលាចំនួន ២៥៣វគ្គ ដែលមានអ្នកចូលរួមសរុប ១៣ ៣៨៨នាក់។
- បានផ្តល់ការណែនាំនិងប្រឹក្សាយោបល់អាជីព ដល់និស្សិតតាមរយៈសិក្ខាសាលាចំនួន ៥៣លើក ដែលមានអ្នកចូលរួមសរុប ៤ ១៩០នាក់។

### ៤- ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- បានអនុវត្តផ្នែកហានិភ័យការងារ ៩ ៧២៤សហគ្រាស គ្រឹះស្ថាន ស្មើនឹងចំនួន ១ ១៨៦ ៤៥៣នាក់ ផ្នែកថែទាំសុខភាពក្នុងប្រព័ន្ធ ២ ៤៦៧ សហគ្រាស គ្រឹះស្ថាន ស្មើនឹង ១ ០៤៧ ៤៦១៥០នាក់។
- ការអនុវត្តរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន (ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនដាក់ដំណើរការឆ្នាំ២០១៨ ដោយឡែកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈដាក់ឱ្យដំណើរការឆ្នាំ២០១៩)។
- ផ្តល់តាវកាលិកហានិភ័យការងារ មានចំនួន ៤០ ២៧០ឯកសារ កើនឡើងស្មើនឹង ១០,៣០% ដែលមានចំនួនជនរងគ្រោះ ២១ ២៦៧នាក់ បើប្រៀបធៀបនឹងឆ្នាំ២០១៦។ ការចំណាយ តាវកាលិកហានិភ័យការងារ មានចំនួន ១៩ប៊ីលានរៀល មានការកើនឡើងស្មើនឹង ២១,៩៨%។
- បានអនុវត្តរបបថែទាំសុខភាពចាប់ពីខែមិថុនា ឆ្នាំ២០១៦ ដោយបានពង្រីកដល់សហគ្រាស គ្រឹះស្ថាន និងបានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញត្រឹមឆ្នាំ២០១៧នេះ បានចំនួន ២ ៤៦៧ សហគ្រាស មានកម្មករនិយោជិតចំនួន ១ ០៤៧ ៤៦១នាក់។
- បានចុះបញ្ជីសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ២១ ៣៧៩ សហគ្រាស មានកម្មករសរុប ១៨៤ ៤៣៦នាក់ ដែលទទួលបានមូលនិធិសមធម៌។
- បានអនុវត្តកម្មវិធីផ្តល់ការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់ ដោយមិនបង់ប្រាក់បានចំនួន ២៣០ ៧៣៥នាក់ ចំណាយថវិកាចំនួន ២៧,៣ ប៊ីលានរៀល។
- បានផ្តល់ប្រាក់ឈ្នួល ១២០ភាគរយ និងការឈប់សម្រាករយៈពេល៣ខែ ក្នុងពេលសម្រាលកូន ដល់កម្មការិនីចំនួន ៥ ៦០៤នាក់ ដោយផ្តល់ថវិកាអស់ចំនួន ៨,៧ ប៊ីលានរៀល។
- បានអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីសម្រាលកូន គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ មានកម្មការិនីសម្រាលកូនចំនួន ៩ ៩២៥ នាក់ ចំនួនកូន ៩ ៩៩០ នាក់ (កូនភ្លោះ២ ចំនួន ៦៧នាក់) ដែលបានផ្តល់ប្រាក់ឧបត្ថម្ភសរុបចំនួន ៣ ៩៩៦លានរៀល។
- បានកំណត់ឱ្យនិយោជកជាប់កាតព្វកិច្ចបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព១០០% ជំនួសកម្មករនិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨ មានចំនួន ៦ ៥៦៩ សហគ្រាស ដែលមានកម្មករនិយោជិត ១ ២៩០ ៧៥៦នាក់។
- បានបន្តសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិតតាមរយៈការរៀបចំកែសម្រួលមធ្យោបាយដឹកជញ្ជូន និងពង្រឹងការអនុវត្តច្បាប់ចរាចរផ្លូវគោក។
- កំពុងសហការជាមួយបណ្តាប្រទេសអាស៊ានក្នុងការអនុវត្តរបបសោធននិវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយបន្ទាប់ពីចប់កិច្ចសន្យាការងារ និងដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធននិវត្តន៍។ ពលករដែលធ្វើការនៅក្រៅប្រទេសអាចទទួលបានរបបនេះដូចនៅក្នុងប្រទេសចាប់ពីឆ្នាំ២០១៩។

## ខ. ទិសដៅអនុវត្តបន្តឆ្នាំ២០១៨

បន្តអនុវត្តនូវកំណែទម្រង់អាទិភាពទាំង៥ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ឱ្យបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ដូចខាងក្រោម៖

១-បន្តខិតខំអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ នូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ទាំង៩ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីគាំពារ និងសម្រួលដល់បន្ទុកចំណាយ ក៏ដូចជាដោះស្រាយបញ្ហានានារបស់បងប្អូនកម្មករនិយោជិត។

២-បន្តពង្រឹងសមត្ថភាព និងគុណភាពការងាររបស់មន្ត្រីអធិការកិច្ចការងារក្នុងការអនុវត្តច្បាប់ស្តីពីការងារ បន្តធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ ព្រមទាំងបន្តសហការជាមួយគម្រោងកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) គម្រោងបទដ្ឋានសង្គម និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ី (GIZ, SLSG) នៅប្រទេសកម្ពុជា និងគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងជាសកល របស់ស៊ុយអ៊ែត។

៣-បន្តខិតខំដោះស្រាយវិវាទការងារជូនដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ព្រមទាំងខិតខំទប់ស្កាត់ការធ្វើកូដកម្ម បាតុកម្មខុសច្បាប់ ដើម្បីធានាបាននូវសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ។ រៀបចំប្រកាសស្តីពីនីតិវិធីដោះស្រាយករណីរោងចក្របិទទ្វារដោយម្ចាស់រត់ចោល និងប្រកាសស្តីពីនីតិវិធីទូទាត់អត្ថប្រយោជន៍ជូនកម្មករនិយោជិត។

៤-បន្តពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងការរៀបចំការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកសោធននិវត្តន៍នៅឆ្នាំ២០១៩ ពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ពង្រីកការអនុវត្តប្រកាសអន្តរក្រសួងស្តីពីការអនុវត្តការថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិត ជាស្ត្រីនៅពេលសម្រាលកូន។

៥-បង្កើនការអប់រំ ការផលិតស្ពតអប់រំ និងការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរ ដើម្បីបង្ការទប់ស្កាត់គ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ និងការជួលសន្លប់។

៦-បន្តពង្រឹងគុណភាពកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាំងរយៈពេលខ្លី និងវែងឱ្យស្របទៅតាមតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគតឱ្យបានទូលំទូលាយរហូតដល់តំបន់ដាច់ស្រយាលទូទាំង ២៥ រាជធានី ខេត្ត តាមរយៈការបង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិ សម្រាប់ធ្វើតេស្តបញ្ជាក់សមត្ថភាព និងប្រកួតប្រជែងជំនាញថ្នាក់ជាតិឱ្យស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដាជាតិសមត្ថភាព និងកម្មវិធីសិក្សាក្នុងតំបន់។

៧-បន្តលើកកម្ពស់ការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព ដោយពង្រីកយន្តការ "វេទិកាការងារ" ព្រមទាំងការជំរុញកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់កម្លាំងពលកម្ម ជាមួយបណ្តាប្រទេសដៃគូ។

៨-រៀបចំអនុក្រឹត្យស្តីពីរបបនិកម្មភាពដើម្បីធានាទូទាត់អត្ថប្រយោជន៍ កម្មករនិយោជិតករណីរោងចក្របិទទ្វារ ទន្ទឹមនឹងនេះរៀបចំច្បាប់ស្តីពីរបបសន្តិសុខសង្គមដើម្បីឱ្យស្របតាមតម្រូវការវិវត្តរបស់សង្គម និងធានាការដាក់ឱ្យអនុវត្តរបបសោធននិវត្តន៍នាឆ្នាំ២០១៩។

៩-ជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ព្រមទាំងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១២រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨

## មន្ត្រីយោធាភូមិភាគ៤ធ្វើសេដ្ឋកិច្ចប្រមូលប្រាក់បទល្មើសឈើឆ្លងដែនឲ្យលោកឧត្តមសេនីយ៍ត្រី ជា សុភ័ក្រ ដែលឲ្យពលករឆ្លងដែនចូលទៅកាប់ឈើគ្រញូង

http://nokorwatnews.com/ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០១៨

ខេត្តឧត្តរមានជ័យ ៖ នៅថ្ងៃចន្ទ ១១រោច ខែផល្គុន ឆ្នាំ រកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៨ មានការបែកធ្លាយព័ត៌មានមកថា ឈ្មោះ យុន បូរីហៅ (ទីណូ)ជាមន្ត្រីយោធាបម្រើការងារនៅអង្គភាពភូមិភាគ ៤ និងជាអ្នកធ្វើសេដ្ឋកិច្ចនៅតាមក្រវាត់ព្រំដែនស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីប្រមូលប្រាក់ ពីអ្នករកស៊ីបទល្មើសឈើគ្រញូងឆ្លងដែន ជូនលោកឧត្តមសេនីយ៍ត្រី ជា សុភ័ក្រ។ ប្រភពព័ត៌មានពីមន្ត្រីយោធាបានឲ្យដឹងថាឈ្មោះ យុន បូរី បានល្បីតៗគ្នាថា បានដាក់កម្លាំងពលករឆ្លងដែនចូលទៅកាប់ឈើគ្រញូងនៅតំបន់ប្រករបៀងទឹកជប់ នៅក្នុងភូមិទំនប់អភិវឌ្ឍន៍ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ។ សព្វថ្ងៃនេះ ក្រោយនៅតំបន់ទិសទី២ សមរភូមិមុខ ស្រុកត្រពាំងប្រាសាទ បានកក្រើកឡើងយ៉ាងខ្លាំង នូវចរាចរណ៍ឈើគ្រញូងឆ្លងដែន ធ្វើឲ្យឈ្មួញ និងកងកម្លាំង ផ្ទះកំហឹងដាក់គ្នា ដើរបេកអាក្រាតគ្នាទៅវិញទៅមក និងបានប្រព្រឹត្តអំពើពុករលួយ បើកភ្លើងខៀវឲ្យពលករឆ្លងដែនយ៉ាងអនាធិបតេយ្យចូលទៅកាប់ឈើនៅស្រុកថៃ និងសកម្មភាពឈ្មួញដឹកជញ្ជូនឈើគ្រញូង និងទំនិញខុសច្បាប់យ៉ាងគគ្រឹកគគ្រេង។

ក្រៅពីឈ្មោះ យុន បូរី បានដាក់ពលករនៅតំបន់ខាងលើ ក៏មានការបែកធ្លាយជាបន្តបន្ទាប់ថា មនុស្ស៣នាក់ផ្សេងទៀត ទី១-ឈ្មោះ តា ថ្មាំខ្លាំង ត្រូវជាឪពុកក្មេកលោកឧត្តមសេនីយ៍ត្រីម្នាក់ ទី២-ឈ្មោះ ប្រុស និង ទី៣-ឈ្មោះ ហង្ស ជាអ្នកកៀងគរអ្នកទាំងអស់ខាងលើ បានកៀងគរពលករឆ្លងដែនទៅកាប់ឈើគ្រញូងនៅប្រករបៀងទឹកជប់ និងប្រករបៀងថ្មប្រេះផងដែ ។ ដោយក្នុងនោះ មានកងកម្លាំងយោធាភូមិភាគបួន ប្រចាំការនៅប្រករបៀងថ្មប្រេះ មានឈ្មោះ យ៉ា និងឈ្មោះ គ្រាក់ ជាអ្នកមើលកម្លាំងពលករចុះឡើង។ ចំពោះការចោទប្រកាន់ខាងលើ លោក យុន បូរី មន្ត្រីយោធាភូមិភាគបួនបានឲ្យដឹងថា រឿងនេះ សុទ្ធសឹងតែជារឿងលាបពណ៌ និងចោទប្រកាន់មកលើរូបលោកទាំងស្រុង ។ លោកថា មិនដែលមានពាក់ព័ន្ធជាមួយនឹងដាក់ពលករឆ្លងដែនរកស៊ីឈើគ្រញូងស្អីនោះទេ លោកបានស្បថស្បែដាក់ជីវិតលោក និងក្រុមគ្រួសារ ។ លោកបន្តថា បើលោករកមែននោះ មិនបាច់ចាំចុះផ្សាយទេ ដាក់ឲ្យអ្នកច្បាប់បើកការស៊ើបអង្កេតទៅ នឹងរកឃើញហើយ ។ លោកថា បើលោកមានជាប់ពាក់ពន្ធ័មែននោះ លោកនឹងប្រគល់ខ្លួនឲ្យសមត្ថកិច្ចចាត់ការរូបលោកទៅតាមច្បាប់ចុះ ។ លោកបន្តសុំឲ្យអ្នកច្បាប់ដាក់ការស៊ើបអង្កេតនៅក្នុងតំបន់ខាងលើទៅដឹងថា អ្នកណាល្អ អ្នកណាអាក្រក់ហើយ ។ ជាតុពិត ក្រុមអ្នករកស៊ីខិលខូច តែងកាច់កុងមកលើរូបលោកតែម្តង ។

លោកឧត្តមសេនីយ៍ត្រី ជា សុភ័ក្រ ភ្នាក់ងារយកព័ត៌មានកាសែតនគរវត្តមិនអាចទាក់ទងសុំការបញ្ជាក់បានឡើយ ព្រោះគ្មានលេខទូរស័ព្ទរបស់លោក ៕ ប៉ែន នួន

## ថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៨

## បច្ចុប្បន្នមានពលករខ្មែរជាង១លាន២សែននាក់កំពុងធ្វើការនៅប្រទេសចំនួន៦

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 14 March, 2018

ភ្នំពេញ ៖ បើគិតត្រឹមឆ្នាំ២០១៨នេះ ប្រជាពលរដ្ឋខ្មែរជាង១លាន ២សែននាក់ កំពុងធ្វើ ការងារ ជាពលករនៅក្រៅប្រទេស តាមរយៈការជួយស្វែងរកដោយរាជរដ្ឋាភិបាលកម្ពុជា។ នេះបើយោងតាមរបាយការណ៍លទ្ធផលការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ របាយការណ៍នេះក៏បានបញ្ជាក់ដែរថា មានប្រទេសចំនួន៦ ដែលរាជរដ្ឋាភិបាលកម្ពុជាបានចរចារជាមួយ ដើម្បីស្នើសុំការផ្តល់ការងារដល់ពលរដ្ឋខ្មែរ ក្នុងនោះប្រទេសថៃជាប្រទេសដែលកម្ពុជាបញ្ជូនពលករទៅច្រើនជាងគេ មានរហូតដល់ទៅជាង ១លាន៥ម៉ឺន ៦ពាន់នាក់។ បន្ទាប់មកគឺសាធារណៈរដ្ឋកូរ៉េ មានពលករកម្ពុជាចំនួនជាង៤ម៉ឺន៤ពាន់នាក់។ ប្រទេសម៉ាឡេស៊ី មានចំនួនប្រមាណ៣ម៉ឺននាក់។ ប្រទេសជប៉ុន មានចំនួន

ជាង៦ពាន់នាក់។ ប្រទេសសឹង្ហបុរី មានចំនួនជិត៥រយនាក់ ។ចំណែកតំបន់រដ្ឋបាលពិសេសហុងកុងដែលទើបចាប់ផ្តើមទទួលយកពលការិនីពីកម្ពុជាមានចំនួន១៥នាក់។

គួរកត់សំគាល់ថា រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា ថវិកាចំណូលរបស់ពលករកម្ពុជាដែលធ្វើការនៅក្រៅប្រទេស គឺជាការរួមចំណែកមួយយ៉ាងសំខាន់សម្រាប់ក្រុមគ្រួសារ និងប្រទេសជាតិ ដោយថវិកាសរុបដែលពលករទាំងនោះបានផ្ញើរមកកាន់ស្រុកកំណើត មានប្រមាណជា២ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ នាពេលកន្លងមក ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក៏បានជម្រុញអោយក្រសួងការងារ និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការពន្លឿនការងារ ដើម្បីអោយពលករខ្មែរទទួលបានភាពស្របច្បាប់ ដើម្បីបានធ្វើការនិងរស់នៅក្រៅប្រទេសដូចជាប្រទេសថៃ និងប្រទេសម៉ាឡេស៊ីជាដើម។ បន្ថែមពីនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបង្ហាញពីគោលបំណងចង់ស្វែងរកទីផ្សារការងារជូនពលរដ្ឋខ្មែរនៅតំបន់មជ្ឈិមបូព៌ា ជាពិសេសសម្រាប់បងប្អូនខ្មែរឥស្លាមផងដែរ៕

## ក្រុមអង្គការ ILO នាំគ្នាមកប្រមូលផ្តុំគ្នាដើម្បីដាក់ញត្តិ នៅទីស្តីការគណៈរដ្ឋមន្ត្រី

http://cambodiapolice.com/ 11:20 am 15 មីនា 2018

**ភ្នំពេញ ៖** ក្រុមអង្គការ ILO មានគ្នាប្រហែលជាង៣០នាក់ដឹកនាំដោយ ១.អ៊ុំ ឌីណា, ២.យ៉ុង លាភ, ៣.សឿន ផល្លី ៤.ហេង ចិន្តា, ៥.វ៉ាន់ នី បាននាំគ្នាមកប្រមូលផ្តុំគ្នាដើម្បីដាក់ញត្តិ នៅទីស្តីការគណៈរដ្ឋមន្ត្រីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ ម៉ោង៩និង៣០នាទី នៅចំណុចផ្លូវ១២៨ កែងផ្លូវ១៣៩ ប្រកចូលខាងក្រោយទីស្តីការគណៈរដ្ឋមន្ត្រី។

គោលបំណងទី១.ស្នើរសុំផ្តល់សច្ចាបណ្ណលើអនុសញ្ញាអង្គការអន្តរជាតិខាងការងារ ILO គឺអនុសញ្ញាលេខ១៨៣ ស្តីពី(កិច្ចគាំពារមាតុភាព) និងអនុសញ្ញាលេខ១៨៩ ស្តីពីការងារសមរម្យ សម្រាប់អ្នកធ្វើការងារផ្ទះ ទី២. ស្នើសុំគាំទ្រឲ្យមានអនុសញ្ញារបស់អង្គការ ILO ថ្មី ស្តីពីការបញ្ឈប់អំពើហិង្សា ផ្អែកលើ យែនឌ័រ នៅក្នុងពិភពការងារ និងសុំឲ្យមានដំណោះស្រាយផ្លូវច្បាប់ឆ្ពោះទៅរកការបញ្ឈប់ការប្រើប្រាស់កិច្ចសន្យាការងារខ្លី ក្នុងមុខរបរដែលមានវិនិយោគរយៈពេលវែង។ នៅវេលាម៉ោង៩និង៤០នាទី តំណាង០៦នាក់ បានចូលដាក់ញត្តិ ហើយ ផ្នែករដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រីជាអ្នកទទួលញត្តិ។ ក្រោយពីតំណាងទទួលញត្តិរួចហើយពួកគាត់បានរំសាយត្រលប់ទៅវិញ ៕

## អាក្រា រួមគ្នា លើកស្ទួយ ការជ្រើសរើស ប្រកបដោយក្រម សីលធម៌ ដើម្បីបង្ការទប់ស្កាត់ អំពើជួញ ដូរមនុស្ស

https://www.dap-news.com/kh/ ព្រហស្បតិ៍, ១៥ មិនា ២០១៨ 12:24 ដោយ: ហង្ស ទេព ID:012

ភ្នំពេញ៖ អង្គការជំនួយផ្លូវច្បាប់ ដល់កុមារ និងស្រ្តី បានបើកវគ្គបណ្តុះ បណ្តាល ស្តីពីការជ្រើស រើសពលករប្រកបដោយក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារឯកជន រយៈពេល២ថ្ងៃ គឺចាប់ពី ថ្ងៃទី១៥-១៦ ខែមីនា ឆ្នាំ២០១៨នេះ។ លោកស្រី អ៊ឹង ស៊ាងរិទ្ធី ប្រធានសមាគមទីភ្នាក់ងារ ពលករកម្ពុជា (អាក្រា) បានឱ្យដឹងថា "ការបណ្តុះបណ្តាលនេះធ្វើឡើង ក្នុងគោលបំណង ដើម្បីចូលរួម ជាមួយរាជរដ្ឋាភិបាល ក្នុង ការកាត់បន្ថយការធ្វើចំណាកស្រុក ដោយប្រថុយប្រថាន អំពើជួញដូរមនុស្ស ក៏ដូចជា ធ្វើការ ពង្រឹងការអនុវត្តច្បាប់នៅកម្ពុជា" ។ វគ្គនេះ ធ្វើឡើងក្រោម គម្រោងប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នៅកម្ពុជា ដែលឧបត្ថម្ភ ថវិកា ដោយទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ តាមរយៈអង្គការ វីនរ៉ក់ អន្តរជាតិ បានចុះហត្ថលេខាលើ អនុស្សារណៈយោគយល់គ្នា ស្តីពី ការពង្រឹងកិច្ច សហប្រតិបត្តិការ លើកស្ទួយការជ្រើសរើស ប្រកបដោយក្រមសីលធម៌ ក្នុងចំណោម ទីភ្នាក់ងារជ្រើសរើសឯកជន ជាមួយទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (អាក្រា)។ ក្រៅពីនេះ ក៏ដើម្បីពង្រឹងសមត្ថភាពបន្ថែម ដល់សមាជិកសមាគម អាក្រា នៅក្នុងដំណើរការ ជ្រើស រើសពលករ ប្រកបដោយភាពត្រឹមត្រូវ ស្របជាមួយនិងច្បាប់ អនុក្រិត្យ ប្រកាស បទបញ្ញាតិ គោល

នយោបាយ បទដ្ឋានគតិយុត្តិ និងក្រមសីលធម៌របស់សមាគម អាក្រា និងគោលការណ៍នានា ដែលទាក់ទងនឹងការគ្រប់គ្រង លើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ ទៅធ្វើការនៅបរទេស។

សមាគម អាក្រា ក៏បានសហការជាមួយ អាយឡូ និងដៃគូពាក់ព័ន្ធធ្វើសកម្មភាពជាច្រើនទៀត ដើម្បីធ្វើយ៉ាងណាឱ្យមានការការពារ នូវអត្ថប្រយោជន៍ស្របច្បាប់ ជូនសមាជិក សមាគម និង ការការពារអត្ថប្រយោជន៍ ក៏ដូចជាលើកកម្ពស់សិទ្ធិរបស់ពលករខ្មែរ ទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើស ពលករឯកជន ពិសេស ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ ចតុកោណ របស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា។

លោក ហ៊ូ វុទ្ធី អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមាន ប្រសាសន៍ក្នុងពិធីនោះថា មានពលរដ្ឋជាច្រើន ជាពិសេស ប្រទេសដែលមានសេដ្ឋកិច្ច មិនទាន់អភិវឌ្ឍន៍ បាននិងកំពុងយកទេសន្តប្រវេសន៍ការងារ ធ្វើជាមធ្យោបាយសម្រាប់ រំដោះខ្លួនចេញពីភាពក្រីក្រ សម្រាប់កែលំអរកម្រិតជីវភាពគ្រួសារ។ ចំនួនពលករទេសន្តប្រវេសន៍ បាននិងកំពុងកើនឡើងជាលំដាប់ដោយ បានផ្តល់កម្លាំងពលកម្ម ជួយកិច្ចអភិវឌ្ឍន៍ប្រទេស និងទទួលយកមកវិញនូវផលប្រយោជន៍ ខាងសេដ្ឋកិច្ច និង មុខ ជំនាញ ឬ បទពិសោធន៍ការងារ។ ជាមួយគ្នានោះ គេក៏សង្កេតឃើញក្នុងចំណោមពួក គេក៏មានអ្នកទទួលរងនូវប្រព្រឹត្តកម្ម ឬ ការរំលោភបំពានផងដែរ។ លោក អនុរដ្ឋលេខាធិការ បញ្ជាក់ថា "រហូតមកដល់បច្ចុប្បន្ន ពលករខ្មែរទាំង២ភេទ បាននិង កំពុងចាកចេញ ទៅធ្វើការនៅបរទេស ដោយស្របច្បាប់ និងមិនស្របច្បាប់ មានប្រមាណ ជាង១លាន១សែននាក់ តាមប្រព័ន្ធវិស័យឯកជន ដែលមានទីភ្នាក់ងារជ្រើសរើស ឯកជនជាង ៧០ ក្រុមហ៊ុន ។ ទន្ទឹមនេះ ការបញ្ជូនទៅប្រទេសកូរ៉េ ដោយប្រព័ន្ធរដ្ឋ និងរដ្ឋ មានពលករ ប្រមាណ៦ម៉ឺននាក់។ ពលករទាំងនោះបានបញ្ជូនប្រាក់មកកម្ពុជាវិញ ប្រមាណជា២ពាន់លាន ដុល្លារ អាមេរិកក្នុង១ឆ្នាំ"។ លោកវាយតម្លៃខ្ពស់ ចំពោះការវគ្គបណ្តុះបណ្តាល ប្រកបដោយ សីលធម៌ សម្រាប់ទីភ្នាក់ ងារជ្រើសរើសពលករ វិស័យឯកជន នាពេលនេះ ពិតជាបានរួមចំណែក ដល់ការលើក ស្ទួយការជ្រើសរើសពលករ ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពាននានា ពិសេសបានជួយកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋ ជាមួយរាជរដ្ឋាភិបាលកម្ពុជា៕

## ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៨

## រដ្ឋបាលខេត្តព្រះសីហនុផ្សព្វផ្សាយប្រកាសអន្តរក្រសួងលេខ៧១៩ប្រក ស្តីពីការពង្រឹងការធ្វើអធិការកិច្ចហត្ថពលកម្មបរទេសនៅកម្ពុជា

http://www.akp.gov.kh/ AKP ព្រះសីហនុ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨

នៅសាលាខេត្តព្រះសីហនុនាព្រឹកថ្ងៃព្រហស្បតិ៍១៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ រដ្ឋបាលខេត្តព្រះសីហនុ បានធ្វើការផ្សព្វ ផ្សាយប្រកាសអន្តរក្រសួងលេខ៧១៩ប្រក ស្តីពីការពង្រឹងការធ្វើអធិការកិច្ចហត្ថពលកម្ម បរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសេចក្តីជូនដំណឹងលេខ១៨៨ សជណ .អអ របស់រាជរដ្ឋាភិបាល ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក យុន សំបូរ អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ លោក ជា វិជ្ជៈ អភិបាលរងខេត្តព្រះសីហនុ ដោយមានការចូលរួមពីអគ្គនាយក រោងចក្រ សហគ្រាស សិប្បកម្ម កាស៊ីណូ ក្លឹបកម្សាន្ត និងអាជីវកម្មតាមOnline។

លោក ជា វិជ្ជៈ អភិបាលរងខេត្តព្រះសីហនុ មានប្រសាសន៍ថា រដ្ឋបាលខេត្តបានផ្សព្វផ្សាយប្រកាសអន្តរក្រសួងលេខ៧១៩ប្រក ស្តីពីកាតព្វកិច្ចរបស់ ជនបរទេស ក្នុងការធ្វើអធិការកិច្ចហត្ថពលកម្មបរទេស ក្នុងព្រះរាជាណាចក្រកម្ពុជា និងសេចក្តីជូនដំណឹង ស្តីពីកាតព្វកិច្ចដល់ម្ចាស់រោងចក្រ សហគ្រាស ក្លឹបកម្សាន្ត កាស៊ីណូ អាជីវកម្មតាមប្រព័ន្ធ Online អាជីវកម្មពេលរាត្រី និងជនបរទេសដែលមកវិនិយោគ ឬប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងប្រើប្រាស់ពលករបរទេស និងជនបរទេសមិនបានបំពេញកាតព្វកិច្ចធ្វើប័ណ្ណ សៀវភៅការងារឱ្យបានគ្រប់គ្នា។ រាជរដ្ឋាភិបាលកម្ពុជា បានដាក់បញ្ចូលខេត្តព្រះសីហនុ ក្នុងគោលនយោបាយ ថ្នាក់ជាតិ ជាតំបន់សេដ្ឋកិច្ចគំរូពហុបំណង

តែមួយគត់ ក្នុងប្រទេសកម្ពុជា ផ្តោតលើសេដ្ឋកិច្ច កសិកម្ម វប្បធម៌ ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ដែលមានតំបន់សេដ្ឋកិច្ចចំនួន៤ មានរោងចក្រ សហគ្រាស ៧១១ ដោយឡែករោងចក្រមានជាង១០០ សណ្ឋាគារ ៧៣ ផ្ទះសំណាក់ ៣៦៦ ភោជនីយដ្ឋាន អាហារដ្ឋាន ២៥៤។ មានជនបរទេសប្រកបមុខ របរយៈពេលវែង និងខ្លីមានជាង ២ម៉ឺននាក់ ក្នុងឆ្នាំ២០១៦ សុំសៀវ ភៅការងារជិត៥,០០០នាក់ ម្យ៉ាងទៀតដោយសារតែលំហូរភ្ញៀវទេសចរតាមច្រក ព្រលានយន្តហោះអន្តរជាតិកងកេងខេត្តព្រះសីហនុ ព្រលានយន្តហោះអន្តរជាតិភ្នំពេ និងសៀមរាប ដែលមានជនបរទេសជាច្រើន មិនបានទាន់បំពេញកាតព្វកិច្ច សុំសៀវភៅការងារ ឬប័ណ្ណការងារតាមផ្លូវច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តមឧត្តមសេនីយ៍ឯក យុន សំបូរ អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រ វេសន៍ មានប្រសាសន៍ថា ដោយអនុវត្តន៍តាមយន្តការច្បាប់ ផ្សព្វផ្សាយដល់ហត្ថពលកម្មបរទេស ដើម្បីជំរុញឱ្យជនបរទេសធ្វើសៀវភៅការងារ ប័ណ្ណការងារ តាមទិដ្ឋភាពច្បាប់ ស្តីពីការពង្រឹងអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា ម្ចាស់សហគ្រាស គ្រឹះស្ថាន និងបរទេសមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាពុំទាន់អនុវត្តន៍ កាតព្វកិច្ច ឬបន្តគេចវេះប្រើប្រាស់ពលករបរទេសដោយពុំបានបំពេញកាតព្វកិច្ចធ្វើសៀវភៅការងារ ដូច្នេះត្រូវរួសរាន់បំពេញបែបបទបង់អាករប័ណ្ណ សៀវភៅការងារក្នុងរយៈពេល ៣០ថ្ងៃ អធិការកិច្ចហត្ថពលកម្មបរទេស និងចុះត្រួតពិនិត្យតាមដានតាមបណ្តាសហគ្រាស ការដ្ឋានសំណង់ កាស៊ីណូ ក្លឹបកម្សាន្តនានា អាជីវកម្មរណប អាជីវកម្មតាមអនឡាញ អាជីវកម្មពេលរាត្រី អាជីវកម្មលើផ្ទៃទឹក និងអាជីវកម្មផ្សេងៗទៀតនឹងត្រូវធ្វើការផ្តន្ទាទោសតាមបញ្ញត្តិជំពូក១៦ នៃច្បាប់ស្តីពីការងារ។ បច្ចុប្បន្នជនបរទេសចូលកម្ពុជាមាន ២ប្រភេទ គឺ ជនបរទេសតំណាងស្ថានទូត និងជនបរទេសអន្តោប្រវេសន៍ សរុបប្រហែល ៥,៦ សែននាក់។

ឯកឧត្តម ឧត្តមសេនីយ៍ឯក យុន សំបូរ បន្តថា ការចុះពង្រឹងអធិការកិច្ច ហត្ថពលកម្មនៅខេត្តព្រះសីហនុគឺ៖ ១. ជនបរទេសត្រូវ មានលិខិតឆ្លងដែនមានសុពលភាព, ២.មានទិដ្ឋាការសម្រាប់ធ្វើការងារ តាមគោលការណ៍ច្បាប់, ៣. ត្រូវមានសៀវភៅការងារ ប័ណ្ណការងារត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ស្តីពីការងារ, ៤. បណ្តាក្រុមហ៊ុន សហគ្រាស រោងចក្រ កាស៊ីណូ សិប្បកម្ម ប្រកបអាជីវកម្ម ឈប់ទទួលយកពលករបរទេសដែលមិនស្របច្បាប់ មកបម្រើការងារបន្តទៀត។ ឯកឧត្តម ឧត្តមសេនីយ៍ឯក យុន សំបូរ បានផ្តាំផ្ញើឱ្យអគ្គនាយកក្រុមហ៊ុន តំណាងក្រុមហ៊ុន ឬពលករត្រូវស្វែងរកសៀវភៅការងារ ប័ណ្ណការងារឱ្យបានគ្រប់គ្នា នៅពេលខាងមុខ៕ ដោយ ង៉ូ សុមុនី

## រាជរដ្ឋាភិបាលកម្ពុជាបានឯកភាពនឹងបញ្ជូនពលការិនីកម្ពុជាទៅធ្វើការនៅប្រទេសម៉ាឡេស៊ី

http://www.akp.gov.kh/ AKP ភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨

ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ថា ពេលនេះរាជរដ្ឋាភិបាលកម្ពុជាបានឯកភាពសារជាថ្មីជាមួយភាគីម៉ាឡេស៊ី ក្នុងការបញ្ជូនពលការិនីពីកម្ពុជា ដែលនឹងចាប់ផ្តើមពីខែឧសភា ឆ្នាំ២០១៨នេះតទៅ បន្ទាប់ពីត្រូវបានផ្អាកអស់រយៈពេលជាង ៧ឆ្នាំរួចមកនោះ។ ឯកឧត្តម អ៊ិត សំហេង មានប្រសាសន៍បែបនេះ ក្នុងឱកាសបិទវគ្គបណ្តុះបណ្តាល គ្រូបង្គោល បង្ហាត់ បង្រៀនពលការិនី មុននឹងចាកចេញដំណើរទៅបំពេញការងារនៅប្រទេសម៉ាឡេស៊ីដែលបានធ្វើឡើងនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលតម្រង់ទិសរបស់ក្រុមហ៊ុនហ្វូមីស (FOMIS) ម៉ូឌែន៥ ឬស្សីកែវ កាលពីរសៀលថ្ងៃព្រហស្បតិ៍ ១៤រោច ខែផល្គុន ឆ្នាំរកា នព្វស័កព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ ។ ឯកឧត្តម បានបញ្ជាក់ថា ក្រោមកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា ដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រទេសម៉ាឡេស៊ី ដែលមានក្រសួងធនធានមនុស្ស គឺបានចុះកិច្ចព្រមព្រៀងសារជាថ្មី កាលពីដើមខែកុម្ភៈ ឆ្នាំ២០១៨ ក្នុងការទទួលយកពលការិនី

កម្ពុជាសារជាថ្មី ដោយឈរលើយន្តការ MOU តាមលក្ខខណ្ឌ សមស្របស័ក្តិសមនឹងទទួលយកបាន ទាំងពីរភាគី ជាពិសេសមានលក្ខខណ្ឌក្នុងការលើកលែងច្រើនដល់ពលការិនី ។

ឯកឧត្តមបន្តថា ដើម្បីពង្រឹងសមត្ថភាព និងចំណេះដឹងមួយចំនួនដល់ពលការនីកម្ពុជាក្រសួងនៃភាគីប្រទេសទាំងពីរ បានសម្រេចផ្តល់លក្ខខណ្ឌនៃការបញ្ជូនពលការិនី គឺពួកគាត់ត្រូវទទួលយកវគ្គបណ្តុះបណ្តាលតម្រង់ទិសចំនួន ៨ថ្ងៃយ៉ាងតិចជាមុនសិន ។ ឯកឧត្តម អូស្មាន ហាស្សាន់ បានឱ្យដឹងដែរថា សម្រាប់ពេលនេះមានតែក្រុមហ៊ុនហ្វូមីស (FOMIS) តែមួយគត់ដែលទទួលសិទ្ធិស្របច្បាប់ ពីនាយកដ្ឋានអភិវឌ្ឍន៍ជំនាញ នៃក្រសួងធនធានមនុស្សរបស់ម៉ាឡេស៊ី ដើម្បីទទួលរ៉ាប់រងការងារ ក្នុងការផ្តល់វគ្គបណ្តុះបណ្តាល រាល់ពលការិនីដែលត្រៀមចេញដំណើរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី បើទោះបីមានក្រុមហ៊ុនជាច្រើនបានដាក់ពាក្យស្នើសុំមកក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ កម្ពុជាយ៉ាងណាដោយ ។ ឯកឧត្តមបានផ្តាំផ្ញើដល់សិក្ខាកាម ជាគ្រូបង្គោលទាំង២៤រូប ត្រូវខិតខំអភិវឌ្ឍន៍ជំនាញរបស់ខ្លួន និងត្រូវយកទៅអនុវត្តន៍ឱ្យបានល្អប្រសើរ ដើម្បីអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស ទាំងខ្លួនឯង និងពលការិនីកម្ពុជា រក្សាប្រពៃណី វប្បធម៌ខ្មែរ និងតម្លៃខ្លួនឯងផងដែរ ។

សូមបញ្ជាក់ថា នេះគឺជាវគ្គបណ្តុះបណ្តាលដំបូងគេ បន្ទាប់ពីប្រទេសទាំងពីរកម្ពុជា-ម៉ាឡេស៊ីបានចុះ MOU ស្តីពីការបញ្ជូនពលករកម្ពុជាទៅបម្រើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ី កាលពីឆ្នាំ២០១៥ ហើយបានព្រមព្រៀងគ្នាអនុវត្តន៍ MOUនេះកាលពីដើមខែកុម្ភៈ ឆ្នាំ២០១៨កន្លងទៅ ។ រាជរដ្ឋាភិបាលកម្ពុជា នឹងចាប់ផ្តើមបញ្ជូនពលករខ្មែរ ផ្នែកជំនួយការមេផ្ទះ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី សារជាថ្មីម្តងទៀត នៅខែឧសភា ឆ្នាំ២០១៨ ខាងមុខនេះ ក្រោយយន្តការនេះត្រូវបានផ្អាកអស់រយៈពេល៧ឆ្នាំកន្លងមក ពោលគឺចាប់តាំងពីឆ្នាំ២០១១ ៕ ដោយសួស សំរិត

## ភ្នាក់ងារជ្រើសពលករ សន្យាលើកកម្ពស់ក្រមសីលធម៌

http://www.postkhmer.com/ Daphne Chen | Publication date 16 March 2018 | 10:37 ICT

ភ្នំពេញៈ កាលពីថ្ងៃព្រហស្បតិ៍សមាគមទីភ្នាក់ងារជ្រើសរើសពលករចំណាស់ជាងគេបំផុតមួយនៅកម្ពុជាបានសន្យាថា នឹងលើកកម្ពស់ការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌ដែលនេះជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីកាត់បន្ថយការរំលោភបំពាន និងកេងប្រវ័ញ្ចដែលពលករចំណាកស្រុកកម្ពុជាតែងតែជួបប្រទះ។ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA) បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាមួយជាមួយអង្គការក្រៅរដ្ឋាភិបាលដែលគាំទ្រផ្នែកច្បាប់សម្រាប់ស្ត្រី និងកុមារដើម្បីពង្រឹងកិច្ចសហការគ្នានឹងផ្តោតទៅលើការលើកកម្ពស់ការបណ្តុះបណ្តាលមុនពេលពលករចេញដំណើរ និងលើកទឹកចិត្តពលករឱ្យធ្វើដំណើរទៅស្របតាមផ្លូវច្បាប់។ លោកស្រីប្រធានសមាគម ACRA និងជាឧកញ៉ា អ៊ុង សៀងរិទ្ធី បានថ្លែងថា៖ «ប្រសិនបើពួកគេទៅបរទេសតាមរយៈក្រុមហ៊ុនស្របច្បាប់នោះពួកគេនឹងមិនមានបញ្ហានោះទេ។ ប៉ុន្តែពលកររបស់យើងធ្វើអ្វីមួយឆាប់ហ័សពេក។ ពួកគេគិតថ្ងៃនេះនៅថ្ងៃស្អែកពួកគេចេញទៅក្រៅប្រទេស ហើយមិនបានគិតឲ្យបានល្អិតល្អន់ទេ ពួកគេធ្វើចំណាកស្រុកដោយខុសច្បាប់ ដូច្នេះហើយត្រូវប្រឈមនឹងបញ្ហាជាច្រើនដូចជាការកេងប្រវ័ញ្ចពីឈ្មួញកណ្តាល ឬទៅធ្វើការដោយគ្មានទិដ្ឋាការការងារ ឬគ្មានទម្រង់បែបបទផ្សេងៗជាដើម»។ គម្រោងនេះផ្តោតសំខាន់ទៅលើពលករចំណាកស្រុកនៅប្រទេសថៃដែលត្រូវបានផ្តល់មូលនិធិដោយទីភ្នាក់ងារ USAID និងអនុវត្តដោយអង្គការ Winrock International។

ពលករចំណាកស្រុកកម្ពុជានៅតែប្រឈមនឹងហានិភ័យខ្ពស់ពីការរំលោភបំពាន និងកេងប្រវ័ញ្ច។ ហើយបើយោងតាមការសិក្សាមួយពីអង្គការពលកម្មអន្តរជាតិ ILO និងអង្គការ IOM កាលពីឆ្នាំមុនបានរកឃើញថាពលករចំណាកស្រុកកម្ពុជា ៨ នាក់ក្នុងចំណោម ១០ នាក់បានរងការរំលោភសិទ្ធិការងារ។ ទោះបីយ៉ាងនេះក្តីរដ្ឋាភិបាលបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបញ្ជូនពលករកម្ពុជាទៅក្រៅប្រទេសក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះហើយថ្មីៗ

នេះមានពលករមួយចំនួនត្រូវបានបញ្ជូនទៅកាន់ទីក្រុងហុងកុង និងប្រទេសម៉ាឡេស៊ីហើយគ្រោងនឹងបញ្ជូនបន្ថែមទៀតទៅកាន់ប្រទេស កាតា អារ៉ាប៊ីសាអ៊ូឌីត និងប្រទេសជប៉ុន។

នៅក្នុងសុន្ទរកថាបើកសិក្ខាសាលារយៈពេល ២ ថ្ងៃស្ដីពីក្រមសីលធម៌នៃការជ្រើសរើសពលករនេះលោក ហ៊ូ វុទ្ធី អនុរដ្ឋលេខាធិការក្រសួងការងារបានទទួលស្គាល់អំពីហានិភ័យនេះ ប៉ុន្តែលោកបាននិយាយថារដ្ឋាភិបាលមិនអាចធានាសុវត្ថិភាពពលករចំណាកស្រុកតែម្នាក់ឯងបានទេ។ លោក វុទ្ធី មានប្រសាសន៍ថា៖ «រដ្ឋាភិបាលត្រូវការការគាំទ្រពីវិស័យឯកជន និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត។ ដូច្នេះហើយវិស័យឯកជនត្រូវតែពង្រឹងការងាររបស់ពួកគេ»។

លោក Dy The Hoya មន្ត្រីអង្គការការពារសិទ្ធិការងារបានយល់ស្របថាវគ្គបណ្ដុះបណ្ដាលពលករមុនពេលចេញដំណើរទៅធ្វើការក្រៅប្រទេសត្រូវការកែលម្អបន្ថែម ហើយលោកបានអំពាវនាវឱ្យរដ្ឋាភិបាលផ្ដោតលើការពង្រឹងការតាមដានពលករ និងត្រូវដាក់ទណ្ឌកម្មទៅលើទីភ្នាក់ងារជ្រើសរើសពលករ និងនិយោជកដែលគ្មានក្រមសីលធម៌។ លោកថា៖ «ខ្ញុំមិនគិតថាវាអាចលុបបំបាត់ការរំលោភបំពានបានដោយគ្រាន់តែផ្ដល់ការបណ្ដុះបណ្ដាល មុនពេលពួកគេចាកចេញនោះទេ។ ពួកគេត្រូវតែបង្កើតប្រព័ន្ធការពារដ៏មានប្រសិទ្ធភាពមួយសម្រាប់ការពារពលករហើយការអនុវត្តក៏ត្រូវតែមានប្រសិទ្ធភាពផងដែរ »។

ក្រុមអ្នកស្រាវជ្រាវក៏បានរកឃើញថា កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យពលករចំណាកស្រុកទៅធ្វើការស្របច្បាប់ត្រូវបានរាំងដោយការចំណាយខ្ពស់។ លោក បាន ប៉ាន់ប្រមាណថាដំណើរការជ្រើសរើសពលករឲ្យបានការងារធ្វើស្របច្បាប់នៅក្នុងប្រទេសថៃគឺមានតម្លៃចន្លោះពី ៦០០ ទៅ ៨០០ ដុល្លារ។ របាយការណ៍មួយដែលចេញផ្សាយកាលពីថ្ងៃអង្គារបានបង្ហាញថាក្រសួងបានរកឃើញថាមានពលករចំណាកស្រុកខ្មែរតែចំនួន ៩៦ ពាន់នាក់ប៉ុណ្ណោះដែលទៅធ្វើការតាមរយៈភ្នាក់ងារជ្រើសរើសពលករឯកជន៕ NS/រាយការណ៍បន្ថែមដោយ នៀម ឆេង

## ប្រព័ន្ធស្បៀងបម្រុងកម្ពុជា កំពុងខិតខំជួយកសិករ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក

http://bayontv.com.kh/ 16/03/2018

សៀមរាប ៖ ការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ជាពិសេស ប្រទេសថៃ គឺជាទម្លាប់ ដែលពិបាកនឹងកែប្រែ របស់ប្រជាកសិករខ្មែរ នៅតាមបណ្ដាខេត្តជាប់ព្រំប្រទល់ដែនប្រទេសថៃ ដែលអ្នកខ្លះទៅដោយស្របច្បាប់និងមួយចំនួនទៀតទៅដោយខុសច្បាប់ដែលវាបានធ្វើឲ្យពួកគេប្រឈមនិងហានិភ័យ។ ប្រព័ន្ធស្បៀងបម្រុងកម្ពុជាបាននឹងកំពុងខិតខំជួយដល់កសិករខ្មែរ តាមរយៈការធ្វើសកម្មភាពផ្គត់ផ្គង់ គ្រាប់ពូជបន្លែ និងដំណាំរួមផ្សំផ្សេងៗ ដោយឥតគិតថ្លៃ ដល់កសិករធ្វើស្រែ គឺជាការចូលរួមកាត់បន្ថយស្ថានភាព នៃការធ្វើចំណាកស្រុកដោយខុសច្បាប់ របស់ប្រជាកសិករជនបទ ដោយសារតែពួកគេអាចរកចំណូលគ្រួសារ បន្ថែមទៀត តាមរយៈនៃការដាំដុះបង្កបង្កើនផល។

កាលពីថ្ងៃទី១៥ ខែមីនា ម្សិលមិញ ក្នុងខេត្តសៀមរាប ប្រព័ន្ធស្បៀងបម្រុងកម្ពុជា បានផ្សព្វផ្សាយ ស្ដីពីការផ្គត់ផ្គង់គ្រាប់ពូជបន្លែ និងដំណាំរួមផ្សំផ្សេងៗ ដោយឥតគិតថ្លៃដល់កសិករធ្វើស្រែ ទៅកាន់អាជ្ញាធរមូលដ្ឋានស្រុក/ក្រុង ដើម្បីបន្ត ផ្សព្វផ្សាយបំផុសទៅដល់ប្រជាកសិករធ្វើស្រែ ដែលមានតម្រូវការដាំដុះដំណាំបន្លែ បានយល់ជ្រាប គឺជាប្រយោជន៍ដល់ការគាំទ្រប្រជាកសិករទាំងនោះ បានអនុវត្តការដាំដំណាំរួមផ្សំផ្សេងៗ ទទួលបានទិន្នផលល្អ កែប្រែជីវភាពរស់នៅកាន់តែប្រសើរឡើង។

ឯកឧត្តម វង់ សណ្ដាប់ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រព័ន្ធស្បៀងបម្រុងកម្ពុជា បានបញ្ជាក់ថា កម្មវិធីនេះ នឹងជាការរួមចំណែកដោះស្រាយបញ្ហាប្រឈម ស្ថានភាពខ្វះខាតរបស់ប្រជាកសិករ ដោយការយាយីពីគ្រោះធម្មជាតិ មានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ជាដើមផង។ ឯកឧត្តម បានបញ្ជាក់ទៀតថា ប្រព័ន្ធស្បៀងបម្រុងកម្ពុជា មានគោលការណ៍ផ្ដល់គ្រាប់ពូជបន្លែ និងដំណាំ រួមផ្សំដោយឥតគិតថ្លៃ រួមមាន ទី១. ការប៉ាន់ស្មានចំនួនកសិករត្រូវទទួលដោយផ្អែកទៅលើបញ្ជីឈ្មោះ ដែលត្រូវ បានផ្ដល់ឲ្យដោយឃុំ/សង្កាត់

ទី២. ផ្តល់ជូនកសិករធ្វើស្រែ ដែលមានតម្រូវការដាំដុះបន្លែ និងដំណាំរួមផ្សំបន្ថែម ទី៣. ផ្តល់ជូនគ្រាប់ពូជបន្លែ និងដំណាំរួមផ្សំ ចំនួន២មុខ ក្នុងគ្រួសារនីមួយៗ ទី៤. ការផ្តល់គ្រាប់ពូជបន្លែ និងដំណាំរួមផ្សំ ផ្អែកទៅតាមចំនួនប្រជាជនដែលមានវត្តមានជាក់ស្តែង (មិនមានការចែកជូនជាបញ្ញើនោះទេ)។ មុខគ្រាប់ពូជបន្លែ និងដំណាំរួមផ្សំទាំងនោះ រួមមាន ពោតដំណើប១កញ្ចប់ ៥០០ក្រាម ពោតផ្អែម១កញ្ចប់ ៥០០ក្រាម ល្ពៅ ១កញ្ចប់ ២៥ក្រាម ស្ពៃចង្កឹះ ១កញ្ចប់ ១០ក្រាម សាលាដ់ ១កញ្ចប់ ២៥ក្រាម ត្រកួន ១កញ្ចប់ ៥០ក្រាម សណ្តែកកួរ ១កញ្ចប់ ៥០ក្រាម និងត្រសក់ ១កញ្ចប់ ១០ក្រាម៕

## កម្ពុជាស្នើកូរ៉េខាងត្បូង បន្ថែមជំនាញសេវាកម្ម សម្រាប់ពលករខ្មែរ

https://www.dap-news.com/kh/ សុក្រ, ១៦ មិនា ២០១៨ 12:33 ដោយ: ស សំណាង ID:014

ភ្នំពេញ៖ រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើដល់កូរ៉េឲ្យបន្ថែម ជំនាញសេវាកម្មសម្រាប់ពលករកម្ពុជា ដើម្បីបញ្ជូនពលករ ដែលមានជំនាញសេវាកម្ម ទៅធ្វើការនៅប្រទេសកូរ៉េបន្ថែមទៀត។ ការស្នើសុំរបស់លោក អ៊ិត សំហេង រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើឡើងនៅក្នុងឱកាស អនុញ្ញាតឲ្យលោក អូ ណាត់យ៉ុង អគ្គរដ្ឋទូតសាធារណៈរដ្ឋកូរ៉េថ្មីប្រចាំកម្ពុជា ចូលជួបពិភាក្សាការងារនៅថ្ងៃទី១៦ ខែមីនា នាទីស្តីការក្រសួង។

លោក អ៊ិត សំហេង បានមានប្រសាសន៍ថា កូរ៉េមានកិច្ចសហប្រត្តិបត្តិការ អំពីប្រព័ន្ធអនាម័យ សុវត្ថិភាពការងារ ដែលភាគីកូរ៉េកន្លងមកនេះ តែងផ្តល់ការគាំទ្រ ខាងផ្នែកបច្ចេកទេស មកដល់ពេទ្យ ការងារ និងការអប់រំផ្សព្វផ្សាយអំពីប្រព័ន្ធអនាម័យ សុវត្ថិភាពការងារ ការបណ្តុះបណ្តាល សមត្ថភាពបច្ចេកទេស និងការផ្តល់ឧបករណ៍បច្ចេកទេស សម្រាប់ការពិនិត្យស្ថានភាព សុវត្ថិភាពការងារ នៅតាមសហគ្រាសជាដើម ។ ហើយម៉្យាងវិញទៀត ប្រទេសទាំងពីរនឹងបន្តពង្រីក កិច្ចសហប្រតិបត្តិការថែមទៀត ក្នុងនោះមា នផ្នែករបបសន្តិសុខសង្គម គ្រាដែលកន្លងមកកូរ៉េក៏ធ្លាប់បាន ផ្តល់ជំនួយនេះដែរ បន្ទាប់ពីដាក់ឲ្យដំណើរការ លើផ្នែកហានិភ័យការងារ។ លោកបានបន្តថា កន្លងមក ភាគីកូរ៉េ ក៏បានផ្តល់ជាវគ្គបណ្តុះបណ្តាលមន្រ្តី ប.ស.ស នៅកូរ៉េដើម្បីផ្លាស់ប្តូរ បទពិសោធន៍អំពីដំណាក់កាល របបសន្តិសុខសង្គម ដោយនិរន្តរភាព សុវត្ថិភាព ដោយប្រសិទ្ធិភាព ហើយផ្នែកនេះ ក៏នឹងបន្តពង្រីក កិច្ចសហប្រតិបត្តិកា រថែមទៀតផងដែរ។

ក្នុងជំនួបនេះ ប្រទេសទាំងពីរក៏បានពិភាក្សាទៅលើ គ ម្រោងនៃការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលកម្ពុជា បានស្នើគម្រោងនេះ ទៅដល់កូតាកូរ៉េ នៅកម្ពុជា ដើម្បីជួយកូតាបន្ថែមទៀត ទៅលើការអភិវឌ្ឍវិស័យបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាមួយក្រសួងការងារ។ ជាមួយគ្នានោះដែរ លោករដ្ឋមន្រ្តី ក៏បានឲ្យដឹងថា "នៅឆ្នាំនេះ(២០១៨) កូរ៉េនឹងផ្តល់កូតាចំ នួនប្រមាណជាង ៤ពាន់កូតា សម្រាប់ពលករខ្មែរទៅ ធ្វើការនៅទីនោះ ប៉ុន្តែរឿងសំខាន់យើងត្រូវប្រើប្រាស់ ឲ្យអស់នូវកូតា ដែលមានជារៀងរាល់ឆ្នាំ។ កម្ពុជាបានស្នើដល់កូរ៉េ លើជំនាញសេវាកម្ម ខណៈ បច្ចុប្បន្ន កូរ៉េមានតែជំនាញឧស្សាហកម្ម និងកសិកម្ម"។

ជាការឆ្លើយតប លោក អូ ណាត់យ៉ុង អគ្គរដ្ឋទូតសាធារ ណៈរដ្ឋកូរ៉េថ្មីប្រចាំកម្ពុជា បានឲ្យដឹងថា បញ្ហានេះ កូរ៉េកំពុងពិចារណា ទៅលើការស្នើសុំលើសេវាកម្មកូរ៉េ ទៅរដ្ឋាភិបាលសារធាណៈរដ្ឋកូរ៉េ។ លោកបន្តថា បច្ចុប្បន្នមានពលករខ្មែរ កំពុងធ្វើការនៅកូរ៉េ មានប្រមាណជាង៥ពាន់នាក់។ លោកបានបញ្ជាក់ថា ចំនួនប្រទេស ដែលទទួលបាន អ៊ីភីអេស (EPS) ប្រព័ន្ធអនុគ្រោះពេលនេះ កើនឡើងប្រទេសមួយ ដោយកូរ៉េបានកាត់កូតាពី ក្នុងប្រទេសចាស់ៗ ដើម្បីថែមទៅឲ្យប្រទេសថ្មី ប៉ុន្តែបញ្ហានេះ គឺមិនមានប៉ះពាល់ដល់កម្ពុជានោះទេ៕

## ប្រទេសកូរ៉េទទួលយកពលករខ្មែរប្រមាណជាង៤ពាន់នៅឆ្នាំនេះ

http://bayontv.com.kh/ 16/03/2018

ភ្នំពេញ ៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា នៅឆ្នាំ២០១៨នេះ កូរ៉េនឹងផ្តល់កូតាចំនួនប្រមាណ ជាង៤ពាន់នាក់ សម្រាប់ពលករខ្មែរទៅធ្វើការនៅប្រទេសនេះ ដែលចំនួននេះគឺមានចំនួនប្រហាក់ប្រហែលនឹងឆ្នាំមុនផងដែរ។

នៅក្រោយជំនួបពិភាក្សាការងារ ជាមួយឯកឧត្តម អ៊ូណាក់ យ៉ុង (OH NAK-YOUNG) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា នាព្រឹកថ្ងៃទី១៦ មិនានេះ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានមានប្រសាសន៍ប្រាប់ដល់អ្នកសារព័ត៌មានថា ទាក់ទងនឹងចំនួនកូតាជាង៤ពាន់នេះ ភាគីកូរ៉េបានឲ្យដឹងថា ចំនួនប្រទេសដែលទទួលបានប្រព័ន្ធអនុគ្រោះ (PPS) នាពេលនេះបានកើនឡើងប្រទេសមួយថែមទៀត ដូច្នេះភាគីកូរ៉េ នឹងកាត់កូតាពីក្នុងប្រទេសចាស់ៗ ដើម្បីបន្ថែមកូតាដល់ពលករទៅឲ្យប្រទេសថ្មី ប៉ុន្តែបញ្ហានេះក៏មិនប៉ះពាល់មកដល់កម្ពុជានោះទេ។ ឯកឧត្តម រដ្ឋមន្ត្រីលើកឡើងថា កម្ពុជាបានស្នើកូរ៉េជួយលើជំនាញសេវាកម្មបន្ថែមពីលើជំនាញបច្ចុប្បន្ន គឺជំនាញឧស្សាហកម្ម និងកសិកម្ម។ ហើយបញ្ហានេះ ភាគីកូរ៉េសុំពេលពិចារណាផងដែរ ខណៈដែលនៅប្រទេសកូរ៉េមិនទាន់បានគិតលើជំនាញនេះនៅឡើយ។

ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានបញ្ជាក់ឲ្យដឹងផងដែរថា កិច្ចពិភាក្សានេះ បានផ្តោតទៅលើកិច្ចសហប្រតិបត្តិការ លើវិស័យការងារ និងការផ្តល់ឱកាសឲ្យបងប្អូនពលករកម្ពុជាទៅធ្វើការនៅកូរ៉េ ដែលក្នុងកិច្ចសហប្រតិបត្តិការលើវិស័យការងារនេះ គឺមានច្រើនក្នុងនោះ រួមមាន ផ្នែកអនាម័យ និងសុវត្ថិភាពការងារ ដែលកន្លងមកភាគីកូរ៉េ តែងបានផ្តល់នូវការគាំទ្រខាងផ្នែកបច្ចេកទេសដល់ពេទ្យការងារ ដើម្បីអប់រំផ្សព្វផ្សាយអំពីប្រព័ន្ធអនាម័យ សុវត្ថិភាពការងារ ការបណ្តុះបណ្តាលសមត្ថភាពបច្ចេកទេស និងការផ្តល់ឧបករណ៍បច្ចេកទេស សម្រាប់ការពិនិត្យស្ថានភាពសុវត្ថិភាពការងារ នៅតាមសហគ្រាសជាដើម ។ គិតមកទល់ពេលនេះពលករខ្មែរ ដែលបាន និងកំពុងធ្វើការ នៅសាធារណរដ្ឋកូរ៉េ មានចំនួនសរុបជាង៥៤,០០០នាក់៕

## ទឹកភ្នែកទៀតហើយម្តងនេះចំពោះអ្នក(ត)ប័ត្រស៊ីជម្ពូមិនទាន់

http://www.pheaktraprak.com/ March 15, 2018

ក្នុងកិច្ចប្រជុំពិភាក្សាមួយរវាងក្រសួងការងារ និងក្រសួងការមហាផ្ទៃថៃ ស្តីពីការគ្រប់គ្រងសូន្យ OSSOne (StopService) កាលពីពេលថ្មីៗកន្លងទៅនេះ លោកអាឌុល សែងសិងកែវ រដ្ឋមន្ត្រីក្រសួងការងារថៃ បានមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មានក្នុងស្រុកថៃ អោយបានដឹងថា ក្រសួងការងារថៃ និងមិនបន្ថែមរយៈពេលធ្វើត្បៀតប្រវត្តិហៅថា(តប័ត្រស៊ីជម្ពូ)អោយពលករបរទេសតទៅទៀតឡើយ ទោះបីជារយៈពេលដំណើរការ(ត)ប័ត្រស៊ីជម្ពូនិងវីសារការងារជូបពលករបរទេសនៅសល់ត្រឹមតែពីរសប្តាហ៍ទៀតប៉ុណ្ណោះក៏ដោយ។ ដោយលោកលើកឡើងថា នេះបច្ចុប្បន្ននេះក្រសួងការងារបានធ្វើត្បៀតប្រវត្តិ(តប័ត្រស៊ីជម្ពូ)ពលករបរទេសរួចហើយប្រមាណជាង ៦សែននាក់ហើយ ហើយនៅសល់តែ 1លានទៀតប៉ុណ្ណោះដែលកំពុងដំណើរការដោយក្រសួងការងារបានចែកសំណុំបែបបទចូលទៅសូន្យOSS ដល់ថៅកែថៃនិងសហគ្រាសមួយចំនួនទៀតដើម្បីបំពេញសុំណុំបែបបទចូលសូន្យអោយមានភាពឆាប់រហ័ស និងងាយស្រួល។

លោករដ្ឋមន្ត្រីអាឌុល សែងសិងកែវ បានបញ្ជាក់បន្ថែមផងដែរថា បច្ចុប្បន្ននេះមានពលករដែលត្រូវចូលសូន្យ OSS គឺមានចំនួនពីរក្រុមគឺទីមួយក្រុមដែលបានត្រួតសញ្ជាតិរួចរាល់ហើយនៅសល់ប្រមាណ5សែននាក់ ត្រូវដំណើរការទៅត្រួតសុខភាពនិងស្នើសុំវីសារធ្វើការអោយបានចប់សព្វគ្រប់នៅថ្ងៃទី31 ខែមីនា ឆ្នាំ2018នេះ និងក្រុមទីពីរក្រុមដែលមិនបានត្រួតសញ្ជាតិនៅសល់ប្រមាណជាង ៦សែននាក់ ត្រូវត្រូវដំណើរការធ្វើប័ត្រស៊ីជម្ពូ និងតប័ត្រស៊ីជម្ពូអោយចប់

សព្វគ្រប់នៅថ្ងៃទី31 ខែមីនាខាងនេះរួចបន្តត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅទីតាំងការិយាល័យផ្តល់ភាពស្របច្បាប់របស់ប្រទេសខ្លួនអោយរួចរាល់មុនថ្ងៃទី31 ខែមិថុនា ឆ្នាំ2018ដូចគ្នា។ ចំពោះពលករដែលបានត្រួតសញ្ជាតិរួចរាល់ហើយត្រូវទៅដំណើរការទៅសុំវីសារនិងបែអនុញ្ញាតធ្វើការពីឆ្នាំបានត្រឹមត្រូវបើមិនដូច្នេះទេនិងត្រូវមានទោសតាមផ្លូវច្បាប់។ ដកស្រង់ព័ត៌មានពី :matichon.co.th

## ពលករខ្មែររាប់រយនាក់ឈរតម្រង់ជួរហាលថ្ងៃរងចាំតប័ត្រស៊ីជម្ពូនិងធ្វើវីសារពីរឆ្នាំ

http://www.pheaktraprak.com/ March 15, 2018

គួរអោយអាណិតខ្លាំងណាស់ពលករខ្មែរធ្វើការនៅប្រទេសថៃ រាប់រយនាក់កំពុងនាំគ្នាឈរតម្រង់ជួរហាលថ្ងៃព្រោះរងចាំចូលទៅតប័ត្រស៊ីជម្ពូ និងវីសារពីរឆ្នាំនៅទីតាំងសូន្យវ៉ាន់ស្តប់សីរីតនៅក្នុងប្រទេសថៃ។ នេះជាទិដ្ឋភាពហេតុការណ៍បងប្អូនពលករខ្មែរ,ភូមា, ឡាវ ដែលកំពុងឈរតម្រង់ជួរហាលថ្ងៃព្រោះរងចាំចូលទៅតប័ត្រស៊ីជម្ពូនិងធ្វើវីសារពីរឆ្នាំអោយបានត្រឹមត្រូវនៅសូន្យOSS នៅតាមបណ្តាលខេត្តមួយចំនួននៅក្នុងប្រទេសថៃ។

## រន្ធត់,កម្មករយ៉ាងហោចណាស់12នាក់បានរងរបួសនិងមនុស្ស15នាក់ទៀតបានបាត់ខ្លួននៅហេតុការណ៍បាក់អាគារនៅខេត្តត្រាត

http://www.pheaktraprak.com March 15, 2018

ពលករខ្មែរយ៉ាងហោចណាស់ចំនួន10នាក់បានរងរបួសធ្ងន់ និងស្រាលនៅហេតុការណ៍បាក់អាគារសូន្យអូថប់ខេត្តត្រាប្រទេសថៃកាលពីថ្ងៃព្រហស្បតិ៍នេះ ករណីនេះបានកើតឡើងកាលពីវេលាម៉ោង05:58នាទីល្ងាចថ្ងៃព្រហស្បតិ៍ទី15 ខែមីនា ឆ្នាំ2018 នៅត្រង់ចំណុចបរិវេណអាគារ(អបច)ត្រាតស្ថិតក្នុងសង្កាត់វ៉ាំងក្រះចៃក ស្រុកមឿង ខេត្តត្រាតប្រទេសថៃ។ យោងតាមប្រភពព័ត៌មានបឋមពីកន្លែងកើតហេតុបានឲ្យដឹងថាកម្មករធ្វើការសំណង់នៅទីនោះប្រមាណជាង 12នាក់ បានរងរបួសធ្ងន់និងស្រាល និងមានមនុស្សប្រមាណជាង15នាក់ទៀតកំពុងបាត់ខ្លួននៅក្នុងហេតុការណ៍បាក់អាគារសំណង់ខាងលើនេះ។ ក្រោយពេលកើតហេតុជនរងគ្រោះទាំង12នាក់ ត្រូវសមត្ថកិច្ចថៃបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តត្រាត។ ហើយរហូតមកដល់ពេលនេះកម្លាំងអាជ្ញាធរថៃចំនួនរាប់សិបនាក់កំពុងធ្វើការចុះអន្តរាគមន៍ជួយរុករកមនុស្សដែលកំពុងបាត់ខ្លួននៅក្នុងហេតុការណ៍នេះដើម្បីបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យ។ ក្នុងករណីគ្រោះថ្នាក់បាក់អាគារខាងលើនេះមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ កំពុងធ្វើការទំនាក់ទំនងជួយអន្តរាគមន៍ដល់ជនរងគ្រោះនៅក្នុងហេតុការណ៍នេះ។

## ព័ត៌មានលំអិតជុំវិញករណីបាក់អាគារនៅខេត្តត្រាតមនុស្សរងរបួសចំនួន15នាក់

http://www.pheaktraprak.com/ March 16, 2018

សរុបហេតុការណ៍ករណីគ្រោះថ្នាក់បាក់អាគារសំណង់នៅខេត្តត្រាតកាលពីល្ងាចថ្ងៃព្រហស្បតិ៍ទី15 ខែមីនា ឆ្នាំ2018 មានមនុស្សរងរបួសចំនួន 15នាក់ ក្នុងមានរងរបួសបាក់ដៃ និងជើងចំនួន03នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តត្រាតចំនួន12នាក់ សម្រាកព្យាបាលនៅមន្ទីរក្រុងថេបត្រាតចំនួន03នាក់ *ក្នុងករណីនេះមានពលករខ្មែររងគ្រោះថ្នាក់ចំនួន10នាក់ ហើយក្នុងនោះមានពលករចំនួន05នាក់ អាចវិលត្រឡប់ទៅកន្លែងស្នាក់នៅវិញបានព្រោះមិនបានរងរបួសធ្ងន់ធ្ងរនោះទេ។ បញ្ជាក់ក្នុងហេតុការណ៍គ្រោះថ្នាក់ខាងលើនេះមិនមនុស្សស្លាប់នោះទេមានត្រឹមតែរងរបួសប៉ុណ្ណោះ។

## ដំណឹងបន្ទាន់(ត)វីសារពីរឆ្នាំដោយមិនចាំបាច់ជួសឈាមនៅសូន្យOSS

http://www.pheaktraprak.com/ March 16, 2018

ដំណឹងល្អឥឡូវនេះបងប្អូនពលករខ្មែរអាចទៅ (ត) វីសារពីរឆ្នាំនៅសូន្យOSS ដោយមិនចាំបាច់ជួសឈាមបានហើយ។ ដំណឹងបន្ទាន់ក្រសួងការងារថៃអនុញ្ញាតឲ្យពលករខ្មែរ,ភូមា,ឡាវទៅធ្វើ(ត)វីសារពីរឆ្នាំនៅសូន្យOSSបានដោយ

មិនចាំបាច់ត្រួតសុខភាពដូចពេលមុនទៀតឡើយ។ ដូច្នេះសូមបងប្អូនពលករខ្មែរទាំងអស់ដែលមានលិខិតឆ្លងដែនធ្វើការនិងមានវីសារផុតកំណត់ថ្ងៃទី31 ខែមីនា ខាងនេះប្រញាប់រាសរាន់ឡើងនាំគ្នាទៅ(ត) វីសារពីរឆ្នាំនៅសូន្យOSS ដែលមានទីតាំងគ្រប់ខេត្តក្រុងទូទាំងប្រទេសថៃអោយចប់សព្វគ្រប់នៅថ្ងៃទី31 ខែមីនា ឆ្នាំ2018 តែប៉ុណ្ណោះ។

## ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៨
## ស្ត្រីខ្មែរ ៧នាក់ដែលចាញ់បោកមេខ្យល់ត្រូវបានស្ថានទូតកម្ពុជាជួយសង្គ្រោះនិងបញ្ជូនត្រឡប់មកកម្ពុជាវិញ

https://wmc.org.kh/ WMC ថ្ងៃចន្ទ ទី១៩ ខែមីនា ឆ្នាំ២០១៨ ជុំ ដោគជាតា

ភ្នំពេញ៖ស្ថានឯកអគ្គរាជទូតកម្ពុជាបានជួយសង្គ្រោះស្ត្រីខ្មែរ ៧ នាក់ ដែលចាញ់បោកមេខ្យល់នាំទៅរៀបការនិងធ្វើការដោយខុសច្បាប់នៅក្រៅប្រទេស ។ ស្ត្រីខ្មែរ ៧នាក់ដែលស្ថានទូតកម្ពុជាបានជួយស្រង្គោះមានមកពីប្រទេសម៉ាឡេស៊ី ប្រទេសវៀតណាម ប្រទេសចិន និងប្រទេសសឹង្ហបុរី។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសកម្ពុជា ។ នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសដែលចុះនៅថ្ងៃទី ៩ ខែមីនា ឆ្នាំ២០១៨ជដែលនេះ គឺបញ្ជាក់ថា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ីបានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ីដោះស្រាបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន ២នាក់ មកពីខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង ២នាក់នោះ បានមកដល់កម្ពុជាវិញ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៨។

ជាមួយនេះស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម បានសហការជាមួយអាជ្ញាធរវៀតណាម ជួយសង្គ្រោះស្ត្រីខ្មែរ ៣នាក់ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតបម្រុងនាំទៅរៀបការជាមួយបុរសជនជាតិចិន។ ស្ត្រី ២នាក់មកពីខេត្តត្បូងឃ្មុំ និងខេត្តតាកែវ បានធ្វើដំណើរចេញពីកម្ពុជាតាមរថយន្តទៅដល់ទីក្រុងហាណូយកាលពីថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៨ រួចបន្តដំណើរឆ្ពោះទៅព្រំដែនវៀតណាម – ចិន ប៉ុន្តែត្រូវបាននគរបាលប្រកទ្វារព្រំដែនខេត្តឡាងសឺនឃាត់ខ្លួន នៅថ្ងៃទី ១៦ ខែកុម្ភៈ។ ចំណែកស្ត្រីរងគ្រោះ ១នាក់ទៀតមកពីភ្នំពេញត្រូវបានមេខ្យល់នាំឆ្លងកាត់តាមប្រទេសវៀតណាមទៅចិន កាលពីអំពឡុងខែតុលា ឆ្នាំ២០១៧ ទៅរៀបការជាមួយបុរសជនជាតិចិន ហើយចុងក្រោយត្រូវបានមេខ្យល់បំបរបង់ចោលក្នុងព្រំដែនខេត្តឡាងសឺន ប្រទេសវៀតណាម ដោយសារនាងមានជំងឺ។ ស្ថានទូតបានទទួលស្ត្រីទាំង៣នាក់ខាងលើមកស្នាក់នៅបណ្តោះអាសន្នក្នុងស្ថានទូតនិងបានបញ្ជូនពួកគេតាមយន្តហោះត្រឡប់មកដល់កម្ពុជាវិញជាបន្តបន្ទាប់ នៅថ្ងៃទី ០២ និងថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨។

ទន្ទឹមនឹងនេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសចិនក៏បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចខេត្តជាំងស៊ី ជួយសង្គ្រោះស្ត្រីខ្មែរ ១នាក់ ឈ្មោះ ឡ. ស អាយុ ២២ឆ្នាំ មកពីខេត្តកណ្តាលដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការជាមួយបុរសជនជាតិចិននៅអំឡុងខែធ្នូ ឆ្នាំ២០១៧ ។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅអាហារបរិភោគ សម្ភារៈប្រើប្រាស់ និងរៀបចំឯកសារធ្វើដំណើរ ហើយនាងបានមកដល់កម្ពុជាវិញ នៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៨។ ក្នុងនេះស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសសឹង្ហបុរីក៏បានជួយរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ ១នាក់ អាយុ ២៤ឆ្នាំ មកពីខេត្តព្រៃវែង ដែលមិនអាចទ្រាំទ្រការងារលំបាកនៅសឹង្ហបុរីបាន។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅអាហារបរិភោគ និងជួយទាមទារលិខិតឆ្លងដែន និងសំបុត្រយន្តហោះពីភ្នាក់ងារនាំពលករ ហើយពលការិនីបានមកដល់កម្ពុជាវិញ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨៕

## អាជីវករថៃឆេះជុំ, រឿងពលករខ្មែរទៅដណ្តើមមុខរបររកស៊ីលក់ដូរនៅក្នុងផ្សារខេត្តចាន់បុរី

http://www.pheaktraprak.com/ March 17, 2018

ក្រុមអាជីវករថៃលក់ដូរបន្លែត្រីសាច់នៅក្នុងចាន់បុរី ប្តឹងទៅសារព័ត៌មានថៃអោយចុះផ្សាយរឿងករណីពលករខ្មែរមកដណ្តើមមុខរបរលក់ដូរនៅផ្សារខេត្តចាន់បុរីយ៉ាងណាធិបតេយ្យ។ យោងតាមបណ្តាញសារព័ត៌មានរបស់ថៃបានចុះផ្សាយកាលពីថ្ងៃសុក្រ ទី16 ខែមីនា ឆ្នាំ2018ម្សិលមិញនេះបានឲ្យដឹងថា ក្រុមអាជីវករថៃលក់ដូរបន្លែត្រីសាច់នៅក្នុងផ្សារសួនម៉ាកមួង សង្កាត់តាឡាត ស្រុកមឿង ខេត្តចាន់បុរី ប្រទេសថៃ បានសម្តែងការមិនពេញចិត្តយ៉ាងខ្លាំងចំពោះពលករខ្មែរមួយចំនួនដែលមកប្រកបមុខរបរកស៊ីលក់ដូរបន្លែ សាច់នៅក្នុងផ្សារសួនម៉ាកមួងយ៉ាងអាណាធិបតេយ្យដោយមិនគោរពច្បាប់ការងាររបស់ប្រទេសថៃ។

តាមការអះអាងរបស់ស្ត្រីអាជីវករម្នាក់ដែលប្រកបរបរលក់ដូរនៅក្នុងផ្សារខាងលើបានប្រាប់អ្នកសារ ព័ត៌មានក្នុងស្រុកថៃអោយបានដឹងថា មានពលករខ្មែរប្រមាណជាង10នាក់បានមកប្រកបមុខរបរកស៊ីលក់ដូរដោយខ្លួនឯងទាំងច្បាប់ការងារប្រទេសថៃ មិនអនុញ្ញាតអោយពលករបរទេសណាមកប្រកបមុខរបរកស៊ីលក់ដូរនៅក្នុងប្រទេសថៃជាដាច់ខាត។ ស្ត្រីដដែលបានបន្តទៀតការដែលពលករបរទេសមកប្រកបមុខរបស៊ីដោយខ្លួនឯងបែបនេះគឺធ្វើឲ្យជនជាតិថៃត្រូវបាត់បង់មុខរបស៊ី ព្រោះត្រូវបុគ្គលតាងដាវមកដណ្តើមអាជីពដែលហាមឃាត់យកទៅធ្វើជាមុខបរបស់ខ្លួន និងបំពានច្បាប់ប្រទេសថៃយ៉ាងធ្ងន់ធ្ងរ។

## បុរសពលករម្នាក់, ត្រូវគេចាក់សម្លាប់នៅមុខបន្ទប់គ្មាននរណាដឹង

http://www.pheaktraprak.com/ March 17, 2018

បុរសពលករបរទេសមិនស្គាល់អត្តសញ្ញាណម្នាក់ត្រូវឃាតករយកអាវុធមុខរួចចាក់សម្លាប់យ៉ាងព្រៃផ្សៃនៅបន្ទប់ស្នាក់នៅរបស់កម្មករសំណង់ក្នុងការដ្ឋានមួយកន្លែងស្ថិតនៅក្រុងប៉ាតាយ៉ាខេត្តឈុនបុរី។ ករណីអំពើឃាតកម្មចាក់ស្លាប់មនុស្សនេះបានកើតឡើងកាលពីវេលាម៉ោង10យប់ នាថ្ងៃសុក្រទី16 ខែមីនា ឆ្នាំ2018 នៅត្រង់ចំណុចមុខបន្ទប់ស្នាក់នៅរបស់ពលករសំណង់ ស្ថិតនៅក្នុង(សយ)ប្រាក់ដំណាក់(5) សង្កាត់ណងព្រឺរ ស្រុកបាងឡាម៉ុងខេត្តឈុនបុរី ប្រទេសថៃ។ យោងតាមរបាយការណ៍បឋមរបស់សមត្ថកិច្ចថៃបានដឹងថា បុរសពលករវ័យប្រមាណ25-30ឆ្នាំ ម្នាក់ត្រូវឃាតករមិនដឹងចំនួនបានយករុំមុខរួចចាក់ចំនួន 9កាំបិតដេកស្លាប់នៅក្បែរអាងទឹកមុខបន្ទប់ស្នាក់នៅរបស់ពលករសំណង់ស្នាក់ទីនោះ។

តាមការសាកសួរពលករដែលស្នាក់នៅបន្ទប់ក្បែរនោះបានប្រាប់ថាមិនមាននណាស្គាល់ជនរងគ្រោះហើយក៏មិនបានហេតុការណ៍ឃាតកម្មដែរ ករណីអំពើឃាតកម្មនេះបានធ្វើឲ្យសមត្ថកិច្ចថៃមានការសង្ស័យយ៉ាងខ្លាំងព្រោះទាំងមនុស្សទាំងកាមេរ៉ាសុវត្ថិភាពនៅត្រង់បរិវេណការដ្ឋានស្នាក់នៅខាងលើមិនអាចប្រើការ។ នៅវេលាបន្តបន្ទាប់កម្លាំងសមត្ថកិច្ចតម្រួតក្រុងប៉ាតាយ៉ា បានធ្វើការចុះត្រួតពិនិត្យកន្លែងកើតហេតុយ៉ាងលំអិតម្តងទៀតរួចនាំខ្លួនពលករខ្មែរដែលស្នាក់នៅទីនោះប្រមាណចំនួន23នាក់ យកទៅធ្វើការសាកសួរនៅយ៉ាងលំអិតនៅអធិការដ្ឋានតម្រួតក្រុងប៉ាតាយ៉ា ព្រោះពលករទាំងអស់គ្មានឯកសារបញ្ជាក់ស្ថានណាក់ធ្វើការស្នាក់នៅក្នុងប្រទេសថៃតាមផ្លូវច្បាប់។

## កម្មករ(តាងដាវ)យ៉ាងហោចណាស់ចំនួន 03នាក់ត្រូវឆ្លើងឆេះស្លាប់នៅក្នុងរថយន្ត

http://www.pheaktraprak.com/ March 18, 2018

រន្ធត់,មានករណីរថយន្តឈ្នួលដឹកពលករ (តាងដាវ) បុកគូទរថយន្តសណ្តោងបណ្តាលឲ្យកើតអគ្គិភ័យស្លាប់មនុស្សចំនួន03នាក់ និងមានមនុស្សរងរបួសចំនួន08នាក់។ ករណីនេះបានកើតឡើងកាលពីវេលាម៉ោង02:30នាទីយប់រំលងអធ្រាត្រឈានចូលថ្ងៃសៅរ៍ ទី17 ខែមីនា ឆ្នាំ2018 នៅត្រង់ចំណុចគីឡូម៉ែត្រ77+400 លើផ្លូវជាតិអេសៀរ ស្ថិតក្នុងស្រុកផរ៉ុមបុរី ខេត្តសិង្ហបុរី ប្រទេសថៃ។ យោងតាមប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថា រថយន្តឈ្នួល12កៅអី

ម៉ាកToyota មួយគ្រឿងពាក់ស្លាកលេខ33-1501(ក្រុងថេប) បានបើកបុកពីក្រោយរថយន្តសណ្តោងមួយគ្រឿងទៀតពាក់ស្លាកលេខ80-8432 (សិង្ហបុរី) ពេញទំហឹងធ្វើឲ្យកើតអគ្គិភ័យឆាបឆេះរថយន្តឈ្នួលខាងលើខ្ទេចទាំងស្រុង។ យោងតាមការបញ្ជាក់របស់សមត្ថកិច្ចដែលចុះអន្តរាគមន៍កន្លែងកើតហេតុប្រាប់ឲ្យដឹងថា ករណីគ្រោះថ្នាក់ចរាចរខាងលើនេះមានពលករសញ្ជាតិភូមាចំនួន 08នាក់បានរងរបួស និងចំនួន 03នាក់ ទៀតត្រូវភ្លើងឆេះស្លាប់នៅក្នុងរថយន្ត ចំណែកឯជនរងគ្រោះត្រូវបានសមត្ថកិច្ចបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យសិង្ហបុរីចំនួន 06នាក់និងមន្ទីរពេទ្យផរ៉ុមបុរីចំនួន02នាក់។ បច្ចុប្បន្នសមត្ថកិច្ចថៃកំពុងធ្វើការស្រាវជ្រាវរកមូលហេតុដែលបង្កឲ្យកើតគ្រោះថ្នាក់ចរាចរដ៏រន្ធត់មួយនេះ។

## ករកើតទៀតហើយ ម្តងនេះរឿងបែចាប់គូភ្លែងក្លាយ

http://www.pheaktraprak.com/ March 18, 2018

កាលពីថ្ងៃសៅរ៍ ទី17 ខែមីនា ឆ្នាំ2018 ម្សិលមិញមានករណីពលករបរទេសចំនួន 15នាក់ត្រូវកម្លាំងសមត្ថកិច្ចតម្រួតថៃប្រចាំសូន្យOSS ខេត្តនុនថាកបុរី ចាប់ខ្លួនពីបទក្លែងបន្លំឯកសារបន្ទាប់ពីមានថៅកែថៃនាំពលករទាំងអស់នោះទៅធ្វើត្បៀតប្រវត្តិនិង(ត)វីសារពីរឆ្នាំនៅក្នុងសូន្យOSS ខេត្តនុនថាកបុរី ប្រទេសថៃ ។ ក្នុងករណីខាងលើនេះគេនៅមិនទាន់ដឹងច្បាស់ថាពលករដែលត្រូវសមត្ថកិច្ចថៃចាប់ខ្លួននោះជាជនជាតិអ្វីនៅឡើយទេ ក៏ប៉ុន្តែនៅលើបណ្តាញសង្គមទំនាក់ទំនងហ្វេសប៊ុករបស់ក្រុមអ្នកគ្រប់គ្រងពលករបរទេសបានបង្ហាញអំពីរូបភាពតួយ៉ាងនៃ (ប៉ៃចាប់គូរ) ក្លែងក្លាយរបស់ពលករភូមាម្នាក់ ដើម្បីដាស់តឿនដល់ថៅកែថៃផ្សេងទៀតកុំឲ្យលុងជឿលើក្រុមជនខិលខូចដែលតែងតែបោកប្រាស់ថៅកែថៃ និងពលករដែលកំពុងធ្វើការខុសច្បាប់នៅក្នុងប្រទេសថៃ។ ដូច្នេះហើយសូមបងប្អូនពលករខ្មែរខុសច្បាប់នៅក្នុងប្រទេសថៃទាំងអស់សូមមេត្តាកុំលុងជឿលើបុគ្គលខិលខូចបោកប្រាស់ណាដែលនិយាយថា អាចធ្វើលុងបៀនថ្មីជូនពលករអត់ខុសច្បាប់បានម្តងទៀតអោយសោះ ពីព្រោះពលករខុសច្បាប់មានតែធ្វើប៉ាស្ព័រការងារMOUពីខាងប្រទេសរបស់ខ្លួនមកវិញប៉ុណ្ណោះទើបអាចធ្វើការនៅក្នុងប្រទេសថៃបាន។

## គ្រោះថ្នាក់បាក់អាគារសំណង់ ទៀតហើយ នៅក្នុងខេត្តនុនថាកបុរី

http://www.pheaktraprak.com/ March 18, 2018

មានករណីបាក់អាគារសំណង់មួយខ្នងនៅខេត្តនុនថាកបុរី បណ្តាលឱ្យសង្កត់កម្មករខ្មែរ ម្នាក់និងជនជាតិម្នាក់ស្លាប់នៅនឹងកន្លែងកើតហេតុ។ ករណីគ្រោះថ្នាក់ដ៏រន្ធត់នេះបានកើតឡើងកាលពីវេលាម៉ោង12 ថ្ងៃត្រង់ នៅថ្ងៃអាទិត្យទី18 ខែមីនា ឆ្នាំ2018 នៅត្រង់ចំណុចផ្លូវក្បែរផ្លូវជាតិឆែយ៉ាព្រឹក ស្ថិតក្នុងភូមិ(5) សង្កាត់ខ្លងប្រាក់ជុំ ស្រុកបាក់ក្រេត ខេត្តនុនថាកបុរី ប្រទេសថៃ ។ យោងតាមប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថា អាគារសំណង់កំពុងសាងសង់ចំនួនមួយខ្នងកម្ពស់ពីរជាន់ បានបាក់ស្រុតចុះក្រោមបណ្តាលឲ្យសង្កត់បុរស កម្មករខ្មែរម្នាក់ឈ្មោះ ឆេន ភេទប្រុសអាយុ 37ឆ្នាំ ជាជាងសំណង់ស្លាប់ និងបុរសម្នាក់ទៀតឈ្មោះ Suvaht moseng អាយុ 37ឆ្នាំ សញ្ជាតិថៃ ជាថៅកែក្រុមហ៊ុនកសាងខាងលើស្លាប់នៅនឹងកន្លែងកើតហេតុព្រមទាំងមានកម្មករម្នាក់ទៀតរងរបួសផងដែរ។ តាមការសន្និដ្ឋានបឋមបានអោយដឹងថា ករណីបាក់អាគារខាងលើនេះប្រហែលបណ្តាលមកពី(ណាងរាន)ទ្រមេតុងទើបចាក់ហើយមិនអាចទ្រ និងទម្ងន់ស៊ីម៉ង់បានទើបធ្វើឲ្យបាក់ស្រុតចុះមកបែបនេះ ក្រោយពេលកើតហេតុសមត្ថកិច្ចថៃបានចុះធ្វើការត្រួតពិនិត្យអាគារសំណង់ខាងលើយ៉ាងលម្អិតម្តងទៀត ដើម្បីរកមូលហេតុដែលធ្វើអោយកើតគ្រោះថ្នាក់នេះ។

## ច្បាប់ការងារថ្មីរបស់ថៃ,ត្រៀមប្រកាសដាក់ឲ្យអនុវត្តនៅពេលឆាប់ៗខាងមុខនេះហើយ.!

http://www.pheaktraprak.com/ March 19, 2018

ព្រះរាជក្រឹត្យថ្មី ស្តីពីច្បាប់ការងារថ្មីរបស់ប្រទេសថៃប្រចាំឆ្នាំ2018 ត្រៀមប្រកាសដាក់អោយអនុវត្តច្បាប់នៅពេលឆាប់ៗខាងមុខនេះហើយ ដោយច្បាប់ការងារថ្មីរបស់ប្រទេសថៃនេះមានចំនួនប្រាំបីមាត្រាថ្មីត្រូវប្រកាសដាក់អោយ

អនុវត្តជាផ្លូវការហើយបន្ទាប់ពីកែសម្រួលអស់រយៈពេលជាច្រើនខែរួចមក។ តើព្រះរាជក្រឹត្យស្តីអំពីច្បាប់ការងារថ្មីមានសារៈសំខាន់អ្វីខ្លះសូមចូលអានមើលនៅខាងក្រោមនេះទាំងអស់គ្នា÷

1/ច្បាប់ប្តូរថៅកែថ្មី ពលករដែលធ្វើការរស់នៅក្នុងតំបន់តែមួយអាចប្តូរថៅកែថ្មីបានដោយគ្រាន់តែបញ្ជូនឯកសារ, មិនចាំបាច់ស្នើសុំច្បាប់ការងារថ្មី ម្តងទៀតឡើយ។

2/ច្បាប់ស្នាក់អាស្រ័យពលករ,ពលករអាចស្នាក់នៅកន្លែងធ្វើការឬផ្ទះថៅកែបាន ដោយមិនចាំបាច់រាយការណ៍ជូនសមត្ថកិច្ចនៅក្នុងតំបន់ឡើយ។

3/ច្បាប់បានហាមឃាត់មិនឲ្យថៅកែ,កាត់ប្រាក់ខែឬប្រាក់ចំណូលផ្សេងៗពីពលករជាដាច់ខាត។

4/ច្បាប់បានបន្ថែមរយៈពេលប្តូរថៅកែថ្មីជូនពលកររយៈពេលចំនួន 30ថ្ងៃ។

5/ករណីពលករដែលធ្លាប់ជាប់ទោសពីបទលួចឆ្លងដែនខុសច្បាប់, ត្រូវហាមឃាត់មិនឲ្យចូលមកធ្វើការនៅប្រទេសថៃរយៈពេលពីរឆ្នាំ។

6/ច្បាប់ហាមឃាត់មិនឲ្យថៅកែរឹបអូសប៉ាស្ព័រឬបែអនុញ្ញាតធ្វើការនិងប័ត្រស៊ីជម្ពូរបស់ពលករជាដាច់ខាត។

7/ករណីលួចឆ្លងដែនខុសច្បាប់,និងធ្វើការនៅក្នុងប្រទេសថៃដោយគ្មានច្បាប់អនុញ្ញាត ត្រូវមានទោសពិន័យជាប្រាក់ចាប់ពី5000฿ ដល់ 50,000฿។

8/ករណីធ្វើការខុសលក្ខខ័ណ្ឌ ត្រូវមានទោសផាកពិន័យចាប់ពីរ 10,000฿ ដល់ 100,000฿។

## ទូកក្រុមចំណាកស្រុកលិចក្បែរ ឆ្នេរសមុទ្រ ក្រិក ស្លាប់ជនចំណាកស្រុក ១៦ នាក់

http://www.postkhmer.com/ AFP Publication date 19 March 2018 | 12:53 ICT

**ក្រុងអាថែន:** មនុស្សយ៉ាងតិច ១៦ នាក់រួមទាំងក្មេង ៦ នាក់ផងបានលង់ទឹកស្លាប់ កាលពីថ្ងៃសៅរ៍ បន្ទាប់ពីទូកក្រុមចំណាកស្រុកមួយគ្រឿងបានក្រឡាប់លិចនៅក្នុងដែនសមុទ្រអេហ្គីន (Aegean Sea) ជាឧបទ្ទវហេតុដ៏គ្រោះថ្នាក់បំផុត ដែលបានកើតឡើងនៅក្នុងតំបន់នេះចាប់តាំងពីមានកិច្ចព្រមព្រៀង ដ៏ចម្រូងចម្រាសមួយ កាលពីពីរឆ្នាំកន្លងទៅរវាងក្រុមរដ្ឋសមាជិក EU និង តួកគី ដើម្បីជួយទប់ស្កាត់លំហូរនៃក្រុមចំណាកស្រុកទៅកាន់ទ្វីបអឺរ៉ុប។ ក្រុមប៉ូលិសបានឲ្យដឹងថា មនុស្ស ៣ នាក់ដទៃទៀតកំពុងបាត់ខ្លួន បន្ទាប់ពីទូកនោះបានលិចទាំងពាក់កណ្ដាលយប់នៅក្នុងដែនដីទឹកក្បែរកោះ Agathonissi ខណៈទូកនេះកំពុងដឹកជញ្ជូនក្រុមជនចំណាកស្រុកពីតួកគី ទៅកាន់ប្រទេស ក្រិក។ ស្ត្រីពីរនាក់និងបុរសម្នាក់ដែលបានព្យាយាមហែលទៅកាន់ទីកន្លែងមានសុវត្ថិភាព នៅលើកោះមួយបានផ្ដល់សញ្ញាគ្រោះថ្នាក់ហើយដែលទូកជាច្រើនគ្រឿងនិងឧទ្ធម្ភាគចក្រមួយគ្រឿង បានចូលរួមស្រាវជ្រាវរកសាកសពក្រុមជនរងគ្រោះនិងអ្នកបាត់ខ្លួន។

លោក DimitrisVitsas រដ្ឋមន្ត្រីទទួលបន្ទុកផ្នែកចំណាកស្រុកបានឲ្យដឹងថា៖ «យើងមិនអាចនិងមិនត្រូវអនុញ្ញាតឲ្យមានមនុស្ស ឬ ក្មេងៗស្លាប់នៅក្នុងដែនសមុទ្រ អេហ្គីន ទៀតឡើយ»។ លោកបានថ្លែងថា ដំណោះស្រាយគឺត្រូវធ្វើយ៉ាងណាជានាឲ្យបាននូវ «ច្រកផ្លូវសុវត្ថិភាពនិងវិធានការនានាសម្រាប់ក្រុមជនភៀសខ្លួននិងក្រុមជនចំណាកស្រុកអាចប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខុសច្បាប់»។

ក្រុមអាជ្ញាធរបានឲ្យដឹងថា ជនចំណាកស្រុក ២ នាក់ដទៃទៀតបានស្លាប់ កាលពីថ្ងៃសៅរ៍ នៅក្បែរដែនដីមួយជាប់ព្រំដែនតួកគីខណៈដែលរថយន្តដឹកទំនិញមួយគ្រឿង ដែលកំពុងដឹកពួកគេបានក្រឡាប់ខណៈព្យាយាមរត់គេចពីប៉ុស្តិ៍ត្រួតពិនិត្យរបស់ប៉ូលិស។ ទីភ្នាក់ងារជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ UNHCR បានឲ្យដឹងថា មនុស្ស ៥០០ នាក់បានស្លាប់ ឬ បាត់ខ្លួននៅក្នុងដែនសមុទ្រអេហ្គីនអំឡុងរយៈពេល២ឆ្នាំកន្លងទៅ ដោយបានបណ្ដាលឲ្យចំនួនជនរងគ្រោះកើនដល់ ១ ០០០ នាក់ដែលបានលង់ទឹកស្លាប់នៅក្នុងច្រកផ្លូវដ៏ចង្អៀតរវាងក្រិកនិងតួកគីនៅក្នុងឆ្នាំ ២០១៥ និងឆ្នាំ ២០១៦ ស្ថិតនៅក្នុងកំរិតខ្ពស់បំផុតនៃវិបត្តិចំណាកស្រុក៕ AFP/ SN

## ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៨
## វិស័យវាយនភណ្ឌ បានជួយស្ត្រី មានការងារធ្វើ ដោយមិនចំបាច់ចំណាកស្រុក

https://wmc.org.kh/ ថ្ងៃចន្ទ ទី១៩ ខែមីនា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ វិស័យវាយនភណ្ឌ បានផ្តល់ការងារដល់ពលរដ្ឋខ្មែររាប់ម៉ឺននាក់ ពិសេសស្ត្រី។ កម្មករ កម្មការិនី អាចទទួលចំណូលពីវិស័យវាយនភណ្ឌ យ៉ាងហោចណាស់ចន្លោះជិត ២ពាន់ ទៅ ៣ពាន់ដុល្លារក្នុងមួយឆ្នាំៗ។ សហជីពយល់ ថា វិស័យនេះ គឺជាផ្នែកមួយដ៏សំខាន់ ដែលជួយដល់ស្ត្រី មិនចាំបាច់ចំណាកស្រុក ។ គិតមកដល់ឆ្នាំ២០១៨នេះ ប្រជាពលរដ្ឋខ្មែរប្រមាណជា ១លាននាក់ បានចូលបម្រើការងារក្នុងវិស័យវាយនភណ្ឌ។ ក្នុងចំណោមនេះ ស្ត្រីមានចំនួនជាង ៩០ភាគរយ។ កម្មការិនី ដែលបានផ្តល់បទសម្ភាសន៍ឲ្យវិទ្យុស្ត្រី បាននិយាយថា វិស័យមួយនេះ បានជួយដល់ពួកគេ ឲ្យមានប្រាក់ចំណូលទៀងទាត់ សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ដោយមិនចាំបាច់ចំណាកស្រុក។

អ្នកស្រី ជិន ផាន់រី កម្មការិនីរោងចក្រស្បែកជើង យីគ័ង ស្ថិតក្នុងខេត្តកំពង់ស្ពឺ បាននិយាយថា អ្នកស្រីបានចាប់ផ្តើមធ្វើការងារជាកម្មការិនីរោងចក្រស្បែងជើងនេះ បានរយៈពេលមួយឆ្នាំហើយ ។ អ្នកស្រី អាចរកចំណូលបានមួយភាគធំសម្រាប់បំពេញសេចក្តីត្រូវការប្រចាំថ្ងៃ របស់គ្រួសារ។ អ្នកស្រី ផាន់រី បន្តទៀតថា កាលពីមុនអ្នកស្រី ធ្វើការងារតាមក្រុមហ៊ុនឯកជន ក៏ប៉ុន្តែអ្នកស្រីបានឈប់ក្រោយពេលដែលអ្នកស្រី មានកូនតូច ហើយមិនអាចដាក់ច្បាប់បានរយៈពេលយូរ។ អ្នកស្រីបន្តទៀតថា បច្ចុប្បន្ននេះ មានរោងចក្រជាច្រើនបានរីកដុះដាលជាបន្តបន្ទាប់ ដែលបានផ្តល់ភាពងាយស្រួលដល់ស្ត្រី ជាប់កូនតូចដូចជាអ្នកស្រី អាចឈ្លៀតទៅធ្វើការងារផង និងមើលកូនផង ដោយមិនចាំបាច់ធ្វើដំណើរទៅឆ្ងាយ។ អ្នកស្រី ជិន ផាន់រី ៖«វាយនភណ្ឌហ្នឹងវាមានច្រើនទូលំទូលាយ វានៅកៀកៗផ្ទះយើង វាសម្បូរ អញ្ចឹងវាជាចំណែកមួយស្រួលដែរដោយសារវានៅកៀកផ្ទះយើង។ តាមពិតកាលពីមុនខ្ញុំធ្វើការតែក្រុមហ៊ុនទេ ដោយសារយើងតម្រូវការទីមួយកូនយើងតូច ធម្មតាយើងជាមនុស្សស្រីតែមានគ្រួសារមានកូន ត្រូវមើលថែមទាំ ហើយឪពុកម្តាយយើងចាស់ យើងមិនអាចប្រលែងឲ្យគាត់មើលទាំងស្រុងទេ។ យើងត្រូវការទៅមើលថៃដែរ អញ្ចឹងវានៅកៀកផ្ទះផង វាជួយសម្រួលដែរ បងគិតថា ចូលធ្វើការទៅទីមួយយើងអាចនៅមើលកូនយើងផង»។

ដូចគ្នាដែរអ្នកស្រី ភិន ចាន់ណា កម្មការិនី រោងចក្រកាត់ដេរសម្លៀកបំពាក់មួយកន្លែងនៅខេត្តកណ្តាល បាននិយាយថា ប្រសិនបើគ្មានវិស័យវានភណ្ឌកាត់ដេរនេះទេ គ្រួសារអ្នកស្រីអាចជួបការលំបាក ពីព្រោះតែក្នុងបន្ទុកគ្រួសារអ្នកស្រីមានកូនប្រុស ស្រី តូចៗចំនួន ០៣នាក់ ដែលកំពុងពេញវ័យសិក្សា។ អ្នកស្រី ចាន់ណា បន្ថែមទៀតថា បើពឹងទៅលើតែការរកចំណូលរបស់ស្វាមីតែម្នាក់ ជីវភាពគ្រួសារ ច្បាស់ជាខ្វះមុខ ខ្វះក្រោយជាក់ជាពុំខាន។ បន្ថែមពីនេះ អ្នកស្រីអាចនឹងត្រូវធ្វើចំណាកស្រុក ដើម្បីរកប្រាក់សម្រាប់ផ្គត់ផ្គង់ជីវិតភាពទៀតផង។ អ្នកស្រី ភិន ចាន់ណា ៖«និយាយរួមទៅប្រជាយើងអត់ចំណូលហ្នឹងចូលមក ក៏យើងលំបាកសព្វគ្រប់ទាំងអស់ខ្វះខាត យើងគិតតែខ្ចីគេចាយហូតគ្រាន់តែកូនរៀន គ្រាន់តែប្រចាំថ្ងៃ ក្នុងមួយអស់ ៣ ទៅ៤ ឬ៥ពាន់រៀល ។ ត្រង់ហើយដែលវាកាន់តែធ្ងន់ៗទៅ វាអត់មានចំណូលចូល យើងគិតតែចំណាយរហូត តែយើងខ្វះខាតច្រើនយើងគិតតែដើរខ្ចីគេ ដើរបុលគេគ្រប់កន្លែងទាំងអស់ដើម្បីកូន»។

ត្រង់ចំណុចនេះ ស្ត្រីមេដឹកនាំសហជីព តំណាងកម្មករ កម្មការិនី ទទួលស្គាល់ថា វិស័យវាយនភណ្ឌ ពិតជាបានជួយដល់ស្ត្រីកម្ពុជាច្រើនពិតមែន បើទោះជាក្នុងវិស័យនេះ ពេលខ្លះមានបញ្ហាចម្រូងចម្រាស់មួយចំនួនក្តី។ លោកស្រី យ៉ាង សុភ័ណ្ឌ ប្រធានសម្ព័ន្ធសហជីពកម្ពុជា មានប្រសាសន៍ថា អ្នកធ្វើការងារក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងស្បែងជើងនេះ ភាគច្រើនសុទ្ធសឹងតែជាស្ត្រី ដែលជាចំណែកដ៏សំខាន់មួយក្នុងការស្វែងរកចំណូល ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ប្រធានសម្ព័ន្ធសហជីពកម្ពុជា បន្តថាថា ប្រសិនជាមិនមានវិស័យវាយនភណ្ឌនេះទេ ស្ត្រីខ្មែរដ៏ច្រើនលើសលប់នឹងធ្វើចំណាកស្រុកជាក់ជាមិនខាន ហើយអ្នកស្រីជឿជាក់ថា មានស្ត្រីតិចតែប៉ុណ្ណោះ ដែលត្រឡប់ទៅធ្វើស្រែចម្ការវិញ

ដោយសារតែបច្ចុប្បន្ននេះ អ្នកស្រីមើលឃើញថា ផលិតផលកសិកម្ម ហាក់ពុំសូវមានទីផ្សារសមស្របសម្រាប់កសិករឡើយ។

អ្នកស្រី យ៉ាង សុភ័ណ្ឌ ៖«ក្នុងករណីដែលអត់មានវិស័យហ្នឹង ១០០ភាគរយ គាត់ប្រាកដជាធ្វើចំណាកស្រុកហើយ ហើយមនុស្សភាគតិចណាស់ដែលត្រឡប់ទៅធ្វើស្រែចម្ការវិញ ដោយសារតែស្រែចម្ការជាទូទៅយើងដឹងហើយថា នៅពេលដែលគាត់ទៅធ្វើ គាត់អត់មានទីផ្សារលក់ដូរ នៅផលិតផលដែលគាត់ដាំ អញ្ចឹងគាត់គឺភាគតិចណាស់ដែលត្រឡប់ទៅធ្វើស្រែចម្ការវិញ»។

ទាក់ទិន វិស័យមួយនេះ លោក អាត់ ធន់ មេដឹកនាំសហភាពការងារកម្ពុជា ដែលធ្វើការងារដើម្បីប្រយោជន៍កម្មករ កម្មការិនី ជាច្រើនឆ្នាំមកហើយ យល់ស្របថា ប្រសិនបើគ្មានវិស័យវាយនភណ្ឌនេះទេ ជម្រើសទីមួយរបស់កម្មករ ពិសេសកម្មការិនី ច្បាស់ជានឹងធ្វើចំណាកស្រុក។ លោកបន្តថា បើកាលណាពួកគេឈានដល់ការធ្វើចំណាកស្រុកទៅក្រៅប្រទេស បញ្ហាប្រឈមនានា នឹងកើតមានឡើងទ្វេដង ដែលមានជាអាទិ៍ ការរំលោភសិទ្ធិការងារ ការបៀតបៀនភេទ ការចាប់រំលោភ ឬក៏ការញៀនថ្នាំជាដើម។ លោក អាត់ ធន់ ៖«ទោះជាការចំណាកស្រុកទាំងក្នុងស្រុកនិងក្រៅស្រុកហ្នឹងបញ្ហាវាតែងតែកើតមានហើយ គ្រាន់តែថា នៅក្នុងស្រុកបញ្ហាវាមានតិចតួច។ បើចំណាកស្រុកក្រៅប្រទេសហ្នឹង យើងដឹងហើយថា សម្ពាធការងារ ការកេញប្រវ័ញ្ចការងារ នៅក្នុងស្រុកក៏មានដែរ ទម្រាំនៅក្រៅប្រទេស ការចាប់រំលោភ ការបោកប្រាស់បៀតបៀនផ្លូវភេទ ឬក៏ការកេញប្រវ័ញ្ចកម្លាំងពលកម្ម រួមទាំង បរិយាកាសសង្គមដែលគេនៅទីនោះមានជំងឺអេដស៍ ឬក៏ប្រើថ្នាំប្រើអីហ្នឹងវាមានបញ្ហាទាំងអស់ហ្នឹងហើយ ដែលធ្វើឲ្យបន្ទុកគ្រួសារគាត់កាន់តែលំបាកថែមទៀត»។

វិស័យវាយនភណ្ឌ បានបើកឱកាសឲ្យពលរដ្ឋខ្មែរទាំងស្រីទាំងប្រុស ទទួលបានការងារធ្វើនៅក្នុងស្រុក បើទោះជាពួកគេចេះ ឬក៏មិនចេះអក្សរក៏ដោយ។ យោងតាមអះអាងពីក្រុមកម្មការិនី ដែលផ្តល់បទសម្ភាសន៍ឲ្យវិទ្យុស្ត្រី បញ្ជាក់ថា យ៉ាងហោចណាស់ ក្នុងមួយឆ្នាំៗ ពួកគេអាចរកចំណូលបានជាមធ្យមជិត ២ពាន់ដុល្លារ និងឆ្នាំខ្លះអាចឈានទៅដល់ជិត ៣ពាន់ដុល្លារ។ បើទោះជាចំណូលរបស់ក្រុមកម្មករ កម្មការិនីសរុបប្រចាំឆ្នាំ ហាក់បានច្រើនគួរសមក៏ពិតមែន ប៉ុន្តែបើបែងចែកសម្រាប់ការចំណាយប្រចាំថ្ងៃ គឺបានត្រឹមតែទប់ប៉ុណ្ណោះ។ កម្មករ កម្មការិនី បង្ហាញក្តីរំពឹងថា ប្រាក់ខែគោលរបស់ពួកគេនឹងត្រូវបានដំឡើងជាបន្តទៀត ស្របទៅតាមអ្វីដែលជាការអះអាងរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រាប់ទៅកម្មករ កម្មការិនី អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ថា ប្រាក់ខែគោលរបស់កម្មករ កម្មការិនី នឹងមិននៅគាំងត្រឹម ១៧០ដុល្លារ សម្រាប់ឆ្នាំ២០១៨នេះឡើយ ពោលរាជរដ្ឋាភិបាល នឹងដំឡើងជាបន្តទៀត។

យ៉ាងណា ការប្តេជ្ញាចិត្តរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល គឺស្របទៅនឹងអ្វី ដែលក្រុមមេដឹកនាំសហជីពតំណាងកម្មករ បានអះអាងនាពេលកន្លងមកថា ប្រាក់ខែគោលរបស់ក្រុមកម្មករ កម្មការិនី ១៧០ដុល្លារនេះ មិនទាន់សមស្រប ដើម្បីធ្វើឲ្យជីវភាពកម្មករ កម្មការិនី កម្ពុជា រួចផុតពីភាពខ្វះខាតបាននៅឡើយទេ បើទោះជាប្រាក់ចំណូលនេះ ខ្ពស់ជាងបណ្តាប្រទេស មួយចំនួន ជិតខាងកម្ពុជាក៏ដោយ។ យោងតាមប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា វិស័យវាយនភណ្ឌ កាត់ដេរ និងស្បែកជើង ទំហំពាណិជ្ជកម្មលើវិស័យមួយនេះ បានឈានដល់ ៧ពាន់ ៦០០លានដុល្លារ នៅឆ្នាំ២០១៧៕

## កិច្ចប្រជុំផ្សព្វផ្សាយច្បាប់អន្តោរប្រវេសន៍ ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថពលករបរទេសនៅក្នុងប្រទេសកម្ពុជា

http://cambodiapolice.com/ 9:04 am 20 មីនា 2018

កំពង់ឆ្នាំង ៖ ឯកឧត្តម ឧត្តមសេនីយ៍ឯក យុន សំបូរ អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោ ប្រវេសន៍បានថ្លែងថា កិច្ចប្រជុំផ្សព្វផ្សាយច្បាប់អន្តោរប្រវេសន៍ស្តីពីការពង្រឹងការងារអធិការកិច្ចហត្ថ ពលករបរទេសនៅក្នុងប្រទេសកម្ពុជា នាពេលនេះមានសារៈសំខាន់ណាស់ ដើម្បីការពារសន្តិសុខជាតិបង្កើនចំណូលថវិការជាតិការពារផលប្រយោជន៍ស្រប

ច្បាប់របស់អ្នកវិនិយោគ និងពលករបរទេសដែល កំពុងធ្វើការងារនៅក្នុងប្រទេសកម្ពុជា។ ឯកឧត្តមបានថ្លែងបែបនេះនៅព្រឹកថ្ងៃទី១៩ ខែមីនាឆ្នាំ២០១៨ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពីកាតព្វកិច្ចធ្វើប័ណ្ណ និងសៀវភៅការការងាររបស់ជនបរទេសដែលកំពុង ស្នាក់នៅធ្វើការងារណាមួយនៅក្នុងប្រទេសកម្ពុជា ជាមួយស្ថាប័នពាក់ពន្ធ័ អាជ្ញាធរឃុំស្រុក និងតំណាងរោងចក្រសហគ្រាស និងខ្លឹបកំសាន្តនានាក្នុងខេត្តកំពង់ឆ្នាំង។ ឯកឧត្តមបានបន្តថា ៖ តាមផែនការរបស់ក្រសួងនៅក្នុងខែ០៣និង០៤នេះត្រូវផ្សព្វផ្សាយ ច្បាប់អន្តោប្រវេសន៍ឲ្យបានទូលំទូលាយដល់បណ្តាខេត្តក្រុងទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ហើយចាប់ពីថ្ងៃ០១ខែ០៥ឆ្នាំ២០១៨ទៅ ត្រូវនឹងធ្វើអធិការកិច្ចដោយផ្ទាល់ជាមួយអាជ្ញាធរខេត្ត ស្រុក និងមន្ទីរពាក់ពន្ធ័ដើម្បីចុះត្រួតពិនិត្យជនបរទេសជាពលករនិងអ្នកធ្វើវិនិយោគដែលកំពុងស្នាក់នៅ ក្នុងខេត្ត។

តាមច្បាប់អន្តោប្រវេសន៍របស់កម្ពុជា ជនបរទេសម្នាក់ៗដែលមកស្នាក់នៅធ្វើការត្រូវមានលិខិតឆ្លងដែន និងទិដ្ឋាការតាមការសុំស្នាក់នៅពី១ឆ្នាំដល់៣ឆ្នាំ ដោយមានកាតព្វកិច្ចបង់ប្រាក់ចូលថវិការជាតិក្នុង ម្នាក់ៗចំនួន១០០ដុល្លាក្នុង១ឆ្នាំ។ នៅក្នុងទិដ្ឋភាពច្បាប់ ទី១ចំពោះជនបរទេសដែលមិនគោរពកាតព្វកិច្ច នៃច្បាប់អន្តោប្រវេសន៍ នឹងត្រូវធ្វើការផាកពិន័យប្រាក់ចំនួន១២៥ដុល្លាហើយត្រូវចាប់បញ្ជូនទៅឲ្យ ក្រសួងការងារនៃប្រទេសកម្ពុជា ចំពោះអ្នកមិនអនុវត្តច្បាប់និងត្រូវធ្វើការបណ្តេញចេញពីកម្ពុជាដោយ ប្រកាសរបស់ក្រសួងមហាផ្ទៃ។ ទី២.ចំពោះអ្នកគេចវេះ នឹងត្រូវចាប់ខ្លួនដាក់ពន្ធនាគារពី១ខែទៅដល់៦ខែ ហើយនឹងត្រូវបណ្តេញចេញពីកម្ពុជា។ ដូច្នេះចំពោះពលករដែលកំពុងធ្វើការនៅក្នុងក្រុមហ៊ុនរោងចក្រសហគ្រាសទាំងអស់ត្រូវត្រៀមឯកសារផ្ទាល់ខ្លួនមានលិខិតឆ្លងដែន មានទិដ្ឋាការនិងមានសៀវភៅការងារ ដើម្បីការពារខ្លួន និងត្រូវបង្ហាញដល់ក្រុមការងារក្នុងពេលចុះធ្វើអធិការកិច្ច។ ក្នុងពេលចុះអធិការកិច្ច បើសង្ស័យក្រុមហ៊ុនណាមួយមានពលករបរទេសមិនស្របច្បាប់ ឬមិនគោរពកាតព្វកិច្ច នោះលោក ព្រះរាជអាជ្ញាខេត្តនិងចេញដីកាចុះឆែកឆេរភ្លាម ដើម្បីអនុវត្តច្បាប់ដោយតម្លាភាពនិងប្រសិទ្ធភាព។.

ឯកឧត្តមឈួរច័ន្ទឌឿនអភិបាលខេត្តកំពង់ឆ្នាំងនៅក្នុងពិធីនេះបានសំណូមពរ មន្ត្រីរាជការពាក់ពន្ធ័ និងអាជ្ញាធរទាំងអស់ ត្រូវសហការជាមួយក្រុមការងារអធិការកិច្ចដែលបានចាត់តាំងក្នុងលិខិតបង្គាប់ការ ដើម្បីចូលរួមអនុវត្តន៍ច្បាប់នេះអោយមានប្រសិទ្ធិភាពខ្ពស់ និងសូមកុំបន្តឱ្យមានកំហុសតទៅទៀត ដូច ជាការយកសេវាលើសច្បាប់កំណត់ការចេញសំបុត្រកំណើត ឬអត្តសញ្ញាបណ្ណ័អោយជនបរទេសជាដើម ដែលកិច្ចការងារនេះគឺជាព្រះរាជកិច្ចរបស់ព្រះមហាក្សត្រ មិនជាភារកិច្ចរបស់យើងទេ។

នៅក្នុងពិធីនេះដែរ អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ បានប្រគល់កុំព្យូទ័រចំនួន៩ គ្រឿងជូនខេត្តកំពង់ឆ្នាំង គឺជូនដល់អធិការនគរបាលក្រុងស្រុកទាំង៨ក្នុងខេត្ត ដោយ១ស្រុកទទួល បាន១គ្រឿង និង១គ្រឿងទៀតផ្តល់ជូនក្រុមការងារជំនាញរបស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង៕

## ថៃ នឹងចាត់វិធានការតឹងរឹង លើពលករខុសច្បាប់ នៅដើមខែមេសា

https://thmeythmey.com 20, Mar 2018 , 10:33

ភ្នំពេញ៖ ថៃ នឹងចាត់វិធានការតឹងរឹង ចំពោះពលករបរទេសខុសច្បាប់ទាំងអស់ ដែលរស់នៅនិងធ្វើការលើទឹកដីថៃ នៅខែមេសាខាងមុខនេះ។ ការអនុវត្តវិធានការនេះធ្វើឡើងបន្ទាប់ពីថៃបានរៀបចំច្បាប់គ្រប់គ្រងពលករបរទេសកាលពីឆ្នាំ២០១៧ និងទុកពេលឲ្យពលករបរទេសទាំងអស់រៀបចំឯកសារស្របច្បាប់សម្រាប់បំពេញការងារក្នុងទឹកដីថៃ។ ផុតពីថ្ងៃទី៣១ មីនានេះទៅ ពលករបរទេសទាំងអស់ នឹងប្រឈមមុខ ជាមួយចំណាត់ការតាមផ្លូវច្បាប់របស់អាជ្ញាធរថៃហើយ។ នេះជាការបញ្ជាក់របស់ស្ថានទូតខ្មែរប្រចាំប្រទេសថៃ ដែលបានអំពាវនាវឲ្យពលករខ្មែរ មិនទាន់បំពេញឯកសារត្រឹមត្រូវនោះ ប្រញាប់ទៅបន្តសុពលភាពនៅការិយាល័យច្រកចេញ-ចូលតែមួយរបស់ភាគីថៃ តាមបណ្តាខេត្ត-ក្រុងទាំងនោះ ឲ្យបានរួចរាល់មុនថ្ងៃទី៣១ មីនា។ សេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតខ្មែរប្រចាំប្រទេសថៃ ចុះថ្ងៃទី១៩ មីនាបានបញ្ជាក់ដូច្នេះថា៖«ភាគីថៃនឹងបិទដំណើការសុពលភាពបណ្ណស្នាក់នៅ និងធ្វើការបណ្តោះអាសន្ន (បណ្ណស៊ីជំពូ

និងលិខិតបញ្ជាក់ទំនាក់ទំនងរវាងថៅកែ និងពលករ) នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ជាកំហិត។ ផុតកាលកំណត់បរិច្ឆេទថ្ងៃទី៣១ មីនា អាជ្ញាធរនឹងចាត់វិធានការយ៉ាងតឹងរឹងតាមច្បាប់ ចំពោះពលករបរទេសទាំងអស់ ដែលពុំមានច្បាប់អនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការនៅប្រទេសថៃ»។

កន្លងមកក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំក្រុមការងារចល័ត និងមជ្ឈមណ្ឌលមួយចំនួនបន្ថែមទៀត ដើម្បីបង្កើនល្បឿនធ្វើឯកសារស្របច្បាប់ដល់ពលករខ្មែរ ។ ចំណែកភាគីថៃ ក៏បានកំណត់ទីតាំង ដើម្បីរៀបចំបញ្ជីឈ្មោះពលករខ្មែរ និងផ្តល់ទិដ្ឋាការស្នាក់នៅ ហើយនិងទិដ្ឋាការការងារឲ្យពលករខ្មែរផងដែរ។ នេះបើតាមការបញ្ជាក់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា។ ក្រសួងការងារបានឲ្យដឹងថា មជ្ឈមណ្ឌលចំនួន៣កន្លែងដែលក្រុមការងារចល័តចុះធ្វើឯកសារស្របច្បាប់ជូនដល់ពលករខ្មែរ គឺនៅទីក្រុងបាងកក ខេត្តរ៉ាក់យ៉ង និងខេត្តសុងខ្លា។ ក្រសួងការងារបន្តថា ក្រុមការងារចល័តបានធ្វើលិខិតធ្វើដំណើរ(TD)និងបណ្ណពលករខ្មែរ ធ្វើការនៅបរទេស ( OCWC) ដោយក្នុងមួយថ្ងៃផ្តល់ជូនពលករខ្មែរ ពី ១,៧០០ ទៅ១,៨០០នាក់។ បើតាមក្រសួងការងារធ្លាប់បញ្ជាក់កាលពីពេលថ្មីៗនេះ បច្ចុប្បន្ននៅសល់ពលករខ្មែរ ជាង៣០ម៉ឺននាក់ទៀត ដែលមិនទាន់រៀបចំឯកសារឲ្យស្របច្បាប់ប្រទេសថៃ។

កាលពីថ្ងៃទី៥ ខែមីនា នាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចន្ទអូចា បានបង្ហាញការខឹងសម្បារយ៉ាងខ្លាំងចំពោះការយឺតយ៉ាវក្នុងការផ្តល់ឯកសារស្របច្បាប់ដល់ពលករបរទេសខុសច្បាប់រាប់សែននាក់ ដែលកំពុងធ្វើការនៅលើទឹកដីថៃ។ លោក ប្រាយុទ្ធ ខឹងបែបនេះ បន្ទាប់ពីមន្ត្រីក្រសួងការងារលោក Anurak Thossarat បានប្រាប់លោកថា ការងារផ្តល់ឯកសារនេះមានដំណើរការយឺត ព្រោះតែម៉ាស៊ីនស្កេនដើម្បីបញ្ជាក់អត្តសញ្ញាណពលករ មានមិនគ្រប់គ្រាន់។ លោក ប្រាយុទ្ធ ក៏បានគំរាមចាប់ខ្លួនពលករខុសច្បាប់ទាំងអស់ បើពួកគេមិនអាចបំពេញឯកសារឲ្យទាន់ការកំណត់នៅក្នុងខែមិថុនាទេនោះ។ បើតាមរដ្ឋមន្ត្រីក្រសួងការងារថៃ លោក Anurak ពលករចំនួន៩៨៨ ៧៩៨នាក់ បានចុះឈ្មោះបញ្ជាក់សញ្ជាតិរបស់ពួកគេរួចរាល់ហើយ ក្នុងនោះពលករមីយ៉ាន់ម៉ាមានចំនួន៧៨៤ ០៩១នាក់ កម្ពុជាចំនួន១៥៧២៣២នាក់ និងឡាវចំនួន៤៧ ៤៧៥នាក់។ នៅសល់ពលករចំនួនប្រមាណជិត៧សែននាក់ទៀត ដែលមិនទាន់ទៅបញ្ជាក់អត្តសញ្ញាណនៅឡើយ ហើយពួកគេមានពេលត្រឹមខែមិថុនាដើម្បីបំពេញឯកសារចាំបាច់ និងអាចបន្តធ្វើការនៅថៃបានពីរឆ្នាំដោយស្របច្បាប់៕

## អាជ្ញាធរថៃនឹងចាត់វិធានការ តាមច្បាប់ចំពោះ ពលករបរទេសដែលពុំមានច្បាប់ អនុញ្ញាឲ្យធ្វើការនិងស្នាក់ ក្នុងប្រទេសខ្លួន

https://www.dap-news.com/kh/ ថ្ងៃច័ន្ទ, ១៩ មិនា ២០១៨ 17:24 ដោយ: ដើមអម្ពិល ID:049

ភ្នំពេញ៖ អាជ្ញាធរថៃនឹងចាត់វិធានការ យ៉ាងតឹងរឹងតាមច្បាប់ ចំពោះពលករបរទេសទាំងអស់ ដែលពុំមានច្បាប់អនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ តាមសេចក្តីប្រកាស ព័ត៌មាន របស់ស្ថានទូតនៃព្រះរាជណាចក្រកម្ពុជា ប្រចាំនៅព្រះរាជាណាច្រកថៃ នៅរសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ នេះ បានឲ្យដឹងថា "ភាគីថៃនឹងបិទការបន្តសុពលភាព ប័ណ្ណស្នាក់នៅ ធ្វើការ បណ្តោះអាសន្ន (ប័ណ្ណស៊ីជំពូ និងលិខិតបញ្ជាក់ទំនាក់ទំនង រវាងថៅកែនិង ពលករ) នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ ជាកំហិត។ ផុតកាលកំណត់បរិច្ឆេទថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ អាជ្ញាធរថៃនឹងចាត់វិធានការ យ៉ាងតឹងរឹងតាមច្បាប់ ចំពោះពលករបរទេសទាំងអស់ ដែលពុំមានច្បាប់ អនុញ្ញាតឲ្យស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ"។

ជាមួយគ្នានេះ ស្ថានទូតនៃព្រះរាជណាចក្រកម្ពុជា ប្រចាំនៅព្រះរាជាណាច្រកថៃ ក៏បានអំពាវនាវ ដល់ពលករកម្ពុជាទាំងអស់ ដែលមិនទាន់បានបន្តសុពលភាព ប័ណ្ណស្នាក់នៅនិងធ្វើការបណ្តោះអាសន្ន សូមមេត្តាប្រញាប់រួសរាន់ទៅបន្តសុពលភាព នៅការិយាល័យច្រកចេញចូលតែមួយ របស់ភាគីថៃ តាមបណ្តាខេត្ត-ក្រុង ដែលបងប្អូនរស់នៅ និង

ធ្វើការឲ្យបានរួចរាល់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។ សូមជម្រាបថា កាលពីពេលថ្មីៗនេះ អាជ្ញាធរថៃ ចាប់ពលករខ្មែរខុសច្បាប់បញ្ជូនតាមច្រកទ្វារអន្តរជាតិ ប៉ោយប៉ែតមានចំនួន៣ ៦៨៤នាក់ (ស្ត្រី ១ ១៦០នាក់ និងកុមារ ២៨៦នាក់) ៕

## ត្រៀមបើកសូន្យOSS (ត)ប័ត្រស៊ីជម្ព និង(ត)វីសារពីរឆ្នាំពេញ 24ម៉ោង

http://www.pheaktraprak.com/ March 19, 2018

ក្រសួងការងារថៃត្រៀមប្តូរផែនការថ្មី ដោយបើកសូន្យOSS (One Stop Service) ដំណើរការ(ត)ប័ត្រស៊ីជម្ពូ និង(ត)វីសារពីរឆ្នាំ ជូនពលករបរទេសពេញរយៈពេល 24ម៉ោង ដោយចាប់ផ្តើមដំណើរការនៅថ្ងៃព្រហស្បតិ៍ទី22 ខែមីនា ឆ្នាំ2018នេះតទៅ បន្ទាប់ពេលវេលាធ្វើឯៀតប្រវត្តិ(ប័ត្រស៊ីជម្ពូ)ជូនពលករខ្មែរ,ឡាវ,ភូមានៅសល់រយៈពេលត្រឹមតែ10ថ្ងៃប៉ុណ្ណោះនិងបិតដំណើរ។

## ចាប់ខ្លួនបានហើយ, ឃាតករដៃដល់ ចាក់សម្លាប់ពលករខ្មែរនៅ Pattaya

http://www.pheaktraprak.com/ March 20, 2018

កាលពីថ្ងៃច័ន្ទ ទី19 ខែមីនា ឆ្នាំ2018 កម្លាំងសមត្ថកិច្ចតម្រួត ក្រុងប៉ាតាយ៉ា ខេត្តឈុនបុរី ប្រទេសថៃ បានបំបែកសំណុំរឿងក្តីករណីបុរសពលករខ្មែរមិនស្គាល់អត្តសញ្ញាណម្នាក់ ត្រូវឃាតករដៃដល់ចាក់សម្លាប់ចំនួនប្រាំបួន កន្លែងនៅលើខ្លួនប្រាណ បណ្តាលឱ្យជនរងគ្រោះដេកស្លាប់នៅក្បែរអាងទឹកមុខបន្ទប់ស្នាក់នៅកម្មករសំណង់របស់ក្រុមហ៊ុនមួយស្ថិតនៅSoi ប្រាក់ដំណាក់(5) សង្កាត់ណងព្រឺរ ស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ប្រទេសថៃ កាលពីរាត្រីថ្ងៃសុក្រទី16 ខែមីនាឆ្នាំ2018កន្លងទៅថ្មីៗនេះ។

យោងតាមរបាយការណ៍របស់សមត្ថកិច្ចតម្រួតក្រុងប៉ាតាយ៉ា បានអោយដឹងថា ជនដៃដល់ដែលជាឃាតករមានឈ្មោះ វី អាយុ 24 ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាកម្មករសំណង់ធ្វើការនៅនឹងកន្លែងកើតហេតុ។ យោងតាមចម្លើយសារភាពរបស់ជនដៃដល់ដែលជាឃាតករបានប្រាប់ថា ជនរងគ្រោះដែលស្លាប់ទើបតែយ៉ាយមកធ្វើការនៅកន្លែងកើតហេតុបានប្រមាណជាង 10ថ្ងៃប៉ុណ្ណោះ ហើយនៅយប់កើតហេតុជនដៃដល់បានអង្គុយផឹកស្រាជុំគ្នាជាមួយអ្នកស្លាប់នៅមុខបន្ទប់ស្នាក់នៅក្បែរកន្លែងកើតហេតុ ហើយក្រោយមកកើតរឿងទាស់គ្នានៅក្នុងវង់ផឹកស៊ីធ្វើឲ្យជនដៃដល់ខឹងហើយមានចរិកជាបងធំប្រចាំកន្លែងទៀតនោះ បានដើបស្ទុះទៅចាក់ជនរងគ្រោះដែលកំពុងអង្គុយផឹកជាមួយគ្នាបណ្តាលឲ្យជនរងគ្រោះរងរបួសធ្ងន់ បន្ទាប់មកជនរងគ្រោះបានរត់មកដួលស្លាប់នៅក្បែរអាងទឹកមុខបន្ទប់ស្នាក់កើតហេតុខាងលើ ក្រោយពេលកើតហេតុជនដៃដល់បានរត់គេចខ្លួនភ្លាម ទៅស្នាក់បណ្តោះអាសន្នជាមួយមិត្តភក្តិជាពលករខ្មែរដូចគ្នាដែលកំពុងធ្វើការនៅម្តុំតំបន់ឧស្សាហកម្ម(និគមឡែមច្បាំង) ស្រុកស៊ីរាចធា ខេត្តឈុនបុរី បន្ទាប់មកត្រូវកម្លាំងសមត្ថកិច្ចតម្រួតក្រុងប៉ាតាយ៉ាតាមទៅចាប់ខ្លួនបាន ជាមួយនឹងវត្ថុតាងដែលបង្កហេតុរួមមានដែកឆាបមចំនួន 01 ដើម និងសំលៀកបំពាក់ដែលពាក់នៅយប់ថ្ងៃកើតហេតុផងដែរ។

ក្រោយពេលឃាត់ខ្លួនជនដៃដល់ជាឃាតករត្រូវបានកម្លាំងសមត្ថកិច្ចតម្រួតក្រុងប៉ាតាយ៉ា នាំខ្លួនយកទៅធ្វើសកម្មភាពបង្ហាញនៅកន្លែងកើតហេតុ ដោយមានការចូលរួមសង្កេតការណ៍ពីសំណាក់បងប្អូនពលករខ្មែរដែលស្នាក់នៅទីនោះយ៉ាងច្រើនកុះករផងដែរ បន្ទាប់ពីធ្វើសកម្មភាពបង្ហាញរួចជនដៃដល់ត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅឃុំខ្លួនទុកនៅអធិការដ្ឋានតម្រួតក្រុងប៉ាតាយ៉ា ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ជនបរទេសរំអោសអាភាសនៅសៀមរាប ត្រូវបានតុលាការកាត់ទោសជាប់ពន្ធនាគារមួយឆ្នាំ

https://thmeythmey.com/ 20, Mar 2018 , 11:23 am

ទីបំផុតទៅ តុលាការសាលាដំបូងខេត្តសៀមរាប បានប្រកាសសាលក្រមជនបរទេស ដែលបើកក្លឹបកម្សាន្តរាំអាសអាភាសនៅទីក្រុងសៀមរាប ដោយសម្រេចឲ្យជាប់ពន្ធនាគារមួយឆ្នាំ។ ជនជាប់ចោទ ដាលញ៉េល ចន ត្រូវតុលាការចោទពីបទ ប្រើប្រាស់រូបភាព និងសម្ភារអាសអាភាស ។ ចៅក្រមជំនុំជំរះក្តីលោកមេធាវី អ៊ុំ ចាន់ថុល បាននិយាយថា

សាលក្រមផ្តន្ទាទោសជនបរទេស ដាលញ៉ែល ឲ្យជាប់ពន្ធនាគារមួយឆ្នាំ តែជនជាប់ចោទត្រូវអនុវត្តន៍ទោសចំនួន ១ខែ ២៧ថ្ងៃប៉ុណ្ណោះ នៅសល់ប៉ុន្មានគឺត្រូវព្យួរ។បើតាមចៅក្រម ដាញ៉ែល ចន បានសារភាពកំហុសដោយអចេតនារបស់ខ្លួន ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វប្បធម៌ និងប្រពៃណីខ្មែរ និងសន្យារៀងចាលចំពោះទង្វើនេះតទៅទៀត។

គួររម្លឹកថា កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ កម្លាំងការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជនខេត្ត ដឹកនាំដោយលោកស្រី ដួង ថាវរី ស្នងការរងនគរបាលខេត្តសៀមរាប និងព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត បានចុះបង្ក្រាបករណីរូបភាព និងសម្ភារអាសអាភាស ដែលស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប។ ក្នុងប្រតិបត្តិការនេះ អាជ្ញាធរបានឃាត់ខ្លួនជនសង្ស័យដែលជាជនបរទេស និងជាអ្នករៀបចំកន្លែងខាងលើចំនួន ១០នាក់ ប៉ុន្តែក្រោយមកពួកគេបានដោះលែងវិញ នៅសល់ ដាញ៉ែល ចន តែម្នាក់ប៉ុណ្ណោះ៕

## អាជ្ញាធរខេត្តបន្ទាយមានជ័យជំរុញពង្រឹងសន្តិសុខសណ្តាប់ធ្នាប់និងទប់ស្កាត់ការរត់ពន្ធទំនិញខុសច្បាប់

http://www.akp.gov.kh/ AKP បន្ទាយមានជ័យ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨

អាជ្ញាធរខេត្តបន្ទាយមានជ័យបានជំរុញដល់អាជ្ញាធរ សមត្ថកិច្ច ពាក់ព័ន្ធទាំងអស់ឱ្យបន្តបង្កើនការយកចិត្តទុកដាក់ក្នុងការពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ទាំងក្នុងភូមិសាស្រ្ត និងតាមបណ្តោយព្រំដែនទប់ស្កាត់ការរត់ពន្ធទំនិញឆ្លងដែនខុសច្បាប់ដើម្បីធានាសុវត្ថិភាពបានកាន់តែល្អប្រសើរថែមទៀតដល់ភាពសុខសាន្ត ការរស់នៅរបស់ប្រជាពលរដ្ឋ និងបង្កើនចំណូលថវិកាជាតិ។ ក្នុងកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកាលពីរសៀលថ្ងៃចន្ទ៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ អភិបាល ខេត្តបន្ទាយមាន ជ័យ ឯកឧត្តម សួន បវរ អភិបាលខេត្តបន្ទាយមានជ័យ បានមានប្រសាសន៍ក្រើនរម្លឹកដល់ គណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក-ក្រុង និងកងកម្លាំងប្រដាប់អាវុធពាក់ព័ន្ធទាំងអស់ ត្រូវ បន្តពង្រឹងការរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម ជាពិសេសនោះនៅក្នុងពិធីបុណ្យ ចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរយើងនាពេលខាងមុខនេះ។ ចំពោះការងារសន្តិសុខតាមតំបន់ព្រំដែន ត្រូវបន្តយកចិត្តទុកដាក់អនុវត្តន៍តាមគោល នយោបាយរបស់រាជរដ្ឋាភិបាល រក្សាឱ្យបានព្រំដែនស្ថិរភាព សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ រក្សាបាននូវបូរណភាពទឹកដី និងបានប្រែក្លាយតំបន់ទាំងនោះជាតំបន់ ពាណិជ្ជកម្មដ៏មានសារៈសំខាន់និងជាតំបន់ដ៏មានសក្តានុពលក្នុងការទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិឆ្លងកាត់តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតដែលកំពុងតែមានកំណើននោះ។

ឯកឧត្តមអភិបាលខេត្តបានជំរុញដល់អាជ្ញាធរស្រុក-ក្រុង ឃុំ-សង្កាត់សមត្ថកិច្ចពាក់ព័ន្ធត្រូវយកចិត្តទុកដាក់រួមសហការគ្នាបន្តចុះពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ធ្វើការចុះផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ផ្លូវគោកតាមមូលដ្ឋាន ការចុះត្រួតពិនិត្យការប្រើ ប្រាស់អាវុធជាតិផ្ទុះខុសច្បាប់ បង្ក្រាបបទល្មើសផ្សេងៗរួមមានៈគ្រឿងញៀន ចោរលួច ចោរ ប្លន់ ល្បែងស៊ីសង ជាដើម។ ឯកឧត្តម សួន បវរ បានបន្តទៀតថា ត្រូវខិតខំប្រែក្លាយនគរបាលប៉ុស្តិ៍ឱ្យទៅជានគរ បាលសហគមន៍ក្នុងគោលដៅធ្វើឱ្យកាន់តែល្អប្រសើរការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ និងពង្រីកបន្ថែមកម្លាំងប្រជាការពារដែលមានសារៈសំខាន់ក្នុងការចូលរួមអាចជួយក្នុងការពង្រឹងសន្តិសុខ នៅតាមមូលដ្ឋានបានទាន់ពេលនោះ។ ពាក់ព័ន្ធការទប់ស្កាត់ទំនិញគេចពន្ធនោះ ឯកឧត្តមអភិបាលខេត្តបន្ទាយមានជ័យបាន ឱ្យដឹងដែរថា នៅខេត្តបន្ទាយមានជ័យ ក្រៅពីច្រកទ្វារអន្តរជាតិប៉ោយប៉ែត យើងមានទីស្នាក់ ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែនម៉ាឡៃ បឹងត្រកួន សម្រាប់ដល់ការធ្វើពាណិជ្ជកម្មនាំទំនិញ ចេញ-ចូលតាមតំបន់នីមួយៗ និងមានច្រករបៀងនៅតាមបណ្តោយព្រំដែននេះជាបញ្ហាលំបាក ហើយទាមទារដល់កងកម្លាំងប្រដាប់អាវុធ ដែលកំពុងឈរជើងតាមព្រំដែន និងសមត្ថកិច្ចជំ នាញត្រូវតែបន្តរួមគ្នាបង្កើនការទប់ស្កាត់ នូវការរត់ពន្ធទំនិញខុសច្បាប់ ទំនិញគេចពន្ធ ទំនិញខូចគុណភាព

ការនាំពលករតាមរយៈមេខ្យល់ដោយគ្មានច្បាប់ត្រឹមត្រូវ ពិសេសការជួញដូរស្ត្រី និងកុមារ គ្រឿងញៀន ចោរលួច ចោរប្លន់ឆ្លងដែនឃាតកម្ម និងភេរវកម្មឆ្លងដែនជាដើម៕ ដោយ ឈុន សារ៉ាត

## ចុះពន្យារសុពលភាពលិខិតឆ្លងដែន អាចជួយពលរដ្ឋខ្មែរ បានច្រើនយ៉ាងនៅកូរ៉េ

http://www.cen.com.kh/ March 20, 2018

កូរ៉េខាងត្បូង ៖ ការចុះពន្យារសុពលភាពលិខិតឆ្លងដែន ជូនបងប្អូនប្រជាពលរដ្ឋនៅកូរ៉េ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ តែងតែអនុវត្តជាប្រចាំ ហើយ ការងារនេះវាមិនមែនគ្រាន់តែជាការជួយកាត់បន្ថយការលំបាកក្នុងការធ្វើដំណើរ ពេលវេលាដល់បងប្អូនប៉ុណ្ណោះទេ តែវាក៏ជាការបើក វេទិកាសាធារណៈពិគ្រោះយោបល់មួយ ដើម្បីបានយល់ពីសុខទុក្ខ ការបកស្រាយចម្ងល់នានា ដោះស្រាយបញ្ហាប្រឈមផ្សេងៗជូនបងប្អូនខ្មែរយើងបានមួយកម្រិតទៀតផងដែរ។

នេះជាការលើកឡើងរបស់លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ក្នុងកម្មវិធីចុះផ្តល់សេវាបន្តសុពលភាពលិខិតឆ្លងដែនដោយឥតគិតថ្លៃ ប្រឹក្សាយោបល់ផ្នែកច្បាប់ការងារ កាលពីថ្ងៃអាទិត្យទី១៨ ខែមីនា ឆ្នាំ ២០១៨ នាទីក្រុងអ៊ីយចងប៊ូ ខេត្តខ្យុងគី។ លោកបន្តថា យ៉ាងហោចណាស់ការងារនេះវា បានជួយសម្រួលដល់បងប្អូនពលករខ្មែរបានចំនួន ៩៥នាក់ ពុំចាំបាច់ចំណាយពេលវេលា និងថ្លៃធ្វើដំណើរមកបន្តប៉ាស្ព័រនៅស្ថានទូត និងបានផ្សព្វផ្សាយច្បាប់ការងារ និងបើកវេទិកាពិគ្រោះយល់បល់ជាមួយបងប្អូនពលករប្រមាណ ១៥០នាក់ ពាក់ព័ន្ធនឹងស្ថានភាពរស់នៅ និងបញ្ហាប្រឈមរបស់ពលករខ្មែរដែលកំពុងបម្រើការនៅសាធារណរដ្ឋកូរ៉េ ដើម្បីស្វែងរកដំណោះស្រាយជាមួយស្ថាប័នពាក់ព័ន្ធ៕ ដោយ ៖ បញ្ញាស័ក្តិ

## ស្តាប់សម្តីពលករខ្មែរ ពិតជាអាណិតពន់ពេកណាស់

https://kohsantepheapdaily.com.kh ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨ម៉ោង ០៩:៥៧ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ក្នុងសភាពដូចអស់សង្ឃឹមអង្គុយម្នាក់ឯងរហូតទល់យប់នៅបរិវេណវត្តបាលិលេយ្យស្ថិតក្នុងភូមិក្បាលស្ពាន2 សង្កាត់ប៉ោយប៉ែត ក្រោយសួរនាំទើបដឹងការពិត និងអាណិតជាពន់ពេក គឺពលករម្នាក់ ទើបត្រូវគេបញ្ជូនពីថៃមក តែគ្មានប្រាក់ធ្វើសាហ៊ុយទៅស្រុកកំណើតទេ។ ពលករដ៏គួរឱ្យអាណិតខាងលើនេះឈ្មោះ វន វដ្តា ភេទប្រុស អាយុ30ឆ្នាំ ជាកម្មករសំណង់នៅបាងកក ប្រទេសថៃ និងមានទីលំនៅភូមិក្រាំងស្បូវ ឃុំព្រះពុទ្ធ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ពេលឃើញពលកររូបនេះអង្គុយលេងនៅបរិវេណវត្តខាងលើដោយអស់សង្ឃឹមរហូតដល់យប់ ដោយមានសង្ស័យភ្នាក់ងារកោះសន្តិភាពក៏សាកសួរទើបដឹងរឿងពិត គឺពលកររូបនេះអះអាងថា រូបគាត់ទើបត្រូវគេបញ្ជូនតាមរថយន្តទ្រុងរបស់ថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតកាលពីយប់ថ្ងៃទី18 មីនា បន្ទាប់ពីជាប់គុកធំ(ស៊ូនប្លូ) របស់ថៃអស់ជាង10ថ្ងៃ ។ ដោយសារគាត់ឆ្លងព្រំដែនពីខេត្តបន្ទាយមានជ័យតាមរយៈមេខ្យល់អស់ប្រាក់2700បាតនាំទៅធ្វើការជាកម្មករសំណង់នៅក្រុងបាងកកបានប្រហែល1ខែ។ ហើយការងារសំណង់នោះ ដោយខ្លួនមិនសូវចេះក៏ត្រូវថៅកែថៃដេញឲ្យឈប់ ប៉ុន្តែមិនបានប្រាក់សូម្បី1បាត ខណៈកំពុងដើររករថយន្តជិះត្រឡប់មកស្រុកចំណុចចំណតរថយន្ត (ម៉ឈីត) ស្រាប់តែតម្រួតថៃចាប់ដាក់គុកស៊ូនប្លូអស់ជាង10ថ្ងៃ ទើបតែបញ្ជូនត្រឡប់មកវិញ។

អ្វីដែលគួរឲ្យអាណិតបំផុតនោះពលករខាងលើអះអាងថា យប់ថ្ងៃ18 មីនានោះ ពេលសមត្ថកិច្ចថៃបញ្ជូនដល់ទីតាំងទទួលពលករក្នុងក្រុងប៉ោយប៉ែត ខណៈដើរចេញពីទីនោះខ្លួនបានទៅអង្គុយលេងនៅចំណុចរង្វង់មូលច្រកទ្វារអន្តរជាតិប៉ោយប៉ែតមួយយប់ទល់ភ្លឺ ព្រោះតែគ្មានប្រាក់ធ្វើដំណើរត្រឡប់ទៅស្រុកវិញ ពិសេសថ្លៃផ្ទះសំណាក់ ឬសណ្ឋាគារ ។ មិនតែប៉ុណ្ណោះនៅថ្ងៃទី១៩ បន្តសម្រាកនៅវត្តបាលិលេយ្យមួយថ្ងៃទល់យប់បន្តទៀត។ យ៉ាងណាក៏ដោយតាមរយៈអ្នកយកព័ត៌មានកោះសន្តិភាព និងព្រះច័ន្ទកម្ពុជា ពលកររូបនេះត្រូវបានសាខាលក់សំបុត្ររថយន្តក្រុងជួយសំបុត្ររថយន្តក្រុង1សន្លឹក ដើម្បីបន្តដំណើរទៅស្រុកកំណើតជួបមុខប្រពន្ធ និងកូន ។ ក្រៅពីនេះដោយមើលឃើញពីការខ្វះខាត

ព្រះសង្ឃគង់នៅវត្តបាលិលេយ្យព្រះនាម ម៉ាឡៃ និងអ្នកព័ត៌មាន ក៏បានជួយជាថវិកាដល់ពលករូបនេះមួយចំនួន ដើម្បីបានទិញនំចំណីហូបតាមផ្លូវទៀតផង៕

## ថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៨

## អូស្ត្រាលីសន្យា ផ្តល់ប្រាក់៨០ លានដុល្លារ អូស្ត្រាលី ដល់អាស៊ាន សម្រាប់បន្តកិច្ច សហប្រតិបត្តិការ ប្រឆាំងការជួញដូរមនុស្ស

https://www.dap-news.com/kh/ អង្គារ, ២០ មិនា ២០១៨ 17:15 ដោយៈ ដើមអម្ពិល ID:112

ភ្នំពេញ៖ រដ្ឋាភិបាល អូស្ត្រាលី បានសន្យា ផ្តល់ប្រាក់៨០ លានដុល្លារ អូស្ត្រាលី ដល់អាស៊ាន សម្រាប់បន្តកិច្ចសហប្រតិបត្តិការ ប្រឆាំងការជួញដូរមនុស្ស និងផ្តល់អាហារូបករណ៍ ចំនួន ៥០កន្លែង ដល់អ្នកដឹកនាំជំនាន់ ក្រោយមកពីបណ្តាញ ប្រទេសអាស៊ាន សម្រាប់បន្តការ សិក្សាថ្នាក់ក្រោយ ឧត្តមនៅប្រទេសអូស្ត្រាលី។ យោងតាមលទ្ធផលកិច្ចប្រជុំ កំពូលពិសេស អាស៊ាន-អូស្ត្រាលី ចាប់ពីថ្ងៃទី ១៦-១៨មីនា ដែលក្រសួង ការបរទេសខ្មែរ ទើបចេញផ្សាយ នៅថ្ងៃទី២០មីនានេះ បានឲ្យដឹងបន្ថែមថា "ថ្នាក់ដឹកនាំទាំងអស់ បានប្តេជ្ញាចិត្តបង្កើនការឆ្លើយតប ចំពោះបញ្ហាប្រឈមក្នុងតំបន់ និងសាកលលោក ដែលរួមមានបញ្ហាឧបទ្វីបកូរ៉េ ភេរវកម្ម និងជ្រុលនិយមហិង្សា និងសមុទ្រ ចិនខាងត្បូង"។

សេចក្តីប្រកាសព័ត៌មានដដែល បន្តថាកិច្ចប្រជុំកំពូល បានទទួលស្គាល់ពីតួនាទី ស្នូលរបស់ អាស៊ាននៅក្នុងដំណើរ វិវត្តន៍និម្មាបនកម្មតំបន់ ក្នុងការថែរក្សាសន្តិភាព ស្ថិរភាព និងកំណើន ប្រកបដោយបរិយាប័ន្ន ការរួមចំណែករបស់អាស៊ាន នៅក្នុងរយៈកាល ៥០ឆ្នាំកន្លងទៅ ដើម្បីសន្តិភាព និងវិបុលភាពតំបន់ព្រមទាំង បានកោតសរសើរ ចំពោះការ រួមចំណែក របស់អូស្ត្រាលី ដល់ការកសាងសហគមន៍អាស៊ានផងដែរ ។ កិច្ចប្រជុំកំពូលនេះ បានបញ្ជាក់ ជាថ្មីនូវសារៈសំខាន់ ដ៏ចាំបាច់ នៃការគោរពគ្នាទៅវិញ ទៅមកសំរាប់គោល ការណ៍ អធិបតេយ្យភាព បូរណភាពដែនដី សមភាព និងការមិនជ្រៀតជ្រែកកិច្ចការ ផ្ទៃក្នុង ដូចដែលមាន ចែងនៅក្នុងធម្មនុញ្ញរបស់អង្គការ សហប្រជាជាតិធម្មនុញ្ញអាស៊ាន និង សន្ធិសញ្ញាមិត្តភាពនិង កិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍។

ថ្នាក់ដឹកនាំអាស៊ាន-អូស្ត្រាលី បានឯកភាពពង្រឹង កិច្ចសហប្រតិបត្តិការផ្នែកសមុទ្រ កិច្ចការ ព័ត៌មានវិទ្យា (cyber affairs) ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ឧក្រិដ្ឋកម្មឆ្លងដែន និងការដោះស្រាយ ចំពោះការគំរាមកំហែងថ្មីៗផ្នែកសុខភាពក្នុងតំបន់។ ថ្នាក់ដឹកនាំក៏បានឯកភាពក្នុងការបង្កើន ទំនាក់ទំនងផ្នែកពាណិជ្ជកម្មការ វិនិយោគនិងធុរកិច្ច ព្រមទាំងជម្រុញទៅមុខនូវគំនិតផ្តួចផ្តើមថ្មីនៃទីក្រុងឆ្លាត (smart cities) ការអភិវឌ្ឍហេដ្ឋា រចនាសម្ព័ន្ធ និងកិច្ចសហប្រតិបត្តិការ គោលនយោបាយសេដ្ឋកិច្ច។ ថ្នាក់ដឹកនាំ អាស៊ាន-អូស្ត្រាលីក៏បានអញ្ជើញជាសក្ខីភាពក្នុងពិធីចុះហត្ថលេខាលើ "អនុស្សរណៈ នៃការយោគយល់គ្នា រវាងអាស៊ាន និងអូស្ត្រាលី ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងភេរវកម្មអន្តរជាតិ"៕

## ក្រសួងការងារកម្ពុជា ជំរុញឲ្យពលករខ្មែរដែលមិនទាន់បន្តសុពលភាពបណ្ណស៊ីជម្ពូនៅថៃ រួសរាន់ទៅបន្តឲ្យបានមុនថ្ងៃ៣១ ខែមីនា

http://www.freshnewsasia.com/ 2018-03-20

**(ភ្នំពេញ)៖** ក្រោយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ចេញសេចក្តីប្រកាសថា ភាគីថៃនឹងបិទដំណើរការបន្តសុពលភាពបណ្ណពណ៌ស៊ីជម្ពូ ដល់ពលករបរទេសរួចមក លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ បានជំរុញបន្ថែមដល់ពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅថៃ ហើយមិនទាន់ទៅបន្តសុពលភាពបណ្ណស៊ីជម្ពូនេះ ត្រូវរួសរាន់ទៅបន្តសុពលភាពបណ្ណស៊ីជម្ពូរបស់ខ្លួន ពីការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងការងារថៃ ឲ្យបានមុនថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។ លោកទទួចយ៉ាងដូច្នេះ ដោយសារមូលហេតុគតិយុត្តថា បើពលករដែលស្នាក់នៅ និងធ្វើការនៅប្រទេសថៃមិនទៅបន្តសុពលភាពបណ្ណពណ៌ស៊ីជម្ពូនេះទេ នោះអាជ្ញាធរថៃនឹងមិនអនុញ្ញាតឲ្យពលករទាំងនោះ អាចស្នាក់នៅនិងធ្វើការនៅប្រទេសថៃបានឡើយ។ លោក ហេង សួរ ហៅបណ្ណពណ៌ស៊ីជម្ពូនេះថា «បណ្ណមិនមែនសញ្ជាតិថៃ»។

ឆ្លើយតបជាមួយអង្គភាពព័ត៌មាន Fresh News នាល្ងាចថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨នេះ លោក ហេង សួរ បានឲ្យដឹងថា សេចក្តីប្រកាសព័ត៌មានពាក់ព័ន្ធនឹងសុពលភាព នៃការផ្តល់បណ្ណមិនមែនសញ្ជាតិថៃនេះ មិនពាក់ព័ន្ធនឹងយុទ្ធនាការផ្តល់ភាពស្របច្បាប់របស់គណៈកម្មការផ្តល់ភាពស្របច្បាប់ ដល់ពលករកម្ពុជាដែលស្នាក់នៅ និងធ្វើការនៅប្រទេសថៃទេ ពោលគឺគ្រាន់តែជាការក្រើនរំឭក និងជូនដំណឹងបន្ថែមដល់ពលករកម្ពុជាកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលមិនទាន់មានបណ្ណមិនមែនសញ្ជាតិថៃ (បណ្ណពណ៌ស៊ីជម្ពូ) ឲ្យប្រញាប់រួសរាន់ទៅធ្វើបណ្ណមិនមែនសញ្ជាតិថៃនេះ ពីការិយាល័យច្រកចេញចូលតែមួយរបស់ក្រសួងការងារថៃ ដែលនឹងផុតកំណត់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ ប៉ុណ្ណោះ។ ចំពោះការងារបន្តសុពលភាពបណ្ណស៊ីជម្ពូជូនពលករនេះ ជាសមត្ថកិច្ចរបស់ក្រសួងការងារថៃ។ មន្ត្រីជាន់ខ្ពស់ផ្នែកសកម្មប្រចាំក្រសួងការងាររូបនេះបានបន្តថា ក្រោយពលករទទួលបានបណ្ណមិនមែនសញ្ជាតិថៃពីអាជ្ញាធរថៃហើយ ពលករកម្ពុជាអាចទៅដាក់ពាក្យស្នើសុំបញ្ជាក់អត្តសញ្ញាណ ពីក្រុមការងារអន្តរក្រសួងចល័តរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់បាន។

ដោយសារមូលហេតុទាំងនេះហើយ ទើបអ្នកនាំពាក្យក្រសួងការងារកម្ពុជារូបនេះ អំពាវនាវយ៉ាងទទូចដល់ពលករខ្មែរត្រូវរួសរាន់បំពេញកិច្ចការចាំបាច់នេះឲ្យខាងតែបាន ព្រោះបើមិនបានទៅបន្តសុពលភាពបណ្ណមិនមែនសញ្ជាតិថៃតាមការបរិច្ឆេទទេ ពលករនឹងត្រូវប្រឈមនឹងការស្នាក់នៅ និងធ្វើការនៅប្រទេសថៃដោយខុសច្បាប់ ហើយអាជ្ញាធរថៃនឹងចាត់វិធានការយ៉ាងតឹងរឹង និងពុំអនុញ្ញាតឲ្យពលករទាំងនោះស្នាក់នៅ និងធ្វើការនៅប្រទេសថៃនោះឡើយ។ លោកបានបន្ថែមទៀតថា គិតត្រឹមថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជាសរុបចំនួន ៣០៩,៧៧២នាក់ ហើយយុទ្ធនាការនេះនៅតែអនុវត្តជាបន្តទៀត៕

## មួយថ្ងៃថៃបញ្ជូនសពពលករខ្មែរ៣នាក់ ឲ្យសាច់ញាតិ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៨ ម៉ោង ២១:៣៦ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ ត្រឹមតែមួយថ្ងៃសោះមានសាកសពពលករខ្មែរចំនួន៣នាក់ ត្រូវបានភាគីថៃ ធ្វើការបញ្ជូនឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅថ្ងៃទី២០ មីនា ២០១៨នេះ។ ២នាក់ស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ និងម្នាក់ដេកស្លាប់សង្ស័យខ្យល់គ។ ជនរងគ្រោះស្លាប់ដោយ គ្រោះថ្នាក់ចរាចរណ៍បានកើតឡើងនៅក្រុងបាងកក កាលពីថ្ងៃទី១៧ មីនា ២០១៨ ខណៈដើរឆ្លងផ្លូវ ពេលចេញពីធ្វើការត្រូវរថយន្តបុក។ ហើយម្នាក់ឈ្មោះ សៅ ម៉ៅ ភេទប្រុស អាយុ៤៣ឆ្នាំ ជាកម្មករសំណង់ និងមានទីលំនៅស្រុកគិរីវង់ ខេត្តតាកែវ និងម្នាក់ឈ្មោះ ជុំ ចេក ភេទប្រុស អាយុ២២ឆ្នាំ ជាកម្មករសំណង់ និងមានទីលំនៅឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ ដោយឡែកករណីដេកស្លាប់សង្ស័យ ខ្យល់គ បានកើតឡើងនៅខេត្តសាមុទ្រប្រាកាន កាលពីយប់ថ្ងៃទី១៩ មីនា ២០១៨។ ជនរងគ្រោះឈ្មោះ ហែល ម៉ាប់ ភេទប្រុស អាយុ២១ឆ្នាំ ជាកម្មកររើសអេតចាយ និងមានទីលំនៅភូមិចេក ឃុំស្វាយចចឹក ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ សពទាំង៣ ក្រោយភាគីថៃបញ្ជូនដល់កម្ពុជា ក្រុមសាច់ញាតិជួលរថយន្តដឹកបន្តទៅស្រុកកំណើតរៀងខ្លួន ដើម្បីធ្វើបុណ្យតាមប្រពៃណី៕

## ពលករខ្មែរម្នាក់ដេកស្លាប់នៅក្នុងបន្ទប់,សាច់ញាតិសង្ស័យថាកើតខ្យល់គរ

http://www.pheaktraprak.com/ March 20, 2018

ករណីពលករខ្មែរដេកស្លាប់បាត់បង់ជីវិតនេះបានកើតឡើងកាលពីវេលាម៉ោង09:40នាទី ព្រឹកនាថ្ងៃអង្គារទី20 ខែមីនា ឆ្នាំ2018 នៅត្រង់ចំណុចក្នុងបន្ទប់ស្នាក់នៅរបស់កម្មករសំណង់មួយកន្លែងស្ថិតនៅក្នុង(ម៉ូបាន)ថាសាលា សង្កាត់ថាសាលា ក្រុងបាងកក ជាប់ខេត្តនុនថាកបុរី ប្រទេសថៃ។ យោងតាមរបាយការណ៍ពីរបស់សមត្ថកិច្ចដែលចុះត្រួតពិនិត្យសាកសពនៅនិងកន្លែងកើតហេតុបានឲ្យដឹងថា អ្នកស្លាប់មានឈ្មោះ ចឹន សុខ (Chin Sok) អាយុ 38ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាកម្មករសំណង់ធ្វើការនៅនិងកន្លែងកើតហេតុ។ តាមការបញ្ជាក់របស់សាច់ញាតិរបស់អ្នកស្លាប់

ទាំងប្រាំនាក់ដែលធ្វើការសំណង់នៅទីនោះបានប្រាប់សមត្ថកិច្ចអោយដឹងថា កាលពីព្រឹកមិញនេះគេមិនឃើញបុរស់ខាងលើចុះទៅធ្វើការ ហើយសាច់ញាតិគាត់បានឡើងទៅដាស់អោយចុះធ្វើការតែមិនក្រោកលុះដល់ត្រួតពិនិត្យទើបដឹងថាគាត់បានស្លាប់បាត់បង់ជីវិតទៅហើយ ហើយរាយការណ៍ជូនសមត្ថកិច្ចថៃ អោយមកធ្វើការត្រួតពិនិត្យ បន្ទាប់ពីធ្វើការត្រួតពិនិត្យបឋមរួចសមត្ថកិច្ចបានបញ្ជូនសពអ្នកស្លាប់ទៅរក្សាទុកនៅមន្ទីរពេទ្យដើម្បីធ្វើការវិនិច្ឆ័យនៃការស្លាប់ម្តងទៀត រួចទើបប្រគល់ជូនសាច់ញាតិអោយយកទៅធ្វើបុណ្យតាមប្រពៃណី។

## កម្មករភូមាព្រហើនត្រួតគ្នាវាយប្រពន្ធពលករខ្មែរបែកចិញ្ចើម,ត្រូវពលករខ្មែរកាប់ស្លាប់ម្នាក់របួសធ្ងន់ម្នាក់

http://www.pheaktraprak.com/ March 21, 2018

កម្មករភូមាចំនួន02នាក់ ត្រូវបុរស់ពលករខ្មែរម្នាក់ចាក់បណ្តាលឲ្យស្លាប់ម្នាក់ និងរងរបួសធ្ងន់ចំនួន01នាក់ បន្ទាប់ពីកម្មករសញ្ជាតិភូមាទាំង02នាក់ ប្រើអំពើហិង្សាវាយមកស្ត្រីជនជាតិថៃម្នាក់ត្រូវជាប្រពន្ធរបស់បុរសពលករខ្មែរ ហូតដល់បែកចិញ្ចើម។ ករណីហេតុការណ៍បង្កអំពើហិង្សាចាក់គ្នាស្លាប់និងរបួសនេះបានកើតឡើងនៅកាលពីម៉ោង 10:45នាទីយប់ថ្ងៃអង្គារទី20 ខែមីនា ឆ្នាំ2018 នៅត្រង់ចំណុចបរិវេណកន្លែងស្នាក់នៅរបស់កម្មករធ្វើការសំណង់មួយ កន្លែងក្បែរផ្លូវជាតិឡាំប៉ាង-ឈាងម៉ៃទល់មុខនៅមុខមហាវិទ្យាល័យថាមសាត ស្ថិតក្នុងសង្កាត់ប៉ុងយ៉ាងខក ស្រុកហាងឆាត ខេត្តឡាំប៉ាង ប្រទេសថៃ។

យោងតាមរបាយការណ៍ពីកន្លែងកើតហេតុបានឲ្យដឹងថា បុរសកម្មករឈ្មោះ អ៊ីក ធូលូ អាយុ 32ឆ្នាំ សញ្ជាតិភូមា ត្រូវគេចាក់ និងកាំបិតធ្លាយពោះវៀនចេញខាងក្រៅរួចស្លាប់បាត់បង់ជីវិត ខណៈពេលកំពុងគេបញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ ចំណែកឯជនរងគ្រោះម្នាក់ទៀតឈ្មោះធូន លុងម៉ុង អាយុ25ឆ្នាំសញ្ជាតិភូមា បានរងរបួសត្រូវគេចាក់និងកាំបិតចំស្មាខាងឆ្វេងនិងក្រោយខ្នងបណ្តាលឱ្យរងរបួសធ្ងន់ ក្នុងហេតុការណ៍នេះនៅមានស្ត្រីជនជាតិថៃម្នាក់ទៀតឈ្មោះ ចាន់តាក់ណា រ៉ះយ៉ាណា អាយុ31ឆ្នាំ រស់នៅក្នុងខេត្តឈាងម៉ៃ បានរងរបួសបែកចិញ្ចើមផងដែរ។ ប្រភពពីស្ត្រីជនជាតិថៃឈ្មោះចាន់តាក់ណាបានរៀបរាប់ប្រាប់សមត្ថកិច្ចនៅនិងកន្លែងកើតហេតុឲ្យបានដឹងថា នៅមុនកើតហេតុបុរសកម្មករភូមាទាំងពីរនាក់បានប្រើអំពើហិង្សាមកលើរូបនាង ខណៈពេលនោះប្តីរបស់នាងដែលជាពលករខ្មែរនៅក្បែរនោះឃើញហេតុការណ៍បានស្រវាកាំបិតចាក់លើកម្មករភូមាទាំងពីរនាក់បណ្តាលឱ្យដួលសន្លប់នៅនឹងកន្លែង ក្រោយពេលកើតហេតុប្តីរបស់នាងបានឡើងរថយន្តតូយូតា វីហ្គូ ពាក់ស្លាកលេខក្រុងថេបមួយគ្រឿងជិះចេញទៅបាត់ទៅ។ បច្ចុប្បន្នកម្លាំងសមត្ថកិច្ចតម្រួតថៃកំពុងធ្វើការតាមស្រាវជ្រាវចាប់ខ្លួនបុរសពលករខ្មែរខាងលើ ដើម្បីយកមកធ្វើការសាកសួរនិងចាត់វិធានការតាមផ្លូវច្បាប់។

## ថៃ ដាក់ឱសានវាទចាត់វិធានការលើពលករបរទេស ដែលបម្រើការខុសច្បាប់

http://www.postkhmer.com/ ឃុត សុភចរិយា | Publication date 21 March 2018 | 09:01 ICT

**ភ្នំពេញៈ** អាជ្ញាធរថៃបានព្រមានចាត់វិធានការផ្លូវច្បាប់យ៉ាងតឹងរ៉ឹងបំផុត ទៅលើពលករបរទេសទាំងអស់ រួមទាំងពលករកម្ពុជាដែលកំពុងស្នាក់នៅ និងបម្រើការងារដោយខុសច្បាប់នៅក្នុងប្រទេសថៃ។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ដែលបានចេញផ្សាយកាលពីថ្ងៃចន្ទ និងដែលភ្នំពេញ-ប៉ុស្តិ៍ទទួលបានកាលពីម្សិលមិញនេះ។ សេចក្តីប្រកាសព័ត៌មានបានឲ្យដឹងថារដ្ឋាភិបាលថៃនឹងបិទដំណើរការបន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្តោះអាសន្ន (ប័ណ្ណស៊ីជម្ពូ និងលិខិតបញ្ជាក់ទំនាក់ទំនងរវាងថៅកែ និង ពលករ) នៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៨ ជាកំហិត។ ផុតកាលកំណត់បរិច្ឆេទខាងលើនេះអាជ្ញាធរថៃនឹងចាត់វិធានការតឹងរ៉ឹងតាមច្បាប់ចំពោះពលករបរទេសទាំងអស់ដែលពុំមានច្បាប់អនុញ្ញាត ឲ្យស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ ជាមួយគ្នានេះស្ថានទូតក៏បានធ្វើការអំពាវនាវឲ្យពលករខ្មែរទាំងអស់ដែលកំពុងបម្រើការងារនៅប្រទេសថៃ ដែលនៅពុំទាន់បានបន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្តោះអាសន្ន ឲ្យប្រញាប់រួសរាន់ទៅបំពេញបែបបទដើម្បីបន្តសុពលភាពប័ណ្ណស្នា

ក់នៅ និងធ្វើការបណ្ដោះអាសន្ននៅការិយាល័យច្រកចេញចូលតែមួយរបស់ភាគីថៃ ដែលស្ថិតនៅតាមបណ្ដាខេត្ត-ក្រុង ដែលបងប្អូនកំពុងរស់នៅ និង បម្រើការងារជាបណ្ដោះអាសន្នក្នុងប្រទេសថៃនេះឲ្យបានរួចរាល់ត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៨ ខាងមុខនេះ។

លោក ឈីវ ធន្ទះ លេខាទី ២ ស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក ប្រទេសថៃ កាលពីម្សិលមិញថ្លែងថា ស្ថានទូតជំរុញឲ្យពលករខ្មែរមានការភ្ញាក់រឭក និងកុំជឿឃោសនាមេខ្យល់ដែលនាំឲ្យខាតបង់ពេលវេលា និងថវិកា និងដែលអាចប្រឈមទៅនឹងការចាត់វិធានការផ្លូវច្បាប់របស់អាជ្ញាធរថៃ។ លោកបានថ្លែងថា៖ «យោងតាមសេចក្ដីជូនដំណឹងរបស់រដ្ឋាភិបាលថៃ កាលពីដើមខែកុម្ភៈការបន្តផ្ដល់សុពលភាពប័ណ្ណស៊ីជម្ពូ និងលិខិតបញ្ជាក់ទំនាក់ទំនងរវាងថៅកែ និង ពលករដល់ពលករបទេសទាំងអស់គឺបានចាប់ផ្ដើមពីថ្ងៃទី ៥ ខែកុម្ភៈដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៨ ខាងមុខនេះ។ ក្នុងករណីពលករបរទេសណាម្នាក់យឺតយ៉ាវក្នុងការបំពេញបែបបទបន្តសុពលភាពតាមកាលកំណត់ អាជ្ញាធរ [ថៃ] នឹងចាត់វិធានការយ៉ាងតឹងរ៉ឹងបំផុតទៅតាមផ្លូវច្បាប់»។ លោក ធន្ទះ ថា ប័ណ្ណស៊ីជម្ពូ និងលិខិតបញ្ជាក់ទំនាក់ទំនងរវាងថៅកែ និងពលករមានសុពលភាពរយៈពេល ២ ឆ្នាំ មានន័យថារៀងរាល់ ២ ឆ្នាំម្ដងពលករត្រូវទៅបំពេញបែបបទបន្តសុពលភាពឡើងវិញ។ ទោះជាបែបណាក្ដីលោកមិនអាចបញ្ជាក់អំពីប្រសិទ្ធភាពរបស់ប័ណ្ណនេះនៅក្នុងការប្រើប្រាស់សម្រាប់ធ្វើដំណើរទៅមកដោយឆ្លងកាត់ព្រំដែននៃប្រទេសទាំង ២ (កម្ពុជា-ថៃ) នោះទេ។

លោកថ្លែងថា៖ «ប័ណ្ណនោះគឺសម្រាប់បញ្ជាក់ពីទំនាក់ទំនងរវាងថៅកែ និងពលករ និងកន្លែងស្នាក់អាស្រ័យបណ្ដោះអាសន្នរបស់ពលករដែលចេញដោយភាគីថៃប៉ុណ្ណោះ។ ការធ្វើដំណើរឆ្លងកាត់ទៅ-មកក្នុងប្រទេសកម្ពុជា-ថៃ គឺត្រូវមានលិខិតធ្វើដំណើរ ឬ លិខិតបញ្ជាក់អត្តសញ្ញាណ (Travel Document) ដែលមន្ត្រីរដ្ឋាភិបាលយើងកំពុងចុះមកធ្វើ និងផ្ដល់ជូនពលករយើងដល់ប្រទេសថៃ ហើយតាមរយៈកិច្ចព្រមព្រៀងក្រសួងការងារនៃប្រទេសទាំង ២ ការធ្វើលិខិតធ្វើដំណើរ ឬលិខិតបញ្ជាក់អត្តសញ្ញាណ (Travel Document) ដល់ពលករខ្មែរដែលកំពុងស្នាក់នៅ និងបំពេញការងារក្នុងប្រទេសថៃ និងបន្តរហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៨ ខាងមុខនេះ»។

យោងតាមរបាយការណ៍ព័ត៌មានរបស់ក្រសួងការងារ ពលករខ្មែរដែលកំពុងបម្រើការងារនៅប្រទេសថៃមានប្រមាណជាង ១ លាន ៥ ម៉ឺននាក់ក្នុងនោះមានជាង ៧០ ម៉ឺននាក់ជាពលករស្របច្បាប់ ខណៈជាង ៣០ ម៉ឺននាក់ទៀតនៅពុំទាន់មានភាពស្របច្បាប់នៅឡើយ។ លោក ឃុន ថារ៉ូ មន្ត្រីកម្មវិធីជាន់ខ្ពស់នៃមជ្ឈមណ្ឌលអាមេរិកាំង ដើម្បីសាមគ្គីភាពការងារអន្តរជាតិ (ACILS) បានថ្លែងនៅថ្ងៃម្សិលមិញថា ដើម្បីកាត់បន្ថយភាពស្មុគស្មាញ និងហានិភ័យនានាដល់ពលករចំណាកស្រុកកម្ពុជាដែលកំពុងស្នាក់នៅ និងបំពេញការងារនៅក្នុងប្រទេសថៃ រដ្ឋាភិបាលកម្ពុជាគួរតែរិះរកមធ្យោបាយបញ្ចុះបញ្ចូលរដ្ឋាភិបាលថៃឲ្យលុបចោលប័ណ្ណស៊ីជម្ពូនេះ។ លោកបានថ្លែងថា៖ «ប័ណ្ណស៊ីជម្ពូគ្រាន់តែជាឯកសារបណ្ដោះអាសន្នដែលបញ្ជាក់អំពីទំនាក់ទំនងរវាងថៅកែ និងពលករ វាមិនមានភាពស្របច្បាប់ទូលំទូលាយនោះទេ ព្រោះវាមិនមែនជាឯកសារបញ្ជាក់អត្តសញ្ញាណ ឬ ឯកសារធ្វើដំណើរដែលចេញដោយប្រទេសកំណើតរបស់ពលករទេ។ ផ្ទុយទៅវិញឯកសារនេះបង្កឲ្យមានភាពស្មុគស្មាញ និងការខាតបង់ថវិកាជាច្រើនដល់ពលករ។ ខ្ញុំយល់ថាបើរដ្ឋាភិបាលកម្ពុជាយើងអាចនិយាយបញ្ចុះបញ្ចូលរដ្ឋាភិបាលថៃឲ្យលុបចោលប័ណ្ណស៊ីជម្ពូនេះបាន គឺល្អខ្លាំងណាស់សម្រាប់ពលករយើង»។ បើតាមការអះអាងរបស់លោក ថារ៉ូ ពលករខ្មែរដែលកំពុងបម្រើការងារនៅប្រទេសថៃមានប្រមាណជាង ១ លាន ៥ សែននាក់ក្នុងនោះពលករប្រមាណជិត ១ លាននាក់ទទួលបានភាពស្របច្បាប់ហើយ ខណៈជាង ៥០ ម៉ឺននាក់ទៀតនៅពុំទាន់មានភាពស្របច្បាប់នៅឡើយ។ លោកបានបញ្ជាក់ថា៖ «បើសិនជាពុំមានការសម្របសម្រួល ឬ ចរចាជុំវិញករណីនេះទេ ពលករខ្មែរដែលនៅពុំទាន់ទទួលបានភាពស្របច្បាប់ ឬ នៅមិនទាន់បានបន្តសុពលភាពប័ណ្ណស៊ីជម្ពូនោះនឹងត្រូវប្រឈមការចាប់ខ្លួន ឬ បណ្ដេញចេញពីប្រទេសថៃដូចកាលពីប៉ុន្មានឆ្នាំមុននេះ»៕

# ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៨

# កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ ជំរុញឲ្យមានកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរ

http://www.rasmeinews.com/ March 22, 2018, 7:25 AM

**ដោយ ៖ វិបុល**/(ភ្នំពេញ)៖ ក្រសួងការពារប្រទេសថៃ បានទទួលធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំ គណៈកម្មាធិការព្រំដែនទូទៅ ថៃ-កម្ពុជា (GBC) លើកទី១៣ ដែលបានប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ដែលកិច្ចប្រជុំនេះ ត្រូវបានដឹកនាំដោយសហប្រធាន នាយឧត្តមសេនីយ៍ ប្រាវីត វង្សសុវណ្ណ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេសថៃ និងសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា។ កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ លើកទី១៣នេះ មានគោលបំណងរំលឹកឡើងវិញ ក្នុងពេលកន្លងមកក្នុងការអនុវត្តការងារកំណត់ហេតុ កិច្ចប្រជុំគណៈកម្មការព្រំដែនទូទៅលើកទី១២ រួមទាំងកំណត់ទិសដៅនៃកិច្ចសប្រតិបត្តិការ រក្សាសន្តិភាព ស្ថិរភាពនៅតាមបណ្តោយព្រំដែន នៃប្រទេសទាំងពីរកម្ពុជា-ថៃ។

នៅក្នុងកិច្ចប្រជុំនេះដែរ សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិកម្ពុជា និងនាយឧត្តមសេនីយ៍ ប្រាវីត វង្សសុវណ្ណ ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារប្រទេសនៃព្រះរាជាណាចក្រថៃឡង់ដ៍ បានសន្យារួមគ្នាថានឹងមិនឲ្យព្រំដែននៃប្រទេស ទាំងពីរមានបញ្ហាអ្វីកើតឡើងនោះឡើយហើយនឹងខិតខំធ្វើយ៉ាងណាជម្រុញឲ្យប្រជាជនប្រទេសទាំងពីរមានការអភិវឌ្ឍនិងរីកចម្រើនឡើងលើគ្រប់វិស័យថែមទៀត។នាយឧត្តមសេនីយ៍ ប្រាវីត វង្សសុវណ្ណ បានលើកឡើងថា ដោយសម្ព័ន្ធមេត្រីភាពចំណងមិត្តភាពនិងមនោសញ្ចេតនាស្មោះត្រង់រវាងកងទ័ពទាំងពីរ បានធ្វើឲ្យកិច្ចប្រជុំលើកនេះបានសម្រេចជោគជ័យដូចកិច្ចប្រជុំលើកមុនៗកន្លងមកដែល អាចភ្ជាប់កិច្ចសហប្របត្តិការដែលមានស្រាប់ព្រមទាំងការអភិវឌ្ឍឱ្យមានការរីកចម្រើនឡើងថែមទៀត និងផ្តល់ផលប្រយោជន៍ឱ្យដល់ព្រំដែននៃប្រទេសទាំងពីរគឺជាព្រំដែនសុខសន្តិភាព មិត្តភាពកិច្ចសហប្រតិបត្តិការយ៉ាងពិតប្រាកដ។

ជាមួយគ្នានោះសម្តេចពិជ័យសេនា ទៀ បាញ់ ក៏បានសម្តែងនូវក្តីសោមនស្សរីករាយ ដោយបានឃើញភាពរីកចម្រើនយ៉ាងល្អប្រសើរក្នុងទំនាក់ទំនង និងកិច្ចសហប្របត្តិការរវាងកងទ័ពនៃប្រទេសទាំងពីរកម្ពុជា-ថៃដែលស្តែងឲ្យឃើញ តាមរយៈការបង្កើតយន្តការប្រជុំប្រចាំ ឆ្នាំរវាងអគ្គមេបញ្ជាការកងទ័ព ការបង្កើនតួនាទីការិយាល័យទំនាក់ទំនងព្រំដែន ការចេញបញ្ជីឈ្មោះអ្នកទំនាក់ទំនងបន្ទាន់(Hotline) រវាងអាជ្ញាធរសន្តិសុខនៅតាមតំបន់ព្រំដែនគ្រប់លំដាប់ថ្នាក់ និងការពង្រឹងកិច្ចសហប្រតិបត្តិការលើអង្គភាពពេទ្យយោធា ដែលទាំងអស់នេះជាភស្តុតាងបង្ហាញនូវការវិវត្តន៍ជាវិជ្ជមានក្នុងភាពជាដៃគូនិងចំណងមិត្តភាពដ៏ល្អប្រពៃរវាងប្រទេសយើងទាំងពីរ សមស្របតាមតួនាទីដ៏សំខាន់នៃគណៈកម្មាធិការព្រំដែនទូទៅរបស់យើង លើវិស័យសន្តិសុខ សន្តិភាព និងការអភិវឌ្ឍជាដើម។ សម្តេចពិជ័យសេនា ទៀ បាញ់ បានថ្លែងទៀតថា ការប្រជុំថ្ងៃនេះមិនត្រឹមតែជាវេទិកាមួយផ្តល់ឱកាសឲ្យយើង សម្រាប់ធ្វើការពិភាក្សានិងផ្លាស់ប្តូរទស្សនៈដ៏ល្អជាមួយគ្នាដើម្បីអភិវឌ្ឍន៍ប្រទេសជាតិនិងតំបន់ប៉ុណ្ណោះទេ តែក៏ជាចលករជំរុញអោយភាពជាដៃគូរវាងយើងកាន់តែស៊ីជម្រៅ និងបង្កើនការកសាងទំនុកចិត្តក្នុងគោលបំណងជានាការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារសន្តិភាពប្រកបដោយនិរន្តរភាពស្ថេរភាពកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍តាមមាគ៌ាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល នៃប្រទេសទាំងពីរកម្ពុជា-ថៃ កើតចំណងទាក់ទងល្អភាពជាដៃគូភាពជាអ្នកជិតខាងល្អប្រកបដោយមិត្តភាពនិងការគោរពគ្នាទៅវិញទៅមកលើគ្រប់វិស័យ ដោយអនុលោមទៅតាមផលប្រយោជន៍ជាមូលដ្ឋានរបស់ប្រជាពលរដ្ឋបូជាសពទៅនឹងការរក្សាសន្តិភាពសន្តិសុខ និងសន្តិភាពនៅក្នុងតំបន់ទាំងមូលផងដែរ។

គួរបញ្ជាក់ដែរថា កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ លើកទី១៣ ត្រូវបានរៀបចំឡើងដោយយោងទៅតាមកិច្ចព្រមព្រៀងនៃការបង្កើតកិច្ចសហប្រតិបត្តិការព្រំដែនរវាងកម្ពុជា និងថៃ ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការដើម្បីសន្តិភាព និងសន្តិសុខក្នុងតំបន់ព្រំដែន ក៏ដូចជាការបន្ថែមនូវទំនាក់ទំនង រវាងកងទ័ព និងកងឯកភាពសន្តិសុខពាក់ព័ន្ធដទៃទៀតរបស់កម្ពុជា និងថៃ។ តាមរយៈកិច្ចប្រជុំនេះភាគីទាំងពីរ ក៏បានពិនិត្យឡើងវិញនូវលទ្ធផល នៃការអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការផ្សេងៗ ដែលបានដាក់ចេញដោយកិច្ចប្រជុំគណៈកម្មការព្រំដែនទូទៅ លើកទី១២ កាល

ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧នៅខេត្តសៀមរាប ដូចជាកិច្ចសហប្រតិបត្តិការលើការឆ្លងកាត់ព្រំដែន បញ្ហាពលករ ការទប់ស្កាត់ និងបង្ក្រាបការជួញដូរគ្រឿងញៀន ការលើកកម្ពស់កិច្ចសហប្រតិបត្តិការវាងកងទ័ពកម្ពុជា ជាមួយបណ្ដាអង្គភាពសន្តិសុខថៃ នៅតំបន់ព្រំដែន បញ្ហាកសិកម្ម បញ្ហាសុខភាពសាធារណៈ ការអភិវឌ្ឍន៍ ជាភាពរស់នៅ ការអប់រំ សាសនា និងវប្បធម៌។ កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅលើកទី១៣នេះ ក៏បានជំរុញឲ្យភាគីទាំងពីរ កម្ពុជា-ថៃ បន្តនូវភារកិច្ចក្នុងការថែរក្សាសន្តិភាពស្ថេរភាព តាមបណ្ដោយព្រំដែនប្រទេសទាំងពីរ ដោយស្របតាមគោលការណ៍ និងវិធានការដែលបានកំណត់ ក្នុងកំណត់ហេតុព្រមព្រៀង នៃកិច្ចប្រជុំលើកទី១៣នេះ លើគ្រប់ទិដ្ឋភាពទាំងអស់៕

## ពលករខ្មែរចំណាកស្រុកខុសច្បាប់នៅថៃប្រឈមមុខនឹងការបណ្ដេញចេញ

https://wmc.org.kh/ ថ្ងៃពុធ ទី២១ ខែមីនា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ អាជ្ញាធរថៃនឹងចាប់ផ្ដើមបណ្ដេញពលករបរទេសធ្វើការដោយខុសច្បាប់ទាំងអស់ក្នុងនោះរួមទាំងពលករកម្ពុជាបន្ទាប់ពីអាជ្ញាធរប្រកាសបិទការបន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្ដោះអាសន្នឬប័ណ្ណស៊ីជម្ពូនិងលិខិតទំនាក់ទំនងរវាងថៅកែនិងពលករនៅថ្ងៃទី៣១ ខែ មីនានេះ។ អ្នកនាំពាក្យក្រសួងការងារអះអាងថាយន្តការនេះមិនប៉ះដល់យុទ្ធនាការផ្ដល់ភាពស្របច្បាប់ដល់ពលរដ្ឋកម្ពុជាទេ។

សេចក្ដីប្រកាសព័ត៌មានរបស់ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃចេញផ្សាយនៅថ្ងៃទី ១៩ មីនាថា អាជ្ញាធរថៃនឹងចាត់វិធានការយ៉ាងតឹងរឹងតាមច្បាប់ចំពោះពលករបរទេសទាំងអស់រួមទាំងពលករខ្មែរដែលស្នាក់នៅ និងធ្វើការដោយខុសច្បាប់នៅប្រទេសថៃ។ករណីនេះអាជ្ញាធរថៃនឹងលែងបន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្ដោះអាសន្នឬប័ណ្ណស៊ីជម្ពូ និងលិខិតទំនាក់ទំនងរវាងថៅកែនិងពលករ។ការអនុវត្តច្បាប់តឹងតែងចំពោះពលករបរទេសនឹងចាប់អនុវត្តនៅថ្ងៃទី១ ខែមេសា ឆ្នាំ ២០១៨ខាងមុខនេះ។ ជុំវិញការរឹតបន្តឹងពលករបរទេសនេះ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានប្រាប់អ្នកសារព័ត៌មានតាមរយៈលិខិតរបស់លោកនិយាយថាសុពភាពនៃការផ្ដល់ប័ណ្ណមិនមែនសញ្ញាតិថៃ ពុំពាក់ព័ន្ធនឹងយុទ្ធនាការផ្ដល់ភាពស្របច្បាប់របស់គណៈកម្មាធិការផ្ដល់ភាពស្របច្បាប់សម្រាប់ពលករខ្មែរដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសថៃ។ លោក ហេង សួរ ពន្យល់ថា ការអនុវត្តច្បាប់តឹងតែងចំពោះពលករបរទេសធ្វើនៅប្រទេសថៃនេះ គ្រាន់តែជាការក្រើនរំលឹកនិងជូនដំណឹងដល់ពលករខ្មែរកំពុងស្នាក់នៅនិងធ្វើការនៅថៃមិនទាន់មានប័ណ្ណពណ៌ស៊ីជម្ពូ។ លោក ហេង សួរ បញ្ជាក់ថា ពលករខ្មែរអាចមកដាក់ពាក្យស្នើសុំបញ្ជាក់អត្តសញ្ញាណជាមួយគណៈកម្មាធិការផ្ដល់ភាពច្បាប់ ក្រោយពីពលករខ្មែរទទួលបានប័ណ្ណពណ៌ស៊ីជម្ពូពីអាជ្ញាធរថៃ។ អ្នកនាំពាក្យរូបនេះ អះអាងថា គិតត្រឹមថ្ងៃចន្ទ ទី១៩ មីនានេះ គណៈកម្មការផ្ដល់ភាពស្របច្បាប់ខ្មែរបានផ្ដល់ភាពស្របច្បាប់ពលករខ្មែរសរុបជាង៣សែន៩ពាន់នាក់។លោកថាយុទ្ធនាការផ្ដល់ភាពស្របច្បាប់សម្រាប់ពលករខ្មែរនៅបន្តសុពលភាពជាធម្មតា។

ជាមួយគ្នានេះ ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ បានអំពាវនាវដល់ពលករខ្មែរទាំងអស់ដែលមមិនទាន់បន្តសុពលភាពប័ណ្ណស្នាក់នៅ និងធ្វើការបណ្ដោះអាសន្នត្រូវប្រញាប់រួសរាន់មកបន្តសុពលភាពនៅការិយាល័យច្រកចេញចូលតែមួយឲ្យបានមុនថ្ងៃទី៣១ ខែ មីនានេះ។ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០១៧របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការណ៍អន្តរជាតិបង្ហាញថាយ៉ាងតិចពលករខ្មែរជិត១ពាន់នាក់ត្រូវបាននិរទេសពីប្រទេសថៃមកកម្ពុជាតាមច្រកអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ៕

## ប្រទេសថៃអះអាងជាថ្មីក្នុងការ «ចុះបញ្ជីស្របច្បាប់ដល់ ពលករបរទេស ៣.៨លាននាក់» មកពី មីយ៉ាន់ម៉ា កម្ពុជា និងឡាវ!

http://www.freshnewsasia.com/ 2018-03-22

**(បាងកក)៖** រដ្ឋាភិបាលថៃ បានអះអាងឡើងវិញពីការប្ដេជ្ញាចិត្តរបស់ខ្លួន ក្នុងការចុះបញ្ជី និងផ្ដល់ភាពស្របច្បាប់ដល់ពលករចំណាកស្រុកជាង ៣.៨លាននាក់ មកពីប្រទេស មីយ៉ាន់ម៉ា កម្ពុជា និងឡាវ នៅត្រឹមចុងខែមីនានេះ។ នេះបើតាមការចេញផ្សាយដោយ ទីភ្នាក់ងារសារព័ត៌មានចិន ស៊ីនហួរ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២២ ខែមីនា ឆ្នាំ

២០១៨។ ជាមួយគ្នានោះដែរ បើតាមក្រសួងការងារថៃ រដ្ឋាភិបាលទីក្រុងបាងកក បានចាប់ផ្តើមផ្តល់សេវាកម្មស្របច្បាប់ដល់ពលករបរទេស កាលពីដើមខែកុម្ភៈ តាមរយៈការបើកច្រកចេញចូលតែមួយជាង ៨០កន្លែង ដើម្បីផ្តល់ភាពស្របច្បាប់ សម្រាប់ពួកគេទាំងអស់គ្នា ក្នុងគោលបំណងលុបបំបាត់ការរត់ពន្ធមនុស្សពលកម្មកុមារ និងការបង្ខំឱ្យធ្វើការនៅក្នុងប្រទេសថៃ។ «អ្វីដែលយើងកំពុងធ្វើ គឺមិនមែនជាការធ្វើទុក្ខលើអ្នកធ្វើការ ឬពលករចំណាកស្រុកនោះទេ។ តែផ្ទុយទៅវិញ យើងបាននិងកំពុងផ្តល់ភាព ងាយស្រួលឱ្យពួកគេក្លាយជាអ្នកធ្វើការ ឬពលករស្របច្បាប់ ដែលអាចបម្រើការងារនៅក្នុងប្រទេសថៃ អនុឡោមតាមច្បាប់របស់ថៃ»។ នេះបើតាមមន្ត្រីក្រសួងការងារថៃ លោកស្រី អានុសារី ថាស៊ូវ៉ាន់ (Anusari Thapsuwan) ថ្លែងនៅក្នុងសន្និសីទសារព័ត៌មានមួយនៅឯខេត្ត សាមុត សាខន (Samut Sakhon) កាលពីថ្ងៃចន្ទ។

គួរជំរាបថា ចាប់តាំងពីដើមខែកុម្ភៈ រដ្ឋាភិបាលថៃបានបង្កើត មជ្ឈមណ្ឌលច្រកចេញចូលតែមួយជាង ៨០កន្លែងទូទាំងប្រទេស ដើម្បីផ្តល់ភាពស្របច្បាប់ដល់ពលករបរទេសជាង ០២លាននាក់ ដែលខ្វះឯកសារស្របច្បាប់។ ដោយឡែក បើតាមរដ្ឋមន្ត្រីក្រសួងការងារថៃ លោក អាឌុល សាងស៊ីងកែវ (Adul Sangsingkeo) បច្ចុប្បន្នពលករបរទេសជាង ៣,៨០៩,៥១៩នាក់ កំពុងធ្វើការងារក្នុងប្រទេសថៃ ហើយ ១.៨លាននាក់ ក្នុងចំណោមនោះ កំពុងធ្វើការដោយស្របច្បាប់ ប៉ុន្តែពួកគេនៅតែត្រូវឆ្លងកាត់នីតិវិធីចុះឈ្មោះ ដើម្បីទទួលបានការអនុញ្ញាតឱ្យរស់នៅ និងទិដ្ឋាការធ្វើការងារស្របច្បាប់ ក្នុងប្រទេសថៃសម្រាប់រយៈពេល ០២ឆ្នាំ រហូតដល់ឆ្នាំ២០២០៕

## អាជ្ញាធរខេត្តកោះកុង ទទូចដល់ភាគីថៃ ជួយសម្រួលដល់ពលករខ្មែរ នៅពេលធ្វើដំណើរ ឬធ្វើការមិនទាន់មានច្បាប់ទម្លាប់ សុំត្រឹមចាប់បញ្ជូនមកវិញបានហើយ

http://www.freshnewsasia.com/ 2018-03-22

(កោះកុង)៖ ដើម្បីរិតចំណងមិត្តភាព រវាងស្រុកមណ្ឌលសីមា ខេត្តកោះកុង និងស្រុកខ្លងយ៉ៃ ខេត្តត្រាត ប្រទេសថៃ ដែលមានព្រំប្រទល់ជាប់គ្នា នារសៀលថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ បានបើកកិច្ចប្រជុំពិភាក្សាគ្នា ដើម្បីរកដំណោះស្រាយ ក្រោមប្រធានបទ «ប្រជាជន និងប្រជាជន, មន្ត្រីរាជការ និងមន្ត្រីរាជការ» ។ កិច្ចប្រជុំពិភាក្សានេះ ដោយភាគីកម្ពុជាដឹកនាំដោយលោក ហាក់ ឡេង អភិបាលស្រុកមណ្ឌលសីមា រួមទាំងមន្ត្រីក្រោយឱវាទ និងមន្ត្រីគ្រប់ស្ថាប័នប្រចាំ ច្រកទ្វារអន្តរជាតិចាំយាម។ ចំណែកឯភាគីថៃ ក្រោយការដឹកនាំដោយលោក ឆៃវ៉ាត់ អូធាណានុន អភិបាលស្រុកខ្លងយ៉ៃ រួមទាំងមន្ត្រីក្រោមឱវាទ។ កិច្ចប្រជុំពិភាក្សាខាងលើនេះ ធ្វើឡើងក្នុងបំណងដើម្បីឲ្យមានភាពងាយស្រួលក្នុងការធ្វើដំណើរចេញចូល តាមច្រកទ្វារអន្តរជាតិ ចាំយាម និងហាលិក រវាងប្រជាជនកម្ពុជា និងប្រជាជនថៃ ដើម្បីលើកស្ទួយផ្នែកវិស័យទេសចរណ៍ រវាងខេត្តកោះកុង និងខេត្តត្រាត។

លោក ហាក់ ឡេង បានលើកឡើងថា សូមឲ្យខាងភាគី ជួយសម្រួលដល់ប្រជាពលរដ្ឋកម្ពុជា ដែលពួកគាត់បានធ្វើដំណើរមកប្រទេសថៃ ដើម្បីរកការងារធ្វើ ហើយគ្មានច្បាប់ទំលាប់ ត្រឹមត្រូវ បើកភាគីថៃឃាត់ខ្លួនគាត់ សូមឲ្យអាជ្ញាធរថៃ ត្រូវបញ្ជូនគាត់មកដីកម្ពុជាវិញ ឬក៏ផ្តល់ព័ត៌មាន ជូនដល់អាជ្ញាកម្ពុជា ឲ្យមកទទួលពួកគាត់ មិនត្រូវធ្វើបាបគាត់ ឬយកពួកគាត់ដាក់ ពន្ធធនាគារឡើយ។ អភិបាលស្រុកមណ្ឌលសីមា បានបន្តថា សូមខាងអាជ្ញាធរថៃ មានបើកច្រកទ្វារព្រំដែន ឲ្យបានទូលំទូលាយបន្តិច នៅពេលក្រុមគ្រូពេទ្យ ត្រូវការជួយសង្គ្រោះអ្នកជំងឺបន្ទាន់ បញ្ជូនមក មន្ទីរពេទ្យថៃ បើខ្វះឯកសារបន្តិចបន្តួចអាជ្ញាធរថៃ ត្រូវមានការអនុគ្រោះផង។ លោកបានបន្តថា ក្នុងប្រជុំពិភាក្សាមន្ត្រីទាំងទ្វេភាគី ត្រូវចេះផ្លាស់ប្តូរ បទពិសោធន៍គ្នា ទៅវិញទៅមកនៅកិច្ចការអ្វីមួយ ដើម្បីលើកស្ទួយ ក្នុងការអភិវឌ្ឍន៍ប្រទេស ឲ្យកាន់តែមានភាព រីកចំរើន ទាំងជីវភាពប្រជាពលរដ្ឋ ទាំងផ្នែកវិស័យទេចរណ៍ ទាំងផ្នែកសេដ្ឋកិច្ច ហើយអ្វីដែលសំខាន់ គឺផ្នែកវិស័យទេសចរណ៍តែម្តង។

ចំណែកឯភាគី យល់ទទួលយក នូវសេចក្តីថ្លែងការ របស់លោកអភិបាលស្រុកមណ្ឌលសីមា តែភាគីថៃ និងជូនដំណឹង ក្នុងកិច្ចប្រជុំពិភាក្សារវាងស្រុកមណ្ឌលសីមា និងស្រុកខ្លងយ៉ៃ នៅខែសីហា ម្តងទៀត៕

## នោះ.! តម្រួត(តម៉)ចុះចាប់ដល់គូប ករណីធ្វើការខុសលក្ខខ័ណ្ឌ

http://www.pheaktraprak.com/ March 22, 2018

កាលពីវេលាម៉ោង07 ព្រឹកថ្ងៃពុធ ទី21 ខែមីនា ឆ្នាំ2018 កម្លាំងសមត្ថកិច្ចតម្រួតនិងអាជ្ញាធរមូលដ្ឋានក្នុងខេត្តចាន់បុរី ប្រទេសថៃ បានបើកកិច្ចព្រឹត្តិការណ៍ចុះចាប់ខ្លួនពលករបរទេសមួយចំនួនដែលកំពុងធ្វើការលក់ដូរខុសលក្ខខ័ណ្ឌការងារនៅត្រង់ចំណុចផ្សារប៉ូលីងស្ថិតក្នុងស្រុកមឿង ខេត្តចាន់បុរី ប្រទេសថៃ។ យោងតាមរបាយការណ៍សមត្ថកិច្ចថៃបានឲ្យដឹងថាពលករបរទេសចំនួន01នាក់ ត្រូវកម្លាំងអាជ្ញាធរថៃចាប់ខ្លួនចាប់បន្ទាប់ពីសមត្ថកិច្ចបានរកឃេើញឃើញថាពលកររូបនោះធ្វើការខុសពីបែអនុញ្ញាតការងារដែលក្រសួងការងារថៃបានកំណត់។ តាមការអេះអាងរបស់សមត្ថកិច្ចបានប្រាប់ថា កន្លងមកកម្លាំងសមត្ថកិច្ចធ្លាប់ចុះចាប់ពលករបរទេសដែលធ្វើការខុសលក្ខខ័ណ្ឌនៅផ្សារខាងលើនេះ ជាញឹកញាប់ណាស់ដែរ ក៏ប៉ុន្តែនៅតែមានពលករព្រឹត្តិបទល្មើសច្បាប់ដូចករណីមុនទៀត។ បន្ទាប់ពីឃាត់ខ្លួនពលកររូបនោះត្រូវសមត្ថកិច្ចបញ្ជូនយកទៅធ្វេើការសាកសួរនៅអធិការដ្ឋានតម្រួតអន្តោប្រវេសន៍ខេត្តចាន់បុរីដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការអោយចាត់វិធានការតាមផ្លូវច្បាប់ ។

## កុមាររ៉ូហ៊ីងយ៉ាត្រូវបានគេជួញដូរផ្លូវភេទនៅជំរំជនភៀសខ្លួនក្នុងប្រទេសបង់ក្លាដែស

http://bayontv.com.kh/ 21/03/2018

បង់ក្លាដែស៖ ការស៊ើបអង្កេតរបស់សារព័ត៌មាន BBC បានរកឃើញថា ក្មេងស្រីក្នុងវ័យជំទង់កំពុងត្រូវគេជួញដូរផ្លូវភេទ ក្នុងជំរំជនភៀសខ្លួនរ៉ូហ៊ីងយ៉ាក្នុងប្រទេសបង់ក្លាដែស។ ជនបរទេសកំពុងស្វែងរកសេវាផ្លូវភេទ អាចមានមធ្យោបាយងាយស្រួលក្នុងការទាក់ទងក្មេងៗ ដែលបានរត់ភៀសខ្លួនពីជម្លោះក្នុងប្រទេសមីយ៉ាន់ម៉ា ហើយបច្ចុប្បន្នប្រឈមនឹងការគំរាមកំហែងថ្មីមួយទៀត។ វ័យ ១៤ឆ្នាំក្មេងស្រី Anwara កំពុងរស់ភៀសខ្លួនពីប្រទេសមីយ៉ាន់ម៉ា បន្ទាប់ពីក្រុមគ្រួសាររបស់នាងត្រូវបានគេសម្លាប់ នាងបានស្វែងរកជំនួយនៅតាមដងផ្លូវ ទៅកាន់ប្រទេសបង់ក្លាដែស។ Anwara បាននិយាយថា មានស្ត្រីមួយចំនួនបានជិះរថយន្តមកជិតខ្ញុំ ហើយសួរខ្ញុំថាតើខ្ញុំព្រមទៅជាមួយពួកគេ ឬទេ? បន្ទាប់ពីទទួលយកជំនួយរបស់ពួកគេ នាងត្រូវបានទាញឡើងរថយន្តដោយសន្យាថា នឹងនាំនាងទៅទៅរកជីវិតថ្មី។ ផ្ទុយទៅវិញនាងត្រូវគេនាំទៅកាន់ជំរំជិតទីក្រុងខុកបាសា។ Anwara រៀបរាប់ថា មិនយូរប៉ុន្មានពួកគេបាននាំក្មេងប្រុស ២ នាក់មកឲ្យនាង។ ពួកគេលើកកាំបិតបង្ហាញនាង និងចាកពោះនាងរួចវាយធ្វើបាបរូបនាង ព្រោះនាងមិនព្រមធ្វើតាមពួកគេ។ បន្ទាប់មកក្មេងប្រុសទាំង ២នាក់នោះក៏បានចាប់រំលោភខ្ញុំ។ ការជួញដូរផ្លូវភេទនៅក្បែរជំរំជនភៀសខ្លួនមានកាន់តែច្រើន។ ស្ត្រី និងកុមារគឺជាជនរងគ្រោះខ្លាំងជាងគេ។ កុមារ និងឱពុកម្តាយរបស់គេបានប្រាប់ BBC ថា ពួកគេបានទទួលការងារនៅខាងក្រៅ និងក្នុងរដ្ឋធានីដាកា ជាអ្នកបម្រើតាមផ្ទះ, បុគ្គលិកសណ្ឋាគារ និងកម្មករផ្ទះបាយជាដើម៕ អត្ថបទ៖ សុខមាន

## ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៨

## សាលាឧទ្ធរណ៍ តម្កល់ទោសជននាំពលករ ១០ នាក់ទៅថៃ ឲ្យជាប់គុក ១៥ ឆ្នាំដដែល

http://www.postkhmer.com/ គឹម សារុំ | Publication date 22 March 2018 | 14:20 ICT

ភ្នំពេញៈ សាលាឧទ្ធរណ៍នៅព្រឹកថ្ងៃទី ២២ ខែមីនានេះ បានប្រកាសសាលដីកា សម្រេចតម្កល់ទោស ជនជាប់ចោទម្នាក់ ឲ្យជាប់ពន្ធនាគារ ១៥ ឆ្នាំដដែល បន្ទាប់ពីបើកសវនាការជំនុំជម្រះ កាលពីថ្ងៃទី ១៣ ខែមីនាឆ្នាំ ២០១៨ ពាក់ព័ន្ធនាំពលករ ១០ នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃ កាលពីឆ្នាំ ២០០៩។ ជនជាប់ចោទដែលជាមនុស្សថ្លង់ បានឈរផ្ទៀងត្រចៀកស្តាប់ ការប្រកាសសាលដីកា នៅក្នុងវង្វង់ក្រចកសេះដែលអានដោយលោកស្រីចៅក្រម គឹម ដានី ប្រធាន

ក្រុមប្រឹក្សាជំនុំជម្រះ នោះ បានថ្លែងដោយមិនបញ្ជាក់ពីមូលហេតុ នៃការតម្កល់សាលក្រមថា៖«ជនជាប់ចោទ ពាក់ព័ន្ធបទចោទជួញដូរមនុស្សត្រូវសាលាឧទ្ធរណ៍សម្រេចតម្កល់ទោស ១៥ ឆ្នាំដដែល»។

តាមអង្គហេតុរបស់នគរបាលខេត្តកោះកុង បានបង្ហាញថា កាលពីថ្ងៃ ២៦ ខែមករាឆ្នាំ ២០០៩ ឈ្មោះ នាង រុណ អាយុ ៥៤ ឆ្នាំ នៅថ្ងៃទី ៩ ខែមករាឆ្នាំ ២០០៩ បានបើករថយន្តតាក់ស៊ី ដឹកក្រុមជនរងគ្រោះប្រុស-ស្រីចំនួន ១០ នាក់ ដែលជាអនីតិជន ដើម្បីយកឲ្យចូលទៅធ្វើការនៅក្នុងប្រទេសថៃ។ ប៉ុន្តែពេលជនជាប់ចោទបានបើករថយន្ត ដល់ប្រកចាំយាម ឃុំប៉ាកខ្លង ស្រុកដងទុង ខេត្តកោះកុង ដោយមានការសង្ស័យ សមត្ថកិច្ចក៏ឃាត់រថយន្ត និងឃាត់ខ្លួនជនជាប់ជាប់តែម្តង។ សំណុំរឿងនេះ ត្រូវសាលាដំបូងខេត្តកោះកុង នៅថ្ងៃទី ១១ ខែវិច្ឆិកាឆ្នាំ ២០០៩ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ១៥ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ «ការនាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែននិង សមគំនិត» តាមបញ្ញត្តមាត្រា ១១ ច្បាប់ ស្តីពីការបង្រ្កាបការជួញដូរមនុស្ស និងមាត្រា ៦៨ នៃក្រមព្រហ្មទណ្ឌ ៕

## ក្តៅៗ.! អាជ្ញាធរថៃបើកយុទ្ធនាការបិទទីក្រុងចាប់ជនអន្តោប្រវេសន៍និងពលករខុសច្បាប់

http://www.pheaktraprak.com/ March 23, 2018

ព័ត៌មានក្តៅកម្លាំងអាជ្ញាធរថៃចុះបង្រ្កាបចាប់ជនអន្តោប្រវេសន៍ និងពលករខុសច្បាប់ទូទាំងទីក្រុងបាងកកកាលពីយប់មិញនេះ។ កាលពីវេលាម៉ោង01:00យប់ ថ្ងៃសុក្រទី23 ខែមីនា ឆ្នាំ2018នេះ កម្លាំងតម្រួតទេសចរណ៍ថៃសហការជាមួយកម្លាំងសមត្ថកិច្ចនានានៅក្នុងទីបាងកកចំនួនប្រមាណរាប់រយនាក់ បានបើកកិច្ចព្រឹត្តិការណ៍បិទប្ញីក្រុងចំនួន 108កន្លែង ដើម្បីត្រួតពិនិត្យចាប់ពលករបរទេសខុសច្បាប់ ក្នុងព្រឹត្តិការណ៍នេះកម្លាំងសមត្ថកិច្ចថៃធ្វើការឃាត់ខ្លួនបានជនបរទេស និងពលករខុសច្បាប់សរុបចំនួន125 នាក់ ក្នុងនោះមានពលករខុសច្បាប់សញ្ជាតិភូមា 60នាក់ ជនជាតិខ្មែរកាន់លិខិតឆ្លងដែនស្នាក់នៅផុតពលភាពចំនួន 4នាក់ និងពលករខ្មែរលួចឆ្លងដែនមកធ្វើការខុសច្បាប់ចំនួន 4នាក់ព្រមទាំងជនអន្តោប្រវេសន៍សញ្ជាតិផ្សេងទៀតរាប់សិបនាក់ទៀត។

## ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ ៤៨នាក់

https://www.dap-news.com/kh/ សុក្រ, ២៣ មិនា ២០១៨ 10:59 ដោយ: ស៊ាន កុសល ID:114

ភ្នំពេញ៖ស្ថានតំណាងកម្ពុជា ប្រចាំប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបូរី និងប្រទេសឡាវ បានជួយអន្តរាគមន៍ពលរដ្ឋខ្មែរ ចំនួន៤៨នាក់ បានវិលត្រឡប់មកស្រុកកំណើតវិញ នេះបើយោងតាមសេចក្តីជូនព័ត៌មាន របស់លោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស ដែលមជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល ទទួលបាននៅព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨នេះ។ បើតាមលោក ជុំ សុន្ទរី បានបញ្ជាក់ថា ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសឥណ្ឌូនេស៊ី បានជួយសម្របសម្រួល រៀបចំមាតុភូមិនិវត្តន៍ របស់ពលករនេសាទខ្មែរ ចំនួន៥នាក់ មកពីខេត្តព្រៃវែង ដែលត្រូវបានអាជ្ញាធរឥណ្ឌូនេស៊ីឃាត់ខ្លួន អំឡុងខែតុលា ឆ្នាំ២០១៧ ក្រោយពីទូកនេសាទ ដែលពួកគេធ្វើការ បានចូលក្នុងដែនទឹកឥណ្ឌូនេស៊ី។ ពលករទាំង៥នាក់នោះ បានត្រឡប់មកដល់កម្ពុជាវិញ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨ ដោយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ បានឧបត្ថម្ភសំបុត្រយន្តហោះជូន តាមសំណើរបស់ស្ថានទូត។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរ មានសមត្ថកិច្ច របស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍ របស់ពលករ-ពលការិនីខ្មែរ ចំនួន១៤នាក់ (នារី៩នាក់ បុរស៥នាក់) ដែលទៅធ្វើការដោយខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង១៤នាក់នោះ បានមកដល់កម្ពុជាវិញជាបន្តបន្ទាប់ នៅចន្លោះថ្ងៃទី១០ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ ។

លោកបានបន្តទៀតថា ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសសិង្ហបូរី បានជួយរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនី ខ្មែរ១នាក់ អាយុ៣៥ឆ្នាំ មកពីខេត្តព្រៃវែង ដែលមិនអាចទ្រាំទ្រ ការងារលំបាកនៅសិង្ហបូរីបាន។ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ និងជួយទាមទារលិខិតឆ្លងដែន និងសំបុត្រយន្តហោះពីភ្នាក់ងារនាំពលករ

ហើយពលការិនីបានមកដល់កម្ពុជាវិញ នៅថ្ងៃទី២០ ខែ មីនា ឆ្នាំ២០១៨ ។ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងប៉ាក់សេ ប្រទេសឡាវ បានអន្តរាគមន៍ ឲ្យមានការដោះលែងពលរដ្ឋខ្មែរ ចំនួន២៨នាក់ (ស្រី១នាក់) ដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចខេត្តអត្តពឺ ឃាត់ខ្លួនពីបទឆ្លងដែន និងធ្វើការខុសច្បាប់ក្នុងប្រទេសឡាវ។ ពលរដ្ឋទាំងនោះ បានត្រឡប់មកដល់កម្ពុជាវិញ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ តាមច្រកទ្វារអន្តរជាតិត្រពាំងក្រៀល (កម្ពុជា)-ណាងណុកខៀន (ឡាវ)៕

## ក្រុមការងារអន្តរក្រសួងពិភាក្សា និងពិនិត្យទៅលើសេចក្តីព្រាងច្បាប់ ស្តីពីការពពោះជំនួស

https://www.facebook.com/mojcambodia/ ក្រសួងយុត្តិធម៌ Ministry of Justice ថ្ងៃទី ២២ មីនា ២០១៨

ក្នុងថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ២២ មីនា ២០១៨ នៅទីស្តីការក្រសួងយុត្តិធម៌ លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានដឹកនាំក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សា និងពិនិត្យទៅលើសេចក្តីព្រាងច្បាប់ ស្តីពី «ការពពោះជំនួស» ជាមួយនឹងលោកជំទាវ ចាន់ សុទ្ធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌ តំណាងដ៏ខ្ពង់ខ្ពស់ របស់ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិភាក្សា និងពិនិត្យទៅលើសេចក្តីព្រាងច្បាប់ ស្តីពី «ការពពោះជំនួស» ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងស្ថាប័នពាក់ព័ន្ធ មន្ត្រីក្រសួងយុត្តិធម៌ និងអ្នកជំនាញការ ចំនួន.....នាក់ ។ នៅក្នុងសេចក្តីព្រាងច្បាប់នេះ បែងចែកជា ៩ ជំពូក និង ៦២ មាត្រា និងមានគោលបំណងធានាការ អនុវត្តឲ្យបានត្រឹមត្រូវនូវការពពោះជំនួស ដើម្បីការពារសិទ្ធិរបស់ជនដែលពាក់ព័ន្ធ ទៅនឹងការពពោះជំនួស ជា ពិសេសស្ត្រី និងកុមារ ឲ្យបានសមស្របតាមបញ្ញត្តិច្បាប់ និងការពារ ទប់ស្កាត់ មិនឲ្យមានអាជីវកម្មតាមរយៈសេវា ពពោះជំនួសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

# ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៨

## ក្រសួងការងារជំរុញឲ្យពលករខ្មែរធ្វើការនៅប្រទេសថៃ ប្រញាប់ទៅធ្វើបណ្ណស៊ីជម្ពូ

http://km.rfi.fr/cambodia/ ដោយ អេង គីមហុង 25/03/2018

អ្នកនាំពាក្យក្រសួងការងារកម្ពុជានៅថ្ងៃអាទិត្យនេះ បានជំរុញទៅពលករខ្មែរធ្វើការនៅថៃ ឲ្យប្រញាប់ទៅធ្វើបណ្ណស៊ីជម្ពូដើម្បីទទួលបានការស្នាក់នៅបណ្តោះអាសន្ននៅក្នុងទឹកដីថៃ។ ការជំរុញដូច្នេះធ្វើឡើងបន្ទាប់ពីថៃគ្រោងចាត់វិធាការយ៉ាងតឹងរ៉ឹងចំពោះពលករបរទេសទាំងអស់ដែលរស់នៅខុសច្បាប់ ចាប់ពីដើមខែមេសាខាងមុខតទៅ។ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានអះអាងប្រាប់វិទ្យុបារាំងថា បើពលករដែលស្នាក់នៅ និងធ្វើការនៅប្រទេសថៃមិនទៅបន្តសុពលភាពបណ្ណពណ៌ស៊ីជម្ពូទេ នោះអាជ្ញាធរថៃនឹងមិនអនុញ្ញាតឲ្យពលករទាំងនោះស្នាក់នៅនិងធ្វើការនៅប្រទេសថៃបន្តទៀតឡើយ។ លោក ហេង សួរ គូសបញ្ជាក់បន្ថែមថា ពលករកម្ពុជាចំនួន៦៣ម៉ឺននាក់ មានបណ្ណស្នាក់នៅពណ៌ស៊ីជម្ពូបណ្តោះអាសន្ន។ ក្នុងចំណោម៦៣ម៉ឺននាក់នេះអាជ្ញាធរបានធ្វើលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរជូនដល់ពលករចំនួន៤៣ម៉ឺននាក់រួចរាល់ហើយ។ ចំនួនសល់ពីនេះ ប្រមាណ១៩ម៉ឺននាក់ផ្សេងទៀត អាជ្ញាធរកម្ពុជាកំពុងធ្វើលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរជូន។

គួរជម្រាបជូនថា បណ្ណស៊ីជម្ពូ គឺជាបណ្ណស្នាក់នៅបណ្តោះអាសន្នប៉ុណ្ណោះ។ ហើយគ្រប់ពលករខ្មែរដែលមានបណ្ណពណ៌ស៊ីជម្ពូនៅក្នុងដៃ អាចនៅស្នាក់នៅបណ្តោះអាសន្នក្នុងប្រទេសថៃ បានត្រឹមថ្ងៃទី៣០មិថុនាឆ្នាំ២០១៨។ ដូច្នេះ លោក ហេង សួរ បានរំឭកឲ្យពលករខ្មែរ ប្រញាប់ស្វែងរកភាពស្របច្បាប់ឲ្យបានពេញលេញ តាមរយៈលិខិតធ្វើដំណើរចេញដោយអាជ្ញាធរកម្ពុជា និងបណ្ណពលករកម្ពុជា ទើបទទួលបានការស្នាក់នៅប្រទេសថៃស្របច្បាប់។ គួររម្លឹកថា ការជំរុញរបស់ក្រសួងការងារកម្ពុជានាពេលនេះ ធ្វើឡើងបន្ទាប់ពីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ចេញសេចក្តីប្រកាសថា

ភាគីថៃនឹងបិទដំណើរការបន្តសុពលភាពបណ្ណពណ៌ស៊ីជម្ពូ ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។ ហើយចាប់ពីខែមេសាតទៅ អាជ្ញាធរថៃនឹងចាត់វិធានការយ៉ាងតឹងរឹង និងពុំអនុញ្ញាតឲ្យពលករទាំងនោះស្នាក់នៅ និងធ្វើការនៅប្រទេសថៃនោះឡើយប្រសិនបើគ្មានភាពស្របច្បាប់។

ជាការកត់សម្គាល់ ដើម្បីឆ្លើយតបនឹងវិធានការរបស់រដ្ឋាភិបាលថៃយ៉ាងដូច្នេះ ភាគីកម្ពុជាបានបើកយុទ្ធនាការ១០០ថ្ងៃ ផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរនៅប្រទេសថៃ។ គិតត្រឹមថ្ងៃទី១៩ ខែមីនា គណៈកម្មការផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជានៅប្រទេសថៃ បានផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជាសរុបចំនួន ៣០៩,៧៧២នាក់ ហើយយុទ្ធនាការនេះ នៅតែអនុវត្តជាបន្តទៀត៕

## លោកអភិបាលស្រុកបាងឡាម៉ុង,ដឹកនាំកម្លាំងចុះចាប់ពលករធ្វើការខុសច្បាប់

http://www.pheaktraprak.com/ March 24, 2018

លោកអភិបាលស្រុកបាងឡាម៉ុងខេត្តឈុនបុរី ប្រទេសថៃដឹកនាំកម្លាំងសមត្ថកិចចម្រុះចុះចាប់ពលករខុសច្បាប់ដែលកំពុងធ្វើការសំណង់នៅក្នុង ការដ្ឋានសំណង់សង់ផ្សារទំនើបនៅក្នុងក្រុងប៉ាតាយ៉ា។ ករណីអភិបាលស្រុកបាងឡាម៉ុងដឹកនាំកម្លាំងសមត្ថកិច្ចថៃចម្រុះចុះចាប់ពលករខុសច្បាប់នេះធ្វើឡើងកាលពីវេលាម៉ោង12 ថ្ងៃត្រង់នាថ្ងៃសុក្រទី23 ខែមិនា ឆ្នាំ2018 នៅត្រង់ចំណុចការដ្ឋានសាងសង់ហាងទំនើបមួយកន្លែងស្ថិតនៅតំបន់ប៉ាតាយានឿរ ស្រុកបាងឡាម៉ុងខេត្តឈុនបុរី។

យោងតាមរបាយការណ៍ពីកន្លែងកើតហេតុបានឲ្យដឹងថា ក្នុងការចុះត្រួតពិនិត្យបរិវេណការដ្ឋានសាងសង់ហាងទំនើបខាងលើ សមត្ថកិច្ចបានរកឃើញពលករខុសច្បាប់និងហើយពលករស្របច្បាប់ចំនួនរាប់ពាន់នាក់ ក្នុងនោះមានមេការម៉ៅការនៅទីនោះចំនួន 19ក្រុម ដោយពលករថៃធ្វើការប្រមាណជាង70% និងពលករបរទេសធ្វើការចំនួន30% ក្នុងការត្រួតពិនិត្យបរិវេណទីតាំងខាងលើកម្លាំងសមត្ថកិច្ចថៃបានរកឃើញពលករ( តាងដាវ )សញ្ជាតិខ្មែរនិងភូមាចំនួន 234 នាក់ តាមការត្រួតឯកសារធ្វើការមានពលករមួយចំនួនមានប័ត្រស៊ីជម្ពូនិងបែអនុញ្ញាតធ្វើការត្រឹមត្រូវយកមកបង្ហាញជូនសមត្ថកិច្ចត្រួតពិនិត្យ ប៉ុន្តែនៅមានពលករមួយចំនួនទៀតគ្មានឯកសារធ្វើការយកមកបង្ហាញជូនសម្ថកិច្ចត្រួតពិនិត្យ។ នៅវេលាបន្តបន្ទាប់អាជ្ញាធរពាក់ព័ន្ធបានប្រកាសអោយថៅកែថៃដែលមានពលករបរទេសធ្វើការទីនោះប្រញាប់នាំយកឯកសារធ្វើការរបស់ពលករមកបង្ហាញជូនកម្លាំងសមត្ថកិច្ចថៃធ្វើការត្រួតពិនិត្យតាមច្បាប់ក្រសួងការងារថៃ។

តាមការបញ្ជាក់របស់លោកណារិស លីផាវ៉ានអភិបាលស្រុកបាងឡាម៉ុងបានមានប្រសាសន៍ថា ក្នុងការចុះត្រួតពិនិត្យការដ្ឋានសាងសង់ខាងលើនេះ គឺដោយសារតែមានពលករបរទេសធ្វើការច្រើន ដូច្នេះហើយកម្លាំងសមត្ថកិច្ចថៃត្រូវតែធ្វើត្រួតពិនិត្យដើម្បីទប់ស្កាត់បញ្ហាពលករអន្តោប្រវេសន៍ខុសច្បាប់លួចបន្លំធ្វើការនិងបញ្ហាបទល្មើសផ្សេងទៀត។

## ឯកសារសំណុំបែបបទ, សម្រាប់ធ្វើRe-Entry នៅពេលវិលត្រឡប់ទៅស្រុកកំណើតវិញ

http://www.pheaktraprak.com/ March 26, 2018

វីដេអូបង្ហាញអំពីរបៀបសរសេរស្នើសុំធ្វើ Re-Entry Permit នៅស្ថានីយតម្រួត( តម៉ )សម្រាប់បងប្អូនពលករខ្មែរដែលកំពុងកាន់លិខិតឆ្លងដែនធ្វើការនិង Visa( Non-LA )នៅក្នុងប្រទេសថៃ។ វីដេអូនេះបានរៀបចំឡើងដោយទំព័រហ្វេសប៊ុកឈ្មោះ ต่างด้าว បានបង្ហាញយ៉ាងលំអិតអំពីឯកសារសម្រាប់ស្នើសុំធ្វើ Re-Entry នៅពេលដែលពលករចង់វិលត្រឡប់ទៅលេងស្រុកកំណើតនៅក្នុងឳកាសពិធីបុណ្យផ្សេងនៅឯស្រុកកំណើតរបស់ឬមាន ធុរៈកិច្ចការចាំបាច់នៅឯស្រុកកំណើតរបស់។ ចំពោះលក្ខខ័ណ្ឌស្នើសុំពលករត្រូវមានរូបថតទំហំ( 2នីវ )ចំនួនមួយសន្លឹក និងតម្លៃថាមនាមចំនួន1.000 បាត។ បញ្ជាក់ពលករត្រូវបំពេញសំណុំបែបបទតាមលិខិតឆ្លងដែនធ្វើការរបស់ខ្លួនអោយបានត្រឹមត្រូវ។

## កម្មករចំណាកស្រុកជិត១លាននៅថៃមិនទាន់ចុះបញ្ជី តែរយៈពេលសល់តែមួយអាទិត្យ

http://www.rasmeinews.com/ March 24, 2018, 9:56 AM

កម្មករចំណាក់ស្រុកបរទេសជាង៩៥០.០០០នាក់នៅមិនទាន់ចុះបញ្ជីនៅក្រសួងការងារថៃនៅឡើយទេ ខណៈដែលនៅសល់ពេលតែមួយសប្តាហ៍ប៉ុណ្ណោះសម្រាប់ការចុះឈ្មោះដើម្បីបានការអនុញ្ញាតអោយធ្វើការនៅថៃដោយស្របច្បាប់។ រដ្ឋមន្ត្រីក្រសួងការងារ ឧត្តមសេនីយ៍ អាប់ឌុល សាងស៊ីងកែវ កាលពីថ្ងៃសុក្រម្សិលមិញបានប្រកាសថា ដើម្បីត្រៀមទទួលពលករចំណាកស្រុកដ៏ច្រើនដែលនឹងសំរុកមកចុះឈ្មោះនៅសប្តាហ៍ចុងក្រោយនៃកាលកំណត់នៅចុងខែនេះ ក្រសួងដាក់វិធានការបី រួមមាន ១.កាត់បន្ថយដំណើរការចុះបញ្ជី ២.បន្ថែមម៉ោងធ្វើការនៅមជ្ឈមណ្ឌលច្រកចេញចូលតែមួយ(OSS)និងទី៣គឺ បន្ថែមកន្លែងចុះឈ្មោះ។ លោកអាប់ឌុល បាននិយាយថា មានពលករកម្មករបរទេសប្រមាណ១,៧លាននាក់ដែលត្រូវចុះឈ្មោះសុំប័ណ្ណការងារ។ តែទោះជាយ៉ាងណាគិតមកត្រឹមថ្ងៃសុក្រទី២៣ មីនា មានតែ៧២៧.៩០២ នាក់បានឆ្លងកាត់ដំណើរការនេះ មានន័យថា នៅសល់៩៥៩.៥៧១នាក់ទៀត។

ក្រសួងការងារថៃបានចាប់ផ្តើមការងារចុះបញ្ជីពលករនេះចាប់តាំងពីថ្ងៃ៥ កុម្ភៈ និងរំពឹងថា នឹងបញ្ចប់នៅត្រឹមថ្ងៃ៣១ មីនា។ វិធានការនេះមានបំណងអោយកម្មករពលករដែលចូលមកធ្វើការនៅថៃដែលមិនឆ្លងតាមអនុស្សារណៈនៃការយោគយល់គ្នាណាមួយ បានសិទ្ធិធ្វើការដោយស្របច្បាប់នៅថៃ និងទទួលលិខិតការងាររយៈពេល២ឆ្នាំ។ រដ្ឋមន្ត្រីការងារថៃបានបញ្ជាក់ថា ពលករដែលមិនបានចុះឈ្មោះនឹងមិនបានបន្តទិដ្ឋាការការងាររបស់គេទេ នឹងត្រូវចាកចេញពីប្រទេសថៃ ហើយអាចត្រូវចោទប្រកាន់ពីបទស្នាក់នៅក្នុងប្រទេសថៃដោយខុសច្បាប់ និងអាចរងការពិន័យ៥០.០០០បាត។ យោងតាមរដ្ឋាភិបាលថៃ នេះជាឱកាសចុងក្រោយសម្រាប់ពលករកម្មករបរទេសដែលធ្លាប់តែធ្វើការដោយខុសច្បាប់នៅថៃដើម្បីផ្លាស់ប្តូរឋានៈរបស់គេមកជាពលករស្របច្បាប់មុនច្បាប់ការងារបរទេសចូលជាធរមាននៅចុងខែមិថុនា៕ដោយៈ**វាសនា**

## ជនបរទេស១២១នាក់ត្រូវបានចាប់ខ្លួននៅក្នុងការបង្ក្រាបនៅទូទាំងប្រទេសថៃ

http://www.rasmeinews.com/ March 23, 2018, 5:12 PM

លោក Surachet Hakpal នាយប៉ូលិសរង បាននិយាយកាលពីព្រឹកថ្ងៃសុក្រទី២៣មីនាថា ប៉ូលិសទេសចរណ៍ថៃបានចាប់ខ្លួនជនបរទេសចម្រុះជាតិសាសន៍ចំនួន១២១នាក់ កាលពីថ្ងៃព្រហស្បតិ៍នៅក្នុងការឆ្មក់ឆែកឆេរ រយៈពេលមួយថ្ងៃ ដោយកងកម្លាំងចម្រុះរួមមានប៉ូលិសអន្តោប្រវេសន៍និងប៉ូលិសក្នុងស្រុក បានធ្វើការឆ្មក់ឆែកឆេរនៅតំបន់ចំនួន១០៨ នៅទូទាំងប្រទេសនេះ ។ លោក Surachet បាននិយាយនៅសន្និសីទកាសែតកាលពីព្រឹកថ្ងៃសុក្រថា ប្រតិបត្តិការឆ្មក់ឆែកឆេរនេះ ត្រូវបានធ្វើឡើងដើម្បីរកឧក្រិដ្ឋជនបរទេសដែលក្លែងខ្លួនជាភ្ញៀវទេសចរ។ នៅចុងបញ្ចប់នៃប្រតិបត្តិការនេះ លោក Surachetបាននិយាយថា ជនបរទេសចំនួន១៧នាក់ត្រូវបានឃាត់ខ្លួនដោយសារតែទិដ្ឋាការស្នាក់នៅរបស់ពួកគេ ហួសពេលកំណត់ និងជនបរទេស៩១នាក់ ក្នុងចំណោមជនបរទេសដែលត្រូវបានចាប់ខ្លួននោះបានចូលប្រទេសថៃដោយមិនមានទិដ្ឋាការ ហើយជនបរទេស១៣នាក់ផ្សេងទៀតត្រូវបានចាប់ខ្លួនតាមការចោទប្រកាន់ករណីទោសកំហុសផ្សេងៗទៀត។

ជនត្រូវចាប់ខ្លួនរួមមាន អូស្ត្រាលី បែលហ្ស៊ិក ឥណ្ឌា ចិន កម្ពុជា ប៉ាគីស្ថាន មីយ៉ាន់ម៉ា គេនយ៉ា អេហ្ស៊ីប ឡាវ និងវៀតណាម។ជនកម្ពុជា៦នាក់ដែលត្រូវចាប់ខ្លួនដោយសារតែស្នាក់នៅហួសទិដ្ឋាការ និងចូលថៃដោយគ្មានដោយគ្មានទិដ្ឋាការ។ លោក Surachetបាននិយាយថា ប៉ូលីសបានឆ្មក់ចូលឆែកឆេរនៅវិទ្យាស្ថានអប់រំចំនួន៤៩និងនៅតាមលំនៅដ្ឋានចំនួន៥៩នៅក្នុងប្រតិបត្តិការចុងក្រោយបំផុតនេះ៕ ដោយៈ**សុខា/sn**

# ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៨

## អាជ្ញាធរអត់ចាត់ការលើហាងម៉ាស្សាកោសជប់ដែលកំពុងដុះដូចផ្សិតលួចលាក់បង្កប់សេវាផ្លូវភេទ

http://www.rasmeinews.com/ March 26, 2018, 7:45 PM

ដោយៈសារវក្ស/ភ្នំពេញៈកំណើនហាងម៉ាស្សាកោសជប់តម្លៃ១០.០០០រៀលបានដុះរីកឡើងដូចផ្សិតនៅក្នុងសង្កាត់ស្ទឹងមានជ័យ១ស្ទឹងមានជ័យ២ស្ទឹងមានជ័យ៣ខណ្ឌមានជ័យកំពុងតែត្រូវចិត្តពីសំណាក់ក្រុមអ្នកដើរលេងយប់ និងមានបង្កប់សេវាផ្លូវភេទថែមទៀតផង ។ មិនដឹងថា តើហាងម៉ាស្សាកោស ជប់ណាមួយ មានបង្កប់នូវសេវាបម្រើផ្លូវភេទ ឬអត់នោះឡើយ។ ប៉ុន្តែអ្វីដែលជាបញ្ហា ដែលបានកើតឡើងក្នុងពេលកន្លងមកជាបន្តបន្ទាប់នោះគឺហាងទាំងនោះតែងតែបន្លំលួចលុយភ្ញៀវជាញឹកញាប់ហើយមានភ្ញៀវជាច្រើននាក់មកហើយ ដែលបានរងគ្រោះព្រោះការលួចលុយពេលចូលទៅដល់ទីនោះ។

គេសង្កេតឃើញថា ចាប់ពីវេលាម៉ោង៧យប់ឡើងទៅ មានពន្លឺភ្លើងនៃស្លាកឃីហោ"កោសជប់ម៉ាស្សា តម្លៃ១០.០០០រៀល"បានភ្លឺព្រោងព្រាតចាប់ពីគល់ស្ពានអាកាសស្ទឹងមានជ័យរហូតដល់ព្រំប្រទល់ខណ្ឌពោធិ៍សែនជ័យ។ ដោយឡែកក្រុមអ្នកដើរលេងយប់ និងអ្នកស្វែងរកសេវាកោសជប់និងម៉ាស្សាក៏មានជាហូរហែនៅតាមហាងម៉ាស្សាកោសជប់ទាំងនោះនិងមានអ្នកខ្លះក៏បានស្វែងរកសេវាផ្លូវភេទនៅទីនោះផងដែរ។ ប៉ុន្តែទោះជាយ៉ាងណា អ្នករកស៊ីបើកហាងម៉ាស្សាកោសជប់តម្លៃ១០.០០០រៀលទាំងនោះ ក៏មិនមែនសុទ្ធតែអាក្រក់ទាំងអស់នោះដែរ ។តែក៏មានមួយ ចំនួនធំផងដែរដែលរកស៊ីតាមទុច្ចរិត ពួកគេបានរៀបចំសេណារីយោ ត្រូវដងត្រូវផ្លែគ្នារវាងថៅកែហាង ជាមួយស្ត្រីដែលជាបុគ្គលិកបម្រើការងារនៅក្នុងនោះក្នុង ការលួចលុយភ្ញៀវ ឬក៏បន្លំយកលុយសែនដូរយកលុយពិតប្រាកដរបស់ភ្ញៀវជាហូរហែ។ ដូច្នេះអាជ្ញាធរ និងសមត្ថកិច្ចមូលដ្ឋានគួរតែមានចំណាត់ការទៅលើក្រុមអ្នករកស៊ីបែបទុច្ចរិតនោះផងដើម្បីសុវត្ថិភាពរបស់អ្នកដែលចូលទៅកាសជប់ម៉ាស្សានៅទីនោះហើយដើម្បីទប់ស្កាត់កុំឲ្យមានបញ្ហាខាងលើកើតឡើងនោះ។ អាជ្ញាធរគួរតែហៅម្ចាស់ហាងទាំងនោះឲ្យធ្វើកិច្ចសន្យារកស៊ីឲ្យបានត្រឹមត្រូវ និងទទួលខុសត្រូវនៅពេលមានរឿងខាងលើកើតឡើង។មិនតែប៉ុណ្ណោះប្រសិនបើមានរឿងលួចលុយភ្ញៀវកើតឡើង ឬមានការបម្រើសេវាផ្លូវភេទនៅក្នុងនោះ គួរតែធ្វើការចាប់ខ្លួនពួកគេ ចាត់ការទៅតាមផ្លូវច្បាប់ ដោយគ្មានការ យោគយល់ឬលើកលែងឡើយ។

ដោយឡែកអ្នកដែលចូលចិត្ត ចូលទៅកាន់កន្លែងទាំងនេះ គួរតែមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះទ្រព្យសម្បត្តិរបស់ខ្លួនដូចជាម៉ូតូជាដើម ព្រោះនៅក្នុងហាងទាំងនោះគ្មានសន្តិសុខយាមទេ ហើយកុំពឹងក្រុមនារីកោសជប់ ស្រួលមិនស្រួលអាចស៊ីដាច់ម៉ូតូបាត់ទៀត។ មួយទៀតកាបូបលុយឬគ្រឿងអលង្ការផ្សេងៗ ព្រោះក្រុមអ្នករកស៊ីកោសជប់ម៉ាស្សាទាំងនោះគឺជាក្រុមដែស្និតតែងតែយកលុយក្លែងក្លាយទៅប្តូរយកលុយភ្ញៀវ ដល់ពេលដឹងថាបាត់ មិនដែលយកបានមកវិញទេ មានតែការខូចតែឈ្មោះនិងខ្មាសគេប៉ុណ្ណោះ ដូច្នេះកុំប្រហែសឱ្យសោះ។

តាមការបង្ហើបពីប្រជាពលរដ្ឋបានឱ្យដឹងថា ទីតាំងខាងលើទាំងនេះបានធ្វើរកស៊ីបែបនេះជាយូរមក ហើយៗខាងអាជ្ញាធរសមត្ថកិច្ចដែលពាក់ព័ន្ធមិនបានហៅមកព្រមាន និងធ្វើ កិច្ចសន្យា ឱ្យបញ្ឈប់ការបន្លំលុយភ្ញៀវម្តងណាទេ ទុកអោយម្ចាស់ហាងទាំងនោះនៅតែបន្តការបន្លំលុយភ្ញៀវដដែល ទោះបីជាមានភ្ញៀវមកប្តឹងសមត្ថកិច្ចជាញឹកញាប់ក៏ដោយតែបានមកវិញបានត្រឹមតែភាពអាម៉ាស់ប៉ុណ្ណោះ៕S/

# សេចក្តីជូនដំណឹងគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅប្រទេសថៃ

https://www.facebook.com/clcw.gov.kh/ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៨

សេចក្តីជូនដំណឹង ស្តីពីការផ្លាស់ប្តូរទីតាំងរបស់ក្រុមការងារអន្តរក្រសួងចល័តបញ្ជាក់អត្តសញ្ញាណទីក្រុងបាងកកនៅផ្សារអ៊ីមផើរៀល វើល ឡាតប្រាវ (Imperial World Ladpharo) ពីជាន់ទី៤ ទៅជាន់ទី៦ ចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ នេះរហូតតទៅ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខៈ......៥៥៩......................គ.ផ.ប

## សេចក្តីជូនដំណឹង

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ឱ្យបានជ្រាបថា ក្រុមការងារអន្តរក្រសួងចល័តនៅការិយាល័យទីក្រុងបាងកក ដែលមានអាសយដ្ឋាន នៅ**អ៊ីមផើរៀល វើល ឡាតប្រាវ**(Imperial World Ladpharo) **នឹងផ្លាស់ប្តូរទីតាំងពីជាន់ទី៤ ទៅជាន់ទី៦ ចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ នេះរហូតតទៅ។**

ករណីបងប្អូនពលករមានចង្ងល់ពាក់ព័ន្ធ នឹងបញ្ហានេះ សូមបងប្អូនពលករទាក់ទងមកលេខទូរស័ព្ទ ០៨២ ៤២ ២០ ០១១,០៨២ ៤២ ២០ ០២២ និង០៨២ ៤២ ២០ ០៤៤ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ពិសេសបងប្អូនពលករ ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១១ កើត ខែចេត្រ ឆ្នាំ ចរ នព្វស័ក ព.ស២៥៦១
បាងកក ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨
**ជ.ប្រធានគណៈកម្មការ**
**អនុប្រធាន**

**ឡុង ទិសារណោ**

## ថៃបញ្ជូនសពពលករខ្មែរ២នាក់ប្រគល់ឲ្យសាច់ញាតិ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៨ម៉ោង ០៩:១៧ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ សពពលករខ្មែរ២នាក់ ក្រោយស្លាប់ដោយគ្រោះថ្នាក់ចរាចរនៅខេត្តប៉ាធុមថានី និងដេកស្លាប់សង្ស័យខ្យល់.គនៅខេត្តឈុនបូរី ត្រូវបានភាគីថៃបញ្ជូនឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត នៅល្ងាចនិងយប់ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ។ ករណីរងគ្រោះស្លាប់ដោយគ្រោះថ្នាក់ចរាចរបានកើតឡើងកាលពីយប់ថ្ងៃទី២២ ខែមីនា ខណៈជនរងគ្រោះចេញធ្វើការជិះម៉ូតូឆ្លងផ្លូវត្រូវម៉ូតូមួយគ្រឿងទៀតបុកពេញទំហឹង បណ្តាលឲ្យរបួសធ្ងន់ហើយបានស្លាប់នៅមន្ទីរពេទ្យក្នុងខេត្តកើតហេតុ ។ ជនរងគ្រោះឈ្មោះ ទូច សង្ហាវង្ស ភេទប្រុស អាយុ៣៤ឆ្នាំ ជាកម្មករលើកដាក់ទំនិញឲ្យជនជាតិថៃ និងមានទីលំនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ។

ដោយឡែកករណីដេកស្លាប់សង្ស័យខ្យល់.គបានកើតឡើងនៅខេត្តឈុនបូរី កាលពីព្រឹកថ្ងៃទី២៦ ខែមីនា នេះខណៈមិនឃើញក្រោកទៅធ្វើការដូចសព្វមួយដង ពេលនាំគ្នាទៅដាស់ទើបដឹងថាស្លាប់ ។ ជនរងគ្រោះឈ្មោះ ជេន វណ្ណា ភេទប្រុស អាយុ២៧ឆ្នាំ ជាកម្មកររោងចក្រ និងមានទីលំនៅភូមិត្រពាំងជ្រៃឃុំឈើខ្មៅស្រុកកោះធំ ខេត្តកណ្តាល ។ សពករណីគ្រោះថ្នាក់ចរាចរ ត្រូវបានគេយកទៅធ្វើបុណ្យនៅវត្តសូរិយារាមហៅវត្តថ្មី ក្នុងក្រុងប៉ោយប៉ែត ចំណែកសពដេកស្លាប់សង្ស័យខ្យល់.គ ត្រូវបានសាច់ញាតិជួលរថយន្តដឹកទៅលំនៅដ្ឋានដើម្បីធ្វើបុណ្យតាមប្រពៃណី ៕

## ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៨

## បញ្ជូនមេខ្យល់នាំពលករ ៩៦នាក់ ឲ្យទៅធ្វើការទូកនេសាទនៅប្រទេសថៃ និងជាស្ត្រីជំនួយការមេផ្ទះនៅប្រទេសម៉ាឡេស៊ី ទៅសាលាដំបូងរាជធានីភ្នំពេញ

http://cambodiapolice.com/ 11:29 am 28 មីនា 2018

ភ្នំពេញ ៖ នគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨នេះ បានបញ្ជូនស្ត្រីមេខ្យល់នាំពលករទៅធ្វើការទូកនេសាទនៅប្រទេសថៃ និងជាស្ត្រីជំនួយការមេផ្ទះនៅប្រទេសម៉ាឡេស៊ី ទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។ សមត្ថកិច្ច បានឲ្យដឹងថា កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ កម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយព្រះរាជអជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃាត់ខ្លួនមេខ្យល់ម្នាក់ឈ្មោះ វ៉ាន់ ធារី ភេទស្រី អាយុ ៤៥ឆ្នាំ អាស័យដ្ឋានមិនពិតប្រាកដ ដែលបានធ្វើសកម្មភាពឃោសនា ជ្រើសរើស បោកបញ្ឆោត ដល់ប្រជាពលរដ្ឋតាំងពីអំឡុងឆ្នាំ២០១៤ ដល់ ២០១៧ ឲ្យទៅធ្វើជាពលករទូកនេសាទនៅប្រទេសថៃ និងជាស្ត្រីជំនួយការមេផ្ទះនៅប្រទេសម៉ាឡេស៊ីនឹងទទួលបានប្រាក់ឈ្នួលចាប់ពី ៤០០ដុល្លារទៅ៥០០ដុល្លារអាមេរិក ក្នុងមួយខែ ចំណែកសោហ៊ុយគ្រប់បែបយ៉ាងមេខ្យលរូបនេះជាអ្នកចំណាយទាំងអស់ ។

សមត្ថកិច្ចបញ្ជាក់ថា "មេខ្យល់ វ៉ាន់ ធារី បានអូសទាញប្រជាពលរដ្ឋពីខេត្តកំពង់ចាម ក្រចេះ កំពង់ធំ ស្ទឹងត្រែង និងខេត្តតាកែវ បានចំនួន ៩៦នាក់ ហើយមេខ្យល់រូបនេះបានរៀបចំបែបបទធ្វើលិខិតឆ្លងដែន ហើយបានក្លែងអត្តសញ្ញាណជនរងគ្រោះមួយចំនួន និងមួយចំនួនទៀតគ្មានលិខិតឆ្លងដែន អ្នកទាំងអស់នោះត្រូវបានយកទៅប្រគល់ឲ្យមេខ្យល់ផ្សេងទៀតចំនួន ៧នាក់ ហើយទទួលបានប្រាក់កំរ៉ៃក្នុងម្នាក់ៗពី ១០០ទៅ២០០ដុល្លារអាមេរិក ពីមេខ្យល់ទាំង៧នាក់នេះ ជនរងគ្រោះទាំង៩៦នាក់ ត្រូវបានគេនាំចេញទៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី" ។ សមត្ថកិច្ច បន្តថា នៅប្រទេសគោលដៅ ជនរងគ្រោះត្រូវបានគេដកហូតលិខិតឆ្លងដែន និងបិទសិទ្ធសេរីភាព បង្ខំឲ្យធ្វើការលើទូកនេសាទ ជាស្ត្រីជំនួយការមេផ្ទះ ហើយត្រូវបានថៅកែ និងម្ចាស់ផ្ទះជេរប្រមាថគំរាមកំហែងបង្ខំឲ្យធ្វើការស្ទើរគ្មានម៉ោងឈប់សម្រាកមិនទទួលបានប្រាក់ឈ្នួលគ្រប់ចំនួន និងត្រូវបានសមត្ថកិច្ចប្រទេសម៉ាឡេស៊ី ប្រទេសថៃ សហការជាមួយស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ និងប្រទេសម៉ាឡស៊ី ជួយសង្គ្រោះ និងបញ្ជូនត្រឡប់មកកម្ពុជាវិញជាបន្តបន្ទាប់កាលពីថ្ងៃទី១២,១៤ ខែមីនា ឆ្នាំ២០១៧, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ និងថ្ងៃទី២៤ ខែវិច្ឆកា ឆ្នាំ២០១៧ សរុបបានចំនួន ២៧នាក់ ៕

## ពលការិនីខ្មែរអ៊ិស្លាមម្នាក់ទៀតហើយ ដែលចាញ់បោកក្រុមហ៊ុនខុសច្បាប់ទៅធ្វើការនៅអារ៉ាប៊ីសាអ៊ូឌីត ត្រូវបានរដ្ឋាភិបាលកម្ពុជាជួយមកមាតុភូមិវិញ

http://nokorwatnews.com/ ២៨/០៣/២០១៨

ភ្នំពេញ ៖ ពលការិនីខ្មែរអ៊ិស្លាមម្នាក់ ដែលចាញ់បោកគេទៅធ្វើការងារតាមផ្ទះ នៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត ឈ្មោះ ម៉ាន គីរ៉ស់ អាយុ២៨ឆ្នាំ រស់នៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ តាមរយៈអ្នកជិតខាងឃុបឃិតជាមួយក្រុមហ៊ុនវៀតណាមអនាមិកត្រូវបាន រដ្ឋាភិបាលកម្ពុជាជួយឲ្យបានវិលត្រឡប់មកមាតុភូមិវិញដោយសុវត្ថិភាព កាលពី យប់ថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័កព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៨ នៅឯអាកាសយានដ្ឋាន អន្តរជាតិភ្នំពេញ ។ តាមការរៀបរាប់ពីពលការិនីរងគ្រោះ ឈ្មោះ ម៉ាន គីរ៉ស់ ឲ្យដឹងថា រូបនាងបានជឿតាមការលួងលោមពីមេខ្យល់ប្តីប្រពន្ធមួយគូ ដែលត្រូវជាបងប្អូនផងនោះឲ្យទៅ ធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត តាម រយៈក្រុមហ៊ុននៅវៀតណាមមួយដែលមិន ចាំឈ្មោះ ។

នាងបន្តថា ធ្វើការបាន១ឆ្នាំជាងម្ចាស់ផ្ទះចាប់ផ្តើមរករឿងនាងមិនផ្តល់ប្រាក់ខែនោះទេ ។ នាងក៏សួរជាច្រើនលើក ច្រើនសា ហើយមើលទៅលើស្ថានភាពមិនស្រួល នាងក៏សុំមកក្រុមហ៊ុនវិញ ប៉ុន្តែបែរជាម្ចាស់ផ្ទះហែកចោលលិខិតឆ្លងដែន និងដកឯកសារផ្សេងៗរបស់នាងទៀត ។ ក្រុមហ៊ុនអនាមិកខាងលើដែលមិន មានប្រភពច្បាស់លាស់នៅប្រទេសវៀតណាមបានបោកប្រាស់នាងបន្តទៀត គឺបាននាំទៅធ្វើការនៅផ្ទះផ្សេងទៀត ដោយទៅធ្វើការងារតាមផ្ទះ ពីព្រឹករួចហើយវិល ល្ងាចរយៈពេល៤ខែ ដោយមិនមានកម្រៃអ្វីសោះ នាងក៏សម្រេចស្វែងរកជំនួយតាមរយៈស្ថានទូតថៃ និងស្ថានទូតវៀតណាម ប៉ុន្តែគេមិនអើពើ នាងក៏សម្រេចចិត្តទៅស្ថានទូតគុយវ៉ែត ជាសំណាងល្អ ស្ថានទូតគុយវ៉ែត ក៏បានយកដំណឹងនេះទៅកាន់ឯកអគ្គរាជទូតខ្មែរនៅប្រទេសអេហ្ស៊ីបដែលមានលោក ស្មាន ម៉ាណាន ជាឯកអគ្គរាជទូត ។ ពេលទទួលបានដំណឹងនេះភ្លាមលោក អគ្គរាជទូតខ្មែរយើង ក៏បានទាក់ទងមក សិស្សនិស្សិតខ្មែរអ៊ិស្លាមយើង ដែលកំពុងរៀននៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត ជួយស្រាវ ជ្រាវរកពលការិនីនេះឲ្យមកជួប ហើយ បំពេញឯកសារខ្លះដើម្បីទាក់ទងមកក្រសួងការងារ ដើម្បីបញ្ជូនស្ត្រីរងគ្រោះមកដល់ កម្ពុជាវិញ ។ ជាជោគជ័យមួយដែលស្ត្រី រងគ្រោះបានមកដល់កម្ពុជាវិញ នៅវេលា ជិតម៉ោង១០យប់ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ដោយសុវត្ថិភាពបំផុត ហើយនាងត្រូវបានក្រុមការងារលោកឧកញ៉ា អូស្មាន ហាស្សាន់ នាំទៅសម្រាក និងរៀបចំ បញ្ជូនទៅស្រុកកំណើតវិញនាពេលឆាប់ៗខាងមុខនេះ ។

សូមបញ្ជាក់ថា ស្ត្រីរងគ្រោះរូបនេះបាន ចាញ់បោកមេខ្យល់ តាមរយៈប្តីប្រពន្ធ មួយគូលួងលោមឲ្យទៅធ្វើការងារតាមផ្ទះ នៅប្រទេសអារ៉ាប៊ីសាអ៊ូឌីត បានប្រាក់ខែច្រើនយកមកផ្គត់ផ្គង់ជីវភាពធូរជារ ។ ដូច្នេះនេះជាការទៅធ្វើការដោយប្រថុយប្រថានខុសច្បាប់ ។ បើទោះបីជាយ៉ាងនេះក្តី ស្ត្រីរងគ្រោះមិនបានបង្ហាញអារម្មណ៍ចង់ប្តឹងផ្តល់អ្នកណានោះទេ ហើយក៏ថ្លែងអំណរគុណដល់ លោកឧកញ៉ា អូស្មាន ហាស្សាន់ និង សហការីទាំងអស់ ដែលបានខ្នះខ្នែងជួយ នាងឲ្យបានមកដល់មាតុប្រទេសវិញ ដោយសុវត្ថិភាព ។ នាងក៏ផ្តាំផ្ញើដល់ពលការិនី និងពល រដ្ឋទាំងអស់ បើចង់ធ្វើការនៅ ក្រៅប្រទេស សូមទៅតាមរយៈក្រុមហ៊ុនស្របច្បាប់ និងមានលក្ខណៈការងារល្អ ត្រឹមត្រូវ ខ្លាចជួបវាសនាមិនល្អដូចជានាង ។ នេះជាលើកទី៣ហើយ ដែលលោកឧកញ៉ា អូស្មាន ហាស្សាន់ បានជួយសង្គ្រោះនារីរងគ្រោះទៅធ្វើការនៅប្រទេសអារ៉ាប៊ីសាអ៊ូឌីតបានវិលត្រឡប់មកកម្ពុជាវិញដោយសុវត្ថិភាព ៕ សំរិត

## រាជរដ្ឋាភិបាលថៃ,ប្រកាសមិនយកតំម្លៃសេវាកម្មចេញចូលពលករខ្មែរ,ឡាវ,ភូមា,នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខាងមុខនេះ

http://www.pheaktraprak.com March 27, 2018

ដំណឹងល្អរាជរដ្ឋាភិបាលថៃ ប្រកាសអនុញ្ញាតអោយពលករ ខ្មែរ,ឡាវ,ភូមា អាចធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតរបស់ខ្លួននៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដោយមិនអស់ថ្លៃសេវាកម្មចេញចូល។ នៅព្រឹកថ្ងៃអង្គារ ទី27 ខែមីនា ឆ្នាំ2018 នេះ ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីថៃ បានសម្រេចយល់ស្របអនុម័តអនុញ្ញាតអោយពលករបរទេសសញ្ជាតិខ្មែរ,ឡាវ,ភូមាដែលកំពុងធ្វើការរស់នៅក្នុង អាចវិលត្រលប់ធ្វើដំណើរទៅជួបជុំក្រុមគ្រួសារនៅក្នុងឱ

កាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិរបស់ខ្លួន ដោយមិនអស់ថ្លៃសេវាកម្មចេញចូលទាំងប័ត្រស៊ីជម្ពូ និងលិខិតឆ្លងដែនធ្វើការ នៅតាមច្រកចេញចូលនានា។

ពលករត្រូវទៅស្នើសុំលិខិតសម្រាប់ចេញទៅផ្ទះនៅមន្ទីរការងារខេត្តដែលខ្លួនធ្វើការ ចំពោះអ្នកដែលមានឯកសារគ្រប់គ្រាន់ត្រូវទៅស្នើសុំវិសារទៅផ្ទះនៅការិយាល័យប៉ូលីសអន្តោប្រវេសន៍ក្នុងខេត្តដែលកំពុងធ្វើការ ឬនៅច្រកព្រំដែន ដោយការអនុញ្ញាតនេះនឹងចាប់ផ្តើមដំណើរអនុញ្ញាតចាប់តាំងថ្ងៃពុធ ទី05 ខែមេសា ឆ្នាំ2018 ហើយត្រូវវិលត្រលប់ចូលមកប្រទេសថៃវិញនៅថ្ងៃច័ន្ទទី30 ខែមេសា ឆ្នាំ2018 ជាកំហិត បើមិនដូច្នេះទេនឹងត្រូវចាប់ដំណើរការតាមនិវិវីធីច្បាប់។

ខ្ញុំសុំបញ្ជាក់ប្រាប់បងប្អូនចំពោះបងប្អូនដែលមានបាស្ព័រ បើមានបំណងចង់ទៅលេងស្រុកកំណើត មិនចាំបាច់ទៅសុំបៃដើរផ្លូវទេ គ្រាន់តែចេញច្រកព្រំដែនត្រូវអោយ តម៉ រ៉ៃ (Re_Entvg ត្រាអិនទ្រី) ដើម្បីរក្សារសិទ្ធ (វិសារ) ដល់ពេលបងប្អូនចូលមកវិញកុំភ្លេចវៃចូល ដើម្បីសុំបើក (វិសារ) យើងវិញទើប (វិសារ) បងប្អូនមិនខូច។ ចំពោះបងប្អូនដែលមាន (ប័ត្រស៊ីជម្ពូ) បើបងប្អូនចង់ទៅលេងស្រុកកំណើត ត្រូវទៅសុំបៃដើរផ្លូវនៅក្រុមចាត់ហាងាន នៅតាមខេត្តដែលបងប្អូនធ្វើការសិនទើបចេញចូលច្រកព្រំដែនបាន។

គណៈរដ្ឋមន្ត្រីថៃ បានអនុញ្ញាតអោយពលករបរទេស ចេញចូលច្រកព្រំដែនបានដោយអត់គិតថ្លៃសេវាអ្វីទាំងអស់ ចាប់ពីថ្ងៃទី 5 ខែ 4 រហូតដល់ថ្ងៃទី 30 ខែ 4 ឆ្នាំ 2018 នេះតទៅ ។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

## ពលរដ្ឋខ្មែរ ១១នាក់ ត្រូវបាននាំមកកាន់កម្ពុជាវិញ និង៥នាក់កំពុងរៀបចំឯកសារ

https://wmc.org.kh/ ថ្ងៃពុធ ទី២៨ ខែមីនា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ ប្រជាពលរដ្ឋខ្មែរចំនួន ១១នាក់ ត្រូវបានស្ថានឯកអគ្គរាជទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំនៅក្រៅប្រទេស អន្តរាគមន៍ ឲ្យបានវិលមកកម្ពុជាវិញ និងពលរដ្ឋចំនួន ០៥នាក់ផ្សេងទៀត កំពុងរៀបចំឯកសារដើម្បីឲ្យបានមកដល់កម្ពុជា នៅដើមខែមេសា។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលផ្សព្វផ្សាយនៅថ្ងៃទី២៨ ខែមីនានេះ។

តាមសេចក្តីប្រកាសព័ត៌មាននេះ ពលរដ្ឋខ្មែរសរុបទាំង ១៦នាក់នេះ គឺស្ថិតក្នុងប្រទេសចំនួន ០៣។ ប្រទេសម៉ាឡេស៊ី រដ្ឋកូវ៉ែត និងទីក្រុងសៀងហៃ ប្រទេសចិន។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសម៉ាឡេស៊ី បានអន្តរាគមន៍ជួយដល់ពលរដ្ឋខ្មែរចំនួន ១០នាក់ មានស្រ្តី ០៣នាក់ ដែលបានលួចចូលទៅធ្វើការងារដោយខុសច្បាប់នៅប្រទេសនេះ ឲ្យបានវិលមកកម្ពុជាវិញកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨។ រំលងបានមួយថ្ងៃ គឺនៅថ្ងៃទី២៦ ខែមីនា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំរដ្ឋកូវ៉ែត បានអន្តរាគមន៍ជួយដល់ស្រ្តីខ្មែរម្នាក់ អាយុ ២៨ឆ្នាំ ដែលកំពុងបម្រើការងារជាជំនួយការមេផ្ទះនៅប្រទេស អារ៉ាប៊ីសាអូឌីត ឲ្យបានវិលមកកម្ពុជាវិញ ក្រោយពីនារីម្នាក់នោះ មានធុរៈចាំបាច់ក្នុងគ្រួសារ។

បន្ថែមពីនេះ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំទីក្រុងសៀងហៃ ប្រទេសចិន បានអន្តរាគមន៍ជួយដល់ស្រ្តីខ្មែរចំនួន ០៥នាក់ ដែលត្រូវបានមេខ្យល់បោកយកទៅរៀបការជាមួយបុរសជនជាតិចិន ដើម្បីឲ្យបានវិលមកកម្ពុជាវិញនៅដើម ខែមេសា ខាងមុខ។ ស្រ្តីទាំង ០៥នាក់ មានស្រុកកំណើតនៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកណ្តាល។ នៅពេលនេះ ស្ថានអគ្គកុងស៊ុលខ្មែរ បានផ្តល់កន្លែងស្នាក់នៅ សម្រាប់ពួកគេ រង់ចាំការធ្វើមាតុភូមិនិវត្តន៍៕

## ស្ថានទូតកម្ពុជា ជួយអន្តរាគមន៍ពលរដ្ឋខ្មែរ១៦នាក់ ឲ្យបានត្រឡប់មកស្រុកកំណើតវិញ ក្រោយចាញ់បោកមេខ្យល់ទៅធ្វើការ និងរៀបការដោយខុសច្បាប់

http://www.freshnewsasia.com/ 2018-03-28

**(ភ្នំពេញ)៖** ក្រសួងការបរទេសកម្ពុជា បានជួយអន្តរាគមន៍សម្របសម្រួលដល់ពលរដ្ឋខ្មែរ ១៦នាក់ ឲ្យបានត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីពួកគេបានចាញ់បោកមេខ្យល់ទៅធ្វើការងារ និងរៀបការដោយខុសច្បាប់។ អ្នកនាំពាក្យក្រសួងការបរទេស លោក ជុំ សុន្ទរី បានឲ្យដឹងនៅព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨នេះថា ពលរដ្ឋខ្មែរទាំង ១៦នាក់ដែលជួយអន្តរាគមន៍ឲ្យមកស្រុកកំណើតវិញនេះ រួមមាន៖ ពលរដ្ឋ ១០នាក់ (ប្រុស៧នាក់ នារី ៣នាក់) ចាញ់បោក

មេខ្យល់ទៅធ្វើការងារដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពួកត្រូវបានជួយឲ្យត្រឡប់មកដល់ប្រទេសកម្ពុជាវិញកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨កន្លងទៅថ្មីៗនេះ។

ពលរដ្ឋ ៥នាក់ទៀត ជាស្ត្រីខ្មែររស់នៅក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ និងខេត្តកណ្តាល ត្រូវបានរៀបការ និងស្នាក់នៅដោយខុសច្បាប់នៅប្រទេសចិន។ ពួកគេនឹងត្រូវវិលត្រឡប់មកដល់ប្រទេសវិញនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨។

ដោយឡែកពលរដ្ឋម្នាក់ទៀត ជាស្ត្រីផងដែរ ហើយបានចេញទៅធ្វើការងារផ្ទះនៅប្រទេសអារ៉ាប៊ីសាអូឌីត ហើយចង់ត្រឡប់មកផ្ទះវិញព្រោះមានធុរៈក្នុងគ្រួសារ។ ស្ត្រីដែលមានវ័យ ២៨ឆ្នាំរូបនេះ នឹងធ្វើដំណើរមកដល់កម្ពុជាវិញនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

## ស្ថានតំណាងកម្ពុជា អន្តរាគមជួយពលរដ្ឋខ្មែរ១៦នាក់

---

១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី ដោះស្រាយបញ្ហានិងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**១០នាក់** (បុរស ៧នាក់-នារី៣នាក់) ដែលទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី។ ពលករ-ពលការិនីទាំង១០នាក់នោះ បានមកដល់កម្ពុជាវិញ នៅថ្ងៃទី**២៥ ខែមីនា ឆ្នាំ២០១៨** ។

២. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំរដ្ឋ**គូវ៉ែត** បានជួយសម្រួលមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរ**១នាក់** អាយុ២៨ឆ្នាំ ដែលបម្រើការងារផ្ទះនៅប្រទេសអារ៉ាប៊ីសាអូឌីត ហើយចង់ត្រឡប់មកកម្ពុជា ដោយសារមានធុរៈក្នុងគ្រួសារ។ ស្ថានទូតបានចេញលិខិតធ្វើដំណើរបណ្តោះអាសន្នជូន ហើយស្ត្រីខ្មែររូបនោះបានធ្វើដំណើរពីអារ៉ាប៊ីសាអូឌីត មកដល់កម្ពុជាវិញ នៅថ្ងៃទី**២៦ ខែមីនា ឆ្នាំ២០១៨**។

៣. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុង**សៀងហៃ** ប្រទេស**ចិន** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ចិន អន្តរាគមជួយស្ត្រីខ្មែរ**៥នាក់** (មកពីខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តកណ្តាល) ដែលត្រូវបានមេខ្យល់នាំធ្វើដំណើរពីកម្ពុជាទៅរៀបការនិងស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសចិន។

ស្ថានអគ្គកុងស៊ុល បានផ្តល់កន្លែងស្នាក់នៅ អាហារបរិភោគ សម្ភារៈប្រើប្រាស់ និងរៀបចំឯកសារធ្វើដំណើរដល់ស្ត្រីខ្មែរទាំង៥នាក់ ហើយពួកគេនឹងមកដល់កម្ពុជាវិញ នៅថ្ងៃទី**០៣ ខែ មេសា ឆ្នាំ២០១៨** ។

ថ្ងៃ ពុធ ១២កើត ខែ ចេត្រ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៨
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## មានករណីប៉ះទង្គិចគ្នា,រវាងពលករនិងសមត្ថកិច្ចប្រចាំសូន្យOSS

http://www.pheaktraprak.com March 28, 2018

កាលថ្ងៃអង្គារទី27 ខែមីនា ឆ្នាំ2018 ពីម្សិលមិញនេះ កើតហេតុការណ៍ប៉ះទង្គិចគ្នារវាងពលករនិងកម្លាំងសមត្ថកិច្ចប្រចាំសូន្យ OSS ទ្បែមច្បាំង ខេត្តឈុនបុរី ដោយសារមូលហេតុដណ្ដើមជួរគ្នាឬហៅថា(យ៉ែងខ្សែកាន់)។ យោងតាមប្រភពពីអ្នកឃើញហេតុការណ៍នៅទីនោះបាននិយាយថា ករណីនេះកើតឡើងដោយសារភាពរញ៉េរញ៉ៃរវាងថៅកែថៃមួយចំនួន និងពលករមួយចំនួនទៀតដែលមិនស្តាប់បង្គាប់របស់សមត្ថកិច្ចប្រចាំសូន្យ នៅក្រោយពេលកើតហេតុគេឃើញមានពលករមួយចំនួនត្រូវសមត្ថកិច្ចចាប់ឡើងឡានតែមិនថាយកទៅទីណានោះទេ។

## ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៨

## ថៃ អនុញ្ញាតឲ្យពលករស្របច្បាប់ឈប់សម្រាកជិត១ខែ ដើម្បីត្រឡប់ទៅស្រុកកំណើត

http://kleykley.sabay.com.kh/ ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៨

ពលករស្របច្បាប់ មកពី កម្ពុជា ឡាវ និង មីយ៉ាន់ម៉ា ដែលកំពុងធ្វើការនៅប្រទេសថៃ និងមានកាតពណ៌ផ្កាឈូក នឹងត្រូវអនុញ្ញាតឲ្យឈប់សម្រាក ចាប់ពីថ្ងៃទី៥ រហូតដល់ ៣០ ខែមេសា ឆ្នាំ២០១៨ និងមិនត្រូវបានយកប្រាក់លើការធ្វើដំណើរចេញពីថៃនោះទេ ដើម្បីឲ្យត្រឡប់ទៅប្រទេសកំណើតវិញ ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ឡាវ មីយ៉ាន់ម៉ា និងថៃ។ ការសម្រេចនេះ ត្រូវធ្វើឡើងដោយគណៈរដ្ឋមន្ត្រីថៃ កាលពីថ្ងៃអង្គារ ទី២៧ ខែមីនា ឆ្នាំ២០១៨។ នេះជាការឲ្យដឹងពីអ្នកនាំពាក្យការិយាល័យនាយករដ្ឋមន្ត្រី លោក Athisit Chainuwat ។ លើសពីនេះ គណៈរដ្ឋមន្ត្រីថៃ បានយល់ព្រមពន្យារពេលនៃការចុះបញ្ជីសម្រាប់ពលករធ្វើការងារនៅថៃ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ដើមឡើយ ថៃបានកំណត់យកថ្ងៃទី៣១ ខែមីនា ជាថ្ងៃបញ្ចប់ការចុះបញ្ជី។ មកទល់ពេលនេះ ពលករជាង ៨៨ម៉ឺននាក់ មិនទាន់ត្រូវបានចុះបញ្ជីនៅឡើយទេ៕

## តំណាងរដ្ឋាភិបាលបានជួយសង្គ្រោះស្ត្រីខ្មែរ ៥ នាក់ដែលមេខ្យល់នាំទៅការនៅចិន

https://www.postkhmer.com/ យុត សុភចរិយា | Publication date 29 March 2018 | 10:27 ICT

**ភ្នំពេញ:** អគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងសៀងហៃ ប្រទេសចិនបានសហការជាមួយអាជ្ញាធរក្រុងសៀងហៃអន្តរាគមន៍ជួយដល់ស្ត្រីខ្មែរ ៥ នាក់ដែលត្រូវបានមេខ្យល់នាំធ្វើដំណើរពីកម្ពុជាទៅរៀបការ និងស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសចិន ដើម្បីឲ្យបានត្រឡប់មកស្រុកកំណើតនៅកម្ពុជាវិញ។ នេះបើយោងតាមលិខិតជូនដំណឹងមួយដែលចេញដោយលោក ជុំ សុន្ទរី អ្នកនាំពាក្យក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិកាលពីព្រឹកថ្ងៃពុធ។ ក្នុងលិខិតនោះមិនបានបញ្ជាក់អំពីអត្តសញ្ញាណរបស់ស្ត្រីរងគ្រោះទាំងនោះទេ ប៉ុន្តែបាននិយាយថាពួកគេមួយចំនួនមកពីខេត្តកំពង់ចាម ត្បូងឃ្មុំ និង ខេត្តកណ្ដាល។ នៅពេលនេះស្ថានអគ្គកុងស៊ុលបានផ្ដល់កន្លែងស្នាក់នៅ អាហារបរិភោគ សម្ភារប្រើប្រាស់ និងរៀបចំឯកសារធ្វើដំណើរស្របច្បាប់សម្រាប់ពួកគេដើម្បីត្រឡប់មកកម្ពុជាវិញនៅដើមខែមេសាខាងមុខនេះ។

នៅក្នុងបទសម្ភាសដាច់ដោយឡែកមួយជាមួយភ្នំពេញ-ប៉ុស្តិ៍កាលពីម្សិលមិញលោក ជុំ សុន្ទរី បានថ្លែងថា ការមិនបង្ហាញអត្តសញ្ញាណស្ត្រីរងគ្រោះទាំងនោះ គឺដើម្បីការពារដល់សេចក្ដីថ្លៃថ្នូរ និងកិត្តិយសរបស់ពួកនាងពីការប្រមាថ និងការនិយាយនិន្ទាពីក្រុមអ្នកភូមិរបស់ពួកនាង។ លោកនិយាយថា៖ «ពួកនាងត្រូវបានក្រុមមេខ្យល់នាំយកទៅការប្ដី និងរស់នៅដោយខុសច្បាប់ក្នុងប្រទេសចិន។ ស្ត្រី ២ នាក់ក្នុងចំណោមនោះត្រូវបានគេនាំទៅរៀបការជាមួយបុរសជនជាតិចិនតាំងពីអំឡុងចុងឆ្នាំ ២០១៣ និង ៣ នាក់ទៀត គឺទើបត្រូវបានគេនាំទៅនៅចុងឆ្នាំ ២០១៧ នេះ។ ពួកនាងនឹងមកដល់ប្រទេសកម្ពុជានៅថ្ងៃទី ៣ ខែមេសាឆ្នាំ ២០១៨ នេះ»។

លោក ជុំ សុន្ទរី បានឲ្យដឹងថា នៅក្នុងខែមីនាឆ្នាំ ២០១៨ នេះពលករអន្តោប្រវេសន៍ខុសច្បាប់កម្ពុជា ១៦ នាក់ ហើយរួមទាំងករណីស្ត្រីរងគ្រោះទាំង ៥ នាក់ខាងលើនេះត្រូវបានស្ថានកុងស៊ុលកម្ពុជាជួយអន្តរាគមន៍ឲ្យវិលត្រឡប់មកកម្ពុជាវិញក្នុងនោះពលករកម្ពុជា ១០ នាក់ [ប្រុស ៧ នាក់ និងស្រី ៣ នាក់] ត្រូវបានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស

ម៉ាឡេស៊ី  សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងប្រទេសម៉ាឡេស៊ីជួយអន្តរាគមន៍ឲ្យបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ កាលថ្ងៃទី ២៥ ខែមីនាឆ្នាំ ២០១៨។ ខណៈពលការិនីម្នាក់អាយុ ២៨ ឆ្នាំជាជនជាតិភាគតិចចាមដែលបម្រើការងារជាស្ត្រីមេផ្ទះនៅអារ៉ាប៊ីសាអ៊ូឌីត  ត្រូវបានជួយមកស្រុកវិញក្នុងខែមីនានេះដែរព្រោះគ្រួសារនាងមានទុក្ខធុរៈ  ហើយចង់មកផ្ទះវិញ៕

## សេចក្តីជូនដំណឹងចំពោះការចេញលិខិតធ្វើដំណើរបណ្តោះអាសន្នប្រភេទថ្មី

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok

សេចក្តីជូនដំណឹងចំពោះការចេញលិខិតធ្វើដំណើរបណ្តោះអាសន្នប្រភេទថ្មី( Temporary Travel Document/ Laissez Passer) ជូនបងប្អូនពលរដ្ឋខ្មែរ ដែលបាត់ ខូច ឬគ្មានលិខិតឆ្លងដែន ដើម្បីអាចធ្វើដំណើរទៅកម្ពុជាវិញ។

ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៥៧ /១៨/សកបព

### សេចក្តីជូនដំណឹង

ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍  មានកិត្តិយសសូមជម្រាបជូនប្រជាពលរដ្ឋដែលកំពុងប្រកបការងារ និងស្នាក់នៅព្រះរាជាណាចក្រថៃឡង់ដ៍ទាំងអស់មេត្តាជ្រាបថា  ស្ថានទូតនឹងចេញលិខិតធ្វើដំណើរបណ្តោះអាសន្នប្រភេទថ្មី **(Temporary Travel Document/ Laissez Passer)** ដូចមានជូនភ្ជាប់ ជូនពលរដ្ឋខ្មែរដែលបាត់  ខូច  រឺគ្មានលិខិតឆ្លងដែន ដើម្បីធ្វើដំណើរត្រឡប់មកកម្ពុជាវិញ  ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៨ នេះតទៅ។

ស្ថានទូតស្នើសាម៉ីខ្លួនមកដាក់ពាក្យស្នើសុំដោយផ្ទាល់  នៅផ្នែកកិច្ចការកុងស៊ុលនៃស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍  ក្នុងអំឡុងពេលម៉ោងធ្វើការ ។

ជាមួយគ្នានេះដែរ  ស្ថានទូតស្នើប្រជាពលរដ្ឋផ្តល់ព័ត៌មានអំពីជនខិលខូចដែលរត់ការពាក់ព័ន្ធនឹងការស្នើសុំលិខិតធ្វើដំណើរបណ្តោះអាសន្នប្រភេទថ្មី **(Temporary Travel Document/ Laissez Passer)** ខាងលើនេះ  មកកាន់ផ្នែកកិច្ចការកុងស៊ុល តាមរយៈទូរស័ព្ទលេខ 02-957-5851/2 ភ្ជាប់លេខបន្ត 103 រឺ លេខ 098 34 65 669 **Email:** consularBKK@gmail.com ។

ថ្ងៃអង្គារ ទី១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ពស២៥៦១
បាងកក ថ្ងៃទី២៧ខែ មីនា ឆ្នាំ ២០១៨

អាសយដ្ឋាន 518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310, Kingdom of Thailand
ទូរស័ព្ទ: (៦៦-២) ៥៩៧ ៥៨៥១/៥៩៧ ៥៨៥២ ទូរសារ:(៦៦-២) ៥៩៧ ៥៨៥០ អ៊ីម៉ែល: camemb.tha@mfa.gov.kh

**KINGDOM OF CAMBODIA**

Royal Embassy of Cambodia
Bangkok

No. LP18030001

**NATION RELIGION KING**



## LAISSEZ-PASSER

## Temporary Travel Document

## លិខិតធ្វើដំណើរបណ្ដោះអាសន្ន

| | | | | |
|---|---|---|---|---|
| Surname and Given Name | : **NIP CHANNAY** | | | |
| នាមត្រកូល និងនាមខ្លួន | : នីប ចាន់ណយ | | | |
| Nationality | : Cambodian | Sex | : | Female |
| សញ្ជាតិ | : ខ្មែរ | ភេទ | : | ស្រី |
| Date of Birth | : 17 April 1975 | | | |
| ថ្ងៃខែឆ្នាំកំណើត | : ១៧ មេសា ១៩៧៥ | | | |
| Place of Birth | : Angkor Borei District, Takeo Province | | | |
| ទីកន្លែងកំណើត | : ស្រុក អង្គរបុរី ខេត្ត តាកែវ | | | |
| Date of Expiry | : 28 June 2018 | | | |
| ថ្ងៃផុតកំណត់ | : ២៨ មិថុនា ២០១៨ *(មានរយៈពេលយ៉ាងយូរបំផុត ៣ខែ គិតពីថ្ងៃចេញលិខិតនេះ)* | | | |
| Final Destination | : Cambodia | | | |
| គោលដៅចុងក្រោយ | : កម្ពុជា | | | |

The Royal Embassy of Cambodia, Consular Section, kindly requests all authorities to allow the bearer of this travel document to pass without delay and to provide any assistance and protection as may be necessary.

ស្ថានឯកអគ្គរាជទូតកម្ពុជា ស្នើអាជ្ញាធរទាំងអស់អនុញ្ញាតអោយអ្នកកាន់លិខិតធ្វើដំណើរដែលមានឈ្មោះក្នុងនេះបាន ធ្វើដំណើរឆ្លងកាត់ដោយពុំត្រូវបានពន្យារពេល និងផ្ដល់ការជួយនិងកិច្ចការពារផ្សេងៗក្នុងករណីចាំបាច់។

This travel document is for single use only and for the purpose of the return of the bearer to Cambodia.

លិខិតបើកផ្លូវនេះ ប្រើប្រាស់បានតែមួយលើកគត់ សម្រាប់អោយពលរដ្ឋខ្មែរវិលត្រលប់មកកម្ពុជា។

Done at Bangkok, dated 28 March 2018
ធ្វើនៅបាងកក ថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ២០១៨

Security Code

CONSULARBKK1803281996180628<
LPNIP CHANNAYF<<PNN00226622

**TAN CHANDARAVUTH**
Second Secretary
In Charge of Consular Affairs

SPECIMEN

Address: 518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310, Kingdom of Thailand
Telephone: (66-2) 957 5851/957 5852 Fax: (66-2) 957 5850 Email: camemb.tha@mfa.gov.kh

# ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៨

## កម្ពុជា-ថៃ បង្កើនប្រតិបត្តិការ ទប់ស្កាត់ការជួញដូរមនុស្ស និងពលករឆ្លងដែនខុសច្បាប់

https://www.dap-news.com/kh/ ព្រហស្បតិ៍, ២៩ មិនា ២០១៨ 16:43 ដោយ: អេង ប៊ូឆេង ID:114

ភ្នំពេញ ៖មន្រ្តីជាន់ខ្ពស់កម្ពុជា-ថៃ បានពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ ស្តីអំពីការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស និងការពារ អនីតិជន ដើម្បីទប់ស្កាត់នូវរាល់សកម្មភាព ជនល្មើសជួញដូរមនុស្ស ឬនាំពលករឆ្លងដែន ដោយខុសច្បាប់ ។ ក្នុងជំនួបរវាងលោក AKARAPOL PUNYOPASHTAMBHA នាយកមជ្ឈមណ្ឌល ស្រាវជ្រាវស៊ើប អង្កេត ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនថៃ (DSI) និងឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនកម្ពុជា នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ ភាគីទាំងពីរបានពិភាក្សាផ្លាស់ប្តូរយោបល់ និងបទ ពិសោធន៍ ស្តីអំពីការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីទប់ស្កាត់រាល់សកម្មភាព ជនល្មើស ជួញដូរមនុស្ស ឬនាំពលករឆ្លងដែនដោយខុសច្បាប់។

លោក ប៉ុល ភិធេយ្យ បានថ្លែងថា កន្លងមក កម្ពុជា-ថៃ បានសហការជាច្រើន ដើម្បីទប់ស្កាត់ជនល្មើស នាំពល ករចេញដោយខុសច្បាប់ ជាពិសេសជនល្មើសដែលជាមេខ្យល់ ទាំងនៅកម្ពុជា និងថៃ ។ សកម្មភាពជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទលើស្រ្តី និងកុមារនៅកម្ពុជា នៅតែជាបញ្ហាត្រូវយកចិត្តទុកដាក់រួមគ្នា ដើម្បីប្រយុទ្ធប្រឆាំង ដូចជា បញ្ហា ពេស្យាចារ ជួញដូរព្រហ្មចារី អាជីវកម្មផ្លូវភេទ ការពរពោះជំនួស និងជួញដូរសរីរាង្គ ហើយការចំណាកស្រុក ស្វែងរក ការងារធ្វើ នៅក្រៅប្រទេសដោយខុសច្បាប់ នៅតែជាបញ្ហាប្រឈមដូចជា ទៅសុំទាន នេសាទសមុទ្រ បម្រើការងារតាម ផ្ទះ និងអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ។ លោកបញ្ជាក់ថា បុរសត្រូវបាននាំចេញ ទៅធ្វើការខុសច្បាប់នៅប្រទេសថៃ ចិន ម៉ា ឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី ប៉ាគីស្ថាន សូម៉ាលី ជប៉ុន និងអារ៉ាប៊ីសាអូឌីតជាដើម ។ ប៉ុន្តែតាមរយៈការបង្ក្រាបរបស់សមត្ថ កិច្ច សង្កេតឃើញការជួញ ដូរមនុស្សទៅកាន់ប្រទេសថ្មីមួយទៀត គឺប្រទេសជីបូទី ។ ឧត្តមសេនីយ៍ឯក ប៉ុល ភិធេយ្យ បានអះអាងថា ព្រំដែនកម្ពុជា-ថៃ មានភាពស្មុគស្មាញចម្ងាយវែង និងមានច្រករបៀងច្រើន ការគ្រប់គ្រងនៅមានភាពធូរ លុង ហើយទំនាក់ទំនងផ្តល់ព័ត៌មានឲ្យគ្នា រវាងសមត្ថកិច្ចទាំងពីរមិនទាន់គ្រប់គ្រាន់ ដូច្នេះទាមទារឲ្យបង្កើនសហ ប្រតិបត្តិការ ទាំងការទប់ស្កាត់បទល្មើស ជាពិសេសការផ្លាស់ប្តូរព័ត៌មាន ឲ្យបានទាន់ពេលវេលា ។

ក្នុងឱកាសនោះដែរ លោក AKARAPOL PUNYOPASHTAMBHA មានប្រសាសន៍ថា តួនាទី និងការទទួលខុស ត្រូវ គឺការស៊ើបអង្កេត ការជួយសង្គ្រោះ ជនរងគ្រោះ និងបង្កើតប្រព័ន្ធទិន្នន័យសិក្សាស្វែងយល់ ស្រាវជ្រាវ និងទំនាក់ ទំនងជាមួយប្រទេស ជាប់ទាក់ទងជាមួយរឿងក្តី និងប្រទេសជាសមាជិក ។ ជាពិសេសការផ្លាស់ប្តូរព័ត៌មាន ទិន្នន័យ ជាមួយអង្គការ NGO និងជាមួយមន្រ្តី ដែលជាគ្រូបង្គោលផងដែរ ។ លោកបន្តថា ពលករចំណាកស្រុក ដែលចូលមកធ្វើ ការនៅថៃភាគច្រើន ដោយខុសច្បាប់ ហើយជនរងគ្រោះរងការជួញដូរមនុស្ស ភាគច្រើនទទួលបានប្រាក់ចំណូលតិច ហើយមិនទទួលប្រាក់ចំណូលច្រើននោះទេ ទើបពួកគេងាយទទួលរងគ្រោះ ដោយការជួញដូរមនុស្ស ។ លោកបញ្ជាក់ ថា ការងារធ្វើកន្លងមក គឺជួយសង្គ្រោះកម្មករ ត្រូវបានគេបង្ខំឲ្យធ្វើការកេងប្រវ័ញ្ចផ្លូវភេទ ជួយសង្គ្រោះជនរងគ្រោះ និង ជួយញែកសញ្ជាតិ ជនរងគ្រោះ ដើម្បីឲ្យដឹងថា ជនរងគ្រោះមានសញ្ជាតិណាខ្លះ ។ នេះបើយោងតាមការចេញផ្សាយ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ៕

## ៣ចំណុចកម្ពុជា ស្នើសុំកូរ៉េពាក់ព័ន្ធ និងបញ្ហាពលករខ្មែរ

https://www.dap-news.com/kh/ ព្រហស្បតិ៍, ២៩ មិនា ២០១៨ 16:33 ដោយ: ស៊ាន កុសល ID:112

ភ្នំពេញ៖ ក្នុងជំនួបប្រចាំឆ្នាំ រវាងរដ្ឋមន្ត្រីក្រសួង ការងារកូរ៉េ និងបណ្តាទូត នៃប្រទេស បញ្ជូនពលករ មកកូរ៉េ ភាគីកម្ពុជាបានលើកបញ្ហាពើបប្រទះ ៣ចំណុចក្នុងការដោះស្រាយ បញ្ហាជូនពលករ។ បើតាមបណ្តាញទំនាក់ទំនង សង្គហ្វេសប៊ុក របស់លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ បានឲ្យដឹងនៅរសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨នេះថា "ក្នុងជំនួប ប្រចាំឆ្នាំរវាងរដ្ឋមន្ត្រីក្រសួងការងារកូរ៉េ និងបណ្តាទូត នៃប្រទេសបញ្ជូនពលករមកកូរ៉េយើង បានលើកបញ្ហារៀងៗខ្លួន ដែលយើងពើបប្រទះក្នុងការដោះស្រាយបញ្ហាជូនពលករ"។

លោក ឡុង ឌីម៉ង់ បានបន្តថា "កម្ពុជាបានលើកឡើង៣បញ្ហា ទី១. បន្តស្នើសុំឲ្យមាន មជ្ឈមណ្ឌលគាំពារ ពលករបរទេសតាមតំបន់ ដែលមានពលករលើសពី៥០០នាក់ ដាក់ស្តែងនៅកោះដេជូ។ ទី២. ស្នើសុំឲ្យមានយន្តការ ក្នុងការអប់រំសុខភាព និងព្យាបាល ជម្ងឺដែលពលករងាយនឹងប្រឈម។ និងទី៣. ស្នើឲ្យមានការអនុញ្ញាត លើកទីពីរក្នុងការវិភាគ ទឹកនោមមុននឹងផ្តល់កាត ID នៅពេលពលករធ្វើតេស្តទឹកនោម ហើយកូរ៉េ បានរកឃើញ សារជាតិហាមប្រាម (សារជាតិញៀន) ដែលបងប្អូនបានលេបជាថ្នាំផ្តាសាយ ឬឈឺពោះពេល មុនចេញមកកូរ៉េ ។ ថ្នាំផ្តាសាយ ឬឈឺពោះពេលមុនចេញមកកូរ៉េ"៕

## លិខិតជូនដល់បងប្អូន ពលករខ្មែរ មានបំណងចង់ធ្វើដំណើរទៅលេងស្រុកកំណើត ,ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីខាងមុខនេះ

http://www.pheaktraprak.com/ March 30, 2018

ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានធ្វើលិខិតជូនដំណឹងដល់បងប្អូនពលករខ្មែរ ដែលកំពុងធ្វើការរស់នៅក្នុងប្រទេសថៃ ទាំងមានប៉ាស្ព័រធ្វើការប្រភេទ (PP,TD) និងប័ត្រស៊ីជម្ពូ មានសពុលភាពត្រឹមត្រូវ ហើយមានបំណងចង់ធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតរបស់ខ្លួន នៅឯប្រទេសកម្ពុជានៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំ2018 ខាងមុខនេះ។ ដោយបងប្អូនអាចនាំកូនក្នុងបន្ទុកគ្រួសារ និងសាមីខ្លួនធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើត និងវិលត្រឡប់ឡើងមកប្រទេសថៃវិញបានដោយត្រូវអនុវត្តដូចការណែនាំខាងក្រោម៖

1.ចំពោះបងប្អូនពលករកាន់ប័ត្រស៊ីជម្ពូមានសពុលភាពត្រឹមត្រូវ ត្រូវទៅសុំលិខិតអនុញ្ញាតធ្វើដំណើរនៅមន្ទីការងារថៃ (ក្រុមការចាត់ការងារ) នៅក្នុងខេត្តដែលខ្លួនធ្វើការរស់នៅដោយមិនចាំបាច់បង់ថ្លៃសេវាកម្មអ្វីទាំងអស់ (Free)។

2.ចំពោះបងប្អូនពលករដែលមានប៉ាស្ព័រធ្វើការទាំងពីប្រភេទ (PP,TD) និងវីសារធ្វើការត្រឹមត្រូវ បងប្អូនអាចទៅស្នើសុំ(Re-entry Visa) នៅស្ថានីយតម្រួត (តម៉) នៅក្នុងខេត្តដែលបងប្អូនធ្វើការរស់នៅ ឬនៅតម៉ច្រកព្រំដែនអន្តរជាតិលុងគឿរ (ស្រុកអារញ្ញ និងច្រកអន្តរាជាតិបានឡែមជាដើម ដោយមិនចាំបាច់បង់ថ្លៃសេវាកម្មអ្វីទាំងអស់ (Free)។

*ចំពោះលក្ខខ័ណ្ឌធ្វើដំណើរមានដូចខាងក្រោម៖

បងប្អូនពលករអាចធ្វើដំណើរទៅលេងស្រុកកំណើតរបស់ខ្លួនបាន ចាប់តាំងពីថ្ងៃទី05.04.2018តទៅ ហើយត្រូវវិលត្រលប់ចូលមកប្រទេសថៃវិញអោយមុនថ្ងៃទី30.04.2018 ជាកំហិត។ បញ្ជាក់:ក្នុងការធ្វើដំណើរចេញចូលបងប្អូនត្រូវធ្វើដំណើរចេញចូលតាមរយៈច្រកព្រំដែនអន្តរជាតិតែប៉ុណ្ណោះ ពោលគឺចេញច្រកណា ត្រូវចូលមកវិញតាមច្រកនោះ។ ចំពោះព័ត៌មានបន្ថែម សូមមេត្តាទំនាក់ទំនងទៅកាន់មន្ត្រីស្ថានទូតកម្ពុជាប្រចាំទីក្រុងបាងកក តាមរយៈលេខទូរស័ព្ទដូចខាងក្រោម។ ០២ ៩៥៧-៥៨៥១/០៩២ ៨០៥ ០៥៦១/០៩៤ ០៩២ ៥៩០៥/០៨៦ ៧៩៩ ៩៩៥៧និង០៦៤ ៧៥៤ ៧៤០២។

**ព្រះរាជាណាចក្រកម្ពុជា**

**ស្ថានទូតព្រះរាជាណាចក្រកម្ពុជា**

**ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១៩១ /១៨/សកប៤

# សេចក្ដីប្រកាសព័ត៌មាន

ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមជូនដំណឹងដល់សាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃឱ្យបានជ្រាបថា៖

ក្នុងកំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ឆ្នាំ២០១៨ នាពេលខាងមុខនេះ ភាគីកម្ពុជា និង ថៃ នឹងសហការគ្នា ដើម្បីជួយសម្រួលដល់បងប្អូនពលករកម្ពុជាដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ(ប័ណ្ណពណ៌ស៊ីជម្ពូ) នៅមានសុពលភាព និងបងប្អូនពលករដែលកាន់លិខិតឆ្លងដែន(PP)/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ដែលមានទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារនៅមានសុពលភាព ព្រមទាំងអ្នកនៅក្នុងបន្ទុកអាចធ្វើដំណើរត្រលប់ទៅព្រះរាជាណាចក្រកម្ពុជា និងត្រឡប់មកព្រះរាជាណាចក្រថៃវិញបាន **ចាប់ពីថ្ងៃទី០៥ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ដោយមិនតម្រូវឱ្យបង់ប្រាក់ថ្លៃសេវាអ្វីទាំងអស់។**

ចំពោះបងប្អូនពលករកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) ដែលមានបំណងធ្វើដំណើរត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញក្នុងកំឡុងពេលនេះ ត្រូវទៅស្នើសុំលិខិតអនុញ្ញាតពីមន្ទីរការងារថៃក្នុងខេត្តដែលខ្លួនធ្វើការ។ ដោយឡែក ចំពោះបងប្អូនពលករដែលកាន់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ(TD) ត្រូវទៅស្នើសុំទិដ្ឋាការចេញ-ចូល (Re-Entry Visa) នៅការិយាល័យអន្តោប្រវេសន៍ក្នុងខេត្ត ដែលខ្លួនធ្វើការ ឬនៅច្រកព្រំដែនអន្តរជាតិ ដោយពុំមានបង់កម្រៃសេវាឡើយ។ **ពលករទាំងអស់ត្រូវឆ្លងកាត់ច្រកព្រំដែនអន្តរជាតិ គឺបើធ្វើដំណើរត្រឡប់ទៅព្រះរាជាណាចក្រកម្ពុជាតាមច្រកព្រំដែនអន្តរជាតិមួយណានោះ ត្រូវត្រឡប់មកប្រទេសថៃតាមច្រកព្រំដែនអន្តរជាតិមួយនោះវិញ។**

ក្នុងករណីបងប្អូនពលករមានចង្ងល់អំពីបញ្ហានេះ សូមបងប្អូនពលករទាំងអស់ មេត្តាទាក់ទងមកមន្ត្រីស្ថានទូតកម្ពុជានៅទីក្រុងបាងកក តាមរយៈលេខទូរស័ព្ទ ០២ ៩៥៧ ៥៨៥១/០៩២ ៨០៥ ០៥៦១/០៩៤ ០៩២ ៥៩០៥/០៨៦ ៧៩៩ ៩៩៥៧ និង០៦៤ ៧៥៤ ៧៤០១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

បាងកក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

អាស័យដ្ឋាន 518/4 Pracha Uthit Road, Soi Ramkamhaeng 39, Wangthonglang, Bangkok 10310, Kingdom of Thailand
ទូរស័ព្ទ: (៦៦-២) ៩៥៧ ៥៨៥១/៩៥៧ ៥៨៥២ ទូរសារ:(៦៦-២) ៩៥៧ ៥៨៥០ អ៊ីម៉ែល: camemb.tha@mfa.gov.kh

## ឃាត់ខ្លួនជនសង្ស័យ២នាក់ តាមពាក្យបណ្តឹង ម្តាយជនរងគ្រោះ ករណីបង្ខាំង ក្មេងស្រី

https://www.dap-news.com/kh/ សុក្រ, ៣០ មិនា ២០១៨ 09:29 ដោយ: ជ័យសំរ៉ុង ID:112

កំពង់ស្ពឺ ៖ ជនសង្ស័យ២នាក់ ត្រូវបានកម្លាំងនគរបាល នៃអធិការដ្ឋាន នគរបាលស្រុក ឧដុង្គ ឃាត់ខ្លួននៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង១០និង៣០នាទី តាមពាក្យបណ្តឹងរបស់ម្តាយជនរងគ្រោះករណីបង្ខាំងក្មេងស្រី។ លោកស៊ិន សាផេន ប្រធានការិយាល័យជួញដូរមនុស្ស និងអនិតិជន ខេត្តកំពង់ស្ពឺ បានឲ្យដឹងថា ក្រោយពៅទទួលពាក្យបណ្តឹងរបស់ជនរងគ្រោះ ពាក់ព័ន្ធនិងករណីជួញ ដូរមនុស្សលោកបានបញ្ជាឲ្យកម្លាំង ជំនាញឃាត់ខ្លួនជាក់ស្តែងជនបង្កប្រុសស្រី២នាក់ ឈ្មោះតូ លីមស្រេង ភេទប្រុសអាយុ២៦ឆ្នាំ រស់នៅភូមិសួសនៃ ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងឈ្មោះភឿង រក្សា ភេទស្រីអាយុ១៩ឆ្នាំនៅភូមិតាកោង ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ បច្ចុប្បន្នជនសង្ស័យទាំង២នាក់ ត្រូវបានកម្លាំងជំនាញផ្នែកយុត្តិធម៌ ធ្វើការសាកសួរ ដើម្បីចាត់ការតាមនីតិវិធី ៕

## កម្ពុជា-ថៃសម្រួលបែបបទចេញចូលជូនពលករខ្មែរ មកលេងស្រុកកំណើត ក្នុងឱកាសបុណ្យចូលឆ្នាំ ប្រពៃណីខ្មែរ

http://freshnewsasia.com/ 2018-03-29

**(ភ្នំពេញ)៖** ក្នុងអំឡុងពេលមុន និងក្រោយបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរនាពេលខាងមុខនេះ ភាគីកម្ពុជា និងភាគីថៃ បានសហការគ្នាសម្រួលដល់ពលករខ្មែរធ្វើការនៅប្រទេសថៃ អាចធ្វើដំណើរចេញចូលប្រទេសថៃ-កម្ពុជា បានចាប់ពីថ្ងៃទី៥ រហូតថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។ យោងតាមសេចក្តី ជូនដំណឹងរបស់គណៈកម្មការ ផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលអង្គភាពព័ត៌មាន Fresh News ទទួលបាននៅរសៀលថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ បានបញ្ជាក់ពីគោលការណ៍ចំនួន៤ ដែលសម្រួលដល់ពលករខ្មែរ៖

**ទី១៖** ក្នុងអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ នាពេលខាងមុខនេះ ភាគីកម្ពុជា និងភាគីថៃ បានសហការគ្នាដើម្បីសម្រួលដល់ពលករ ដែលកាន់កាប់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) នៅមានសុពលភាព និងពលករដែលកាន់លិខិតឆ្លងដែន លិខិតធ្វើដំណើរពលករកម្ពុជា ធ្វើការនៅបរទេស (TD) ដែលមានទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារនៅមានសុពលភាព ព្រមទាំងអ្នកនៅក្នុងបន្ទុក អាចធ្វើដំណើរចេញ ចូលប្រទេសថៃ-កម្ពុជា បានចាប់ពីថ្ងៃទី៥ រហូតថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

**ទី២៖** ចំពោះបងប្អូនពលករ កាន់កាប់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) ដែលមានបំណងធ្វើដំណើរត្រឡប់មកកម្ពុជាវិញ ក្នុងអំឡុងពេលនេះ ត្រូវស្នើសុំលិខិតអនុញ្ញាតពីមន្ទីរការងារថៃ ក្នុងខេត្តដែរខ្លួនកំពុងធ្វើការ។ ដោយឡែកចំពោះបងប្អូនពលករ ដែលកាន់កាប់លិខិតឆ្លងដែន លិខិតធ្វើដំណើរ (TD) ត្រូវទៅស្នើសុំទិដ្ឋាការចេញចូលនៅការិយាល័យអន្តោប្រវេសន៍ក្នុងខេត្ត ដែលខ្លួនធ្វើការ ឬច្រកព្រំដែនអន្តរជាតិ ដោយពុំមានបង់កម្រៃឡើយ។

**ទី៣៖** ពលករទាំងអស់ត្រូវឆ្លងកាត់ តាមច្រកព្រំដែនអន្តរជាតិ ប្រសិនបើជាត្រឡប់មកកម្ពុជា តាមច្រកណាត្រូវត្រឡប់ទៅថៃវិញតាមច្រកនោះវិញ។

**ទី៤៖** ពលករកម្ពុជាកាន់ប័ណ្ណមិនមែនសញ្ជាតិខ្មែរ (ប័ណ្ណពណ៌ស៊ីជម្ពូ) មិនត្រូវឲ្យសុំលិខិតធ្វើដំណើរបណ្តោះអាសន្ន ដើម្បីធ្វើដំណើរត្រឡប់មកកម្ពុជាវិញឡើយ ក្នុងអំឡុងពេលភាគីថៃ និងកម្ពុជា បានឯកភាពគ្នានោះ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្តីជូនដំណឹង

យោងតាមការជូនដំណឹង ចុះថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងការងារថៃ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជូនដំណឹង ដល់សាធារណៈជន ជាពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅនិងធ្វើការនៅក្នុងប្រទេសថៃឱ្យបានជ្រាបថា៖

ទី១. ក្នុងកំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនាពេលខាងមុខនេះ ភាគីកម្ពុជា និងថៃនឹងសហការគ្នាដើម្បីសម្រួលដល់ពលករ ដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) នៅមានសុពលភាព និងពលករដែលកាន់លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) ដែលមានទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារនៅមានសុពលភាព ព្រមទាំងអ្នកនៅក្នុងបន្ទុក អាចធ្វើដំណើរចេញ-ចូលប្រទេសថៃ-កម្ពុជាបានចាប់ពីថ្ងៃទី០៥ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

ទី២. ចំពោះបងប្អូនពលករ កាន់ប័ណ្ណមិនមែនសញ្ជាតិថៃ(ប័ណ្ណពណ៌ស៊ីជម្ពូ) ដែលមានបំណងធ្វើដំណើរត្រលប់មកកម្ពុជាវិញក្នុងអំឡុងពេលនេះ ត្រូវទៅស្នើសុំលិខិតអនុញ្ញាតពីមន្ទីរការងារថៃក្នុងខេត្ត ដែលខ្លួនធ្វើការ។ ដោយឡែកចំពោះបងប្អូនពលករ ដែលកាន់លិខិតឆ្លងដែន/លិខិតធ្វើដំណើរ(TD) ត្រូវទៅស្នើសុំទិដ្ឋាការចេញ-ចូល (Re-Entry Visa) នៅការិយាល័យអន្តោប្រវេសន៍ក្នុងខេត្ត ដែលខ្លួនធ្វើការ ឬនៅច្រកព្រំដែនអន្តរជាតិ ដោយពុំមានបង់កម្រៃសេវាឡើយ។

ទី៣. ពលករទាំងអស់ត្រូវឆ្លងកាត់តាមច្រកព្រំដែនអន្តរជាតិ ហើយប្រសិនជាត្រលប់មកកម្ពុជាតាមច្រកណា ត្រូវត្រឡប់ទៅថៃវិញតាមច្រកនោះ។

ទី៤. ពលករកម្ពុជាកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) មិនតម្រូវឱ្យសុំលិខិតធ្វើដំណើរបណ្តោះអាសន្ន (Laissez Passer) ដើម្បីធ្វើដំណើរត្រលប់មកកម្ពុជាវិញឡើយ ក្នុងអំឡុងពេលភាគីថៃ និងកម្ពុជាបានឯកភាពគ្នានេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន ពិសេសបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៨

# លីកាដូ៖ កុមារបញ្ជូនចេញពីកម្ពុជាលួចលាក់ ជាអំពើពុករលួយ ក្នុងប្រព័ន្ធសុំកូនអន្តរប្រទេស

https://www.dap-news.com/kh/ ថ្ងៃសុក្រ, ៣០ មិនា ២០១៨ 10:43 ដោយ: ធី លីថូ ID:114

ភ្នំពេញ៖អង្គការលីកាដូ បានលើកឡើងថា កុមារដែលត្រូវបាន បញ្ជូនចេញពីប្រទេសកម្ពុជា ដោយលួចលាក់ជាការក្លែងបន្លំ និងជាអំពើដែលត្រូវបានអះអាងថា ជាអំពើពុករលួយ ក្នុងប្រព័ន្ធសុំកូនអន្តរប្រទេស។ របាយការណ៍របស់លីកាដូ ដែលត្រូវបង្ហាញក្នុងគេហទំព័ររបស់ខ្លួន នៅព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ បានឲ្យដឹងថា មានស្ត្រីមួយចំនួន ជាអាណាព្យាបាលរបស់ក្មេង ដែលត្រូវបានគេសុំយកទៅចិញ្ចឹម នៅក្រៅប្រទេស បានទាក់ទងមក លីកាដូ ដើម្បីស្នើឲ្យជួយអន្តរាគមន៍ ស្វែងរកកូនរបស់ពួកគេ ដែលត្រូវបានគ្រួសារជាជនបរទេស សុំយកទៅចិញ្ចឹមនៅក្រៅប្រទេស កាលពីទសវត្សរ៍ឆ្នាំ២០០០ ស្ត្រីទាំងនោះ មានស្ថានភាព រស់នៅក្រីក្រខ្លាំង ហើយបានយកកូនរបស់ពួកគេ ដែលមានអាយុចន្លោះពី៣ឆ្នាំ ទៅ ៩ឆ្នាំ មកផ្ញើនៅមណ្ឌលកុមារកំព្រា។ លីកាដូបន្ថែមទៀតថា ក្នុងនោះនៅមានករណីមួយចំនួន ដែលធ្វើឲ្យស្ត្រីទាំងនោះ សម្រេចចិត្តធ្វើបែបនេះ ព្រោះតែចង់ឲ្យកូន បានទៅសាលារៀន ហើយស្ថានភាពកុមារកំពុងតែមានជំងឺ និងត្រូវការការព្យាបាលបានទៀងទាត់ ដែលស្ត្រីជាម្ដាយមិនអាចធ្វើ ទៅបាន ដោយសារពួកគេប្រកបការងារ ជាកម្មការិនីរោងចក្រកាត់ដេរ។ ក្នុងករណីទាំងអស់នេះហើយទើប ស្ត្រីជាម្ដាយនៅតែបន្ត ទៅសួរសុខទុក្ខកូន របស់ពួកគាត់យ៉ាងទៀង ទាត់អំឡុងពេលដែលកុមារទាំងនោះ នៅមណ្ឌលកុមារកំព្រានៅឡើយ។

របាយការណ៍បង្ហាញទៀតថា នៅចន្លោះចុងទសវត្សរ៍ឆ្នាំ១៩៨០ និងឆ្នាំ២០០៩ កុមារកម្ពុជារាប់ពាន់នាក់ត្រូវបានគ្រួសារជាជនបរទេសសុំយកទៅចិញ្ចឹមនៅក្រៅប្រទេស។ អំឡុងពេលនោះមានការលើកឡើងថា កុមារកម្ពុជាជាច្រើនមិនមែនជាកុមារកំព្រាទេ ប៉ុន្តែពួកគេត្រូវបានឪពុក-ម្ដាយយកមកផ្ញើនៅមណ្ឌលកុមារកំព្រា ដើម្បីឲ្យជួយចិញ្ចឹម ដោយសារភាពក្រីក្រខ្លាំង។ ឪពុក-ម្ដាយទាំងនោះបានយកពួកគេមកផ្ញើនៅមណ្ឌលកុមារកំព្រា ដោយសារយល់ឃើញថា ពួកគេអាចនឹងត្រឡប់ទៅផ្ទះវិញនៅថ្ងៃក្រោយ។ ឪពុក-ម្ដាយរបស់ពួកគេមិនបានព្រមព្រៀងក្នុងដំណើរការសុំកូនទេ។ ប៉ុន្តែនាយកមណ្ឌលកុមារកំព្រាទៅវិញទេ ដែលបានឃុបឃិតគ្នា ជាមួយអាជ្ញាធរក្នុងតំបន់ ដើម្បីធ្វើឯកសារមិនពិត ដោយអះអាងថា កុមារទាំងនោះជាកុមារកំព្រា ឬត្រូវបានឪពុក-ម្ដាយ បោះបង់ចោល។

នៅពេលមានភស្តុតាងជាច្រើនបញ្ជាក់លើករណីនេះកាន់តែច្បាស់ ទើបប្រទេសជាច្រើនបានសម្រេចផ្អាកការសុំកូនពីកម្ពុជា ហើយនៅឆ្នាំ២០០៩ កម្ពុជាក៏បានសម្រេចផ្អាកដំណើរការ លើបញ្ហានេះផងដែរ។ ភាគច្រើន ឪពុក-ម្ដាយរបស់កុមារ ដែលត្រូវបានសុំយកទៅចិញ្ចឹម នៅក្រៅប្រទេស គឺមិនចេះអក្សរ និងមិនសូវយល់ដឹងពីសិទ្ធិ ឬមិនស្គាល់ស្ថាប័ន ដែលអាចជួយអន្តរាគមន៍បាន ហេតុដូច្នេះហើយទើបពួកគាត់ គ្មានលទ្ធភាព ក្នុងការស្វែងរកព័ត៌មានអំពីកូន។ របាយការណ៍នេះបន្តថា "សំណូមពរដោយទទូច ឲ្យអាជ្ញាធរកម្ពុជា និងរដ្ឋាភិបាលបរទេសពាក់ព័ន្ធ ធ្វើការសុំទោសដល់អ្នកគ្រប់គ្នា ដែលរងគ្រោះដោយដំណើរការសុំកូន បែបក្លែងបន្លំនេះ ពីអតីតកាល។ អ្នកទាំងនោះ គួរតែបង្កើតឲ្យមានប្រព័ន្ធស៊ើបអង្កេត និងការផ្ដល់សំណង ដល់ប្រជាពលរដ្ឋកម្ពុជា រងគ្រោះ និងបង្កើតយន្តការសម្រាប់កុមារ ដែលត្រូវបានសុំយកទៅចិញ្ចឹម នៅក្រៅប្រទេស ដើម្បីអាចស្រាវជ្រាវរកជីវប្រវត្តិកុមារ និងបង្កើតការទំនាក់ទំនង ជាមួយឪពុក-ម្ដាយបង្កើតរបស់ពួកគេ ប្រសិនបើពួកគេត្រូវការ"៕

## សិង្ហបុរីលុបចោលលិខិត អនុញ្ញាត ការងារទាំងអស់ សម្រាប់ពលករកូរ៉េខាងជើង

https://www.dap-news.com/kh/ ព្រហស្បតិ៍, ២៩ មិនា ២០១៨ 08:16 ប្រែសម្រួល: ប៉ាង កុង ID:115

បរទេស៖ របាយការណ៍ទណ្ឌកម្ម អង្គការសហប្រជា ជាតិថ្មីមួយបង្ហាញថា ប្រទេសសិង្ហបុរី នាពេលថ្មីៗនេះ បានលុបចោល លិខិតអនុញ្ញាតិ ការងារសម្រាប់ពលករកូរ៉េខាងជើង ទាំងអស់នៅតាមព្រំដែន របស់ខ្លួន ដោយអនុលោមទៅតាម សេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ។

នៅក្នុងរបាយការណ៍អនុវត្តមួយ ដែលប្រគល់ឲ្យកាលពីសប្តាហ៍មុន រដ្ឋាភិបាលប្រទេសសិង្ហបុរីបានធ្វើការបញ្ជាក់ថា នៅពេល បច្ចុប្បន្ននេះ គ្មានជនជាតិកូរ៉េខាងជើង មានលិខិតអនុញ្ញាតការងារ នៅប្រទេសសិង្ហបុរីទេ ព្រោះលិខិតការងារត្រូវបានលុបចោល សម្រាប់ជនជាតិ កូរ៉េខាងជើងទាំងអស់ ហើយរដ្ឋាភិបាលនឹងមិនប្រគល់ ឲ្យនូវលិខិតការងារថ្មីទៀតឡើយ ចំណែកជនជាតិ កូរ៉េខាងជើង ដែលមកប្រទេសសិង្ហបុរី ដោយគ្មានទិដ្ឋាការ នឹងត្រូវបដិសេធមិនឲ្យចូល ជាដាក់ខាត។

គួរបញ្ជាក់ថា យោងតាមក្រុមសិទ្ធិ មនុស្សផ្សេងៗ បានឲ្យដឹងថា ជនជាតិកូរ៉េខាងជើងប្រមាណ៦៥.០០០នាក់ កំពុងធ្វើការក្នុងប្រទេស ចំនួន៤០ប្រទេស នៅទូទាំងអឺរ៉ុបខាងកើត និងតំបន់អាស៊ី ក្នុងឆ្នាំ២០១៥ ហើយតាមការប៉ាន់ស្មាន ពួកគេទទួលបានប្រាក់ចន្លោះពី២០០ ទៅ៥០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់របបផ្តាច់ការព្យុងយ៉ាង៕

## កម្មករមីយ៉ាន់ម៉ា២១នាក់ឆេះស្លាប់ក្នុងរថយន្តក្រុងនៅថៃ

http://www.rasmeinews.com/ March 30, 2018, 8:03 AM

រថយន្តក្រុងមួយដែលដឹកកម្មករមីយ៉ាន់ម៉ាមកពីកន្លែងចុះឈ្មោះសុំធ្វើការបានឆេះនៅក្នុងខេត្តតាកកាលពីព្រឹកថ្ងៃសុក្រទី៣០មីនាដោយសម្លាប់អ្នកដំណើរ២១នាក់។ អ្នកដំណើរ២៧នាក់ទៀត រួមទាំងអ្នកបើកនិងប្រពន្ធគាត់បានគេផុតពីអណ្តាតភ្លើង តែរងរបួសនិងត្រូវបាននាំទៅកាន់មន្ទីរពេទ្យ។ របាយការណ៍មកពីខេត្តតាកបាននិយាយថា រថយន្តដែលឆេះបានដឹកកម្មករមីយ៉ាន់ម៉ាប្រមាណ៥០នាក់មកពីខេត្តមេសុត ទៅកាន់តំបន់ស្សាហកម្មមួយក្នុងខេត្តផាធូម ថានីបន្ទាប់ពីពួកគេបានបញ្ចប់ការចុះបញ្ជីសុំលិខិតការងារ។

ជនចំណាកស្រុកទាំងនេះស្ថិតចំណោមមនុស្សរាប់សែននាក់ដែលបានទៅចុះឈ្មោះសុំធ្វើការងារនៅថៃខណៈកាលបរិច្ឆេទឈប់ទទួលការចុះឈ្មោះចូលដល់ទីបញ្ចប់។ គ្រោះថ្នាក់បានកើតឡើងនៅផ្លូវHighway 12ក្នុងឃុំ មេថរ នៅម៉ោងប្រមាន១រំលងអធ្រាត។ របាយការណ៍ដំបូងបាននិយាយថា ម៉ាស៊ីនឡានបានឆេះនិងបានរាលដាលយ៉ាងលឿនទៅតួរថយន្តទាំងមូល តែបើតាមអ្នកនៅមានជីវិតនិយាយថា ភ្លើងបានចាប់ផ្តើមនៅកណ្តាលរថយន្ត ហើយរាលដាលលឿនដោយធ្វើអោយជាប់មនុស្សនៅពាក់កណ្តាលទៅក្រោយ។ បើតាមប៉ូលិស អគ្គិភ័យនេះមានសភាពខ្លាំងរហូតដល់សាកសព្វខ្លះទាមទារអ្នកជំនាញមកពិនិតដើម្បីកំណត់អត្តសញ្ញាណ ឬភេទ៕ដោយ៖*វាសនា*

••••••••••••••••••••••••